រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សៀវភៅណែនាំ

# ស្តីពី

# ការរៀបចំគម្រោងរាជធានី ខេត្ត

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខៈ ០៥៧ ភាសាខ /គ.ជ.អ.ប

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីការរៀបចំគម្រោងរាជធានី ខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៥អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្ដីពីការរៀបចំគម្រោងរាជធានី ខេត្ត សម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងការរៀបចំគម្រោងរបស់រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការរៀបចំគម្រោងរាជធានី ខេត្ត ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

<u>**កន្លែងទទួល**</u> ÷

- *ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប*
  *«ដើម្បីជូនជ្រាប»*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *រដ្ឋបាលរាជធានី ខេត្ត*
- *មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត*
  *«ដើម្បីអនុវត្ត»*
- *ឯកសារ-កាលប្បវត្តិ*

# មាតិកា

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ......i
មាតិកា ......iii

## ជំពូកទី១

## គម្រោងរាជធានី ខេត្ត

១.១. គម្រោង និងលទ្ធផល ......១
១.២. គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ......២
១.៣. គម្រោងសេវាកម្ម ......៣

## ជំពូកទី២

## ការរៀបចំគម្រោងរាជធានី ខេត្ត

២.១. ការបង្កើតគណៈកម្មការរៀបចំគម្រោង ......៤
២.២. ការកំណត់អ្នកជំនួយបច្ចេកទេស ......១០
២.៣. ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិចរបស់គម្រោង ......១០
២.៤. ការរៀបចំក្រុមប្រើប្រាស់ ......១៣
២.៥. ការរៀបចំផែនការសិក្សាគម្រោង ......១៣
២.៦. ការរៀបចំផែនទីគម្រោង ......១៥
២.៧. ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស ......១៥
២.៨. ការសិក្សាផលប៉ះពាល់បរិស្ថាន ......១៥
២.៩. ការសិក្សាដីធ្លី ......១៥
២.១០. ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ......១៦
២.១១. ការរៀបចំគ្រោងការគម្រោង ......១៦
២.១២. ស្លាកសញ្ញាគម្រោង ......១៧
២.១៣. ការប៉ាន់ស្មានតម្លៃគម្រោង និងព័ត៌មានលម្អិតនៃលទ្ធផលគម្រោង ......១៩
២.១៤. ផែនការប្រតិបត្តិការ និងការថែទាំ ......១៩
២.១៥. ការពិនិត្យ និងការអនុម័តសំណើគម្រោង ......១៩
២.១៦. ការពិនិត្យបញ្ជាក់បច្ចេកទេស ......២០
២.១៧. ការពិនិត្យ និងការផ្តល់អនុលោមភាព ......២១

## ជំពូកទី៣

## តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំគម្រោង

៣.១. ក្រុមប្រឹក្សារាជធានី ខេត្ត ......២២
៣.២. គណៈអភិបាលរាជធានី ខេត្ត ......២២
៣.៣. គណៈកម្មការរៀបចំគម្រោង ......២២

៣.៤. អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ ....................................................................................២២
៣.៥. សហគមន៍ និងអ្នកទទួលផលពីគម្រោង ....................................................................................................២៣
៣.៦. អ្នកជំនួយបច្ចេកទេស ......................................................................................................................២៤
៣.៧. ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត.........................................................................................២៤
៣.៨. មន្ទីរ អង្គភាពជំនាញនានា ...................................................................................................................២៤
៣.៩. ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ..........២៤
៣.១០. អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ.........................................................................................២៦

## ជំពូកទី៤

## ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន

៤.១. ទស្សនទានអំពីទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន .......................................................................... ២៧
៤.២. គោលការណ៍ណែនាំសម្រាប់ប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ............................................ ២៧

## ជំពូកទី៥

## បញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ

៥.១. សេចក្តីផ្តើម ......................................................................................................................................៣០
៥.២. គោលបំណង .....................................................................................................................................៣០
៥.៣. តួនាទី និងការទទួលខុសត្រូវ..................................................................................................................៣០
៥.៤. នីតិវិធីនៃការរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារ........................................................................................៣០

## ជំពូកទី៦

## ការបំពេញទម្រង់ព័ត៌មានគម្រោង

៦.១. អ្នកទទួលខុសត្រូវក្នុងការបំពេញទម្រង់ព័ត៌មានគម្រោង.............................................................................៣៩
៦.២. ព័ត៌មានដែលត្រូវបំពេញក្នុងទម្រង់ព័ត៌មានគម្រោង .................................................................................៣៩
៦.៣. បញ្ជីប្រភេទគម្រោង និងមន្ទីរ អង្គភាពជំនាញ.........................................................................................៤៣
៦.៤. ការបំពេញទម្រង់ព័ត៌មានគម្រោង ......................................................................................................... ៤៦

## ជំពូកទី៧

## គោលការណ៍ណែនាំស្តីពីការគណនាតម្លៃប៉ាន់ស្មានគម្រោង

៧.១. ការប៉ាន់ស្មានតម្លៃគម្រោង ................................................................................................................. ៥០
៧.២. តម្លៃផ្ទាល់ តម្លៃប្រយោល និងប្រាក់ចំណេញ......................................................................................... ៥០
៧.៣. ការគណនាតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ..................................................................................៥២
៧.៣.១. ការគណនាតម្លៃប៉ាន់ស្មានសម្រាប់ការងារសំណង់..........................................................................៥២
៧.៣.២. ការគណនាតម្លៃប៉ាន់ស្មានសម្រាប់ការងារដី ...................................................................................៥៧
៧.៤. ការគណនាតម្លៃប៉ាន់ស្មានគម្រោងសេវាកម្ម..........................................................................................៦២
៧.៥. ការបំពេញទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោង...............................................................................៦៦

៧.៦. ការបំពេញទម្រង់ទីតាំងលទ្ធផលគម្រោង ........ ៧០
៧.៧. បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ ........ ៧០

## ជំពូកទី៨

## កិច្ចប្រតិបត្តិការ និងការថែទាំគម្រោង

៨.១. កិច្ចប្រតិបត្តិការគម្រោង ........ ៧១
៨.២. ការថែទាំគម្រោង ........ ៧១
៨.៣. ការរៀបចំផែនការប្រតិបត្តិការ និងការថែទាំ ........ ៧២
៨.៤. ការរៀបចំគម្រោងសម្រាប់សកម្មភាពថែទាំ ........ ៧៦
៨.៥. ការអង្កេតបច្ចេកទេសសម្រាប់ការថែទាំជាប្រចាំ ........ ៧៧
៨.៦. ការប៉ាន់ស្មានតម្លៃសម្រាប់ការថែទាំជាប្រចាំ ........ ៧៨

## ជំពូកទី៩

## គោលការណ៍ណែនាំស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន

៩.១. និយមន័យនៃការវិភាគផលប៉ះពាល់បរិស្ថាន ........ ៨២
៩.២. អ្នកទទួលខុសត្រូវក្នុងការវិភាគផលប៉ះពាល់បរិស្ថាន ........ ៨២
៩.៣. ទីកន្លែងសម្រាប់ធ្វើការវិភាគផលប៉ះពាល់បរិស្ថាន ........ ៨២
៩.៤. ការផ្សព្វផ្សាយអំពីគម្រោងដល់ប្រជាពលរដ្ឋ ........ ៨២
៩.៥. ការរៀបចំផែនទីបរិស្ថាន ........ ៨៣
៩.៦. ការវិភាគផលប៉ះពាល់បរិស្ថាន ........ ៨៥
៩.៧. ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន ........ ៨៨
៩.៨. ការរៀបចំផែនការតាមដានផលប៉ះពាល់បរិស្ថាន ........ ៨៨
៩.៩. ការរៀបចំរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ........ ៨៩
៩.១០. ការពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ........ ៨៩
៩.១១. ការបំពេញទម្រង់របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ........ ៩១

## ជំពូកទី១០

## គោលការណ៍ណែនាំស្តីពីការសិក្សាដីធ្លី

១០.១. និយមន័យនៃការសិក្សាដីធ្លី ........ ៩៨
១០.២. អ្នកទទួលខុសត្រូវក្នុងការសិក្សាដីធ្លី ........ ៩៨
១០.៣. ការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី ........ ៩៨
១០.៤. ការធ្វើអង្កេតដីធ្លីដោយមានការចូលរួម ........ ១០១
១០.៥. ការរៀបចំកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី ........ ១០៣
១០.៦. ការរៀបចំរបាយការណ៍សិក្សាដីធ្លី ........ ១០៤
១០.៧. ការរៀបចំឯកសារដើម្បីចាត់ចែងសំណង ........ ១០៥
១០.៨. ការទូទាត់សំណងជាសាច់ប្រាក់នៅមុនពេលកិច្ចលទ្ធកម្ម ........ ១០៦

១០.៩. ការបំពេញទម្រង់របាយការណ៍លទ្ធកម្មដីធ្លី ............................................................................ ១០៦
១០.១០. ការបំពេញទម្រង់របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ................................................ ១១៦

## ជំពូកទី១១

## គោលការណ៍ណែនាំស្តីពីសុវត្ថិភាពជនជាតិដើមភាគតិច

១១.១. ជនជាតិដើមភាគតិច ............................................................................................................ ១១៧
១១.២. សិទ្ធិ និងការចូលរួមរបស់ជនជាតិដើមភាគតិច .......................................................................... ១១៨
១១.៣. គម្រោងដែលត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ........ ១១៨
១១.៤. ការប្រជុំផ្សព្វផ្សាយអំពីគម្រោងដល់ជនជាតិដើមភាគតិច .................................................... ១១៨
១១.៥. ការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោង ........................................ ១១៩
១១.៦. របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ........................................ ១២០
១១.៧. វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច ...................................................... ១២០
១១.៨. ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ........................... ១២១

## ឧបសម្ព័ន្ធទី១

## ទម្រង់នានា

ទម្រង់ទី១ ៖ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល ............................................ ១២៧
ទម្រង់ទី២ ៖ ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិចរបស់គម្រោង ................................................................................ ១៣១
ទម្រង់ទី៣ ៖ ផែនការសិក្សាគម្រោង ..................................................................................... ១៣២
ទម្រង់ទី៤ ៖ បញ្ជីទុនចូលរួមរបស់ប្រជាពលរដ្ឋ .................................................................. ១៣៣
ទម្រង់ទី៥ ៖ បញ្ជីស្រង់តម្លៃសម្ភារៈសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ..................................... ១៣៤
ទម្រង់ទី៦ ៖ បញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ................................... ១៣៦
ទម្រង់ទី៧ ៖ ព័ត៌មានគម្រោង ............................................................................................ ១៣៨
ទម្រង់ទី៨ ៖ ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលសំណង់ .............................................. ១៤២
ទម្រង់ទី៩ ៖ ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលការងារដី ............................................ ១៤៣
ទម្រង់ទី១០ ៖ ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់គម្រោងសេវាកម្ម ........................................... ១៤៤
ទម្រង់ទី១១ ៖ លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ...................................... ១៤៥
ទម្រង់ទី១២ ៖ លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងសេវាកម្ម .................................................. ១៤៦
ទម្រង់ទី១៣ ៖ ទីតាំងលទ្ធផលគម្រោង ................................................................................ ១៤៧
ទម្រង់ទី១៤ ៖ ផែនការប្រតិបត្តិការ និងការថែទាំគម្រោង ....................................................... ១៤៨
ទម្រង់ទី១៥.១ ៖ របាយការណ៍ស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន ........................................... ១៤៩
ទម្រង់ទី១៥.២ ៖ បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន ................................................................. ១៥០
ទម្រង់ទី១៥.៣ ៖ ផែនការគ្រប់គ្រងបរិស្ថាន ......................................................................... ១៥២
ទម្រង់ទី១៥.៤ ៖ ផែនការតាមដានផលប៉ះពាល់បរិស្ថាន ......................................................... ១៥៣

ទម្រង់ទី១៥.៥ ៖ បញ្ជីឈ្មោះអ្នកចូលរួមវិភាគផលប៉ះពាល់បរិស្ថាន ........................................ ១៥៤
ទម្រង់ទី១៦ ៖ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី........................ ១៥៥
ទម្រង់ទី១៧.១ ៖ របាយការណ៍ស្តីពីលទ្ធកម្មដីធ្លី ........................................................ ១៥៧
ទម្រង់ទី១៧.២ ៖ តារាងលទ្ធកម្មដីធ្លី ........................................................ ១៥៨
ទម្រង់ទី១៧.៣ ៖ កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី ........................................................ ១៥៩
ទម្រង់ទី១៧.៤ ៖ ការគណនាតម្លៃសំណង និងការទូទាត់សំណង ........................................ ១៦១
ទម្រង់ទី១៧.៥ ៖ បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង ........................ ១៦២
ទម្រង់ទី១៧.៦ ៖ សកម្មភាពនានាដែលត្រូវបញ្ចប់មុនពេលចាប់ផ្តើមកិច្ចលទ្ធកម្ម ........................ ១៦៣
ទម្រង់ទី១៧.៧ ៖ សកម្មភាពនានាដែលត្រូវបញ្ចូលក្នុងកិច្ចសន្យា ........................................ ១៦៤
ទម្រង់ទី១៧.៨ ៖ តារាងប្រគល់ ទទួលសំណង ........................................................ ១៦៥
ទម្រង់ទី១៧.៩ ៖ បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី ........................................................ ១៦៦
ទម្រង់ទី១៧.១០ ៖ របាយការណ៍ស្តីពីការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ........................................ ១៦៧
ទម្រង់ទី១៨.១ ៖ របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ........................ ១៦៨
ទម្រង់ទី១៨.២ ៖ វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច ........................................ ១៧០
ទម្រង់ទី១៨.៣ ៖ ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ........................ ១៧១
ទម្រង់ទី១៨.៤ ៖ បញ្ជីឈ្មោះអ្នកចូលរួមប្រជុំ ........................................................ ១៧២

## ឧបសម្ព័ន្ធទី២

## បញ្ជីលទ្ធផលស្តង់ដារ

១). បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ........................................ ១៧៣
២). បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារសម្រាប់គម្រោងសេវាកម្ម ........................................ ១៨៤

# ជំពូកទី១

# គម្រោងរាជធានី ខេត្ត

# ជំពូកទី១

# គម្រោងរាជធានី ខេត្ត

គម្រោងរាជធានី ខេត្ត គឺជាគម្រោងដែលបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ហើយថវិកាដែលបានវិភាជន៍សម្រាប់គម្រោងទាំងនេះ ត្រូវឆ្លុះបញ្ចាំងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត។ គម្រោងរាជធានី ខេត្តអាចមានលក្ខណៈជាគម្រោងរបស់រាជធានី ខេត្តនីមួយៗ ឬជាគម្រោងអន្តររដ្ឋបាលរវាងរដ្ឋបាលរាជធានី ខេត្តជាមួយរដ្ឋបាលប្រភេទដូចគ្នា(ជាមួយរដ្ឋបាលរាជធានី ខេត្ត) ឬប្រភេទខុសគ្នា(ជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬជាមួយរដ្ឋបាលឃុំ សង្កាត់ ឬជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់)។

## ១.១. គម្រោង និងលទ្ធផល

**គម្រោង** គឺជាសំណុំនៃលទ្ធផល(ឬសកម្មភាព) ដែលរួមគ្នាដើម្បីសម្រេចទិសដៅមួយ ក្នុងក្របខ័ណ្ឌពេលវេលាមួយ និងថវិកាជាក់លាក់។ **លទ្ធផល** គឺជាអ្វីមួយ (ហេដ្ឋារចនាសម្ព័ន្ធ ទំនិញ និងសេវាកម្ម) ដែលបានបង្កើតឡើងតាមរយៈការអនុវត្តសកម្មភាពនានានៃគម្រោង ដែលអាចរាប់ឬវាស់វែងបាន។ គម្រោងមួយអាចមាន ៖

- លទ្ធផលខុសៗគ្នា នៅទីតាំងតែមួយ (ឧទាហរណ៍ ៖ ទំនប់មួយខ្សែ ទ្វារទឹកមួយកន្លែង និងប្រឡាយមួយខ្សែ បង្កើតបានជាគម្រោងមួយហៅថា គម្រោងប្រព័ន្ធធារាសាស្ត្រ)។
- លទ្ធផលជាច្រើនដូចៗគ្នា នៅទីតាំងផ្សេងគ្នា (ឧទាហរណ៍ ៖ សាងសង់អគារសិក្សា២ខ្នង ១០បន្ទប់ នៅសាលាបឋមសិក្សា "ក" និង "ខ")។

**គម្រោងមួយត្រូវមាន ៖**

- ឈ្មោះមួយ (ជាការសំខាន់ដែលផ្តល់ឈ្មោះមួយឱ្យគម្រោងដើម្បីសម្គាល់គម្រោងនីមួយៗដាច់ពីគ្នា)
- ប្រភេទគម្រោង (ឧទាហរណ៍ ៖ "ផ្គត់ផ្គង់ទឹកស្អាតជនបទ" "គមនាគមន៍ជនបទ")
- រយៈពេល និងគម្រោងថវិកា (គម្រោងថវិកាដកស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត)
- យ៉ាងហោចណាស់ត្រូវមានទីតាំងមួយ
- យ៉ាងហោចណាស់ត្រូវមានលទ្ធផលមួយ។

**លទ្ធផលមួយត្រូវមាន ៖**

- ប្រភេទលទ្ធផលមួយ
- ទីតាំងមួយ
- ឯកតាមួយសម្រាប់ការវាស់វែង
- បរិមាណមួយ។

**កំណត់សម្គាល់ ៖**

- ជាទូទៅ លទ្ធផលជាច្រើនអាចស្ថិតក្នុងប្រភេទគម្រោងតែមួយ។ ប្រសិនបើលទ្ធផលនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត គឺជាផ្លូវក្រាលក្រួសក្រហម ហើយលទ្ធផលមួយផ្សេងទៀត គឺជាអណ្តូងស្នប់ នោះលទ្ធផលទាំងនេះ ត្រូវតែដាក់នៅក្នុងគម្រោង២ផ្សេងគ្នា គឺ"**គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទ**" និង"**គម្រោងផ្លូវលំជនបទ**" ឬ"**គម្រោងគមនាគមន៍ជនបទ**"។

- ចំពោះគម្រោងសេវាកម្មមួយចំនួនអាចរួមបញ្ចូលគ្នានូវសកម្មភាព ឬលទ្ធផលនានា ដែលមិនស្ថិតនៅក្នុងប្រភេទគម្រោងតែមួយ។ គម្រោងសេវាកម្មប្រភេទនេះអាចរួមបញ្ចូលគ្នានូវសេវាកម្ម សម្ភារៈទំនិញ និងឬការងារសាងសង់តូចតាច ដើម្បីសម្រេចបាននូវទិសដៅរួមរបស់គម្រោង។
- លទ្ធផលនានាដែលរួមគ្នាដើម្បីសម្រេចទិសដៅតែមួយត្រូវដាក់ជាមួយគ្នានៅក្នុងគម្រោងមួយ។
**ឧទាហរណ៍ ៖**
  - លូ ស្ពាន និងផ្លូវក្រាលក្រួសក្រហមមួយខ្សែ ត្រូវដាក់ជាមួយគ្នានៅក្នុងគម្រោងតែមួយ។
  - គម្រោងកសិកម្មចម្រុះដែលរួមមានលទ្ធផល ដូចជាកសិករទទួលបាននូវការបណ្តុះបណ្តាល ស្រះសម្រាប់ចិញ្ចឹមត្រី រោងជីកំប៉ុស្តិ៍ ទ្រុងចិញ្ចឹមសត្វ គ្រាប់ពូជ កូនត្រី ពូជសត្វ និងសម្ភារៈសម្រាប់ការសាងសង់នានា។ លទ្ធផលទាំងអស់នេះត្រូវដាក់បញ្ចូលទៅក្នុងគម្រោងតែមួយ ពីព្រោះលទ្ធផលទាំងអស់នេះរួមគ្នាសម្រេចបាននូវទិសដៅតែមួយ គឺកសិកម្មចម្រុះ ដើម្បីបង្កើនជីវភាពរស់នៅប្រជាពលរដ្ឋ។

**ឧទាហរណ៍អំពីគម្រោង និងលទ្ធផល ៖**

| ប្រភេទគម្រោង | លទ្ធផល |
|---|---|
| គមនាគមន៍ជនបទ | សាងសង់លូ៨កន្លែង សាងសង់ស្ពាន១កន្លែង និងសាងសង់ផ្លូវក្រួសក្រហមប្រវែង១៥គ.ម ឆ្លងកាត់៣ភូមិ ៖<br>• លូ២កន្លែង ស្ពាន១កន្លែង និងផ្លូវក្រួសក្រហម៥គ.ម ស្ថិតនៅភូមិ "ក"<br>• លូ៤កន្លែង និងផ្លូវក្រួសក្រហម៥គ.ម ស្ថិតនៅភូមិ "ខ"<br>• លូ២កន្លែង និងផ្លូវក្រួសក្រហម៥គ.ម ស្ថិតនៅភូមិ "គ" |
| ផ្គត់ផ្គង់ទឹកស្អាត | អណ្តូងលូចំនួន៣០ នៅក្នុងភូមិ៣ និងអណ្តូងស្នប់ចំនួន៤០ នៅក្នុងភូមិ៤។ |
| ការអប់រំ | សាងសង់អគារសិក្សា២ខ្នង ១០បន្ទប់ បំពាក់សង្ហារិម អណ្តូងទឹក២ និងបង្គន់អនាម័យចំនួន៤ នៅអនុវិទ្យាល័យ "ក" និង "ខ" ។ |
| សហគមន៍ជលផល | រចនាសម្ព័ន្ធនិងលក្ខន្តិកៈគ្រប់គ្រងសហគមន៍ ផែនទីសហគមន៍ ការបោះបង្គោលបេតុង៣០០ដើមដើម្បីកំណត់ព្រំប្រទល់សហគមន៍ ការចុះបញ្ជីសហគមន៍ និងកិច្ចព្រមព្រៀងផែនការគ្រប់គ្រងសហគមន៍ (ការការពារកូនឈើព្រៃលិចទឹក ការអភិវឌ្ឍវារីវប្បកម្មទេសចរណ៍ធម្មជាតិ ...។ល។ ) |

**បញ្ជាក់ ÷**

- សកម្មភាពសេវារដ្ឋបាលរបស់រាជធានី ខេត្ត មិនមែនជាគម្រោងទេ។
- ពេលវេលាសម្រាប់អនុវត្តគម្រោងអាចមានរយៈពេលច្រើនជាងមួយឆ្នាំ។ ប្រសិនបើគម្រោងមានទំហំធំពេកមិនអាចអនុវត្តក្នុងរយៈពេលមួយឆ្នាំបាន រាជធានី ខេត្តអាចសម្រេចឱ្យអនុវត្តតាមផ្នែកៗនៃគម្រោងក្នុងឆ្នាំនីមួយៗ សម្រាប់រយៈពេលច្រើនឆ្នាំ។

## ១.២. គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាគម្រោងដែលបង្កើតបានជាអចលនទ្រព្យ ដែលស្ថិតនៅមួយកន្លែង ហើយប្រជាពលរដ្ឋជាទូទៅប្រើប្រាស់បាន។

ឧទាហរណ៍មួយចំនួននៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈរួមមាន ៖

- ផ្លូវ ស្ពាន លូ
- ការផ្គត់ផ្គង់ទឹក ដូចជាអណ្តូង ស្រះ អាងទឹក ឬក៏បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់នៅតាមផ្ទះនៅមូលដ្ឋាន
- អនាម័យសាធារណៈ និងប្រព័ន្ធបង្ហូរទឹកស្អុយ
- ប្រព័ន្ធធារាសាស្ត្រ លើកលែងតែម៉ាស៊ីនបូមទឹកចល័ត
- ប្រព័ន្ធ និងបណ្តាញចែកចាយអគ្គិសនីសម្រាប់ប្រើប្រាស់តាមផ្ទះ
- សំណង់ផ្សារ ឬទីតាំងផ្សារ
- សំណង់សាលារៀន
- មណ្ឌលសុខភាព
- បណ្តាញផ្គត់ផ្គង់ទឹក និងអនាម័យតាមអគារសាធារណៈ ដូចជា ទីផ្សារ សាលារៀន មណ្ឌលសុខភាព
- សំណង់កន្លែងដាក់សំរាម (ឧទាហរណ៍ ឡដុតសំរាមនៅទីផ្សារ)
- សំណង់កន្លែងគាំទ្រប្រព័ន្ធការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- ប្រភេទនៃអគារ ឬសំណង់ផ្សេងទៀត។

## ១.៣. គម្រោងសេវាកម្ម

គម្រោងសេវាកម្ម គឺជាសកម្មភាពមួយ ឬសំណុំសកម្មភាពនានាដែលមានទំនាក់ទំនង និងគាំទ្រគ្នាទៅវិញទៅមកដើម្បីសម្រេចបាននូវទិសដៅគម្រោង ដូចជាការអភិវឌ្ឍធនធានមនុស្ស សកម្មភាពបង្កើនប្រាក់ចំណូល ការផ្តល់សម្ភារៈបរិក្ខារ-ទំនិញ ការផ្តល់ពូជ ការរៀបចំសហគមន៍ និងឬការសាងសង់ខ្នាតតូចជាដើម។

ឧទាហរណ៍ ៖ គម្រោងកសិកម្មចម្រុះ។ ទិសដៅនៃគម្រោងនេះ គឺដើម្បីបង្កើនជីវភាពរស់នៅប្រជាពលរដ្ឋ។ សកម្មភាពនានានៃគម្រោងនេះ អាចមាន ៖

- ការរៀបចំក្រុម និងលក្ខន្តិកៈក្រុម
- ការបណ្តុះបណ្តាល
- ការជីកស្រះសម្រាប់ចិញ្ចឹមត្រី
- ការធ្វើរោងជីកំប៉ុស្តិ៍
- ការធ្វើទ្រុងចិញ្ចឹមសត្វ
- ការផ្តល់គ្រាប់ពូជ កូនត្រី ពូជសត្វ និងសម្ភារៈសម្រាប់ការសាងសង់នានា
- ការចុះតាមដាន និងជួយកសិករគោលដៅក្នុងការអនុវត្តជាក់ស្តែង។

**កំណត់សម្គាល់ ÷**

សំណុំឯកសារគម្រោងត្រូវរក្សាទុកនៅសាលារាជធានី ខេត្ត។ ចំពោះគម្រោងអន្តររដ្ឋបាល សំណុំឯកសារគម្រោងច្បាប់ដើមត្រូវរក្សាទុកនៅការិយាល័យនៃប្រធានគណៈកម្មការរៀបចំគម្រោង ហើយច្បាប់ចតចម្លងរក្សាទុកនៅតាមរដ្ឋបាលដែលពាក់ព័ន្ធគម្រោងនោះ។

# ជំពូកទី២

# ការរៀបចំគម្រោងរាជធានី ខេត្ត

# ជំពូកទី២
# ការរៀបចំគម្រោងរាជធានី ខេត្ត

ការរៀបចំគម្រោងត្រូវធ្វើឡើង បន្ទាប់ពីគម្រោងត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងមុនពេលការចាប់ផ្តើមដំណើរការលទ្ធកម្ម។ ការរៀបចំគម្រោង គឺជាការសិក្សា និងប្រមូលព័ត៌មានទាំងអស់ដែលត្រូវការ ដើម្បីរៀបចំឱ្យបាននូវសំណើគម្រោង។

ការរៀបចំគម្រោងរួមមាន ៖

- ការបង្កើតគណៈកម្មការរៀបចំគម្រោង
- ការកំណត់អ្នកជំនួយបច្ចេកទេស
- ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង
- ការរៀបចំក្រុមប្រើប្រាស់ ឬអ្នកទទួលផល
- ការរៀបចំផែនការសិក្សាគម្រោង
- ការរៀបចំផែនទីគម្រោង
- ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស
- ការសិក្សាផលប៉ះពាល់បរិស្ថាន
- ការសិក្សាដីធ្លី (របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ឬរបាយការណ៍លទ្ធកម្មដីធ្លី)
- ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- ការរៀបចំគ្រោងការគម្រោង
- ការរៀបចំស្លាកសញ្ញាគម្រោង
- ការប៉ាន់ស្មានតម្លៃ និងព័ត៌មានលម្អិតនៃលទ្ធផលគម្រោង
- ការរៀបចំផែនការប្រតិបត្តិ និងថែទាំលទ្ធផលគម្រោង
- ការពិនិត្យ និងអនុម័តសំណើគម្រោង
- ការពិនិត្យបញ្ជាក់បច្ចេកទេស
- ការពិនិត្យ និងការផ្តល់អនុលោមភាព។

## ២.១. ការបង្កើតគណៈកម្មការរៀបចំគម្រោង

រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំបង្កើតគណៈកម្មការរៀបចំគម្រោងមួយ។ គណៈអភិបាលរាជធានី ខេត្ត រៀបចំសមាសភាព និងតួនាទី ភារកិច្ចរបស់គណៈកម្មការរៀបចំគម្រោង ហើយដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័ត។ សមាសភាពគណៈកម្មការនេះត្រូវមានស្ត្រីចូលរួម។ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការរៀបចំគម្រោង។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

### ក). គណៈកម្មការរៀបចំគម្រោង

សមាសភាពរបស់គណៈកម្មការរៀបចំគម្រោងរួមមាន ៖

- អភិបាលរាជធានី ខេត្ត ជាប្រធាន
- អភិបាលរងរាជធានី ខេត្តមួយរូប ជាអនុប្រធាន
- នាយករដ្ឋបាល ឬនាយករងរដ្ឋបាលសាលារាជធានី ខេត្ត ជាសមាជិកអចិន្ត្រៃយ៍

- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ជាសមាជិក
- តំណាងទីចាត់ការ ឬអង្គភាពពាក់ព័ន្ធ ជាសមាជិក
- នាយក ឬនាយករងទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ជាលេខាធិការ

ប្រធានគណៈកម្មការរៀបចំគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការរៀបចំគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យអនុប្រធាន ជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការរៀបចំគម្រោងអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការរៀបចំគម្រោងអវត្តមាន សមាជិកនោះអាចផ្ទេរសិទ្ធិឱ្យទៅសមាជិកណាមួយនៅក្នុងអង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការរៀបចំគម្រោងផងដែរ។ ការផ្ទេរសិទ្ធិនេះត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។

ប្រធានគណៈកម្មការរៀបចំគម្រោងអាចអញ្ជើញគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលផលផ្ទាល់ពីគម្រោង និងបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំគម្រោងក្នុងនាមជាអ្នកសង្កេតការ។

អ្នកជំនួយបច្ចេកទេស និងមន្ត្រីដែលមានភារកិច្ចជួយគាំទ្ររាជធានី ខេត្តត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោង ក្នុងនាមជាអ្នកសង្កេតការ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ខ). គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល**

ក្នុងករណីរដ្ឋបាលរាជធានី ខេត្តធ្វើកិច្ចសហប្រតិបត្តិការ និងព្រមព្រៀងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នា ឬប្រភេទខុសគ្នា រដ្ឋបាលពាក់ព័ន្ធនឹងគម្រោងនោះត្រូវជួបប្រជុំគ្នា ដើម្បីពិភាក្សា និងព្រមព្រៀងទៅលើការបង្កើតគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមួយ សម្រាប់គម្រោងអន្តររដ្ឋបាលនីមួយៗ តាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងនោះ(**ទម្រង់ទី១**)។

គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានសមាសភាពដូចខាងក្រោម ៖

- អភិបាល ឬមេឃុំ ចៅសង្កាត់មួយរូបនៃរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលនោះជាប្រធាន
- អភិបាល ឬមេឃុំ ចៅសង្កាត់ទាំងអស់នៃរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលនោះ ជាសមាជិក
- នាយករដ្ឋបាលឬនាយករងរដ្ឋបាល ឬស្មៀនឃុំ សង្កាត់នៃប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ជាលេខាធិការ

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាអភិបាល ឬជាមេឃុំ ចៅសង្កាត់ដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលនោះ តាមការព្រមព្រៀងឯកភាពគ្នារវាងរដ្ឋបាលពាក់ព័ន្ធនឹងគម្រោងទាំងនោះ។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាតំណាងផ្លូវការក្នុងការចុះហត្ថលេខាលើគ្រប់ឯកសារផ្លូវការនានាពាក់ព័ន្ធនឹងការរៀបចំគម្រោងអន្តររដ្ឋបាល ដោយប្រើប្រាស់ត្រា និងចុះលេខរបស់រដ្ឋបាលសាមី។ ក្នុងករណីប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអវត្តមាន អភិបាលស្តីទី ឬមេឃុំ ចៅសង្កាត់ស្តីទីនៃរដ្ឋបាលដែលទទួលភារកិច្ចជាប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាប្រធានស្តីទីនៃគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការរៀបចំគម្រោង។ ក្នុងករណីប្រធានអវត្តមាន ប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអវត្តមាន សមាជិកនោះអាចផ្ទេរសិទ្ធិឱ្យទៅសមាជិកណាមួយនៅក្នុងអង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលផងដែរ។ ការផ្ទេរសិទ្ធិនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលក្នុងនាមជាអ្នកសង្កេតការ។

អ្នកជំនួយបច្ចេកទេស និងមន្ត្រីដែលមានភារកិច្ចគាំទ្ររាជធានី ខេត្តត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ក្នុងនាមជាអ្នកសង្កេតការ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# ស្តីពី
# ការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល

កិច្ចព្រមព្រៀងនេះ ធ្វើឡើងនៅថ្ងៃទី....... ខែ........... ឆ្នាំ......... រវាង ៖

- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................

ភាគីទាំងអស់បានឯកភាពគ្នាតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោម ៖

**ប្រការ ១.-**

គម្រោង....................................(ឈ្មោះគម្រោង)................................................................. នឹងអនុវត្តទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

**ប្រការ ២.-**

ចំនួនថវិកាប៉ាន់ស្មានដែលត្រូវចូលរួមចំណែកដល់គម្រោងអន្តររដ្ឋបាលនៃរដ្ឋបាលនីមួយៗដែលពាក់ព័ន្ធមានដូចខាងក្រោម ៖

- រដ្ឋបាល............... ចំនួន................ (ជាអក្សរ..............................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ..............................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ..............................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ..............................................................)

**សរុប**......................... (ជាអក្សរ..............................................................)

រដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលបានឯកភាពគ្នា ក្នុងការផ្ទេរថវិកានៃចំណែករបស់ខ្លួនទាំងអស់ ឬជាដំណាក់កាលទៅក្នុងគណនីរបស់រដ្ឋបាលនៃប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល បន្ទាប់ពីកិច្ចសន្យានៃគម្រោងនេះត្រូវបានចុះហត្ថលេខា។

**ប្រការ ៣.-**

គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានសមាសភាពដូចខាងក្រោម ៖

| ល.រ | ឈ្មោះ | ភេទ | មកពី | តួនាទី |
|---|---|---|---|---|
| | | | | ប្រធាន |
| | | | | សមាជិក |

| ល.រ | ឈ្មោះ | ភេទ | មកពី | តួនាទី |
|---|---|---|---|---|
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | លេខាធិការ |

**ប្រការ ៤.-**

គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោងអន្តររដ្ឋបាល
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការរៀបចំ និងការអនុវត្តគម្រោងអន្តររដ្ឋបាល
- រៀបចំសំណើគម្រោងអន្តររដ្ឋបាល ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោងអន្តររដ្ឋបាល។

**ប្រការ ៥.-**

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាតំណាងផ្លូវការរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ក្នុងការចុះហត្ថលេខាលើឯកសារផ្លូវការនានាដែលទាក់ទងនឹងការរៀបចំគម្រោង ដោយប្រើប្រាស់ត្រា និងចុះលេខរបស់រដ្ឋបាលសាមី។

ក្នុងករណីប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអវត្តមាន អភិបាលស្តីទី ឬមេឃុំ ចៅសង្កាត់ស្តីទីនៃរដ្ឋបាលដែលទទួលភារកិច្ចជាប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាប្រធានស្តីទីនៃគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការរៀបចំគម្រោង។ ក្នុងករណីប្រធានអវត្តមាន ប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអវត្តមាន សមាជិកនោះអាចផ្ទេរសិទ្ធិឱ្យទៅសមាជិកណាមួយនៅក្នុងអង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលផងដែរ។ ការផ្ទេរសិទ្ធិនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលក្នុងនាមជាអ្នកសង្កេតការ។

អ្នកជំនួយបច្ចេកទេស និងមន្ត្រីដែលមានភារកិច្ចគាំទ្ររាជធានី ខេត្តត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ក្នុងនាមជាអ្នកសង្កេតការ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ ៦.-**

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មនៃរដ្ឋបាលដែលជាប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ត្រូវបានប្រើប្រាស់សម្រាប់កិច្ចលទ្ធកម្មគម្រោងអន្តររដ្ឋបាលនេះ។

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មដែលត្រូវបានប្រើប្រាស់សម្រាប់កិច្ចលទ្ធកម្មគម្រោងអន្តររដ្ឋបាលនេះ មានតួនាទី និងភារកិច្ចដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មដែលត្រូវបានប្រើប្រាស់សម្រាប់កិច្ចលទ្ធកម្មគម្រោងអន្តររដ្ឋបាលនេះ ត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃកិច្ចលទ្ធកម្មគម្រោងអន្តររដ្ឋបាល ជូនរដ្ឋបាលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលនេះ។

គណៈកម្មាធិការលទ្ធកម្មនៃរដ្ឋបាលពាក់ព័ន្ធដទៃទៀតនៃគម្រោងអន្តររដ្ឋបាលនេះ អាចចូលរួមនៅក្នុងកិច្ចដំណើរការលទ្ធកម្មគម្រោងអន្តររដ្ឋបាលនេះ ជាអ្នកសង្កេតការ។

**ប្រការ ៧.-**

លោក លោកស្រី.................................. ជាអ្នកជំនួយបច្ចេកទេសសម្រាប់គម្រោង...................... ...............(ឈ្មោះគម្រោង)................................................. ។

អ្នកជំនួយបច្ចេកទេសជួយគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលលើការងារដូចខាងក្រោម ៖

- ពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង
- រៀបចំផែនការសិក្សាគម្រោង
- រៀបចំផែនទីគម្រោង
- អនុវត្តការសិក្សាលទ្ធភាពគម្រោង
- ជួយក្នុងការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- រៀបចំគ្រោងការគម្រោង
- ប៉ាន់ស្មានតម្លៃគម្រោង
- បំពេញព័ត៌មានផ្នែកបច្ចេកទេសទៅក្នុងទម្រង់ព័ត៌មានគម្រោង
- ចូលរួមគ្រប់ការប្រជុំគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល។

**ប្រការ ៨.-**

កិច្ចព្រមព្រៀងនេះ រៀបចំឡើងចំនួន........ច្បាប់ដើម ហើយរក្សាទុកនៅរដ្ឋបាលនីមួយៗដែលពាក់ព័ន្ធនឹងគម្រោង០១ច្បាប់។

**ប្រការ ៩.-**

កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អភិបាល ឬមេឃុំ ចៅសង្កាត់**............ **អភិបាល ឬមេឃុំ ចៅសង្កាត់**............

**អភិបាល ឬមេឃុំ ចៅសង្កាត់**............ **អភិបាល ឬមេឃុំ ចៅសង្កាត់**............

## ២.២. ការកំណត់អ្នកជំនួយបច្ចេកទេស

គណៈអភិបាលរាជធានី ខេត្តត្រូវកំណត់អ្នកជំនួយបច្ចេកទេសដើម្បីជួយក្នុងការរៀបចំគម្រោងរបស់ខ្លួន។ អ្នកជំនួយបច្ចេកទេស អាចជា ៖

- មន្ត្រីនៃសាលារាជធានី ខេត្ត។ ក្នុងករណីនេះ គណៈអភិបាលរាជធានី ខេត្តត្រូវតែងតាំងមន្ត្រីបច្ចេកទេសមួយរូប ជាអ្នកជំនួយបច្ចេកទេស។
- មន្ត្រីនៃមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត។ ក្នុងករណីនេះ គណៈអភិបាលរាជធានី ខេត្តត្រូវស្នើសុំទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តជាលាយល័ក្ខណ៍អក្សរ ដើម្បីផ្តល់មន្ត្រីបច្ចេកទេសមួយរូបជាអ្នកជំនួយបច្ចេកទេស។
- អ្នកជំនាញ ឬក្រុមហ៊ុន ឬអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងករណីនេះ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការជ្រើសរើសទៅតាមនីតិវិធីដែលបានកំណត់ និងប្រកបដោយតម្លាភាព។

នៅពេលកំណត់បានអ្នកផ្តល់ជំនួយបច្ចេកទេសហើយ គណៈអភិបាលរាជធានី ខេត្តត្រូវតែងតាំងអ្នកជំនួយបច្ចេកទេសនោះ។

## ២.៣. ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង

អ្នកជំនួយបច្ចេកទេសត្រូវពិនិត្យគម្រោងរាជធានី ខេត្ត ដើម្បីកំណត់ថា តើគម្រោងនោះត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដែរឬទេ។

**គម្រោងដែលត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថាន គឺជាគម្រោងដែល ៖**

- ទីតាំងនៃគម្រោងនោះ ស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន
- ការអនុវត្តនៃគម្រោងនោះអាចបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់កន្លែងមួយចំនួន ដែលមានសារៈសំខាន់លើផ្នែកបរិស្ថាន ឬវប្បធម៌
- ការអនុវត្តនៃគម្រោងអាចបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់ប្រភពផ្គត់ផ្គង់ទឹក ដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់

- លទ្ធផលនៃគម្រោងនោះ ជាខ្សែផ្លូវថ្មី។ ខ្សែផ្លូវថ្មី គឺជា ៖
  - ផ្លូវ ឬផ្នែកមួយនៃផ្លូវដែលមិនមែនជាផ្លូវពីមុន ឬ
  - ផ្នែកមួយនៃផ្លូវចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្សផ្លូវ ឬ
  - ផ្លូវចាស់ត្រូវបានពង្រីកទទឹងផ្លូវធំជាងមុនចាប់ពី២៥%ឡើងទៅ។
- លទ្ធផលគម្រោងនោះ ជាខ្សែទំនប់ថ្មី ឬខ្សែប្រឡាយថ្មី ឬអាងស្តុកទឹកថ្មី(ប្រព័ន្ធធារាសាស្ត្រថ្មី)។ ខ្សែទំនប់ថ្មី ឬខ្សែប្រឡាយថ្មី គឺជា ៖
  - ទំនប់ ឬប្រឡាយ ឬផ្នែកមួយនៃទំនប់ ឬប្រឡាយដែលមិនមែនជាទំនប់ ឬប្រឡាយពីមុន ឬ
  - ផ្នែកមួយនៃទំនប់ ឬប្រឡាយចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្សទំនប់ ឬប្រឡាយ។
- លទ្ធផលគម្រោងនោះ ជាខ្សែព្រែកជីកថ្មីសម្រាប់ការធ្វើដំណើរផ្លូវទឹក និងឬផ្គត់ផ្គង់ទឹកប្រើប្រាស់។ ខ្សែព្រែកជីកថ្មី គឺជា ៖
  - ព្រែកជីក ឬផ្នែកមួយនៃព្រែកជីក ដែលមិនមែនជាព្រែកជីកពីមុន ឬ
  - ផ្នែកមួយនៃព្រែកជីកចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្សព្រែកជីក។

**កំណត់សម្គាល់** ÷ ចំពោះគម្រោងរាជធានី ខេត្តដែលមានទីតាំងស្ថិតនៅឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ទោះបីជាគម្រោងទាំងនោះមាន ឬមិនមាននៅក្នុងចំណុចដូចបានបរិយាយខាងលើក៏ដោយ ក៏ទាមទារការត្រួតពិនិត្យពិសេសអំពីសក្តានុពលនៃផលប៉ះពាល់បរិស្ថាន។ ចំពោះគម្រោងទាំងឡាយណាដែលត្រួតពិនិត្យទៅឃើញថា មានសក្តានុពលនៃផលប៉ះពាល់បរិស្ថាន (ជាពិសេសគ្រប់គម្រោងផ្លូវថ្មីទាំងអស់ និងគម្រោងទាំងឡាយដូចបានបរិយាយខាងលើ) ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងចាត់តាំងមន្ត្រីទទួលបន្ទុកដើម្បីចុះពិនិត្យទីតាំងគម្រោងទាំងនោះ និងផ្តល់យោបល់អំពីរបៀបវិភាគផលប៉ះពាល់បរិស្ថាន និងរបៀបរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងផែនការតាមដានផលប៉ះពាល់បរិស្ថាន។ លើសពីនេះទៀត ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសារឧបសម្ព័ន្ធនានានៃរបាយការណ៍នេះ ជាទម្រង់ឯកសារក្នុងកុំព្យូទ័រ តាមរយៈអ៊ីម៉ែលជូនក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យជាមុនសិន មុននឹងផ្ញើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាននេះទៅមន្ទីរបរិស្ថាន ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ បើពិនិត្យឃើញថា របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសារឧបសម្ព័ន្ធនានា មានចំណុចខុសឆ្គង ឬខ្វះខាតព័ត៌មានមួយចំនួនដែលត្រូវកែតម្រូវឬបំពេញបន្ថែម ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជម្រាបដល់ទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្តវិញ តាមរយៈអ៊ីម៉ែលក្នុងរយៈពេល**១០ថ្ងៃធ្វើការ**។ នៅមុនពេលទទួលបាននូវការយល់ព្រមពីក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តមិនត្រូវផ្ញើព័ត៌មានគម្រោងទាំងនោះទៅមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធសម្រាប់ការពិនិត្យបញ្ជាក់បច្ចេកទេសឡើយ។

**គម្រោងដែលត្រូវធ្វើការសិក្សាដីធ្លី គឺជាគម្រោងដែលនឹងប្រើប្រាស់ ៖**

- ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ទោះបីដីនោះជាដីសាធារណៈ ឬដីឯកជនក៏ដោយ) ហើយគ្រប់គ្រួសារដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង បានយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដោយស្ម័គ្រចិត្តដល់គម្រោង។ មិនមាន

អ្នកប្រើប្រាស់ដីធ្លីណាមួយបានប្រគល់ដីឱ្យទៅគម្រោងច្រើនជាង**៥%** នៃផ្ទៃដីសរុបរបស់ខ្លួននោះទេ ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង**១.០០០.០០០រៀល**ឡើយ។ ចំពោះគម្រោងប្រភេទនេះតម្រូវឱ្យមានការរៀបចំ**របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**។

- ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ទោះបីដីនោះជាដីសាធារណៈ ឬដីឯកជនក៏ដោយ) ហើយគ្រួសារមួយចំនួនដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង មិនយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដល់គម្រោងដោយគ្មានសំណងទូទាត់។ មានអ្នកប្រើប្រាស់ដីធ្លីមួយចំនួន នឹងត្រូវប្រគល់ដីធ្លីច្រើនជាង**៥%**នៃផ្ទៃដីសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង**១.០០០.០០០រៀល**សម្រាប់គម្រោង។ ចំពោះគម្រោងប្រភេទនេះតម្រូវឱ្យមានការរៀបចំ**របាយការណ៍លទ្ធកម្មដីធ្លី**។

**គម្រោងដែលត្រូវការរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច** គឺជាគម្រោងទាំងឡាយ ដែលមានទីតាំងស្ថិតនៅក្នុងភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅ**លើសពី៥ភាគរយ**នៃប្រជាពលរដ្ឋក្នុងភូមិសរុប)។

ឧបសម្ព័ន្ធ២

**ការពិនិត្យអំពីតម្រូវការនៃការសិក្សា**

**ផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង**

| | | |
|---|---|---|
| រាជធានី ខេត្ត ៖ | លេខកូដរាជធានី ខេត្ត ៖ | |
| ឈ្មោះគម្រោង ៖ | | |
| តើគម្រោងត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថានដែរឬទេ? | | បាទ☐ ទេ☐ |
| បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ ៖...................................................<br>...................................................<br>................................................... | | |
| តើគម្រោងត្រូវធ្វើការសិក្សាដីធ្លីដែរឬទេ? | | បាទ☐ ទេ☐ |
| បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ ៖...................................................<br>...................................................<br>................................................... | | |
| តើគម្រោងត្រូវការរៀបចំវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចដែរឬទេ? | | បាទ☐ ទេ☐ |
| បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ ៖...................................................<br>...................................................<br>................................................... | | |

ថ្ងៃទី........ ខែ............. ឆ្នាំ......... ថ្ងៃទី........ ខែ............. ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **អ្នកជំនួយបច្ចេកទេស**

## ២.៤. ការរៀបចំក្រុមប្រើប្រាស់

គ្រប់គម្រោងរាជធានី ខេត្តទាំងអស់ត្រូវមានក្រុមប្រើប្រាស់មួយ ដែលនឹងទទួលខុសត្រូវក្នុងការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង។ គម្រោងមួយចំនួន ក្រុមប្រើប្រាស់នេះត្រូវបានបង្កើតរួចហើយដោយមន្ទីរ អង្គភាពជំនាញ។ ចំពោះគម្រោងណាដែលមិនទាន់បានបង្កើតក្រុមប្រើប្រាស់ រាជធានី ខេត្តត្រូវរៀបចំបង្កើតឡើងនៅដំណាក់កាលចាប់ផ្តើមនៃការរៀបចំគម្រោង។

## ២.៥. ការរៀបចំផែនការសិក្សាគម្រោង

ផែនការសិក្សាគម្រោង(**ទម្រង់ទី៣**)ត្រូវរៀបចំឡើងសម្រាប់ការសិក្សាគម្រោងទាំងមូល មិនមែនសម្រាប់តែលទ្ធផលគម្រោងដែលមានថវិកាអនុវត្តនោះទេ។ ផែនការសិក្សាគម្រោងមួយសម្រាប់គម្រោងមួយ។

អ្នកជំនួយបច្ចេកទេសត្រូវធ្វើការសិក្សាគម្រោងទៅតាមផែនការនេះ។

ផែនការសិក្សាគម្រោងនីមួយៗ ត្រូវបង្ហាញ ៖

- ឈ្មោះគម្រោង
- លទ្ធផលគ្រោងរបស់គម្រោង
- សកម្មភាពសិក្សាគម្រោង
- តម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន
- តម្រូវការនៃការសិក្សាដីធ្លី
- តម្រូវការនៃការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- ចំនួនថ្ងៃសិក្សាគម្រោង
- កាលបរិច្ឆេទគ្រោងបញ្ចប់ការសិក្សាគម្រោង
- យោបល់ផ្សេងៗ។

**កំណត់សម្គាល់** ÷ អ្នកជំនួយបច្ចេកទេសមិនមែនធ្វើការសិក្សាគម្រោងតែម្នាក់ឯងនោះទេ។ រដ្ឋបាលរាជធានី ខេត្តត្រូវធានាឱ្យមានអ្នកទទួលផលពីគម្រោងគ្រប់គ្រាន់ ដើម្បីជួយដល់អ្នកជំនួយបច្ចេកទេសក្នុងការសិក្សាគម្រោង។

**ឧបសម្ព័ន្ធទី៣**

## ផែនការសិក្សាគម្រោងឆ្នាំ២០១៤

| រាជធានី ខេត្ត ៖ កណ្តាល | លេខកូដរាជធានី ខេត្ត ៖ |
|---|---|

| ឈ្មោះគម្រោង | លទ្ធផលគ្រោង | សកម្មភាពសិក្សាគម្រោង | ត្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន | ត្រូវការនៃការសិក្សាដីធ្លី | ត្រូវការវិធានការការពារជនជាតិដើម | ចំនួនថ្ងៃធ្វើការងារ | កាលបរិច្ឆេទបញ្ចប់ផែនការ | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| សាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក‹ក›មកទីរួមខេត្ត | ផ្លូវក្រាលក្រួសក្រហម១៥គម ស្ពានបេតុង១កន្លែង និងលូ៤កន្លែង | ស្ថានភាពផ្លូវ ជម្រៅទឹកជំនន់ សិក្សាកន្លែងដែលត្រូវដាក់លូ និងសាងសង់ស្ពាន | ទេ | ទេ | ទេ | ១០ | ០៧/០២/១៤ | |
| សាងសង់ប្រព័ន្ធធារាសាស្ត្រភូមិ ‹ក› | ស្តាបនាប្រឡាយ៥គម ទ្វារទឹក១ និងលូទឹក២កន្លែង | សិក្សាឋានលេខា ប្រមូលទិន្នន័យពីមន្ទីរធនធានទឹកស្តីពីកម្រិតទឹកក្នុងប្រឡាយមេ វាស់វែងផ្ទៃដីស្រោចស្រព សិក្សាទីតាំងសំណង់។ | បាទ | បាទ | ទេ | ២០ | ២១/០៣/១៤ | ទុកពេលវេលាគ្រប់គ្រាន់សម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន និង របាយការណ៍សិក្សាដីធ្លី |
| សាងសង់សាលារៀននៅអនុវិទ្យាល័យ‹ក› | ១ខ្នង ៥បន្ទប់ អណ្តូងទឹក១ និងបង្គន់អនាម័យ២ | សិក្សាទីតាំងសាងសង់ | ទេ | ទេ | ទេ | ៥ | ១៤/០២/១៤ | |

ថ្ងៃទី........ ខែ............ ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ............ ឆ្នាំ.........

**អ្នកជំនួយបច្ចេកទេស**

## ២.៦. ការរៀបចំផែនទីគម្រោង

ផែនទីគម្រោងត្រូវតែជាផែនទីរាជធានី ខេត្ត ដែលបង្ហាញអំពីទីតាំងនៃលទ្ធផលនានារបស់គម្រោងដែលបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេស និងបណ្តាភូមិទាំងឡាយដែលអ្នកទទួលផលរស់នៅ។ ផែនទីគម្រោងត្រូវប្រថាប់ត្រារដ្ឋបាលរាជធានី ខេត្ត។

មានតែលទ្ធផលដែលបង្ហាញនៅលើផែនទីនេះប៉ុណ្ណោះ ត្រូវបញ្ចូលទៅក្នុងកិច្ចសន្យាដើម្បីអនុវត្ត។ ប្រសិនបើរាជធានី ខេត្តចង់ផ្លាស់ប្តូរទីតាំងលទ្ធផលគម្រោង ឬបង្កើនបន្ថែមចំនួនលទ្ធផលគម្រោងត្រូវអនុវត្តនីតិវិធីនៃការពិនិត្យបញ្ជាក់បច្ចេកទេសជាថ្មីឡើងវិញ។

## ២.៧. ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស

អ្នកជំនួយបច្ចេកទេស នឹងជួយគណៈកម្មការរៀបចំគម្រោងក្នុងការចុះសិក្សាបច្ចេកទេសគម្រោងរាជធានី ខេត្ត នៅទីតាំងគម្រោង ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋ ក្រុមប្រើប្រាស់ និងអង្គការសហគមន៍មូលដ្ឋានក្នុងគោលបំណងប្រមូលព័ត៌មានសំខាន់ៗ និងចាំបាច់ ដើម្បីបំពេញទម្រង់ព័ត៌មានគម្រោង ទម្រង់ព័ត៌មានបច្ចេកទេស និងទម្រង់នានា។

ព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេសត្រូវបានប្រើប្រាស់ដើម្បីបង្កើតគ្រោងការគម្រោង។ ព័ត៌មានបច្ចេកទេសនៃគម្រោងនីមួយៗ អាចខុសៗគ្នាទៅតាមប្រភេទគម្រោងនីមួយៗ។ ព័ត៌មានបច្ចេកទេសត្រូវបំពេញក្នុងទម្រង់ព័ត៌មានបច្ចេកទេស ដែលមាននៅក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសៀវភៅណែនាំបច្ចេកទេសស្តីពីគម្រោងសេវាកម្មរបស់ គ.ជ.អ.ប។

## ២.៨. ការសិក្សាផលប៉ះពាល់បរិស្ថាន

គម្រោងរាជធានី ខេត្តដែលបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងវប្បធម៌ ការសិក្សាពិសេសមួយនឹងត្រូវធ្វើឡើង ហៅថា **ការសិក្សាផលប៉ះពាល់បរិស្ថាន**។ មន្ត្រីដែលទទួលបន្ទុករបស់រាជធានី ខេត្ត ដោយសហការជាមួយនឹងអ្នកពាក់ព័ន្ធនានា នឹងធ្វើការសិក្សាផលប៉ះពាល់បរិស្ថាននៅទីតាំងគម្រោង ឬនៅជិតទីតាំងគម្រោង ដោយមានការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ នីតិវិធីលម្អិតនៃការសិក្សាផលប៉ះពាល់បរិស្ថាន នឹងមានបរិយាយនៅក្នុង**ជំពូកទី៩**។

**កំណត់សម្គាល់ ៖** ទោះបីជាលទ្ធផលមួយចំនួនរបស់គម្រោងត្រូវបានគាំទ្រដោយថវិការាជធានី ខេត្ត ហើយលទ្ធផលមួយចំនួនទៀតត្រូវបានគាំទ្រដោយមូលនិធិផ្សេងក៏ដោយ គម្រោងនោះក៏អាចត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថានផងដែរ។ ឧទាហរណ៍ ម្ចាស់អំណោយព្រមព្រៀងជាមួយរដ្ឋបាលរាជធានី ខេត្តថា គាត់នឹងសាងសង់ផ្លូវមួយខ្សែ ហើយរដ្ឋបាលរាជធានី ខេត្ត នឹងសាងសង់លូ។ ប្រសិនបើផ្លូវនេះ គឺជាខ្សែផ្លូវថ្មី ត្រូវតែធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន ទោះបីជាផ្លូវនេះមិនត្រូវបានគាំទ្រថវិការាជធានី ខេត្តក៏ដោយ។

## ២.៩. ការសិក្សាដីធ្លី

គម្រោងរាជធានី ខេត្តមួយចំនួននឹងប្រើប្រាស់ដីមួយចំនួនដែលប្រើប្រាស់ដោយឯកជន (ទោះបីដីនោះជាដីសាធារណៈ ឬដីរបស់ឯកជនក៏ដោយ)។ ក្នុងករណីនេះ កម្មសិទ្ធិករ ភោគី ឬអ្នកប្រើប្រាស់ដីធ្លីនឹងបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ដីនោះ និងទ្រព្យសម្បត្តិនានាដែលមាននៅលើដីនោះ ដោយសារការអនុវត្តគម្រោង។ រាជធានី ខេត្តត្រូវធ្វើកិច្ចព្រមព្រៀងជាមួយនឹងកម្មសិទ្ធិករ ភោគី ឬអ្នកប្រើប្រាស់ដីធ្លីនោះជាមុនមុនពេលអនុវត្តគម្រោង។

ទាក់ទងទៅនឹងការប្រើប្រាស់ដីធ្លី គម្រោងរាជធានី ខេត្តមាន**៣ប្រភេទ**ដែលត្រូវធ្វើការពិចារណា គឺ៖

១. គម្រោងដែលនឹងត្រូវអនុវត្តលើដីសាធារណៈមិនដែលបានប្រើប្រាស់ដោយឯកជន។ ឧទាហរណ៍ ការសាងសង់អគារសិក្សាលើទីធ្លាក្នុងសាលារៀនដែលមានស្រាប់។

២. គម្រោងដែលនឹងប្រើប្រាស់ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ទោះបីដីនោះ ជាដីសាធារណៈ ឬដីឯកជនក៏ដោយ)។ ក្នុងករណីនេះ ពុំមានបុគ្គល ឬគ្រួសារណានឹងបាត់បង់ច្រើនជាង**៥%**នៃផ្ទៃដីសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិមានតម្លៃលើសពី**១.០០០.០០០រៀល**ឡើយ។ អ្នកប្រើប្រាស់ដីធ្លីដែលទទួលរងនូវផលប៉ះពាល់បានយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដោយស្ម័គ្រចិត្តដល់គម្រោង។ ឧទាហរណ៍ គម្រោងផ្លូវដែលនឹងត្រូវប៉ះពាល់ដីវាលស្រែបន្តិចបន្តួចដែលនៅអមសងខាងផ្លូវ។ ចំពោះគម្រោងប្រភេទនេះ តម្រូវឱ្យមាន**របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**។

៣. គម្រោងដែលនឹងប្រើប្រាស់ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ទោះបីដីនោះ ជាដីសាធារណៈ ឬដីឯកជនក៏ដោយ)។ អ្នកប្រើប្រាស់ដីធ្លីត្រូវបាត់បង់ដីធ្លីលើសពី**៥%**នៃផ្ទៃដីសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិនានាដែលមានតម្លៃលើសពី**១.០០០.០០០រៀល** ឬអ្នកប្រើប្រាស់ដីធ្លីមួយចំនួនបដិសេធក្នុងការប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដោយគ្មានសំណងទូទាត់។ ឧទាហរណ៍ ការសាងសង់សាលារៀនលើដីវាលស្រែ។ ចំពោះគម្រោងប្រភេទនេះ តម្រូវឱ្យមាន**របាយការណ៍លទ្ធកម្មដីធ្លី**។ ប្រសិនបើសំណងទូទាត់នឹងត្រូវផ្តល់ចំពោះដីធ្លី និងទ្រព្យសម្បត្តិដែលបានបាត់បង់ដោយសារការអនុវត្តគម្រោង ទម្រង់គណនាតម្លៃសំណង និងការទូទាត់សំណងត្រូវតែបំពេញឱ្យបានចប់សព្វគ្រប់។

នីតិវិធីលម្អិតក្នុងការរៀបចំសិក្សាដីធ្លី នឹងមានបរិយាយនៅក្នុង**ជំពូកទី១០**។

***កំណត់សម្គាល់*** ÷ ទោះបីជាលទ្ធផលមួយចំនួនរបស់គម្រោងត្រូវបានគាំទ្រដោយថវិការាជធានី ខេត្ត ហើយលទ្ធផលមួយចំនួនទៀតត្រូវបានគាំទ្រដោយមូលនិធិផ្សេងក៏ដោយ គម្រោងនោះក៏ត្រូវធ្វើការសិក្សាដីធ្លីផងដែរ។ ឧទាហរណ៍ ម្ចាស់អំណោយព្រមព្រៀងជាមួយរដ្ឋបាលរាជធានី ខេត្តថា គាត់នឹងសាងសង់ផ្លូវមួយខ្សែ ហើយរដ្ឋបាលរាជធានី ខេត្តនឹងសាងសង់លូ។ ប្រសិនបើផ្លូវនេះនឹងត្រូវបានសាងសង់នៅលើដីដែលប្រើប្រាស់ដោយឯកជនមួយចំនួន នោះត្រូវតែធ្វើការសិក្សាដីធ្លី ទោះបីជាផ្លូវនេះមិនត្រូវបានគាំទ្រថវិការាជធានី ខេត្តក៏ដោយ។

## ២.១០. ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

គម្រោងរាជធានី ខេត្តដែលមានទីតាំងស្ថិតនៅភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី**៥%**នៃប្រជាពលរដ្ឋសរុបក្នុងភូមិ) ចាំបាច់ត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។ នីតិវិធីនៃការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមានបរិយាយលម្អិតនៅក្នុង**ជំពូកទី១១**។

## ២.១១. ការរៀបចំគ្រោងការគម្រោង

បន្ទាប់ពីបានប្រមូលព័ត៌មានសព្វគ្រប់ហើយ អ្នកជំនួយបច្ចេកទេសជួយរៀបចំគ្រោងការគម្រោង។

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ គ្រោងការគម្រោងរួមមានគំនូសប្លង់បច្ចេកទេសគម្រោង ការបរិយាយលម្អិតលក្ខណៈបច្ចេកទេស និងប្លង់ការដ្ឋាន។ ជាទូទៅ គំនូសប្លង់បច្ចេកទេសគម្រោងត្រូវផ្អែកតាមសៀវភៅណែនាំ

ស្ដីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប។

ចំពោះគម្រោងសេវាកម្ម គ្រោងការគម្រោងរួមមានការគ្រោងសកម្មភាពអនុវត្តគម្រោងនានា ការបរិយាយលម្អិតលក្ខណៈបច្ចេកទេស និងគំនូសប្លង់បច្ចេកទេសគម្រោង(បើត្រូវការ)។ ការបរិយាយលម្អិតលក្ខណៈបច្ចេកទេស និងគំនូសប្លង់បច្ចេកទេសគម្រោង អាចមាននៅក្នុងសៀវភៅណែនាំបច្ចេកទេសស្ដីពីគម្រោងសេវាកម្មរបស់ គ.ជ.អ.ប។

គ្រោងការគម្រោងមួយដែលល្អ នឹងផ្ដល់លទ្ធផលចំពោះគម្រោងមួយដែល ៖

- សម្រេចបាននូវគោលបំណង
- មិនថ្លៃពេកក្នុងការអនុវត្ត
- មិនលំបាក ឬមិនថ្លៃពេកក្នុងការប្រតិបត្តិការ និងការថែទាំ
- មិនត្រូវការទំហំដីច្រើនជាងទំហំដីដែលជាតម្រូវការចាំបាច់
- មិនបណ្ដាលឱ្យខូចខាតដល់បរិស្ថាន

អ្នកជំនួយបច្ចេកទេសជួយរៀបចំគ្រោងការគម្រោង ហើយដាក់ជូនគណៈកម្មការរៀបចំគម្រោងពិនិត្យ និងសម្រេច។

### ២.១២. ស្លាកសញ្ញាគម្រោង

ស្លាកសញ្ញាគម្រោងត្រូវបានដាក់នៅទីតាំងគម្រោងដើម្បីប្រាប់ប្រជាពលរដ្ឋឱ្យបានដឹងថា អ្នកណាជាម្ចាស់គម្រោង និងអ្នកណាជាអ្នកផ្ដល់មូលនិធិ។ ស្លាកសញ្ញាគម្រោងត្រូវរៀបចំឡើងក្នុងរយៈពេល**១៥ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្ដើមអនុវត្តកិច្ចសន្យា។

គ្រប់គម្រោងរាជធានី ខេត្តទាំងអស់ដែលបង្កើតបានជាលទ្ធផលស្ថិតនៅជាប់ជាប្រចាំមួយកន្លែង (ដូចជាហេដ្ឋារចនាសម្ព័ន្ធ ស្រះចិញ្ចឹមត្រី សហគមន៍ព្រៃឈើ ទេសចរណ៍ធម្មជាតិ...។ល។) ត្រូវតែមានស្លាកសញ្ញាគម្រោង។

គម្រោងទាំងឡាយណាដែលមានត្រឹមតែសកម្មភាពថែទាំជាប្រចាំ ឬគម្រោងសេវាកម្ម នោះមិនចាំបាច់ត្រូវការស្លាកសញ្ញាគម្រោងទេ។

ចំពោះគម្រោងរាជធានី ខេត្ត ស្លាកសញ្ញាគម្រោងមានមុខងារសំខាន់ណាស់ ដើម្បីផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានី ខេត្តអំពីអ្វីដែលរដ្ឋបាលរាជធានី ខេត្តបានធ្វើ។

ព័ត៌មាននៃស្លាកសញ្ញាគម្រោង រួមមាន ៖

- ឈ្មោះរាជធានី ខេត្ត
- ឈ្មោះគម្រោង ទំហំគម្រោង និងឆ្នាំអនុវត្តគម្រោង
- ចំនួនថវិការាជធានី ខេត្ត
- ចំនួនថវិកាចូលរួមចំណែករបស់ប្រជាពលរដ្ឋ
- ចំនួនថវិកាពីប្រភពផ្សេងៗទៀត បើមាន
- ចំនួនថវិកាសរុប។

| |
|---|
| **រាជធានី ខេត្ត.......................** |
| ....................(ឈ្មោះគម្រោង)......................... |
| **ឆ្នាំ.............** |
| ថវិការាជធានី ខេត្ត ៖....................................រៀល |
| ទុនចូលរួមរបស់មូលដ្ឋាន ៖....................................រៀល |
| ថវិកាពី.................. ៖....................................រៀល |
| សរុប ៖....................................រៀល |

| |
|---|
| **គម្រោងអន្តររដ្ឋបាលឆ្នាំ.........** |
| **ខាងរដ្ឋបាល**.................(ឈ្មោះរដ្ឋបាលពាក់ព័ន្ធ)................. |
| ....................(ឈ្មោះគម្រោង)......................... |
| ថវិកាពីរដ្ឋបាល....................... ៖....................................រៀល |
| ថវិកាពីរដ្ឋបាល....................... ៖....................................រៀល |
| ថវិកាពីរដ្ឋបាល....................... ៖....................................រៀល |
| ទុនចូលរួមរបស់មូលដ្ឋាន ៖....................................រៀល |
| ថវិកាពី.................................... ៖....................................រៀល |
| សរុប ៖....................................រៀល |

ស្លាកសញ្ញាគម្រោងត្រូវ ៖

- ដាក់នៅកន្លែងប្រជាពលរដ្ឋអាចមើលឃើញ និងអានបាន
- មានគុណភាពល្អ ដែលធានាបាននូវការប្រើប្រាស់យូរអង្វែង
- ដាក់តាំងនៅទីតាំងលទ្ធផលគម្រោង។

ចំពោះគម្រោងមួយចំនួន ស្លាកសញ្ញាគម្រោងអាចដាក់ភ្ជាប់ផ្ទាល់ទៅនឹងលទ្ធផលគម្រោង (ឧទាហរណ៍ គម្រោងសាងសង់អគារសិក្សា ស្លាកសញ្ញាគម្រោងអាចដាក់ជាប់នឹងជញ្ជាំងអគារសិក្សានោះ។

ស្លាកសញ្ញាគម្រោងមិនចាំបាច់ធ្វើ និងដាក់ច្រើនពេកទេ។ ឧទាហរណ៍ ៖ គម្រោងផ្លូវលំ ស្លាកសញ្ញាគម្រោងអាចដាក់តែមួយនៅដើមផ្លូវជាការគ្រប់គ្រាន់ មិនចាំបាច់ដាក់ស្លាកសញ្ញានៅគ្រប់កន្លែងដាក់លូនោះទេ។ ស្លាកសញ្ញាគម្រោងនឹងត្រូវបានផ្តល់ដោយអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មដែលអនុវត្តគម្រោងនោះ។ ដូច្នេះអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មត្រូវដឹងអំពីការទទួលខុសត្រូវរបស់ខ្លួនក្នុងការធ្វើស្លាកសញ្ញាគម្រោងមុនពេលដេញថ្លៃគម្រោង។

ស្លាកសញ្ញាគម្រោងត្រូវរៀបចំឡើងនៅក្នុងតម្លៃមួយយ៉ាងសមរម្យបំផុត។

**ជម្រើស** ៖ រាជធានី ខេត្តអាចសម្រេចអនុញ្ញាតឱ្យអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មដាក់ឈ្មោះរបស់ខ្លួននៅលើស្លាកសញ្ញាគម្រោង។ ការធ្វើបែបនេះនឹងផ្តល់ការលើកទឹកចិត្តដល់អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងការធ្វើការងារប្រកបដោយគុណភាពល្អ ពីព្រោះគាត់មិនចង់ឱ្យឈ្មោះខ្លួនមាននៅលើសមិទ្ធផលដែលខូច ឬមានគុណភាពមិនល្អនោះទេ។

### ២.១៣. ការប៉ាន់ស្មានតម្លៃគម្រោង និងព័ត៌មានលម្អិតនៃលទ្ធផលគម្រោង

បន្ទាប់ពីរៀបចំគ្រោងការគម្រោងចប់សព្វគ្រប់ អ្នកជំនួយបច្ចេកទេសនឹងធ្វើការប៉ាន់ស្មានតម្លៃគម្រោង ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ។ ដើម្បីធ្វើការប៉ាន់ស្មានតម្លៃគម្រោង ជាដំបូងត្រូវធ្វើការប៉ាន់ស្មានតម្លៃនៃលទ្ធផលនីមួយៗរបស់គម្រោង ហើយបន្ទាប់មកត្រូវបូកសរុបតម្លៃប៉ាន់ស្មាន របស់លទ្ធផលនីមួយៗនៃលទ្ធផលទាំងអស់របស់គម្រោងនោះ។ តម្លៃប៉ាន់ស្មានសរុបនៃលទ្ធផលទាំងអស់ គឺជាតម្លៃប៉ាន់ស្មាននៃគម្រោង។

បន្ទាប់ពីគណនាតម្លៃប៉ាន់ស្មាននៃលទ្ធផលនីមួយៗរបស់គម្រោង អ្នកជំនួយបច្ចេកទេសត្រូវបំពេញទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោង។

### ២.១៤. ផែនការប្រតិបត្តិការ និងការថែទាំ

ចំពោះគម្រោងនីមួយៗត្រូវមានផែនការប្រតិបត្តិការ និងការថែទាំ។ ផែនការនេះត្រូវបង្ហាញអំពី ៖

**ក). ការងារប្រតិបត្តិការ**

- តើមានការងារប្រតិបត្តិការចាំបាច់អ្វីខ្លះ?
- តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តការងារប្រតិបត្តិការទាំងនេះ?
- តើការចំណាយទៅលើការងារប្រតិបត្តិការទាំងនេះបានមកពីណា?

**ខ). ការងារថែទាំជាប្រចាំ**

- តើមានការងារថែទាំជាប្រចាំជាចាំបាច់អ្វីខ្លះ?
- តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តការងារថែទាំជាប្រចាំទាំងនេះ?
- តើការចំណាយទៅលើការងារថែទាំជាប្រចាំទាំងនេះបានមកពីណា?

**គ). ការងារថែទាំជាខួប**

- តើមានការងារថែទាំជាខួបជាចាំបាច់អ្វីខ្លះ?
- តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តការងារថែទាំជាខួបទាំងនេះ?
- តើការចំណាយទៅលើការងារថែទាំជាខួបទាំងនេះបានមកពីណា?
- តើការចំណាយជាមធ្យមក្នុងមួយឆ្នាំសម្រាប់កិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោងប៉ុន្មាន? (មិនបូកបញ្ចូលចំណាយដែលបានមកពីថវិការបស់រាជរដ្ឋាភិបាល ឧទាហរណ៍ ប្រាក់បៀវត្សរបស់គ្រូបង្រៀន)។
- តើត្រូវចំណាយប៉ុន្មានពីគម្រោងថវិការាជធានី ខេត្តក្នុងមួយឆ្នាំ?

### ២.១៥. ការពិនិត្យ និងការអនុម័តសំណើគម្រោង

នៅពេលរៀបចំសំណើគម្រោង(ព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធនានា)ចប់សព្វគ្រប់ ប្រធានគណៈកម្មការរៀបចំគម្រោងត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តសំណើគម្រោង និងដើម្បីធានាឱ្យមានការយល់ដឹងយ៉ាងពេញលេញអំពីគម្រោង និងផលប៉ះពាល់ដែលរំពឹងទុក។ ប្រសិនបើអាចធ្វើបាន ការប្រជុំនេះត្រូវបានរៀបចំឡើងជាសាធារណៈនៅទីតាំងគម្រោង។

គ្រោងការគម្រោងអាចខុសពីគំនិតដំបូងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។ ក្នុងករណីនេះ មុននឹងគណៈកម្មការរៀបចំគម្រោងអនុម័តសំណើគម្រោង ចំណុចសំខាន់ៗមួយចំនួនខាងក្រោមនេះត្រូវបានលើកយកមកពិភាក្សា និងព្រមព្រៀង ៖

- ប្រសិនបើគ្រោងការគម្រោងបានផ្លាស់ប្តូរ តើគម្រោងនឹងនៅតែសម្រេចបាននូវទិសដៅដើមដែរឬទេ?
- តើអ្នកទទួលផលនឹងនៅតែពេញចិត្តចំពោះលទ្ធផលគម្រោងដែរឬទេ?
- តើមានការព្រមព្រៀងទៅលើតម្លៃប៉ាន់ស្មានដែរឬទេ?
- តើមានបញ្ហាប៉ះពាល់ដីធ្លីដែរឬទេ?។ តើគម្រោងត្រូវបានអនុវត្តនៅលើដី ដែលបច្ចុប្បន្ននេះកំពុងតែប្រើប្រាស់ដោយឯកជន និងប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជនឬទេ?
- តើនឹងមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរណាមួយដែរឬទេ?
- តើនឹងមានផលប៉ះពាល់ចំពោះជនជាតិដើមភាគតិចដែរឬទេ?
- តើផែនការប្រតិបត្តិការ និងការថែទាំមានភាពជាក់ស្តែងដែរឬទេ?
- តើអ្នកប្រើប្រាស់គម្រោងនឹងសប្បាយចិត្តក្នុងការបង់ថ្លៃប្រើប្រាស់ និងថែទាំដែរឬទេ?

## ២.១៦. ការពិនិត្យបញ្ជាក់បច្ចេកទេស

មន្ទីរ អង្គភាពជំនាញរាជធានី ខេត្តជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យបញ្ជាក់បច្ចេកទេសដល់គម្រោងរាជធានី ខេត្ត។

មន្ទីរ អង្គភាពជំនាញនឹងបដិសេធចំពោះគម្រោង ប្រសិនបើ ៖

- មានបញ្ហាបច្ចេកទេសលើគ្រោងការគម្រោង ដែលនឹងបណ្តាលឱ្យគម្រោងទទួលបរាជ័យក្នុងការសម្រេចនូវទិសដៅគម្រោង ឬ
- មានបញ្ហាទំនាស់រវាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តជាមួយនឹងផែនការរបស់មន្ទីរ អង្គភាពជំនាញ។

មន្ទីរ អង្គភាពជំនាញមានសិទ្ធិជំទាស់ចំពោះគម្រោងក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធពីរដ្ឋបាលរាជធានី ខេត្ត។ ប្រសិនបើមន្ទីរ អង្គភាពជំនាញចង់ធ្វើការជំទាស់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលរាជធានី ខេត្ត។

ប្រសិនបើក្នុងរយៈពេល១៥ថ្ងៃ មន្ទីរ អង្គភាពជំនាញមិនធ្វើការជំទាស់ទេ នោះមានន័យថា គម្រោងបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេសដោយស្វ័យប្រវត្តិ។

ចំពោះគម្រោងដែលតម្រូវឱ្យមានការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងឬជនជាតិដើមភាគតិច គម្រោងនោះត្រូវបានជំទាស់ដោយស្វ័យប្រវត្តិ រហូតដល់ការសិក្សាទាំងនេះត្រូវអនុវត្តចប់សព្វគ្រប់ ហើយរបាយការណ៍នៃការសិក្សាទាំងនេះត្រូវបានអនុម័ត។ ការជំទាស់ដោយស្វ័យប្រវត្តិនេះនឹងត្រូវបានដកចេញ នៅពេលណាដែល ៖

- របាយការណ៍វិភាគផលប៉ះពាល់បរិស្ថានត្រូវបានអនុម័ត ចំពោះគម្រោងទាំងឡាយណាដែលត្រូវការរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។
- របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តត្រូវបានអនុម័ត ចំពោះគម្រោងទាំងឡាយណាដែលត្រូវការរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត។
- របាយការណ៍លទ្ធកម្មដីធ្លីត្រូវបានអនុម័ត និងការរៀបចំការទូទាត់សំណងត្រូវបានអនុវត្ត ចំពោះគម្រោងទាំងឡាយណាដែលត្រូវការរបាយការណ៍លទ្ធកម្មដីធ្លី។
- របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចត្រូវបានអនុម័ត ចំពោះគម្រោងទាំងឡាយណាដែលត្រូវការរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។

## ២.១៧. ការពិនិត្យ និងការផ្តល់អនុលោមភាព

គ្រប់គម្រោងរាជធានី ខេត្តទាំងអស់ រួមទាំងគម្រោងដែលប្រើប្រាស់ឥណទានចុងឆ្នាំ បន្ទាប់ពីគម្រោងទាំងនោះទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេស រដ្ឋបាលរាជធានី ខេត្តត្រូវផ្ញើសំណើគម្រោង(ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនានា)មួយច្បាប់ ជូន**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ** ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយមាននាយកដ្ឋានជំនាញជាសេនាធិការ ត្រូវពិនិត្យ និងផ្តល់អនុលោមភាពលើសំណើគម្រោងរាជធានី ខេត្ត ក្នុងអំឡុងពេល**១០ថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានសំណើគម្រោងពីរដ្ឋបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យអនុលោមភាពនេះ ត្រូវពិនិត្យផ្ទៀងផ្ទាត់តាមល័ក្ខខ័ណ្ឌ និងគោលការណ៍ដូចខាងក្រោម ៖

- ឯកសារ និងព័ត៌មានចាំបាច់នានានៃសំណើគម្រោងត្រូវមានគ្រប់គ្រាន់
- គម្រោងត្រូវឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជធានី ខេត្ត
- គម្រោងមានលក្ខណៈសមស្របក្នុងការប្រើប្រាស់ថវិការាជធានី ខេត្ត
- គម្រោងមិនផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តណាមួយជាធរមាន
- តម្លៃប៉ាន់ស្មានគម្រោងមានភាពសមស្រប
- ប្រសិនបើគម្រោងតម្រូវឱ្យមានការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងឬជនជាតិដើមភាគតិច ការសិក្សាផលប៉ះពាល់ទាំងនេះ ត្រូវបានអនុវត្តទៅតាមនីតិវិធីដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត។

ប្រសិនបើសំណើគម្រោងបំពេញបានតាមល័ក្ខខ័ណ្ឌ និងគោលការណ៍នៃការពិនិត្យអនុលោមភាព អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវផ្តល់អនុលោមភាពលើសំណើគម្រោង ដោយជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់រដ្ឋបាលរាជធានី ខេត្ត។

ក្នុងករណីសំណើគម្រោងមិនបំពេញបានតាមល័ក្ខខ័ណ្ឌ និងគោលការណ៍នៃការពិនិត្យអនុលោមភាព អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់រដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំកែសម្រួលឡើងវិញតាមនីតិវិធីជាធរមាន។

រដ្ឋបាលរាជធានី ខេត្តត្រូវពិនិត្យ និងកែតម្រូវសំណើគម្រោងឡើងវិញ ស្របតាមការជូនដំណឹងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។

# ជំពូកទី៣

# តួនាទី និងការទទួលខុសត្រូវរបស់អ្នក
# ពាក់ព័ន្ធក្នុងការរៀបចំគម្រោង

# ជំពូកទី៣
# តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំគម្រោង

## ៣.១. ក្រុមប្រឹក្សារាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ខេត្តទទួលខុសត្រូវក្នុងការ ៖

- ពិនិត្យ និងអនុម័តសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការរៀបចំគម្រោង
- តាមដានដំណើរការនៃការរៀបចំគម្រោង
- បង្កើតយន្តការដើម្បីធានាការចូលរួមរបស់សហគមន៍ឱ្យបានច្រើន ក្នុងការរៀបចំ និងអនុវត្តគម្រោង
- កំណត់អំពីចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោងរាជធានី ខេត្ត។

## ៣.២. គណៈអភិបាលរាជធានី ខេត្ត

គណៈអភិបាលរាជធានី ខេត្តទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការអនុវត្តគម្រោង ឬសកម្មភាពនានា ដែលមាននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត និងគម្រោងថវិការាជធានី ខេត្ត។ នៅក្នុងដំណាក់កាល នៃការរៀបចំគម្រោង គណៈអភិបាលរាជធានី ខេត្តទទួលខុសត្រូវក្នុងការ ៖

- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការរៀបចំគម្រោង ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- គ្រប់គ្រងការសិក្សាគម្រោង និងសម្របសម្រួលការងារជាមួយអ្នកពាក់ព័ន្ធទាំងអស់
- កំណត់ និងតែងតាំងអ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការសិក្សា និងការរៀបចំគម្រោង
- ពិនិត្យ និងអនុម័តបញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង
- ចុះហត្ថលេខាលើព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ។

## ៣.៣. គណៈកម្មការរៀបចំគម្រោង

**គណៈកម្មការរៀបចំគម្រោងមានតួនាទី ដូចខាងក្រោម ៖**

- គ្រប់គ្រងចាត់ចែងការសិក្សា និងការរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង។

**គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានតួនាទី ដូចខាងក្រោម ៖**

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោងអន្តររដ្ឋបាល
- គ្រប់គ្រងចាត់ចែងការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការសិក្សា និងការរៀបចំគម្រោងអន្តររដ្ឋបាល
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោងអន្តររដ្ឋបាល។

## ៣.៤. អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ

ចំពោះគម្រោងទាំងឡាយណាដែលចាំបាច់ត្រូវមានកិច្ចប្រតិបត្តិការនិងការថែទាំ គម្រោងនោះនឹងពុំមាន និរន្តរភាពទេ ប្រសិនបើពុំរៀបចំឱ្យមានការទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំឱ្យបានច្បាស់លាស់។

**ក). រដ្ឋបាលរាជធានី ខេត្ត**

ចំពោះប្រភេទគម្រោងមួយចំនួន រដ្ឋបាលរាជធានី ខេត្តនឹងទទួលខុសត្រូវផ្ទាល់ក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង ហើយការចំណាយសម្រាប់កិច្ចប្រតិបត្តិការនិងការថែទាំនេះ ត្រូវគ្រោងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត។ ជាទូទៅគម្រោងទាំងនោះ គឺជា ៖

- គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល
- គម្រោងសេវាកម្មដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល
- គម្រោងដែលមិនមានភ្នាក់ងារណាមួយរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវ។

**ខ). មន្ទីរ អង្គភាពជំនាញ**

ចំពោះប្រភេទគម្រោងមួយចំនួនទៀត មន្ទីរ អង្គភាពជំនាញជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ។ ឧទាហរណ៍ ៖ មន្ទីរសុខាភិបាលទទួលខុសត្រូវក្នុងការប្រតិបត្តិការនិងការថែទាំមណ្ឌលសុខភាព មន្ទីរអប់រំ យុវជន និងកីឡាទទួលខុសត្រូវក្នុងដំណើរការប្រតិបត្តិការ និងការថែទាំសាលារៀន។ ក្នុងករណីដែលរដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវត្រឹមតែការសាងសង់សំណង់(ដូចជាមណ្ឌលសុខភាព ឬសាលារៀន) រដ្ឋបាលរាជធានី ខេត្តត្រូវព្រមព្រៀងជាមួយមន្ទីរ អង្គភាពជំនាញឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវលើការចំណាយសម្រាប់ដំណើរការប្រតិបត្តិការ និងការថែទាំ។

**គ). ក្រុមប្រើប្រាស់**

ចំពោះប្រភេទគម្រោងមួយចំនួនទៀត ដែលមានក្រុមប្រើប្រាស់ជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ ឧទាហរណ៍ សហគមន៍កសិករប្រើប្រាស់ទឹក(គម្រោងប្រព័ន្ធធារាសាស្ត្រ) ក្រុមប្រើប្រាស់ទឹកស្អាត និងអនាម័យ(គម្រោងអណ្តូងទឹក) រាជធានី ខេត្ត ឬគណៈកម្មការរៀបចំគម្រោងត្រូវរៀបចំបង្កើតក្រុមប្រើប្រាស់នៅដំណាក់កាលចាប់ផ្តើមរៀបចំគម្រោង។

នៅក្នុងការរៀបចំគម្រោង ក្រុមប្រើប្រាស់អាចជួយបំពេញភារកិច្ច ដូចជា ៖

- ការប្រមូលព័ត៌មានដែលត្រូវការសម្រាប់រៀបចំគម្រោង
- ការជ្រើសរើសទីតាំងនៃលទ្ធផលគម្រោង
- ការប្រមូលទុនចូលរួម។

## ៣.៥. សហគមន៍ និងអ្នកទទួលផលពីគម្រោង

**សហគមន៍** មានន័យថាជាប្រជាពលរដ្ឋមួយក្រុមដែលរស់នៅជាមួយគ្នា នៅកន្លែងមួយ មានការពាក់ព័ន្ធគ្នាទៅវិញទៅមក និងមានផលប្រយោជន៍រួមគ្នា។

**អ្នកទទួលផលផ្ទាល់ពីគម្រោង** គឺជាប្រជាពលរដ្ឋ ឬក្រុមគ្រួសារដែលប្រើប្រាស់លទ្ធផលគម្រោងផ្ទាល់។

**ឧទាហរណ៍ ៖**

- អ្នកទទួលផលផ្ទាល់ពីប្រព័ន្ធធារាសាស្ត្រ គឺជាសមាជិកទាំងអស់នៅក្នុងគ្រួសារដែលប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនោះ។
- អ្នកទទួលផលផ្ទាល់ពីអគារសិក្សា គឺជាចំនួនសិស្សដែលរៀននៅអគារសិក្សានោះ មិនរួមបញ្ចូលទាំងសមាជិកនៃគ្រួសាររបស់សិស្សទាំងនោះទេ។
- អ្នកទទួលផលផ្ទាល់ពីការបណ្តុះបណ្តាល គឺអ្នកទាំងឡាយណាដែលបានចូលរៀនវគ្គបណ្តុះបណ្តាលនោះ (ចំនួនសិក្ខាកាម)។

អ្នកទទួលផល និងសហគមន៍ត្រូវចូលរួមឱ្យបានច្រើនក្នុងការរៀបចំគម្រោង និងការតាមដានការអនុវត្តគម្រោង។ លើសពីនេះទៀត អ្នកទទួលផល និងសហគមន៍ចាំបាច់ត្រូវមានតួនាទីក្នុងការចូលរួមថែទាំលទ្ធផលគម្រោង ដើម្បីធានាថា គម្រោងអាចផ្តល់នូវផលប្រយោជន៍យូរអង្វែងដល់សហគមន៍។

### ៣.៦. អ្នកជំនួយបច្ចេកទេស

អ្នកជំនួយបច្ចេកទេសមានភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង
- រៀបចំផែនការសិក្សាគម្រោង
- រៀបចំផែនទីគម្រោង
- អនុវត្តការសិក្សាលទ្ធភាពគម្រោង
- ជួយរាជធានី ខេត្តក្នុងការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- រៀបចំគ្រោងការគម្រោង
- ប៉ាន់ស្មានតម្លៃគម្រោង
- បំពេញព័ត៌មានផ្នែកបច្ចេកទេសនៅក្នុងទម្រង់ព័ត៌មានគម្រោង។

### ៣.៧. ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តមានតួនាទី ដូចខាងក្រោម ៖

- សហការសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងរាជធានី ខេត្ត ព្រមទាំងសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- រៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង
- កត់ត្រា និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវព័ត៌មានគម្រោងរាជធានី ខេត្តទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងរាជធានី ខេត្ត។

### ៣.៨. មន្ទីរ អង្គភាពជំនាញនានា

មន្ទីរ អង្គភាពជំនាញ មានតួនាទី ដូចខាងក្រោម ៖

- ផ្តល់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការរៀបចំគម្រោង តាមការស្នើសុំរបស់រដ្ឋបាលរាជធានី ខេត្ត
- ផ្តល់យោបល់ផ្នែកបច្ចេកទេសក្នុងការរៀបចំគ្រោងការគម្រោង ក្នុងករណីមានការស្នើសុំពីរដ្ឋបាលរាជធានី ខេត្ត
- ពិនិត្យបញ្ជាក់បច្ចេកទេសគម្រោងរាជធានី ខេត្ត ដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន។ គម្រោងមួយអាចតម្រូវឱ្យមានការពិនិត្យបញ្ជាក់បច្ចេកទេសពីមន្ទីរអង្គភាពជំនាញពាក់ព័ន្ធមួយ ឬច្រើន។

### ៣.៩. ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប

ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប គឺជាយន្តការមួយ ដែលបង្កើតឡើង ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ទៅលើ ៖

- ដំណើរការនៃការសិក្សាផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច

- របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។

ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន (ឃុំ សង្កាត់ដែលស្ថិតនៅក្នុងតំបន់ដែលមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន) និងបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៥%នៃប្រជាពលរដ្ឋសរុបក្នុងភូមិ) ហើយដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យនិងសម្រេច។ គ.ជ.អ.ប នឹងផ្តល់បញ្ជីទាំងពីរនេះដល់រាជធានី ខេត្តដែលពាក់ព័ន្ធ និងផ្សព្វផ្សាយបញ្ជីទាំងពីរនេះនៅក្នុងគេហទំព័ររបស់ គ.ជ.អ.ប។

ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិច នៅរៀងរាល់បីឆ្នាំម្តង។

បញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពដោយផ្អែកតាមចំណុចដូចខាងក្រោម ៖

- ទំហំសណ្ឋានដីទាំងអស់ ឬពាក់កណ្តាលរបស់ឃុំ សង្កាត់ដែលគ្របដណ្តប់ដោយព្រៃធម្មជាតិ
- ទំហំសណ្ឋានដីរបស់ឃុំ សង្កាត់គ្របដណ្តប់ដោយតំបន់ដីសើម ឬព្រៃដែលមានទំហំចាប់ពី១០%ឡើងទៅនៃទំហំផ្ទៃដីសរុបរបស់ឃុំ សង្កាត់
- ការកំណត់ដោយថ្នាក់រាជធានី ខេត្ត ឬថ្នាក់ជាតិនូវតំបន់ការពារ តំបន់ព្រៃការពារ តំបន់រក្សាពូជត្រីទឹកសាប និងទឹកប្រៃ ឬតំបន់អភិរក្សបុរាណសាស្ត្រ
- តំបន់ជីវៈចម្រុះផ្សេងៗ ដែលត្រូវបានកំណត់ថា ជាតំបន់ដែលគាំទ្រប្រភេទពូជសត្វព្រៃដែលជិតផុតពូជ
- តំបន់ដែលការអនុវត្តគម្រោងកន្លងមក បណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ
- ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៥%នៃចំនួនប្រជាជនសរុបក្នុងភូមិ។

ចំពោះគម្រោងរាជធានី ខេត្តដែលមានទីតាំងស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹង ៖

- ពិនិត្យឡើងវិញទៅលើការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាននៃគម្រោងទាំងនេះ ដើម្បីបញ្ជាក់អំពីសក្តានុពលនៃផលប៉ះពាល់បរិស្ថាននៃគម្រោងទាំងអស់នេះ
- ចុះពិនិត្យដល់ទីតាំងគម្រោង ផ្តល់ការណែនាំអំពីការវិភាគផលប៉ះពាល់បរិស្ថាន និងពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសារឧបសម្ព័ន្ធនានានៃគម្រោងដែលពិនិត្យទៅឃើញថាមានសក្តានុពលនៃផលប៉ះពាល់បរិស្ថាន (ជាពិសេស គម្រោងផ្លូវថ្មី ប្រព័ន្ធធារាសាស្ត្រថ្មី ប្រឡាយថ្មី ទំនប់ថ្មី អាងស្តុកទឹកថ្មី ឬព្រែកជីកថ្មី)ជាមុន មុននឹងគម្រោងទទួលបានការពិនិត្យបញ្ជាក់បច្ចេកទេស។

ចំពោះគម្រោងរាជធានី ខេត្តដែលមានទីតាំងស្ថិតនៅក្នុងភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹង ៖

- ពិនិត្យឡើងវិញទៅលើការពិនិត្យអំពីតម្រូវការនៃការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចនៃគម្រោងទាំងនេះ ដើម្បីកំណត់អំពីសក្តានុពលផលប៉ះពាល់នៃគម្រោងទាំងនេះទៅលើជនជាតិដើមភាគតិច។

- ពិនិត្យថាតើមានការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចបានត្រឹមត្រូវដែរឬទេ?។

ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការសិក្សា និងវាយតម្លៃប្រចាំឆ្នាំទៅលើផលប៉ះពាល់ដីធ្លី ដែលបណ្តាលមកពីការអនុវត្តគម្រោងរាជធានី ខេត្ត។

## ៣.១០. អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមាននាយកដ្ឋានជំនាញជាសេនាធិការ មានតួនាទី ដូចខាងក្រោម ៖

- រៀបចំសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគម្រោងរាជធានី ខេត្ត ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ជួយរៀបចំ និងធ្វើបច្ចុប្បន្នភាព**លេខកូដ** និង**ឈ្មោះសម្ភារៈ**នៃបញ្ជីស្រង់តម្លៃសម្ភារៈ(ទម្រង់ទី៥) និងបញ្ជីតម្លៃសម្ភារៈស្តង់ដារ(ទម្រង់ទី៦) ហើយផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត នៅក្នុងខែ**កញ្ញា** នៃឆ្នាំនីមួយៗ
- អភិវឌ្ឍសមត្ថភាពរដ្ឋបាលរាជធានី ខេត្តអំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តគម្រោងរាជធានី ខេត្ត
- តាមដាន ត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់រដ្ឋបាលរាជធានី ខេត្តក្នុងការរៀបចំ និងការអនុវត្តគម្រោងរាជធានី ខេត្ត
- ពិនិត្យ និងផ្តល់អនុលោមភាពទៅលើសំណើគម្រោងរបស់រដ្ឋបាលរាជធានី ខេត្ត។

# ជំពូកទី៤

# ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន

# ជំពូកទី៤
# ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន

## ៤.១. ទស្សនទានអំពីទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន

ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន គឺជាការចូលរួមចំណែកជាសាច់ប្រាក់ដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានី ខេត្ត។ សាច់ប្រាក់ដែលប្រមូលបានពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន ត្រូវតម្កល់ទុកក្នុងគណនីប្រាក់បញ្ញើរាជធានី ខេត្ត នៅរតនាគាររាជធានី ខេត្ត ហើយត្រូវបានប្រើប្រាស់ក្នុងការចំណាយមួយផ្នែកនៃតម្លៃគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ គ្រប់គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងអស់របស់រាជធានី ខេត្ត គួរមានទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

គោលបំណងនៃការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន គឺដើម្បី ៖

- ពង្រឹងភាពជាម្ចាស់គម្រោងរបស់ប្រជាពលរដ្ឋ
- បង្កើនចំនួនថវិកាសម្រាប់អនុវត្តគម្រោង។

មុននឹងសម្រេចអំពីការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន រដ្ឋបាលរាជធានី ខេត្តត្រូវកំណត់ឱ្យច្បាស់ថា ៖

- តើអ្នកណាខ្លះជាអ្នកទទួលផលប្រយោជន៍ពីគម្រោង? តើប្រជាពលរដ្ឋណាខ្លះដែលបានទទួលផល និងប្រជាពលរដ្ឋណាខ្លះដែលមិនបានទទួលផលពីគម្រោង? តើគម្រោងនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅទាំងអស់ឬ?
- តើអ្នកណាទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង?

## ៤.២. គោលការណ៍ណែនាំសម្រាប់ប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន

គោលការណ៍ណែនាំសម្រាប់អនុវត្តការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន មានដូចខាងក្រោម ៖

១. គ្រប់ការចំណាយលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់រាជធានី ខេត្ត មួយផ្នែកនៃការចំណាយនេះគួរត្រូវបានរ៉ាប់រងដោយទុនចូលរួមរបស់មូលដ្ឋាន។

២. ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន គឺជាការចូលរួមចំណែកដោយស្ម័គ្រចិត្ត មិនមែនជាកាតព្វកិច្ចផ្លូវច្បាប់ទៅលើរូបវន្តបុគ្គលណាមួយនោះទេ។

៣. ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន គឺជាការប្រមូលសាច់ប្រាក់ពីប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានី ខេត្ត ហើយសាច់ប្រាក់ដែលប្រមូលបាននេះត្រូវបានតម្កល់ទុកក្នុងគណនីប្រាក់បញ្ញើរាជធានី ខេត្ត នៅរតនាគាររាជធានី ខេត្ត។

៤. ចំនួនសរុបនៃទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ត្រូវសម្រេចដោយក្រុមប្រឹក្សារាជធានី ខេត្ត មុននឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត។ ក្នុងការសម្រេចអំពីចំនួនទុនចូលរួមនេះ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ប្រភេទនៃគម្រោងដែលបានស្នើឡើង និងចំនួនគ្រួសារ ព្រមទាំងស្ថានភាពជីវភាពរស់នៅនៃគ្រួសារទាំងនោះ។ លើសពីនេះទៀត ក្រុមប្រឹក្សារាជធានី ខេត្តត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនៅក្នុង

រាជធានី ខេត្តរបស់ខ្លួន ដើម្បីសម្រេចអំពីចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោងនីមួយៗរបស់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់។

៥. ការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានត្រូវអនុវត្តនៅក្នុងឆ្នាំថវិកានីមួយៗ។ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីសម្រេចអំពីពេលវេលានៃការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

៦. ក្រុមប្រឹក្សារាជធានី ខេត្តត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីសម្រេចអំពីវិធីសាស្ត្រសមស្របសម្រាប់ប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលអាចធ្វើឡើងតាមរូបភាព ៖
   - ការប្រមូលទុនចូលរួមតាមគ្រួសារ ៖ ចំនួនទុនចូលរួមនៃគ្រួសារនីមួយៗស្មើគ្នា ឬចំនួនទុនចូលរួមនេះរៀបចំទៅតាមទ្រព្យធននៃគ្រួសារ
   - ការប្រមូលទុនចូលរួមពីក្រុមជាក់លាក់ ដូចជាម្ចាស់យានយន្តដែលបានធ្វើអាជីកម្ម ក្នុងករណីគម្រោងផ្លូវថ្នល់
   - ការរៀបចំពិធីបុណ្យនានាដើម្បីប្រមូលទុនចូលរួម។

   ទោះបីជាយ៉ាងណាក៏ដោយ ជាការសំខាន់នោះ គ្រប់គ្រួសារដែលទទួលផលពីគម្រោងទាំងអស់ត្រូវបានស្នើសុំឱ្យបង់ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

៧. រដ្ឋបាលឃុំ សង្កាត់ជាអ្នកទទួលខុសត្រូវក្នុងការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋ សម្រាប់ចូលរួមអនុវត្តគម្រោងរបស់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់

៨. រដ្ឋបាលឃុំ សង្កាត់ត្រូវចុះបញ្ជិកា ទៅតាមការណែនាំដែលមានចែងនៅក្នុងសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

៩. ពេលបង់ប្រាក់ទុនចូលរួមរបស់ប្រជាពលរដ្ឋដែលប្រមូលបាន ទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត នៅរតនាគាររាជធានី ខេត្ត រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំប័ណ្ណចំណាយប្រាក់ ចុះបញ្ជីបេឡាប្រតិបត្តិការផ្សេងៗ និងរៀបចំសលាកបត្របង់ចូលថវិការបស់រាជធានី ខេត្ត។

១០. ក្រោយពីទទួលបានប្រាក់ទុនចូលរួមដែលបង់ដោយរដ្ឋបាលឃុំ សង្កាត់ រតនាគាររាជធានី ខេត្តត្រូវចេញលិខិតជូនដំណឹងឥណទាន និងចុះហត្ថលេខាលើសលាកបត្របង់ចំណូលថវិការាជធានី ខេត្ត រួចប្រគល់ជូនទៅរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់។

១១. នៅពេលទទួលបានលិខិតជូនដំណឹងឥណទានពីរតនាគាររាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្តត្រូវកត់ត្រាចូលសលាកបត្រតាមដានចំណូលថវិកា ព្រមទាំងរៀបចំបញ្ជីទុនចូលរួមរបស់ប្រជាពលរដ្ឋតាម **ទម្រង់ទី៤** ដោយកត់ត្រានូវឈ្មោះឃុំ សង្កាត់ និងចំនួនទឹកប្រាក់សរុបនៃឃុំ សង្កាត់នីមួយៗ។

១២. ក្នុងករណីដែលគ្រួសារណាមួយយល់ព្រមបរិច្ចាគដីធ្លី ឬទ្រព្យសម្បត្តិផ្សេងៗសម្រាប់គម្រោង គ្រួសារនោះមិនត្រូវបានស្នើសុំឱ្យបង់ទុនចូលរួមទៀតឡើយ។

១៣. រដ្ឋបារាជធានី ខេត្តត្រូវរាយការណ៍ជូនប្រជាពលរដ្ឋ អំពីចំនួនទុនចូលរួមសរុបរបស់រាជធានី ខេត្ត ដោយបិទផ្សាយនៅលើក្ដារព័ត៌មានសាធារណៈរបស់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់(**ទម្រង់ទី៤**)។

**ទម្រង់ទី៤**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជធានី ខេត្ត**......................

**បញ្ជីទុនចូលរួមរបស់ប្រជាពលរដ្ឋឆ្នាំ**.........

| ល.រ | ឈ្មោះឃុំ សង្កាត់ | ចំនួនទុនចូលរួម |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| សរុប | | |
| ចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោង............................................ ............................................................................................................ | | |
| ចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោង............................................ ............................................................................................................ | | |
| ចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោង............................................ ............................................................................................................ | | |

ថ្ងៃទី........ ខែ............ ឆ្នាំ.......... ថ្ងៃទី........ ខែ............ ឆ្នាំ..........

**អភិបាលរាជធានី ខេត្ត** **នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

# ជំពូកទី៥
# បញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់
# គម្រោងហេដ្ឋារចនាសម្ព័ន្ធ

# ជំពូកទី៥
# បញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ

## ៥.១. សេចក្តីផ្តើម

ការសិក្សាតម្លៃសម្ភារៈនៅតំបន់ជាក់លាក់នីមួយៗ នៅក្នុងរាជធានី ខេត្ត ដើម្បីរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់តំបន់នោះ មានសារៈសំខាន់ណាស់នៅក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានសុក្រឹតត្រឹមត្រូវ។ តំបន់ជាក់លាក់នីមួយៗនៅក្នុងរាជធានី ខេត្តត្រូវបានកំណត់ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ និងតម្លៃ។

ជាទូទៅ បញ្ជីតម្លៃសម្ភារៈស្តង់ដារត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពនៅក្នុង**ខែតុលា**នៃឆ្នាំនីមួយៗ។ បញ្ជីតម្លៃសម្ភារៈស្តង់ដារនេះ អាចធ្វើបច្ចុប្បន្នភាពឡើងវិញនៅពេលតម្លៃសម្ភារៈ ឬទំនិញនៅលើទីផ្សារមានការប្រែប្រួលខ្លាំង។

បញ្ជីតម្លៃសម្ភារៈស្តង់ដារនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការគណនាប៉ាន់ស្មានតម្លៃគម្រោងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ៥.២. គោលបំណង

ការរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារ មានគោលបំណងដើម្បី ៖

- កំណត់បាននូវតម្លៃសម្ភារៈសំណង់ តម្លៃការងារដី តម្លៃពលកម្ម និងតម្លៃដឹកជញ្ជូននៃតំបន់ជាក់លាក់នីមួយៗ នៅក្នុងរាជធានី ខេត្ត
- គណនាតម្លៃប៉ាន់ស្មានគម្រោងឱ្យបានសុក្រឹត
- ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តគម្រោង
- ធានាបាននូវតម្លាភាព និងគណនេយ្យភាពក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង។

## ៥.៣. តួនាទី និងការទទួលខុសត្រូវ

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទទួលខុសត្រូវក្នុងការសិក្សាតម្លៃសម្ភារៈនៅតាមទីផ្សារសំខាន់ៗ នៅក្នុងរាជធានី ខេត្ត និងរៀបចំបញ្ជីព្រាងតម្លៃសម្ភារៈស្តង់ដារ ហើយដាក់ជូនគណៈអភិបាលរាជធានីខេត្តពិនិត្យ និងអនុម័ត។ បញ្ជីតម្លៃសម្ភារៈស្តង់ដារនេះត្រូវរៀបចំនៅក្នុងអំឡុង**ខែតុលានៃឆ្នាំនីមួយៗ**។

គណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងអនុម័តបញ្ជីតម្លៃសម្ភារៈស្តង់ដារ មិនយឺតជាង**ថ្ងៃទី៣០ ខែវិច្ឆិកានៃឆ្នាំនីមួយៗ**។ នៅពេលតម្លៃសម្ភារៈឬទំនិញនៅលើទីផ្សារមានការប្រែប្រួលខ្លាំង គណៈអភិបាលរាជធានីខេត្តត្រូវពិនិត្យ និងសម្រេចអំពីការធ្វើបច្ចុប្បន្នភាពឡើងវិញនូវបញ្ជីតម្លៃសម្ភារៈស្តង់ដារ។ បញ្ជីតម្លៃសម្ភារៈស្តង់ដារដែលបានធ្វើបច្ចុប្បន្នភាពឡើងវិញនេះ ក៏ត្រូវពិនិត្យ និងអនុម័តដោយគណៈអភិបាលរាជធានី ខេត្តផងដែរ។

## ៥.៤. នីតិវិធីនៃការរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារ

### ក). ការរៀបចំបញ្ជីឈ្មោះសម្ភារៈដែលត្រូវធ្វើការសិក្សា

សម្ភារៈដែលត្រូវធ្វើការសិក្សាតម្លៃត្រូវកំណត់ឱ្យច្បាស់លាស់ ៖

- តើសម្ភារៈអ្វីខ្លះ?
- ប្រភេទសម្ភារៈ (យថាប្រភេទ គុណភាព ទំហំឬកម្លាំង...)។

បន្ទាប់មករៀបចំឈ្មោះសម្ភារៈទាំងនោះជាបញ្ជីមួយសម្រាប់ចុះស្រង់តម្លៃនៅទីផ្សារ(**ទម្រង់ទី៥**)។ បញ្ជីឈ្មោះសម្ភារៈនេះអាចរៀបចំជាផ្នែកដាច់ដោយឡែកពីគ្នា ដើម្បីងាយស្រួលក្នុងការចុះស្រង់តម្លៃ ៖

- សម្ភារៈសំណង់ដែលលក់នៅក្នុងហាងលក់សម្ភារៈសំណង់
- សម្ភារៈសំណង់ដែលលក់នៅតាមការដ្ឋាន (ឧទាហរណ៍ ៖ ខ្សាច់ ក្រួស ដីក្រួសក្រហម ដី...។ល។)
- ប្រេងឥន្ធនៈ
- កម្លាំងពលកម្ម
- ការងារដី
- ការដឹកជញ្ជូន។

**ខ). ការកំណត់តំបន់ ឬទីផ្សារសម្រាប់ចុះស្រង់តម្លៃ**

តំបន់ ឬទីផ្សារសម្រាប់ចុះស្រង់តម្លៃ ត្រូវកំណត់ដោយផ្អែកតាម ៖

- ទីតាំងភូមិសាស្ត្រ
- តម្លៃសម្ភារៈសំណង់ តម្លៃការងារដី តម្លៃដឹកជញ្ជូន និងតម្លៃពលកម្ម
- ទីផ្សារដែលមានសម្ភារៈសំណង់គ្រប់មុខទាំងអស់ ឬស្ទើរតែទាំងអស់។

**គ). ការចុះស្រង់តម្លៃ**

មន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត(ដែលទទួលភារកិច្ចនេះ)ចាប់ផ្តើមសម្ភាសន៍ដោយជម្រាបអ្នកដែលខ្លួនត្រូវសម្ភាសន៍អំពីគោលបំណងនៃការចុះស្រង់តម្លៃនេះឱ្យបានច្បាស់លាស់ គឺដើម្បីរៀបចំបញ្ជីតម្លៃសម្ភារៈជាក់ស្តែងមួយសម្រាប់គណនាតម្លៃប៉ាន់ស្មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ តម្លៃជាក់ស្តែងនេះ គឺជាតម្លៃដែលអាចទិញសម្ភារៈទាំងនោះបាន។

មន្ត្រីទទួលភារកិច្ចត្រូវធ្វើការសម្ភាសន៍ដោយផ្ទាល់ ហើយត្រូវធានាថា តម្លៃដែលបានស្រង់ទាំងនោះ គឺជាតម្លៃជាក់ស្តែងលើទីផ្សារ។

- **សម្ភារៈសំណង់ដែលលក់នៅក្នុងហាងលក់សម្ភារៈសំណង់** ៖ តម្លៃសម្ភារៈសំណង់ទាំងនេះត្រូវស្រង់ពីតូប ឬហាងលក់គ្រឿងសំណង់យ៉ាងតិចចំនួន៣នៅទីផ្សារដែលបានកំណត់សម្រាប់ធ្វើការស្រង់តម្លៃ។ តូបឬហាងលក់គ្រឿងសំណង់ដែលត្រូវជ្រើសរើសសម្រាប់ស្រង់តម្លៃ គឺជាតូបឬហាងដែលមានលក់សម្ភារៈសំណង់ច្រើនជាងគេ។
- **សម្ភារៈសំណង់ដែលលក់នៅតាមការដ្ឋាន** ៖ សម្ភារៈសំណង់ទាំងនេះត្រូវស្រង់ពីគ្រប់ការដ្ឋានទាំងអស់នៅក្នុងរាជធានី ខេត្ត។
- **ប្រេងឥន្ធនៈ** ៖ តម្លៃប្រេងឥន្ធនៈត្រូវស្រង់ពីស្ថានីយ៍ប្រេងឥន្ធនៈ ឬកន្លែងលក់ប្រេងឥន្ធនៈនៅក្នុងរាជធានី ខេត្ត។
- **កម្លាំងពលកម្ម** ៖ តម្លៃពលកម្មត្រូវស្រង់ពីអ្នកធ្វើអាជីវកម្ម និងក្រុមកម្មករ នៅគ្រប់ផ្សារទីប្រជុំជនទាំងអស់នៅក្នុងរាជធានី ខេត្ត។
- **ការងារដី** ៖ តម្លៃការងារដីត្រូវគណនា ដូចខាងក្រោម ៖

**១). ការឈូសសម្អាតទីតាំង**

| ល.រ | ស្ថានភាពទីតាំង | តម្លៃសម្អាតដីក្នុង១ម² (រៀល) |
|---|---|---|
| ១ | **ងាយស្រួល** ៖ ផ្ទៃលើនៃផ្លូវដែលមានស្រាប់ មានសភាពមិនរាបស្មើ គ្មានគុម្ពោតព្រៃ គ្មានដើមឈើនៅសងខាងផ្លូវ | (0,0១ x D) + ៤0 |
| ២ | **មធ្យម** ៖ ផ្ទៃលើនៃផ្លូវដែលមានស្រាប់មានសភាពមិនរាបស្មើ និងតូចចង្អៀត មានគុម្ពោតព្រៃ ព្រៃឫស្សី និងមានដើមឈើនៅសងខាងផ្លូវ។ | (0,0២ x D) + ៨0 |
| ៣ | **លំបាក** ៖ មិនមែនជាផ្លូវដែលមានស្រាប់ មានគុម្ពោតព្រៃ ព្រៃឫស្សី និងមានដើមឈើច្រើន។ | (0,0៧ x D) + ២៨0 |

D គឺជាតម្លៃប្រេងម៉ាស៊ូតក្នុងមួយលីត្រ គិតជារៀល។

**២). ការជីកដី**

| ល.រ | ស្ថានភាពដី | ការជីកដីក្នុង១ម³ (រៀល) |
|---|---|---|
| ១ | **ងាយស្រួល** ៖ ដីធម្មជាតិគ្មានថ្ម និងក្រួសល្អិតៗ។ | (0,២៧ x D) + ១.២00 |
| ២ | **មធ្យម** ៖ ដីធម្មជាតិមានក្រួសល្អិតៗខ្លះៗ។ | (0,៣៥ x D) + ១.៤00 |
| ៣ | **លំបាក** ៖ ដីធម្មជាតិមានបំណែកថ្មខ្លះៗ។ | (0,៤៣ x D) + ១.៨00 |

**៣). ការបង្ហាប់ដី (ការកៀរពង្រាយ ការស្រោចទឹក និងការបង្ហាប់)**

| ល.រ | ស្ថានភាពដី | តម្លៃបង្ហាប់ដីក្នុង១ម³ (រៀល) |
|---|---|---|
| ១ | **ងាយស្រួល** ៖ ដីធម្មជាតិគ្មានថ្ម និងក្រួសល្អិតៗ។ | (0,២៨ x D) + ១.៤00 |
| ២ | **មធ្យម** ៖ ដីធម្មជាតិមានក្រួសល្អិតៗខ្លះៗ។ | (0,៤0 x D) + ២.000 |
| ៣ | **លំបាក** ៖ ដីធម្មជាតិមានបំណែកថ្មខ្លះៗ។ | (0,៨0 x D) + ៤.១00 |

- **ការដឹកជញ្ជូន**

តម្លៃដឹកជញ្ជូនត្រូវគណនា ដូចខាងក្រោម ៖

**១). តម្លៃដឹកជញ្ជូនសម្ភារៈ និងបរិក្ខារ**

| ល.រ | ស្ថានភាពផ្លូវ | តម្លៃដឹកជញ្ជូនក្នុង១តោនក្នុង១គ.ម (រៀល) | | | |
|---|---|---|---|---|---|
| | | តិចជាង២0គ.ម | ២0-៣៥គ.ម | ៣៥-៥0គ.ម | ច្រើនជាង៥0គ.ម |
| ១ | ស្ថានភាពផ្លូវល្អ (ល្បឿនមធ្យម ៥0គ.ម/ម៉) | (0,១0 x D) + ២00 | (0,0៩ x D) + ២00 | (0,0៨ x D) + ២00 | (0,0៧ x D) + ២00 |
| ២ | ស្ថានភាពផ្លូវមធ្យម (ល្បឿនមធ្យម ២៥គ.ម/ម៉) | (0,១៥ x D) + ៤00 | (0,១៤ x D) + ៤00 | (0,១២ x D) + ៤00 | (0,១១ x D) + ៤00 |
| ៣ | ស្ថានភាពផ្លូវលំបាក (ល្បឿនមធ្យម ១៥គ.ម/ម៉) | (0,១៧ x D) + ៦00 | (0,១៥ x D) + ៦00 | (0,១៤ x D) + ៦00 | (0,១២ x D) + ៦00 |

២). តម្លៃដឹកជញ្ជូនដី ឬក្រួសក្រហម

| ល.រ | ស្ថានភាពផ្លូវ | តម្លៃដឹកជញ្ជូនក្នុង១ម³ក្នុង១គ.ម (រៀល) | | | |
|---|---|---|---|---|---|
| | | តិចជាង២០គ.ម | ២០-៣៥គ.ម | ៣៥-៥០គ.ម | ច្រើនជាង៥០គ.ម |
| ១ | ស្ថានភាពផ្លូវល្អ (ល្បឿនមធ្យម ៥០គ.ម/ម៉) | (០,០៥ x D) + ១០០ | (០,០៤៥ x D) + ១០០ | (០,០៤១ x D) + ១០០ | (០,០៣៧ x D) + ១០០ |
| ២ | ស្ថានភាពផ្លូវមធ្យម (ល្បឿនមធ្យម ២៥គ.ម/ម៉) | (០,០៧ x D) + ២០០ | (០,០៦៣ x D) + ២០០ | (០,០៥៧ x D) + ២០០ | (០,០៥១ x D) + ២០០ |
| ៣ | ស្ថានភាពផ្លូវលំបាក (ល្បឿនមធ្យម ១៥គ.ម/ម៉) | (០,០៨ x D) + ៣០០ | (០,០៧២ x D) + ៣០០ | (០,០៦៥ x D) + ៣០០ | (០,០៥៨ x D) + ៣០០ |

**ឃ). ការរៀបចំបញ្ជីព្រាងតម្លៃសម្ភារៈស្តង់ដារ**

បន្ទាប់ពីស្រង់តម្លៃរួច ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តត្រូវរៀបចំបញ្ជីព្រាងតម្លៃសម្ភារៈស្តង់ដារ (**ទម្រង់ទី៦**) ហើយដាក់ជូនគណៈអភិបាលរាជធានី ខេត្តពិនិត្យ និងអនុម័ត។

**ង). ការអនុម័តបញ្ជីតម្លៃសម្ភារៈស្តង់ដារ**

បន្ទាប់ពីទទួលបានបញ្ជីព្រាងតម្លៃសម្ភារៈស្តង់ដារ អភិបាលរាជធានី ខេត្តត្រូវរៀបចំប្រជុំគណៈអភិបាលរបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តបញ្ជីតម្លៃសម្ភារៈស្តង់ដារ។ នៅក្នុងកិច្ចប្រជុំនេះ ទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្តត្រូវរាយការណ៍អំពីនីតិវិធី និងលទ្ធផលនៃការរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារ។ បន្ទាប់មកគណៈអភិបាលរាជធានី ខេត្តពិនិត្យ និងអនុម័តទៅលើបញ្ជីតម្លៃសម្ភារៈស្តង់ដារ។ ការអនុម័តបញ្ជីតម្លៃសម្ភារៈស្តង់ដារត្រូវធ្វើឡើងយ៉ាងយូរត្រឹមថ្ងៃទី**៣០ ខែវិច្ឆិកានៃឆ្នាំនីមួយៗ**។

បញ្ជីតម្លៃសម្ភារៈស្តង់ដារនៃឆ្នាំនីមួយៗអស់សុពលភាព នៅពេលដែលបញ្ជីតម្លៃសម្ភារៈស្តង់ដារនៃឆ្នាំបន្ទាប់ត្រូវបានអនុម័តដោយគណៈអភិបាលរាជធានី ខេត្ត។

**ច). ការផ្សព្វផ្សាយ និងតម្កល់ទុកបញ្ជីតម្លៃសម្ភារៈស្តង់ដារ**

បន្ទាប់ពីអនុម័ត បញ្ជីតម្លៃសម្ភារៈស្តង់ដារត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដោយបិទផ្សាយនៅលើក្តារព័ត៌មានរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.អ.ប។ បញ្ជីតម្លៃសម្ភារៈស្តង់ដារត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ និងសាលាឃុំ សង្កាត់ សម្រាប់គណនាតម្លៃប៉ាន់ស្មានគម្រោងនានា។

មន្ទីរ ការិយាល័យ អង្គភាពជំនាញ អ្នកទទួលការ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាអាចត្រូវបានផ្តល់ជូននូវបញ្ជីតម្លៃសម្ភារៈស្តង់ដារនេះតាមការស្នើសុំ។ ទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្តអាចស្នើឱ្យអ្នកស្នើសុំបញ្ជីតម្លៃសម្ភារៈស្តង់ដារនេះបង់ថ្លៃ ត្រឹមតែតម្លៃនៃការថតចម្លងឯកសារប៉ុណ្ណោះ។

**បញ្ជាក់ ÷**

- តម្លៃសម្ភារៈនៅក្នុងបញ្ជីតម្លៃសម្ភារៈស្តង់ដារនេះ គឺជាតម្លៃទីផ្សារជាក់ស្តែងនៃកន្លែងលក់ដូរ ឬកន្លែងធ្វើអាជីវកម្មស្របច្បាប់។ នេះមានន័យថា តម្លៃសម្ភារៈទាំងនោះបានរួមបញ្ចូលនូវថ្លៃពន្ធនានា និងថ្លៃសួយសារវត្ថុធាតុដើម ឬសម្ភារៈសំណង់ដែលរដ្ឋតម្រូវឱ្យបង់។
- ចំពោះបញ្ជីតម្លៃស្តង់ដារពូជដំណាំ ពូជសត្វ សម្ភារៈ និងឧបករណ៍សម្រាប់គម្រោងសេវាកម្ម រាជធានី ខេត្តអាចរៀបចំបញ្ជីតម្លៃស្តង់ដារនេះ ទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់រាជធានី ខេត្តនីមួយៗ។ នីតិវិធីក្នុងការរៀបចំបញ្ជីតម្លៃស្តង់ដារនេះ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងនីតិវិធីរៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែរ។
- តម្លៃនានានៅក្នុងទម្រង់ទី៥ (បញ្ជីស្រង់តម្លៃសម្ភារៈ) និងនៅក្នុងទម្រង់ទី៦ (បញ្ជីតម្លៃសម្ភារៈស្តង់ដារ) ត្រូវគិតជាប្រាក់រៀល ដោយបញ្ជាក់អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារសហរដ្ឋអាមេរិកនៅក្រោមទម្រង់ទី៥ និងទម្រង់ទី៦។
- ដើម្បីឱ្យមានលក្ខណៈស្តង់ដារទៅលើលេខកូដ និងឈ្មោះសម្ភារៈ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ នឹងជួយរៀបចំ និងធ្វើបច្ចុប្បន្នភាព**លេខកូដ** និង**ឈ្មោះសម្ភារៈ**នៃបញ្ជីស្រង់តម្លៃសម្ភារៈ(ទម្រង់ទី៥) និងបញ្ជីតម្លៃសម្ភារៈស្តង់ដារ(ទម្រង់ទី៦) ហើយផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត នៅក្នុងខែ**កញ្ញា** នៃឆ្នាំនីមួយៗ។

ទម្រង់ទី៥

# បញ្ជីស្រង់តម្លៃសម្ភារៈសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឆ្នាំ.......

ឈ្មោះផ្សារ................ ឃុំ សង្កាត់................ ក្រុង ស្រុក ខណ្ឌ................ រាជធានី ខេត្ត................

| កូដ | ការពិពណ៌នា | ឯកតា | តម្លៃក្នុងមួយឯកតា(៛) |
|---|---|---|---|
| **0100** | **សម្ភារៈសម្រាប់ការងារបេតុង និងបាយអរ** | | |
| 0101 | | | |
| 0102 | | | |
| ....... | | | |
| **0200** | **សម្ភារៈសម្រាប់គ្រោងដែក** | | |
| 0201 | | | |
| 0202 | | | |
| ....... | | | |
| **0300** | **សម្ភារៈសម្រាប់ការងារឥដ្ឋ** | | |
| 0301 | | | |
| 0302 | | | |
| ....... | | | |
| **0400** | **សម្ភារៈសម្រាប់ការងារដំបូល** | | |
| 0401 | | | |
| 0402 | | | |
| ....... | | | |
| **0500** | **ប្រេងឥន្ធនៈ** | | |
| 0501 | | | |
| 0502 | | | |
| ....... | | | |
| **0600** | **សម្ភារៈឈើ** | | |
| 0601 | | | |
| 0602 | | | |
| ....... | | | |
| **0700** | **សម្ភារៈដទៃទៀត** | | |
| 0701 | | | |
| 0702 | | | |
| ....... | | | |
| **0800** | **ការងារដី** | | |
| 0801 | | | |
| 0802 | | | |

| កូដ | ការពិពណ៌នា | ឯកតា | តម្លៃក្នុងមួយឯកតា(៛) |
|---|---|---|---|
| ....... | | | |
| **0900** | **តម្លៃពលកម្ម** | | |
| 0901 | | | |
| 0902 | | | |
| ....... | | | |
| **1000** | **តម្លៃដឹកជញ្ជូនសម្ភារៈ និងគ្រឿងចក្រ (គណនាតាមរូបមន្ត ÷ តម្លៃប្រេងម៉ាស៊ូត និងចម្ងាយផ្លូវ)** | | |
| 1001 | | | |
| 1002 | | | |
| ....... | | | |

អត្រាប្តូរប្រាក់ ៖ ....................រៀលក្នុងមួយដុល្លារសហរដ្ឋអាមេរិក។

ថ្ងៃទី......... ខែ............. ឆ្នាំ............

**អ្នកស្រង់តម្លៃ**

ឈ្មោះ........................ ឈ្មោះ.........................

តួនាទី.......................... តួនាទី.........................

ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលារាជធានី ខេត្ត...............**
លេខ ៖...............

## បញ្ជីតម្លៃសម្ភារៈស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ

**រាជធានី ខេត្ត.................. ឆ្នាំ.........**

| កូដ | ការពិពណ៌នា | ឯកតា | តម្លៃមធ្យមក្នុងមួយឯកតា | តម្លៃក្នុងមួយឯកតា (រៀល) | | |
|---|---|---|---|---|---|---|
| | | | | ផ្សារ....... | ផ្សារ....... | ផ្សារ....... |
| **0100** | **សម្ភារៈសម្រាប់ការងារបេតុង និងបាយអរ** | | | | | |
| 0101 | | | | | | |
| 0102 | | | | | | |
| ...... | | | | | | |
| **0200** | **សម្ភារៈសម្រាប់គ្រោងដែក** | | | | | |
| 0201 | | | | | | |
| 0202 | | | | | | |
| ...... | | | | | | |
| **0300** | **សម្ភារៈសម្រាប់ការងារឥដ្ឋ** | | | | | |
| 0301 | | | | | | |
| 0302 | | | | | | |
| ...... | | | | | | |
| **0400** | **សម្ភារៈសម្រាប់ការងារដីបូល** | | | | | |
| 0401 | | | | | | |
| 0402 | | | | | | |
| 0403 | | | | | | |
| **0500** | **ប្រេងឥន្ធនៈ** | | | | | |
| 0501 | | | | | | |
| 0502 | | | | | | |
| ...... | | | | | | |
| **0600** | **សម្ភារៈឈើ** | | | | | |
| 0601 | | | | | | |
| 0602 | | | | | | |
| ...... | | | | | | |
| **0700** | **សម្ភារៈដទៃទៀត** | | | | | |
| 0701 | | | | | | |
| 0702 | | | | | | |
| ...... | | | | | | |

| កូដ | ការពិពណ៌នា | ឯកតា | តម្លៃមធ្យមក្នុងមួយឯកតា | តម្លៃក្នុងមួយឯកតា (រៀល) | | |
|---|---|---|---|---|---|---|
| | | | | ផ្សារ....... | ផ្សារ....... | ផ្សារ....... |
| **0800** | **ការខារដី** | | | | | |
| 0801 | | | | | | |
| 0802 | | | | | | |
| ...... | | | | | | |
| **0900** | **តម្លៃពលកម្ម** | | | | | |
| 0901 | | | | | | |
| 0902 | | | | | | |
| ...... | | | | | | |
| **1000** | **តម្លៃដឹកជញ្ជូនសម្ភារៈ និងគ្រឿងចក្រ** (គណនាតាមរូបមន្ត ៖ តម្លៃប្រេងម៉ាស៊ូត និងចម្ងាយផ្លូវ) | | | | | |
| 1001 | | | | | | |
| 1002 | | | | | | |
| ...... | | | | | | |

អត្រាប្តូរប្រាក់ ៖ ....................រៀលក្នុងមួយដុល្លារសហរដ្ឋអាមេរិក។

ថ្ងៃទី.......... ខែ............. ឆ្នាំ..........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

**បានឃើញ និងឯកភាព**

ថ្ងៃទី.......... ខែ............. ឆ្នាំ..........

**អភិបាលរាជធានី ខេត្ត**

# ជំពូកទី៦
# ការបំពេញទម្រង់ព័ត៌មានគម្រោង

# ជំពូកទី៦

# ការបំពេញទម្រង់ព័ត៌មានគម្រោង

## ៦.១. អ្នកទទួលខុសត្រូវក្នុងការបំពេញទម្រង់ព័ត៌មានគម្រោង

អ្នកទទួលខុសត្រូវក្នុងការបំពេញទម្រង់ព័ត៌មានគម្រោងរួមមាន ៖

- គណៈកម្មការរៀបចំគម្រោងទទួលខុសត្រូវជារួមក្នុងការប្រមូលព័ត៌មាន និងការបំពេញព័ត៌មាននៅក្នុងទម្រង់ព័ត៌មានគម្រោង និងព័ត៌មានបច្ចេកទេស
- អ្នកជំនួយបច្ចេកទេសជួយគណៈកម្មការរៀបចំគម្រោងក្នុងការបំពេញព័ត៌មាននានា ពិសេសព័ត៌មានបច្ចេកទេស នៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ
- ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទទួលខុសត្រូវក្នុងការពិនិត្យទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ មុនដាក់ជូនអភិបាលរាជធានី ខេត្តចុះហត្ថលេខា។

ជាធម្មតា គណៈកម្មការរៀបចំគម្រោងត្រូវបំពេញទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនៅផ្នែកដែលមិនទាក់ទងនឹងបច្ចេកទេស។ អ្នកជំនួយបច្ចេកទេសត្រូវបំពេញទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនៅផ្នែកដែលទាក់ទងនឹងព័ត៌មានបច្ចេកទេស។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជាម្ចាស់គម្រោង គណៈកម្មការរៀបចំគម្រោងទទួលខុសត្រូវទាំងស្រុងទៅលើខ្លឹមសារនានានៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ មិនមែនទទួលខុសត្រូវតែផ្នែកដែលខ្លួនបានបំពេញនោះទេ។

## ៦.២. ព័ត៌មានដែលត្រូវបំពេញក្នុងទម្រង់ព័ត៌មានគម្រោង

| **ផ្នែកទី១ ៖ ព័ត៌មានទូទៅ** | |
|---|---|
| ១.១. ឈ្មោះគម្រោង | ព័ត៌មានស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត |
| ១.២. កាលបរិច្ឆេទបញ្ចប់ការសិក្សា | កាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង (ស្រង់កាលបរិច្ឆេទនៃការចុះហត្ថលេខារបស់អ្នកជំនួយបច្ចេកទេសលើទម្រង់ព័ត៌មានគម្រោង) |
| ១.៣. ឈ្មោះអ្នកជំនួយបច្ចេកទេស | |
| ១.៤. ឋានៈអ្នកជំនួយបច្ចេកទេស | អាចជាមន្ត្រីរបស់សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញ អង្គការមិនមែនរដ្ឋាភិបាល ឬផ្នែកឯកជន។ល។ |
| ១.៥. ទិសដៅគម្រោង | ទិសដៅជាក់លាក់របស់គម្រោងដែលត្រូវបង្កើត នៅពេលបំពេញទម្រង់ព័ត៌មានគម្រោង។ |
| ១.៦. វិស័យ ឬផ្នែក | ជាផ្នែកដែលមាននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ)។ |
| ១.៧. ប្រភេទ | ជាប្រភេទគម្រោងដូចមាននៅក្នុងបញ្ជីប្រភេទគម្រោង និងមន្ទីរ អង្គភាពជំនាញ (**ចំណុច៦.៣**)។ |
| ១.៨. លទ្ធផលគ្រោងទុក | ត្រូវចម្លងទាំងស្រុងពីកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។ |

| | | |
|---|---|---|
| ១.៩. | លទ្ធផលគ្រោងទុកក្រោយពីធ្វើការសិក្សា | ការសិក្សាគម្រោងអាចធ្វើការផ្លាស់ប្ដូរលទ្ធផលដែលបានគ្រោងទុក។ ឧទាហរណ៍ ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តបានកំណត់ថា ស្ពានមួយកន្លែង ប៉ុន្តែបន្ទាប់ពីបានធ្វើការសិក្សារួច គម្រោងនោះអាចទៅជាលូពីរកន្លែងវិញ។ |
| ១.១០. | តម្លៃប៉ាន់ស្មានគម្រោងនៅក្នុងកម្មវិធីវិនិយោគ | តម្លៃប៉ាន់ស្មានគម្រោង ដែលមាននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។ |
| ១.១១. | តម្លៃប៉ាន់ស្មានគម្រោងក្រោយការសិក្សាគម្រោង | តម្លៃប៉ាន់ស្មានគម្រោង ក្រោយពីអ្នកជំនួយបច្ចេកទេសបានសិក្សារៀបចំគំនូសប្លង់បច្ចេកទេស និងប៉ាន់ស្មានតម្លៃរួច។ |
| ១.១២. | អ្នកទទួលផលពីគម្រោង | អ្នកទទួលផលផ្ទាល់ពីគម្រោង គឺប្រជាពលរដ្ឋមូលដ្ឋានដែលប្រើប្រាស់លទ្ធផលគម្រោង។ ចំនួនប្រជាពលរដ្ឋដែលជាអ្នកទទួលផល ត្រូវបានចុះបញ្ជីតាមភូមិ និងឃុំ សង្កាត់នីមួយៗ ដោយមានបញ្ជាក់ច្បាស់លាស់នូវចំនួនស្ត្រី និងចំនួនគ្រួសារ។ |
| **ផ្នែកទី២ ៖ កិច្ចប្រតិបត្តិការ និងការថែទាំ** | | |
| ២.១. | ការទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ | ត្រូវបង្ហាញអ្នកដែលនឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង។ ជម្រើសអាចជា ៖<br>• មន្ទីរ អង្គភាពជំនាញ (ឧទាហរណ៍ សាលារៀន)<br>• រដ្ឋបាលរាជធានី ខេត្ត (ឧទាហរណ៍ ផ្លូវ)<br>• ក្រុមប្រើប្រាស់ដែលមានស្រាប់<br>• ក្រុមប្រើប្រាស់ដែលត្រូវបង្កើត<br>• ផ្នែកឯកជន (ឧទាហរណ៍ ប្រព័ន្ធទឹកស្អាត)<br>• . . . ។ល។ |
| **ផ្នែកទី៣ ៖ ផលប៉ះពាល់បរិស្ថាន** | | |
| ៣.១ | តើទីតាំងគម្រោងនេះស្ថិតនៅក្នុងឃុំដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថានដែរឬទេ? | បញ្ជីនេះត្រូវបានដាក់ឱ្យប្រើប្រាស់ដោយ គ.ជ.អ.ប ដើម្បីជំរុញការយកចិត្តទុកដាក់ទៅលើតំបន់ដែលងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន។ |
| ៣.២ | តើការអនុវត្តគម្រោងនេះបណ្ដាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់កន្លែងមួយចំនួន ដែលមានសារៈសំខាន់លើផ្នែកបរិស្ថាន ឬវប្បធម៌ដែរឬទេ? | ឧទាហរណ៍ ព្រៃឈើ ព្រៃលិចទឹក មច្ឆជាតិ រុក្ខជាតិដុះក្នុងទឹក ធនធានរ៉ែលើនិងក្រោមដី សួនសត្វ ឬប្រាង្គប្រាសាទ ទួលអ្នកតា ...។ល។ |
| ៣.៣ | តើការអនុវត្តគម្រោងនឹងបណ្ដាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់ប្រភពផ្គត់ផ្គង់ទឹក ដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់ដែរឬទេ? | ឧទាហរណ៍ ៖ គម្រោងផ្លូវដែលស្ថិតនៅជិតអូរ ឬប្រឡាយដែលប្រជាពលរដ្ឋយកទឹកនោះសម្រាប់ការប្រើប្រាស់ក្នុងផ្ទះសំបែងរាល់ថ្ងៃ។ ប្រសិនបើផ្លូវត្រូវបានធ្វើការសាងសង់ក្នុងរដូវវស្សា ទឹកកខ្វក់នឹងហូរពីផ្លូវចូលទៅក្នុងអូរឬប្រឡាយនោះ ជាហេតុបណ្ដាលឱ្យប្រជាពលរដ្ឋមិនអាចប្រើប្រាស់ទឹកនោះបានឡើយ។ |

| | | |
|---|---|---|
| ៣.៤ | តើលទ្ធផលគម្រោង គឺជាខ្សែផ្លូវថ្មីឬផ្លូវចាស់ដែលមានស្រាប់ត្រូវបានពង្រីកទទឹងចាប់ពី ២៥%ឡើងទៅ? | បើជាខ្សែផ្លូវថ្មី ឬផ្លូវចាស់ដែលមានស្រាប់ត្រូវបានពង្រីកទទឹងចាប់ពី ២៥%ឡើងទៅ ត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន។ |
| ៣.៥ | តើលទ្ធផលគម្រោង ជាខ្សែទំនប់ ឬខ្សែប្រឡាយថ្មី (ប្រព័ន្ធជាពសាស្ត្រថ្មី)? | បើជាខ្សែទំនប់ ឬខ្សែប្រឡាយថ្មី ត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន។ |
| ៣.៦ | តើលទ្ធផលគម្រោងជាខ្សែព្រែកជីកថ្មីសម្រាប់ការធ្វើដំណើរផ្លូវទឹក ឬផ្គត់ផ្គង់ទឹកប្រើប្រាស់? | លទ្ធផលគម្រោងជាខ្សែព្រែកជីកថ្មី ត្រូវសិក្សាផលប៉ះពាល់បរិស្ថាន។ |
| **ផ្នែកទី៤ ៖ ផលប៉ះពាល់ដីធ្លី** | | |
| កម្មសិទ្ធិករ ឬភោគីដីធ្លី | | គណៈកម្មការរៀបចំគម្រោង ត្រូវផ្តល់ចម្លើយដោយស្មោះត្រង់ចំពោះបញ្ហានេះ។ វាមិនសំខាន់ទេថាតើអ្នកនោះមានឬមិនមានប័ណ្ណកម្មសិទ្ធិ។ កម្មសិទ្ធិករឬភោគីដីធ្លី គឺជាអ្នកដែលប្រើប្រាស់ដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈឯកជន ឬក្នុងគោលបំណងផ្សេងទៀត។ ការអង្កេតដីធ្លីដោយមានការចូលរួម នឹងអនុវត្តដើម្បីប្រមូលព័ត៌មាននានាឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ នៅមុនពេលផ្នែកនេះនៃទម្រង់អាចត្រូវបានបំពេញ។ |
| ៤.១ | គម្រោងនឹងត្រូវអនុវត្តនៅលើដីសាធារណៈដែលមិនមានការប្រើប្រាស់សម្រាប់ដាំដុះអ្វីទេ | ឧទាហរណ៍ ៖ ការសាងសង់អគារសិក្សាថ្មីមួយខ្នង នៅក្នុងបរិវេណសាលារៀនដែលមានស្រាប់។ |
| ៤.២ | គម្រោងនឹងត្រូវអនុវត្តនៅលើដីមួយចំនួនដែលកំពុងប្រើប្រាស់ដោយឯកជន ហើយគ្រប់គ្រួសារដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោងបានយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួន ដោយស្ម័គ្រចិត្តដល់គម្រោង។ មិនមានអ្នកប្រើប្រាស់ដីណាមួយនឹងប្រគល់ដីធ្លីច្រើនជាង៥% នៃដីផលិតកម្មសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង ១.០០០.០០០ **រៀល**សម្រាប់គម្រោងនោះទេ។ | ឧទាហរណ៍ ៖ គម្រោងពង្រីកផ្លូវដែលមានស្រាប់ គណៈកម្មការរៀបចំគម្រោងត្រូវរៀបចំឱ្យមានការប្រជុំជាសាធារណៈ ហើយធ្វើការពន្យល់អំពីគម្រោងដល់ប្រជាពលរដ្ឋ។ អ្នកប្រើប្រាស់ដីត្រូវដឹងច្បាស់ថា ពួកគាត់មិនមែនត្រូវតែប្រគល់ដីរបស់ខ្លួនសម្រាប់គម្រោងឡើយ។ គ្រួសារដែលបានបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀតដោយស្ម័គ្រចិត្ត មិនត្រូវបានស្នើសុំឱ្យបង់ទុនចូលរួមនោះទេ។ ចំពោះគម្រោងប្រភេទនេះ តម្រូវឱ្យមាន**របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**។ |

| | | |
|---|---|---|
| ៤.៣ | គម្រោងនឹងត្រូវអនុវត្តនៅលើដីមួយចំនួនដែលកំពុងប្រើប្រាស់ដោយឯកជន ហើយគ្រួសារមួយចំនួនដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ ដោយសារការអនុវត្តគម្រោងមិនយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដល់គម្រោងដោយគ្មានសំណងទូទាត់។ មានអ្នកប្រើប្រាស់ដីធ្លីមួយចំនួននឹងប្រគល់ដីធ្លីច្រើនជាង៥%នៃដីផលិតកម្មសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង ១.០០០.០០០រៀល សម្រាប់គម្រោង។ | ចំពោះគម្រោងប្រភេទនេះ តម្រូវឱ្យមានរបាយការណ៍លទ្ធកម្មដីធ្លី។ ការធ្វើដូច្នេះដើម្បីឱ្យប្រាកដថា គ្មានម្ចាស់ដីធ្លី ឬទ្រព្យសម្បត្តិណាម្នាក់ត្រូវបានគេប្រព្រឹត្តិដោយអយុត្តិធម៌ឡើយ។ |
| **ផ្នែកទី៥ ៖ វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច** | | |
| តើការអនុវត្តគម្រោងនេះ ស្ថិតនៅក្នុងភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិចដែរឬទេ? | | គ.ជ.អ.ប មានរៀបចំបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៥% នៃប្រជាពលរដ្ឋក្នុងភូមិសរុប)។ បើទីតាំងគម្រោងស្ថិតនៅក្នុងភូមិនៃបញ្ជីនេះ ត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។ |
| **ផ្នែកទី៦ ៖ ការសង្ខេបព័ត៌មាន** | | |
| ៦.១ | តើមានហេតុផលណាដែលបណ្តាលឱ្យគម្រោងនេះ មិនទទួលបានជោគជ័យដែរឬទេ? (សំណួរនេះឆ្លើយដោយអ្នកជំនួយបច្ចេកទេស)។ | អ្នកជំនួយបច្ចេកទេសដែលជាអ្នកជួយដល់គណៈកម្មការរៀបចំគម្រោងក្នុងការរៀបចំគ្រោងការគម្រោង ធ្វើការកត់សម្គាល់បន្ថែមអំពីមូលហេតុនានាដែលអាចបណ្តាលឱ្យគម្រោងទទួលបរាជ័យ។ |
| ៦.២ | តើព័ត៌មាន និងឯកសារពាក់ព័ន្ធនានាត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយឬនៅ? | គណៈកម្មការរៀបចំគម្រោង(ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស) ត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងទៅលើព័ត៌មានដែលបានបំពេញក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនានា។ |
| ការចុះហត្ថលេខា | | • អ្នកជំនួយបច្ចេកទេសត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់ថា រាល់ព័ត៌មានទាំងអស់បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ។<br>• នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់ថា រាល់ឯកសារ និងព័ត៌មានទាំងអស់ត្រូវបានពិនិត្យត្រឹមត្រូវ។ |

| | |
|---|---|
| | • អភិបាលរាជធានី ខេត្តត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់អំពីការអនុម័តទៅលើសំណើគម្រោង។ |
| **ឯកសារភ្ជាប់មកជាមួយ** | |
| ផែនទីគម្រោង | ផែនទីគម្រោងត្រូវតែជាផែនទីរាជធានី ខេត្ត ដែលបង្ហាញអំពីទីតាំងនៃលទ្ធផលនានារបស់គម្រោង ដែលបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេស និងបណ្តាភូមិទាំងឡាយដែលអ្នកទទួលផលរស់នៅ។ ផែនទីគម្រោងត្រូវប្រថាប់ត្រារដ្ឋបាលរាជធានី ខេត្ត។ |
| ព័ត៌មានបច្ចេកទេស និងប្លង់ការដ្ឋាន | ប្រភេទព័ត៌មានបច្ចេកទេសអាស្រ័យទៅនឹងប្រភេទគម្រោង។ អ្នកជំនួយបច្ចេកទេសត្រូវតែទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានទាំងនេះ ដែលត្រូវបានបញ្ចូលទៅក្នុងទម្រង់ព័ត៌មានគម្រោង។ |
| គំនូសប្លង់បច្ចេកទេស | រាល់គំនូសប្លង់បច្ចេកទេសណាមួយដែលត្រូវប្រើប្រាស់សម្រាប់គម្រោងត្រូវភ្ជាប់មកជាមួយ។ |
| តម្លៃប៉ាន់ស្មានគម្រោងលម្អិត | ទម្រង់នេះបង្ហាញអំពីតម្លៃប៉ាន់ស្មានតាមលទ្ធផលគម្រោងនីមួយៗ ឬលទ្ធផលគម្រោងទាំងមូល អាស្រ័យនឹងប្រភេទគម្រោង។ |
| លទ្ធផលគម្រោង និងតម្លៃប៉ាន់ស្មាន | ទម្រង់នេះបង្ហាញតាមលទ្ធផលគម្រោងនីមួយៗ និងតម្លៃប៉ាន់ស្មាន។ អ្នកជំនួយបច្ចេកទេសនឹងជួយបំពេញក្នុងទម្រង់នេះ។ |
| ទីតាំងគម្រោង | ទម្រង់នេះបង្ហាញអំពីទីតាំងលទ្ធផលគម្រោងដោយប្រើប្រាស់កូអ័រដោនេ GPS។ ទម្រង់នេះនឹងបំពេញដោយអ្នកជំនួយបច្ចេកទេស។ |
| ផែនការប្រតិបត្តិការ និងការថែទាំ | ទម្រង់នេះបង្ហាញពីផែនការសម្រាប់កិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង។ |
| របាយការណ៍សិក្សាដីធ្លី | ទម្រង់នេះបង្ហាញអំពីដីធ្លី និងទ្រព្យសម្បត្តិឯកជន ដែលទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង។ |
| របាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន | ទម្រង់នេះបង្ហាញអំពីផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការអនុវត្តគម្រោង និងផែនការគ្រប់គ្រងបរិស្ថាន។ |
| របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច | ទម្រង់នេះ បង្ហាញអំពីវិធានការទាំងឡាយដែលការពារសុវត្ថិភាពចំពោះជនជាតិដើមភាគតិច និងផែនការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច។ |

## ៦.៣. បញ្ជីប្រភេទគម្រោង និងមន្ទីរ អង្គភាពជំនាញ

| ល.រ | ប្រភេទគម្រោង | មន្ទីរ អង្គភាពជំនាញ |
|---|---|---|
| ១ | គមនាគមន៍ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ២ | គមនាគមន៍ទីប្រជុំជន | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| ៣ | កសិកម្ម | មន្ទីរកសិកម្ម |
| ៤ | ធារាសាស្ត្រ | មន្ទីរធនធានទឹកនិងឧតុនិយម |
| ៥ | ប្រព័ន្ធបង្ហូរទឹកស្អុយ | មន្ទីរសាធារណការ និងដឹកជញ្ជូន |

| ល.រ | ប្រភេទគម្រោង | មន្ទីរ អង្គភាពជំនាញ |
|---|---|---|
| ៦ | ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី |
| ៧ | អគ្គិសនី | មន្ទីររ៉ែ និងថាមពល |
| ៨ | អភិវឌ្ឍន៍ផ្នែកសិប្បកម្ម | មន្ទីរឧស្សាហកម្ម និងសិប្បកម្ម |
| ៩ | អភិវឌ្ឍន៍ផ្នែកទេសចរណ៍ | មន្ទីរទេសចរណ៍ |
| ១០ | ការផ្គត់ផ្គង់ទឹកស្អាតជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ១១ | ការផ្គត់ផ្គង់ទឹកស្អាតទីក្រុង | មន្ទីរឧស្សាកម្ម និងសិប្បកម្ម |
| ១២ | អនាម័យជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ១៣ | ការអប់រំ | មន្ទីរអប់រំ យុវជន និងកីឡា |
| ១៤ | អប់រំមនុស្សពេញវ័យ | មន្ទីរអប់រំ យុវជន និងកីឡា |
| ១៥ | សុខាភិបាល | មន្ទីរសុខាភិបាល |
| ១៦ | វប្បធម៌ និងសាសនា | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ និងមន្ទីរធម្មការនិងកិច្ចការសាសនា |
| ១៧ | អន្តរាគមន៍ផ្នែកសង្គមកិច្ច | មន្ទីរសង្គមកិច្ចនិងអតីតយុទ្ធជននិងមន្ទីរកិច្ចការនារី |
| ១៨ | ការគ្រប់គ្រងបរិស្ថាន | មន្ទីរបរិស្ថាន |
| ១៩ | សហគមន៍ព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ២០ | សហគមន៍ជលផល | រដ្ឋបាលជលផល |
| ២១ | ការគ្រប់គ្រងសំណល់រឹង រាវ | មន្ទីរបរិស្ថាន |

**ឧទាហរណ៍ ÷**

| ប្រភេទ | សាងសង់ និងឧបករណ៍ | សេវាកម្ម | សហគមន៍គាំទ្រ |
|---|---|---|---|
| ការផ្គត់ផ្គង់ទឹកស្អាតជនបទ | អណ្តូងទឹក | ធ្វើតេស្តទឹក | ក្រុមប្រើប្រាស់ទឹក និងអនាម័យ |
| | បណ្តាញផ្គត់ផ្គង់ទឹក | | |
| | ស្រះ | | |
| ការផ្គត់ផ្គង់ទឹកស្អាតទីក្រុង | បណ្តាញផ្គត់ផ្គង់ទឹក | | |
| គមនាគមន៍ជនបទ | ផ្លូវ | | |
| | ស្ពាន | | |
| | លូ | | |
| | កំពង់ចម្លង | | |
| | សាឡាង ឬទូកចម្លង | | |
| គមនាគមន៍ទីប្រជុំជន | ផ្លូវកៅស៊ូ ផ្លូវបេតុង | | |
| | ភ្លើងសញ្ញាចរាចរណ៍ | | |
| | គំនូស និងស្លាកសញ្ញាចរាចរណ៍ | | |
| អប់រំ | អគារសិក្សា | ប្រាក់ឧបត្ថម្ភគ្រូបង្រៀន | គណៈកម្មការទ្រទ្រង់សាលា |

| ប្រភេទ | សាងសង់ និងឧបករណ៍ | សេវាកម្ម | សហគមន៍គាំទ្រ |
|---|---|---|---|
| | គ្រឿងសង្ហារិម | | |
| | អណ្តូងឬបណ្តាញផ្គត់ផ្គង់ទឹក | | |
| | បង្គន់អនាម័យ | | |
| អប់រំមនុស្សពេញវ័យ | | ថ្នាក់អក្ខរកម្ម | |
| សុខាភិបាល | មណ្ឌលសុខភាព | អប់រំផ្សព្វផ្សាយ ចំណេះដឹងអំពីអេដស៍ | |
| | ឧបករណ៍ និងបរិក្ខារ | ផ្គត់ផ្គង់ស្រោមអនាម័យ | |
| | អណ្តូងឬបណ្តាញផ្គត់ផ្គង់ទឹក | | |
| | បង្គន់អនាម័យ | | |
| កសិកម្ម | មណ្ឌលបណ្តុះបណ្តាលកសិករ | ពូជស្រូវ | សហគមន៍កសិករ |
| | | សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម | |
| វប្បធម៌និងសាសនា | ឧបករណ៍ភ្លេង | ការបង្រៀនភ្លេង | |
| គ្រប់គ្រងបរិស្ថាន | | សេវាបន្ថយសំលេង | |
| អន្តរាគមន៍ផ្នែកសង្គមកិច្ច | | ផ្សព្វផ្សាយអំពីការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ | |
| ធារាសាស្ត្រ | ទ្វារទឹក | ប្រេងសម្រាប់ម៉ាស៊ីនបូមទឹក | សហគមន៍កសិករប្រើប្រាស់ទឹក |
| ប្រព័ន្ធបង្ហូរទឹកស្អុយ | បណ្តាញលូបង្ហូរទឹកស្អុយ | | |
| | ប្រឡាយដោះទឹកភ្លៀង | | |
| | ស្ថានីយបូមទឹកស្អុយ | | |
| ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ | សំណង់ផ្សារ | សម្អាតទីផ្សារ | |
| | ផ្លូវជុំវិញផ្សារ | | |
| | ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | | |
| | បង្គន់អនាម័យ | | |
| ការគ្រប់គ្រងសំណល់រឹង រាវ | ទីលានចាក់សំរាម | សេវាប្រមូលសំរាម | |
| អគ្គិសនី | ប្រព័ន្ធបណ្តាញអគ្គិសនី | សេវាអគ្គិសនី | |
| អភិវឌ្ឍន៍ផ្នែកសិប្បកម្ម | | | សមាគមពាណិជ្ជករខ្នាតតូច |
| សហគមន៍ព្រៃឈើ | រៀបចំព្រំប្រទល់តំបន់ព្រៃឈើ | | |
| អភិវឌ្ឍន៍ផ្នែកទេសចរណ៍ | មណ្ឌលទេសចរណ៍ | | |

## ៦.៤. ការបំពេញទម្រង់ព័ត៌មានគម្រោង (ទម្រង់ទី៧)

| ព័ត៌មានគម្រោង | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |

### ផ្នែកទី១ ÷ ព័ត៌មានទូទៅ

| | | |
|---|---|---|
| ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក ក មកទីរួមខេត្ត | | |
| កាលបរិច្ឆេទបញ្ចប់ការសិក្សា ៖ ០៧/០២/២០១៤ | ឈ្មោះអ្នកជំនួយបច្ចេកទេស ៖ ប្រុស ហេង | ឋានៈអ្នកជំនួយបច្ចេកទេស ៖ មន្ត្រីទីចាត់ការផែនការ និងវិនិយោគ |
| ទិសដៅរបស់គម្រោង ៖ នៅដំណាច់ឆ្នាំ២០១៤ ប្រជាពលរដ្ឋមានផ្លូវល្អសម្រាប់ការធ្វើដំណើរពីស្រុក ក មកទីរួមខេត្ត។ | | |
| វិស័យ ឬផ្នែក ៖ សេដ្ឋកិច្ច | ប្រភេទគម្រោង ៖ គមនាគមន៍ជនបទ | |
| គម្រោងហេដ្ឋារចនាសម្ព័ន្ធ ☑ | គម្រោងសេវាកម្ម ☐ | គម្រោងផ្គត់ផ្គង់ទំនិញ ☐ |
| លទ្ធផលគ្រោង (ស្រង់ចេញពីកម្មវិធីវិនិយោគរាជធានី ខេត្ត) ផ្លូវ៣,៥០គម និងលូ៤កន្លែង។ | លទ្ធផលគ្រោងក្រោយពីសិក្សា ផ្លូវ៤,៥០គម និងលូ៥កន្លែង។ | |
| តម្លៃប៉ាន់ស្មានក្នុងកម្មវិធីវិនិយោគ ៖ ១៣០.០០០.០០០រៀល | តម្លៃប៉ាន់ស្មានក្រោយពីសិក្សា ៖ ២១៨.៣០២.៧៥៥រៀល | |

| ឆ្នាំ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| លទ្ធផលតាមឆ្នាំ | ផ្លូវ២គម និងលូ៣កន្លែង | ផ្លូវ១,៥គម និងលូ២កន្លែង | |
| តម្លៃប៉ាន់ស្មានតាមឆ្នាំ | ១២៥.២៩៨.៥០៣រៀល | ៩៣.០០៤.២៥២រៀល | |

### អ្នកទទួលផលពីគម្រោង

| ល.រ | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | ចំនួនអ្នកទទួលផល | | ចំនួនគ្រួសារ |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ១ | ភូមិ១ | ឃុំ ក១ | ស្រុក ក | ២.០០០ | ១.២០០ | ៥៣០ |
| ២ | ភូមិ២ | ឃុំ ក១ | ស្រុក ក | ១.៩០០ | ៨០០ | ៥០០ |
| ៣ | ភូមិ១ | ឃុំ ក២ | ស្រុក ក | ១.៥០០ | ៦០០ | ៣០០ |
| ៤ | ភូមិ២ | ឃុំ ក២ | ស្រុក ក | ១.៦០០ | ៧០០ | ៤០០ |
| សរុប | | | | ៧.០០០ | ៣.៣០០ | ១.៧៣០ |

### ផ្នែកទី២ ÷ ការទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការ និងការថែទាំ

| តើអ្នកណាទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង? | |
|---|---|
| មន្ទីរ អង្គភាពជំនាញ | |
| រដ្ឋបាលរាជធានី ខេត្ត | ✓ |
| ក្រុមប្រើប្រាស់ដែលមានស្រាប់ | |
| ក្រុមប្រើប្រាស់ដែលត្រូវបង្កើតមុនពេលចាប់ផ្តើមអនុវត្តគម្រោង | |

| | |
|---|---|
| ផ្នែកឯកជន | |
| .......... | |

**ផ្នែកទី៣ ÷ ផលប៉ះពាល់បរិស្ថាន**

| | | |
|---|---|---|
| ១ | តើទីតាំងគម្រោងស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថានដែរឬទេ? | ទេ |
| ២ | តើការអនុវត្តគម្រោងបណ្តាលឱ្យមានការប៉ះពាល់ខូចខាតដល់ទីកន្លែងណាមួយដែលមានសារៈសំខាន់ចំពោះបរិស្ថាន ឬទីតាំងវប្បធម៌ដែរឬទេ? (ឧទាហរណ៍ ៖ ព្រៃឈើ ឧទ្យាន សត្វព្រៃ ឬប្រាសាទ) | ទេ |
| ៣ | តើការអនុវត្តគម្រោងបណ្តាលឱ្យមានការប៉ះពាល់ខូចខាតដល់ប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋដែរឬទេ? | ទេ |
| ៤ | តើលទ្ធផលគម្រោង គឺជាខ្សែផ្លូវថ្មី? | បាទ |
| ៥ | តើលទ្ធផលគម្រោង គឺជាខ្សែទំនប់ ឬខ្សែប្រឡាយថ្មី ឬអាងស្តុកទឹកថ្មី (ប្រព័ន្ធធារាសាស្ត្រថ្មី)? | ទេ |
| ៦ | តើលទ្ធផលគម្រោង គឺជាខ្សែព្រែកជីកថ្មី សម្រាប់ធ្វើដំណើរផ្លូវទឹក ឬផ្គត់ផ្គង់ទឹកប្រើប្រាស់? | ទេ |

**កំណត់សម្គាល់ ÷**

- ខ្សែផ្លូវថ្មីមួយ មានន័យថា ជាផ្លូវមួយខ្សែ ឬផ្នែកមួយនៃផ្លូវដែលមិនមែនជាផ្លូវពីមុន ឬផ្នែកមួយនៃផ្លូវចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្សផ្លូវ ឬផ្លូវចាស់ដែលត្រូវបានពង្រីកទទឹងផ្លូវធំជាងមុនចាប់ពី២៥%ឡើងទៅ។
- ប្រព័ន្ធធារាសាស្ត្រថ្មី មានន័យថា ជាប្រព័ន្ធធារាសាស្ត្រ ឬផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រដែលមិនមែនជាប្រព័ន្ធធារាសាស្ត្រពីមុន ឬផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្ស។
- ព្រែកជីកថ្មី មានន័យថា ជាព្រែកជីក ឬផ្នែកមួយនៃព្រែកជីក ដែលមិនមែនជាព្រែកជីកពីមុន ឬផ្នែកមួយនៃព្រែកជីកចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្ស។
- ប្រសិនបើមានចម្លើយណាមួយចំពោះសំណួរទី១ ដល់សំណួរទី៦ ឆ្លើយថា “បាទ” នោះតម្រូវឱ្យមានការសិក្សាផលប៉ះពាល់បរិស្ថាន។

**ផ្នែកទី៤ ÷ ផលប៉ះពាល់ដីធ្លី**

ព័ត៌មានដែលផ្តល់នៅផ្នែកទី៤នេះ គឺផ្អែកតាមការអង្កេតដីធ្លីដោយមានការចូលរួមដែលបានបញ្ចប់នៅថ្ងៃទី..... ខែ....... ឆ្នាំ........*(យកថ្ងៃខែឆ្នាំនៃការប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង ឬយកថ្ងៃខែឆ្នាំនៃលិខិតរបស់អភិបាលរាជធានី ខេត្តដែលបញ្ជាក់អះអាងថា ដីនោះគឺជាដីសាធារណៈ)*។

លទ្ធផលគម្រោងនឹងត្រូវបានសាងសង់ ៖ (សូមជ្រើសរើសយកចម្លើយមួយ)

| | | |
|---|---|---|
| ១ | នៅលើដីសាធារណៈ ហើយមិនមានត្រូវបានប្រើប្រាស់ដោយឯកជន។ | |
| ២ | នៅលើដីមួយចំនួនដែលបច្ចុប្បន្នកំពុងប្រើប្រាស់ដោយឯកជន ហើយគ្រប់គ្រួសារដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង បានយល់ព្រមប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដោយស្ម័គ្រចិត្តដល់គម្រោង។ មិនមានអ្នកប្រើប្រាស់ដីណាមួយនឹងប្រគល់ដីធ្លីច្រើនជាង៥%នៃដីសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង១.០០០.០០០រៀលសម្រាប់គម្រោងនោះទេ។ | ✓ |

| | | |
|---|---|---|
| ៣ | នៅលើដីមួយចំនួនដែលបច្ចុប្បន្នកំពុងប្រើប្រាស់ដោយឯកជន ហើយគ្រួសារមួយចំនួនដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង មិនយល់ព្រម ប្រគល់ដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដល់គម្រោងដោយគ្មានសំណងទូទាត់។ មានអ្នកប្រើប្រាស់ដីធ្លីមួយចំនួននឹងប្រគល់ដីធ្លីច្រើនជាង៥%នៃដីសរុបរបស់ខ្លួន ឬទ្រព្យសម្បត្តិផ្សេងៗទៀតមានតម្លៃច្រើនជាង១.០០០.០០០រៀលសម្រាប់គម្រោង។ | |

**កំណត់សម្គាល់ ÷**

- ប្រសិនបើចម្លើយទី១ត្រូវបានជ្រើសរើស នោះមិនចាំបាច់រៀបចំរបាយការណ៍សិក្សាដីធ្លីទេ ប៉ុន្តែត្រូវមានលិខិតរបស់អភិបាលរាជធានី ខេត្តដែលបញ្ជាក់អះអាងថា ដីនោះគឺជាដីសាធារណៈ។
- ប្រសិនបើចម្លើយទី២ត្រូវបានជ្រើសរើស ត្រូវរៀបចំ**របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**។
- ប្រសិនបើចម្លើយទី៣ត្រូវបានជ្រើសរើស ត្រូវរៀបចំ**របាយការណ៍លទ្ធកម្មដីធ្លី**។

**ផ្នែកទី៥ ÷ វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច**

លទ្ធផលគម្រោង នឹងត្រូវបានសាងសង់ ៖ (សូមជ្រើសរើសយកចម្លើយមួយ)

| | | |
|---|---|---|
| ១ | នៅក្នុងភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៥% នៃប្រជាពលរដ្ឋសរុបនៅក្នុងភូមិ) | |
| ២ | នៅក្រៅភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច។ | ✓ |

**កំណត់សម្គាល់ ÷**

- ប្រសិនបើចម្លើយទី១ត្រូវបានជ្រើសរើស នោះចាំបាច់រៀបចំ**របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច**។
- ប្រសិនបើចម្លើយទី២ត្រូវបានជ្រើសរើស នោះមិនចាំបាច់រៀបចំ**របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច**ទេ។

**ផ្នែកទី៦ ÷ ការពិនិត្យឡើងវិញមុនចុះហត្ថលេខា**

៦.១. តើមានហេតុផលណាដែលបណ្តាលឱ្យគម្រោងនេះ មិនទទួលបានជោគជ័យដែរឬទេ? (ចម្លើយរបស់អ្នកជំនួយបច្ចេកទេស)

*១. ត្រូវបញ្ចូលលទ្ធផលគម្រោងដែលនៅសល់(ផ្លូវ២គ.ម និងលូ២កន្លែង)ទៅក្នុងកម្មវិធីវិនិយោគឆ្នាំបន្ទាប់។*

*២. ពេលខ្លះមានរថយន្តធំៗប្រើប្រាស់ផ្លូវនេះ ខេត្តត្រូវត្រួតពិនិត្យចរាចរណ៍ និងបង្ការកុំឱ្យរថយន្តធំៗប្រើប្រាស់ ឬបំផ្លាញផ្លូវ។*

៦.២. តើការសិក្សាព័ត៌មានគម្រោង ត្រូវបានផ្តល់ទាំងអស់ដែរឬទេ?

| លរ | ព័ត៌មាន | ពិនិត្យដោយគណៈកម្មការរៀបចំគម្រោង |
|---|---|---|
| ១ | ទិសដៅ | ✓ |
| ២ | វិស័យ ឬផ្នែក | ✓ |
| ៣ | ប្រភេទគម្រោង | ✓ |
| ៤ | អ្នកទទួលផលពីគម្រោង | ✓ |

| | | |
|---|---|---|
| ៥ | ផែនទីគម្រោង | ✓ |
| ៦ | ព័ត៌មានបច្ចេកទេស (អាស្រ័យនឹងប្រភេទគម្រោង) | ✓ |
| ៧ | គំនូសប្លង់បច្ចេកទេស | ✓ |
| ៨ | តម្លៃប៉ាន់ស្មានគម្រោងលម្អិត | ✓ |
| ៩ | លទ្ធផលគម្រោង និងតម្លៃប៉ាន់ស្មានគម្រោង | ✓ |
| ១០ | ទីតាំងលទ្ធផលគម្រោង | ✓ |
| ១១ | ផែនការប្រតិបត្តិការ និងការថែទាំ | ✓ |
| ១២ | របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត | ✓ |
| ១៣ | របាយការណ៍លទ្ធកម្មដីធ្លី | មិនត្រូវការ |
| ១៤ | របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន | ✓ |
| ១៥ | របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច | មិនត្រូវការ |

| | | |
|---|---|---|
| ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ | ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ | ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ |
| **អភិបាលរាជធានី ខេត្ត** | **នាយកទីចាត់ការផែនការ និងវិនិយោគ** | **អ្នកជំនួយបច្ចេកទេស** |

# ជំពូកទី៧
# គោលការណ៍ណែនាំស្តីពីការគណនាតម្លៃប៉ាន់ស្មានគម្រោង

# ជំពូកទី៧
# គោលការណ៍ណែនាំស្តីពីការគណនាតម្លៃប៉ាន់ស្មានគម្រោង

## ៧.១. ការប៉ាន់ស្មានតម្លៃគម្រោង

បន្ទាប់ពីគណៈកម្មការរៀបចំគម្រោងព្រមព្រៀងទៅលើគ្រោងការគម្រោង ជំហានបន្ទាប់ គឺការប៉ាន់ស្មានតម្លៃគម្រោង។

ការប៉ាន់ស្មានតម្លៃគម្រោងត្រូវធ្វើឡើងដោយមានតម្លាភាព និងអាចជឿទុកចិត្តបាន។ តម្លៃប៉ាន់ស្មានគម្រោងត្រូវតែគណនាដោយប្រើប្រាស់វិធីសាស្ត្រដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំនេះ។ អ្នកជំនួយបច្ចេកទេសមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់វិធីសាស្ត្រផ្សេងពីនេះឡើយ។

អ្នកជំនួយបច្ចេកទេសជាអ្នករៀបចំប៉ាន់ស្មានតម្លៃគម្រោង ហើយគណៈកម្មការរៀបចំគម្រោងជាអ្នកពិនិត្យ និងអនុម័តទៅលើតម្លៃប៉ាន់ស្មាននេះ។ បើគិតថាតម្លៃប៉ាន់ស្មាននេះមិនត្រឹមត្រូវ គណៈកម្មការរៀបចំគម្រោងមិនត្រូវទទួលយកតម្លៃប៉ាន់ស្មាននេះឡើយ។ ក្នុងករណីនេះ គណៈកម្មការរៀបចំគម្រោងអាច ៖

- ប្រៀបធៀបតម្លៃក្នុងបញ្ជីសម្ភារៈជាមួយនឹងតម្លៃជាក់ស្តែងនៅលើទីផ្សារ។
- ប្រៀបធៀបតម្លៃប៉ាន់ស្មានជាមួយនឹងតម្លៃជាក់ស្តែងនៃគម្រោងប្រហាក់ប្រហែលគ្នានេះ (អ្នកជំនួយបច្ចេកទេសត្រូវផ្តល់បញ្ជីតម្លៃទាំងនេះដល់គណៈកម្មការរៀបចំគម្រោង)។
- ស្នើសុំវិស្វករឯកជនឱ្យជួយពិនិត្យតម្លៃ។

## ៧.២. តម្លៃផ្ទាល់ តម្លៃប្រយោល និងប្រាក់ចំណេញ

| តម្លៃប៉ាន់ស្មាន = តម្លៃផ្ទាល់ + តម្លៃប្រយោល + ប្រាក់ចំណេញ |
|---|

### ក). តម្លៃផ្ទាល់

តម្លៃផ្ទាល់ គឺជាតម្លៃដែលអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ត្រូវចំណាយដើម្បីអនុវត្តគម្រោង។ តម្លៃផ្ទាល់មាន ៖

- តម្លៃសម្ភារៈ ឧទាហរណ៍ ស៊ីម៉ង់ត៍ ខ្សាច់ និងថ្ម ដើម្បីធ្វើបេតុង
- តម្លៃសម្ភារៈដែលបាត់បង់ ឧទាហរណ៍ ក្តារពុម្ព ស៊ីម៉ង់ត៍ដែលកំពប់លើដី កំណាត់ដែកខ្លីៗ
- តម្លៃពលកម្ម
- តម្លៃឧបករណ៍ ឧទាហរណ៍ តម្លៃប្រើប្រាស់ម៉ាស៊ីនលាយបេតុង
- តម្លៃដឹកជញ្ជូន។

### ខ). តម្លៃប្រយោល

តម្លៃប្រយោល គឺជាតម្លៃដែលអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ត្រូវចំណាយដើម្បីធ្វើជាអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ប៉ុន្តែមិនមែនជាលទ្ធផលផ្ទាល់ពីគម្រោងទេ។

ឧទាហរណ៍ តម្លៃប្រយោលរួមមាន ៖

- តម្លៃសម្រាប់ការិយាល័យរបស់អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម។
- តម្លៃសម្រាប់បុគ្គលិកអចិន្ត្រៃយ៍ (អ្នកដែលត្រូវបើកលុយជាទៀងទាត់ ទោះបីជាក្រុមហ៊ុនមិនមានការងារធ្វើក៏ដោយ)។

- តម្លៃប្រើប្រាស់រថយន្តរបស់អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ឧទាហរណ៍ តម្លៃសម្រាប់ធ្វើដំណើរទៅចូលរួមប្រជុំដេញថ្លៃ។
- ការប្រាក់ដែលអ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មបានខ្ចី។
- ថ្លៃពន្ធទាក់ទងនឹងការធ្វើអាជីវកម្មនានា។

**ត). ប្រាក់ចំណេញ**

បើអ្នកទទួលការសំណង់ឬអ្នកផ្តល់សេវាកម្មអនុវត្តគម្រោងទៅតាមកិច្ចសន្យា អ្នកទទួលការសំណង់ឬអ្នកផ្តល់សេវាកម្មត្រូវទទួលបានប្រាក់ចំណេញ។ ដូច្នេះ ចំនួនភាគរយនៃប្រាក់ចំណេញសម្រាប់អ្នកទទួលការសំណង់ឬអ្នកផ្តល់សេវាកម្មត្រូវបញ្ចូលទៅក្នុងតម្លៃប៉ាន់ស្មានគម្រោង។

**ឃ). ជំហានានាក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង**

នៅក្នុងគម្រោងរាជធានី ខេត្ត លទ្ធផលមួយត្រូវបានកំណត់ជាប្រភេទរបស់មួយ នៅក្នុងភូមិមួយ។

**ឧទាហរណ៍ ៖**

- លូពីរកន្លែងដែលមានទំហំដូចគ្នានៅក្នុងភូមិ "ក" គឺជាលទ្ធផលមួយ
- លូមួយកន្លែងនៅក្នុងភូមិ "ក" ហើយលូមួយកន្លែងទៀតនៅក្នុងភូមិ "ខ" គឺជាលទ្ធផលពីរ
- លូពីរកន្លែងដែលមានទំហំខុសគ្នានៅក្នុងភូមិ "ក" គឺជាលទ្ធផលពីរ។

នៅក្នុងទម្រង់ការប៉ាន់ស្មានតម្លៃលម្អិត ត្រូវសរសេរ ៖

- ឈ្មោះភូមិ ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ
- ការពិពណ៌នាអំពីលទ្ធផល
- បរិមាណ (ឬចំនួន) និងឯកតាលទ្ធផល។

**ជំហានទី១ ៖ គណនាតម្លៃផ្ទាល់នៃប្រភេទលទ្ធផលនីមួយៗ**

ចំពោះលទ្ធផលមួយចំនួន ដូចជាអណ្តូងទឹក ស្រះ ស្ពាន លូ ទ្វារទឹក ផ្លូវបង្ហៀរ និងមណ្ឌលសុខភាព ជាដំបូងត្រូវគណនាតម្លៃក្នុងមួយឯកតានៃលទ្ធផល ហើយបន្ទាប់មក យកតម្លៃមួយឯកតានោះ *គុណនឹង* បរិមាណនៃលទ្ធផល ដើម្បីទទួលបានតម្លៃសរុបនៃលទ្ធផលទាំងអស់ ។

ចំពោះលទ្ធផលមួយចំនួន ដូចជាផ្លូវ ទំនប់ ប្រឡាយ និងសាលារៀន ត្រូវគណនាតម្លៃនៃលទ្ធផលទាំងមូល។

**ជំហានទី២ ៖ គណនាតម្លៃប្រយោល និងប្រាក់ចំណេញនៃប្រភេទលទ្ធផលនីមួយៗ**

ដោយសារតែយើងមិនអាចដឹងបាននូវតម្លៃប្រយោលពិតប្រាកដ ដូច្នេះយើងគណនាតម្លៃប្រយោល និងប្រាក់ចំណេញតាមរយៈការគណនាជាភាគរយនៃតម្លៃផ្ទាល់នៃប្រភេទលទ្ធផលនីមួយៗ។ ជាអនុសាសន៍សម្រាប់ការគណនាតម្លៃប្រយោល និងប្រាក់ចំណេញ គឺយកតម្លៃផ្ទាល់នៃប្រភេទលទ្ធផលនីមួយៗ *គុណនឹង* ១០%។

| |
|---|
| **តម្លៃប្រយោលនិងប្រាក់ចំណេញ = តម្លៃផ្ទាល់នៃប្រភេទលទ្ធផលនីមួយៗ X ១០%** |

ដូច្នេះ:

| |
|---|
| **តម្លៃសរុបនៃប្រភេទលទ្ធផលនីមួយៗ = តម្លៃផ្ទាល់នៃប្រភេទលទ្ធផលនីមួយៗ + តម្លៃប្រយោលនិងប្រាក់ចំណេញនៃប្រភេទលទ្ធផលនីមួយៗ** |

**ជំហានទី៣ ៖ គណនាតម្លៃសរុបនៃគម្រោង**

បន្ទាប់ពីគណនាតម្លៃសរុបនៃប្រភេទលទ្ធផលនីមួយៗ ជំហានបន្ទាប់ ត្រូវគណនាតម្លៃសរុបនៃគម្រោងទាំងមូល។ តម្លៃសរុបនៃគម្រោងទាំងមូល គឺជាផលបូករវាងតម្លៃសរុបរបស់ប្រភេទលទ្ធផលនីមួយៗ នៃប្រភេទលទ្ធផលទាំងអស់របស់គម្រោង។

| |
|---|
| **តម្លៃសរុបរបស់គម្រោង = ផលបូករវាងតម្លៃសរុបរបស់ប្រភេទលទ្ធផលនីមួយៗ នៃប្រភេទលទ្ធផលទាំងអស់របស់គម្រោង** |

## ៧.៣. ការគណនាតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ

ការងារនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ មានពីរប្រភេទ គឺការងារសំណង់ និងការងារដី។ នីតិវិធីក្នុងការគណនាតម្លៃប៉ាន់ស្មាននៃការងារសំណង់ និងការងារដីមានលក្ខណៈខុសគ្នា។

ចំពោះការងារសំណង់ ដូចជាសំណង់សាលារៀន លូ ស្ពាន និងអគារផ្សេងៗ ជាធម្មតាផ្នែកដែលថ្លៃជាងគេ គឺសម្ភារៈ (ឧទាហរណ៍ ខ្សាច់ ថ្ម ដែក និងស៊ីម៉ង់ត៍)។

ចំពោះការងារដី ដូចជាការស្ថាបនាផ្លូវដី ផ្លូវក្រួសក្រហម និងទំនប់ជាដើម សម្ភារៈ (ឧទាហរណ៍ ដីក្រួសក្រហម) មិនសូវជាថ្លៃទេ។ ជាធម្មតា ផ្នែកដែលថ្លៃជាងគេ ចំពោះការងារដី រួមមាន ៖

- តម្លៃដឹកជញ្ជូន បើក្រួសក្រហម ឬដី ត្រូវបានដឹកជញ្ជូនទៅការដ្ឋាន
- តម្លៃគ្រឿងចក្រ បើគម្រោងអនុវត្តដោយប្រើប្រាស់គ្រឿងចក្រ សម្រាប់ការងារដី ដូចជាប្រើគ្រឿងចក្រក្នុងការជីក កៀរ ស្រោចទឹក និងកិនបង្ហាប់ជាដើម
- តម្លៃពលកម្ម បើគម្រោងអនុវត្តដោយប្រើប្រាស់កម្លាំងពលកម្ម។

### ៧.៣.១. ការគណនាតម្លៃប៉ាន់ស្មានសម្រាប់ការងារសំណង់

**ជំហានទី១ ៖ គណនាបរិមាណការងារសំណង់នីមួយៗ ក្នុងមួយឯកតានៃលទ្ធផល**

បរិមាណការងារសំណង់ គឺជាទំហំការងារ ដែលត្រូវការជាចាំបាច់សម្រាប់ស្ថាបនាឱ្យបាននូវលទ្ធផលមួយ (ឬសំណង់មួយ)។

ប្រសិនបើប្រើប្រាស់គំនូសប្លង់បច្ចេកទេសពីសៀវភៅណែនាំស្ដីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប បរិមាណការងារសំណង់នីមួយៗ ត្រូវបានបង្ហាញជាតារាងនៅលើគំនូសប្លង់បច្ចេកទេស។

ឧទាហរណ៍ បរិមាណការងារសម្រាប់សាងសង់លូទោល០១កន្លែងដែលមានប្រវែង៥ម៉ែត្រ និងមានអង្កត់ផ្ចិត០,៨ម៉ែត្រ គឺ ៖

- ការងារបេតុងឡប់ឡៃ(១:៣:៦ ) ១,៤ម$^{៣}$
- ការងារបេតុង(១:២:៤ ) ៣,៤ម$^{៣}$
- ការងារឡើងក្ដារពុម្ព ១៨ម$^{២}$
- ការងារជីកដីធ្វើគ្រឹះ ៧ម$^{៣}$

**ជំហានទី២ ៖ គណនាបរិមាណសម្ភារៈ និងកម្លាំងពលកម្មសម្រាប់ការងារសំណង់នីមួយៗ**

បរិមាណសម្ភារៈ និងកម្លាំងពលកម្មសម្រាប់ការងារសំណង់នីមួយៗ គឺជាចំនួនសម្ភារៈ និងកម្លាំងពលកម្ម ដែលត្រូវការជាចាំបាច់សម្រាប់ស្ថាបនាឱ្យបាននូវលទ្ធផលមួយ (ឬសំណង់មួយ)។

តារាងបរិមាណសម្ភារៈ និងកម្លាំងពលកម្ម មាននៅក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប។

**ឧទាហរណ៍ទី១ ៖ បេតុង១ម³ (១:២:៤) គឺ ៖**

១). **សម្ភារៈ**

- ស៊ីម៉ង់ត៍ ៖ ៣២៥គ.ក្រ
- ខ្សាច់ ៖ 0,៤៣ម³
- ថ្ម ៖ 0,៨៦ម³

២). **កម្លាំងពលកម្ម**

- មានជំនាញ ៖ 0,១នាក់/ថ្ងៃ
- មានជំនាញខ្លះៗ ៖ ១នាក់/ថ្ងៃ
- គ្មានជំនាញ ៖ ៤នាក់/ថ្ងៃ

**ឧទាហរណ៍ទី២ ៖ ដែក១តោន (១.000គ.ក្រ)**

១). **សម្ភារៈ**

- ដែក ៖ ១.១00គ.ក្រ
- ខ្សែលួសចំណង ៖ ៥គ.ក្រ

២). **កម្លាំងពលកម្ម**

- មានជំនាញ ៖ ១នាក់/ថ្ងៃ
- មានជំនាញខ្លះៗ ៖ ១នាក់/ថ្ងៃ
- គ្មានជំនាញ ៖ ៦នាក់/ថ្ងៃ

**ឧទាហរណ៍ទី៣ ៖ ១ម²នៃការងារឡើងក្តារពុម្ព**

១). **សម្ភារៈ**

- ឈើ ៖ 0,0១ម³
- ដែកគោល ៖ 0,១២គ.ក្រ

២). **កម្លាំងពលកម្ម**

- មានជំនាញ ៖ 0,១នាក់/ថ្ងៃ
- មានជំនាញខ្លះៗ ៖ 0,២៥នាក់/ថ្ងៃ
- គ្មានជំនាញ ៖ 0,0៥នាក់/ថ្ងៃ

**ជំហានទី៣ ៖ គណនាតម្លៃសម្ភារៈ និងកម្លាំងពលកម្ម**

ការគណនាតម្លៃសម្ភារៈ ត្រូវអនុវត្តដូចខាងក្រោម ៖

- កំណត់រកតម្លៃឯកតានៃប្រភេទសម្ភារៈនីមួយៗ (តម្លៃឯកតានៃប្រភេទសម្ភារៈនីមួយៗ ស្រង់ចេញពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ)
- គណនាតម្លៃនៃប្រភេទសម្ភារៈនីមួយៗ។ តម្លៃនៃប្រភេទសម្ភារៈនីមួយៗ គឺជាលទ្ធផលនៃផលគុណរវាងបរិមាណនៃប្រភេទសម្ភារៈនីមួយៗ និងតម្លៃឯកតា

**តម្លៃនៃប្រភេទសម្ភារៈនីមួយៗ = បរិមាណនៃប្រភេទសម្ភារៈនីមួយៗ x តម្លៃឯកតា**

- គណនាតម្លៃសម្ភារៈសរុប។ តម្លៃសម្ភារៈសរុប គឺជាលទ្ធផលនៃផលបូកនៃតម្លៃរបស់ប្រភេទសម្ភារៈនីមួយៗ

| **តម្លៃសម្ភារៈសរុប = ផលបូកនៃតម្លៃរបស់ប្រភេទសម្ភារៈនីមួយៗ** |
|---|

ការគណនាតម្លៃកម្លាំងពលកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

- កំណត់រកតម្លៃឯកតានៃប្រភេទកម្លាំងពលកម្មនីមួយៗ (តម្លៃឯកតានៃប្រភេទកម្លាំងពលកម្មនីមួយៗ ស្រង់ចេញពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ)
- គណនាតម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ។ តម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ គឺជាលទ្ធផលនៃផលគុណរវាងបរិមាណនៃប្រភេទកម្លាំងពលកម្មនីមួយៗ និងតម្លៃឯកតា

| **តម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ = បរិមាណនៃប្រភេទកម្លាំងពលកម្មនីមួយៗ x តម្លៃឯកតា** |
|---|

- គណនាតម្លៃកម្លាំងពលកម្មសរុប។ តម្លៃកម្លាំងពលកម្មសរុប គឺជាលទ្ធផលនៃផលបូកនៃតម្លៃរបស់ប្រភេទកម្លាំងពលកម្មនីមួយៗ

| **តម្លៃកម្លាំងពលកម្មសរុប = ផលបូកនៃតម្លៃរបស់ប្រភេទកម្លាំងពលកម្មនីមួយៗ** |
|---|

**ជំហានទី៤ ៖ គណនាតម្លៃដឹកជញ្ជូន**

ការគណនាតម្លៃដឹកជញ្ជូន ត្រូវអនុវត្តដូចខាងក្រោម ៖

- គណនាតម្លៃឯកតា។ តម្លៃឯកតា គឺជាតម្លៃនៃការដឹកជញ្ជូនសម្ភារៈទម្ងន់មួយតោនក្នុងចម្ងាយផ្លូវមួយគីឡូម៉ែត្រ (តម្លៃឯកតា ស្រង់ចេញពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ)
- គណនាតម្លៃ T។ តម្លៃ T គឺជាលទ្ធផលនៃផលគុណរវាងចម្ងាយផ្លូវដឹកជញ្ជូនសម្ភារៈ (ចម្ងាយផ្លូវពីទីផ្សារទៅការដ្ឋាន) និងតម្លៃឯកតា

| **តម្លៃ T = ចម្ងាយផ្លូវដឹកជញ្ជូនសម្ភារៈ x តម្លៃឯកតា** |
|---|

- គណនាតម្លៃដឹកជញ្ជូនសរុប។ តម្លៃដឹកជញ្ជូនសរុប គឺជាលទ្ធផលនៃផលគុណរវាងទម្ងន់សម្ភារៈសរុប និងតម្លៃ T

| **តម្លៃដឹកជញ្ជូនសរុប = ទម្ងន់សម្ភារៈសរុប x តម្លៃ T** |
|---|

ឧទាហរណ៍ តម្លៃប្រេងម៉ាសូត១លីត្រ ស្មើនឹង៥.០០០រៀល **នោះតម្លៃឯកតា**(តម្លៃដឹកជញ្ជូនសម្ភារៈទម្ងន់មួយតោនក្នុងចម្ងាយផ្លូវមួយគីឡូម៉ែត្រ) មានដូចខាងក្រោម ៖

| **ល.រ** | **ស្ថានភាពផ្លូវ** | **តម្លៃដឹកជញ្ជូនក្នុង១តោន ក្នុង១គ.ម (រៀល)** | | | |
|---|---|---|---|---|---|
| | | **តិចជាង២០គ.ម** | **២០-៣៥គ.ម** | **៣៥-៥០គ.ម** | **ច្រើនជាង៥០គ.ម** |
| ១ | ស្ថានភាពផ្លូវល្អ (ល្បឿនមធ្យម ៥០គ.ម/ម៉) | ៧០០ | ៦៥០ | ៦០០ | ៥៥០ |
| ២ | ស្ថានភាពផ្លូវមធ្យម (ល្បឿនមធ្យម ២៥គ.ម/ម៉) | ១.១៥០ | ១.១០០ | ១.០០០ | ៩៥០ |
| ៣ | ស្ថានភាពផ្លូវលំបាក (ល្បឿនមធ្យម ១៥គ.ម/ម៉) | ១.៤៥០ | ១.៣៥០ | ១.៣០០ | ១.២០០ |

ឧទាហរណ៍ ៖ ទីតាំងគម្រោងមានចម្ងាយប្រវែង១០គ.ម ពីផ្សារ ហើយផ្លូវមានស្ថានភាពមធ្យម។ តម្លៃដឹកជញ្ជូនសម្ភារៈទម្ងន់១តោន ក្នុង១គ.ម គឺ ១.១៥០រ/តោន/គ.ម (ដកស្រង់ពីតារាងខាងលើ)។

តម្លៃ T នៃគម្រោងនេះ = ១.១៥០រ/តោន/គ.ម x ១០គ.ម = ១១.៥០០រ/តោន។

ទម្ងន់សម្ភារៈសរុបសម្រាប់គម្រោងនេះ គឺ ១៧,៦០តោន

ដូច្នេះ តម្លៃដឹកជញ្ជូន គឺ ១១.៥០០រ/តោន x ១៧,៦០តោន = ២០២.៤០០រ។

ទោះបីជាយ៉ាងដូច្នេះក៏ដោយ ចំពោះរាជធានី ខេត្តមួយចំនួនអាចមានតម្លៃពិសេសដែលត្រូវពិចារណាបន្ថែម។ ឧទាហរណ៍ ដូចជាថ្លៃឆ្លងសាឡាង ឬថ្លៃប្រើប្រាស់ផ្លូវ។ តម្លៃទាំងនេះត្រូវតែបូកបន្ថែមទៅនឹងតម្លៃ T សម្រាប់រាជធានី ខេត្តទាំងនោះ។

**ជំហានទី៥ ៖ គណនាតម្លៃឧបករណ៍តូចតាច**

ឧបករណ៍តូចតាច រួមមានដូចជាចប ប៉ែល បង្គី ស្លាបព្រាបាយអ ប្រដាប់លាយស៊ីម៉ង់ត៍...។ល។)។ តម្លៃឧបករណ៍តូចតាច ស្មើនឹងតម្លៃពលកម្ម *គុណនឹង* ៣%។

| |
|---|
| **តម្លៃឧបករណ៍តូចតាច = តម្លៃពលកម្ម X ៣%** |

| |
|---|
| **តម្លៃផ្ទាល់ = តម្លៃសម្ភារៈនិងពលកម្ម + តម្លៃដឹកជញ្ជូន + តម្លៃឧបករណ៍តូចតាច** |

**ជំហានទី៦ ៖ គណនាតម្លៃប្រយោល និងប្រាក់ចំណេញ**

តម្លៃប្រយោល និងប្រាក់ចំណេញ ស្មើនឹងតម្លៃផ្ទាល់ *គុណនឹង* ១០%។

| |
|---|
| **តម្លៃប្រយោល និងប្រាក់ចំណេញ = តម្លៃផ្ទាល់ X ១០%** |

ដូច្នេះ:

| |
|---|
| **តម្លៃសរុប = តម្លៃផ្ទាល់ + តម្លៃប្រយោលនិងប្រាក់ចំណេញ** |

**ជំហានទី៧ ៖ គណនាតម្លៃសរុបសម្រាប់លទ្ធផលទាំងមូល**

តម្លៃសរុបសម្រាប់លទ្ធផលទាំងមូល ស្មើនឹងតម្លៃសរុបក្នុងមួយឯកតា *គុណនឹង* ចំនួនលទ្ធផល។ ឧទាហរណ៍ ប្រសិនបើលទ្ធផល គឺជាលូ៣កន្លែង តម្លៃសរុបសម្រាប់លទ្ធផលទាំងមូល ស្មើនឹងតម្លៃសរុបសម្រាប់លូមួយកន្លែង គុណនឹង ៣។

## ឧទាហរណ៍ ៖ ការប៉ាន់ស្មានតម្លៃលម្អិត (ឧម្រង់ទី៨)

| ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលសំណង់ | | | | | |
|---|---|---|---|---|---|
| រាជធានី ខេត្ត ៖ *កំពង់ចាម* | | | លេខកូដរាជធានី ខេត្ត ៖ | | |
| ឈ្មោះគម្រោង ៖ *គម្រោងសាងសង់ផ្លូវដីសពីទីរួមស្រុក.ក. មកទីរួមខេត្ត* | | | | | |
| ការពិពណ៌នាលទ្ធផលគម្រោង ៖ *លូទោលមានអង្កត់ផ្ចិត០,៨ម និងប្រវែងបណ្តោយ៧ម៉ែត្រ ចំនួន៣កន្លែង។* | | | | | |
| ទីតាំងលទ្ធផលគម្រោង ៖ *ភូមិ១ និងភូមិ២ នៃឃុំក១ ស្រុក.ក.* | | | | | |
| **ការប៉ាន់ស្មានតម្លៃសម្រាប់មួយឯកតានៃលទ្ធផល** | | | | | |
| **លរ** | **ការពិពណ៌នា** | **ឯកតា** | **ចំនួន** | **តម្លៃឯកតា (៛)** | **សរុប (៛)** |
| ១ | *ស៊ីម៉ងត៍* | *បាវ* | ២១ | ២០.៥០០ | ៤៣០.៥០០ |
| ២ | *ខ្សាច់* | *ម$^{៣}$* | ២,៩០ | ៣០.០០០ | ៨៧.០០០ |
| ៣ | *ដែក* | *គក្រ* | ៤៨ | ៥.០០០ | ២៤០.០០០ |
| ៤ | *ថ្ម (១០ X២០)* | *ម$^{៣}$* | ៣,៣០ | ១៤០.០០០ | ៤៦២.០០០ |
| ៥ | *ថ្ម (២០ X៤០)* | *ម$^{៣}$* | ១,៦០ | ៨០.០០០ | ១២៨.០០០ |
| ៦ | *លូដែលមានអង្កត់ផ្ចិត៨០០មម* | *កង់* | ៧ | ១២០.០០០ | ៨៤០.០០០ |
| ៧ | *ក្តារពុម្ព* | *ម$^{២}$* | ២០ | ១៦.០០០ | ៣២០.០០០ |
| ៨ | *ដែកគោល* | *គក្រ* | ០,២០ | ៦.៨០០ | ១.៣៦០ |
| ៩ | *ខ្សែលួស* | *គក្រ* | ០,៤០ | ៦.៥០០ | ២.៦០០ |
| | តម្លៃដឹកជញ្ជូនសម្ភារៈទៅការដ្ឋាន | តោន | ១៧,៦០ | ១១.៥០០ | ២០២.៤០០ |
| | តម្លៃដឹកជញ្ជូនបរិក្ខារពីការដ្ឋាន | តោន | ១,២០ | ១១.៥០០ | ១៣.៨០០ |
| | ពលកម្មគ្មានជំនាញ | នាក់ថ្ងៃ | ៣៦ | ១៥.០០០ | ៥៤០.០០០ |
| | ពលកម្មមានជំនាញខ្លះ | នាក់ថ្ងៃ | ៨ | ២០.០០០ | ១៦០.០០០ |
| | ពលកម្មជំនាញ | នាក់ថ្ងៃ | ៣ | ២៥.០០០ | ៧៥.០០០ |
| | ឧបករណ៍តូចតាច (%នៃតម្លៃកម្លាំងពលកម្ម) | | | ៣% | ២៣.២៥០ |
| តម្លៃផ្ទាល់សរុប | | | | | ៣.៥២៥.៩១០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ៣៥២.៥៩១ |
| **តម្លៃសរុប** | | | | | ៣.៨៧៨.៥០១ |

| តម្លៃលទ្ធផលទាំងមូល | | | | |
|---|---|---|---|---|
| **ការពិពណ៌នា** | **ឯកតា** | **ចំនួន** | **តម្លៃឯកតា (រៀល)** | **សរុប (រៀល)** |
| *លូទោល* | *កន្លែង* | ៣ | ៣.៨៧៨.៥០១ | ១១.៦៣៥.៥០៣ |

| | |
|---|---|
| ឈ្មោះផ្សារ ៖ *ផ្សារ .ក.* | ចម្ងាយផ្លូវដឹកជញ្ជូន ៖ *១០គម (ស្ថានភាពផ្លូវមធ្យម)* |

ថ្ងៃទី...... ខែ......... ឆ្នាំ....... ថ្ងៃទី...... ខែ......... ឆ្នាំ....... ថ្ងៃទី...... ខែ......... ឆ្នាំ.......

**អភិបាលរាជធានី ខេត្ត** **នាយកទីចាត់ការផែនការ និងវិនិយោគ** **អ្នកជំនួយបច្ចេកទេស**

### ៧.៣.២. ការគណនាតម្លៃប៉ាន់ស្មានសម្រាប់ការងារដី

**ជំហានទី១ ៖ គណនាតម្លៃឯកតាការងារដី**

**១). ការងារធ្វើដោយគ្រឿងចក្រ**

ការងារដីមិនមែនជារបស់ដែលអាចទិញនៅទីផ្សារបាននោះទេ។ តម្លៃមួយភាគធំនៃការងារដី គឺជាតម្លៃសម្រាប់ប្រតិបត្តិការគ្រឿងយន្ត។ នីតិវិធីគណនាតម្លៃស្តង់ដារនៃការងារដី មានបរិយាយនៅជំពូកទី៥។

ឧទាហរណ៍ តម្លៃប្រេងម៉ាសូត១លីត្រ ស្មើនឹង៥.០០០រៀល នោះតម្លៃឯកតានៃការដឹកជញ្ជូនដី ឬក្រួសក្រហមក្នុង១ម³ក្នុងចម្ងាយផ្លូវ១គ.ម មានដូចខាងក្រោម ៖

| ល.រ | ស្ថានភាពផ្លូវ | តម្លៃដឹកជញ្ជូនក្នុង១ម³ក្នុង១គ.ម (រៀល) | | | |
|---|---|---|---|---|---|
| | | តិចជាង២០គ.ម | ២០-៣៥គ.ម | ៣៥-៥០គ.ម | ច្រើនជាង៥០គ.ម |
| ១ | ស្ថានភាពផ្លូវល្អ (ល្បឿនមធ្យម ៥០គ.ម/ម៉) | ៣៥០ | ៣២៥ | ៣០៥ | ២៨៥ |
| ២ | ស្ថានភាពផ្លូវមធ្យម (ល្បឿនមធ្យម ២៥គ.ម/ម៉) | ៥៥០ | ៥១៥ | ៤៨៥ | ៤៥៥ |
| ៣ | ស្ថានភាពផ្លូវលំបាក (ល្បឿនមធ្យម ១៥គ.ម/ម៉) | ៧០០ | ៦៦០ | ៦២៥ | ៥៩០ |

**តម្លៃឯកតានៃការឈូសសម្អាតទីតាំងក្នុង១ម² ៖**

| ល.រ | ស្ថានភាពទីតាំង | តម្លៃសម្អាតដីក្នុង១ម² (រៀល) |
|---|---|---|
| ១ | **ងាយស្រួល ៖** ផ្ទៃលើនៃផ្លូវដែលមានស្រាប់មានសភាពមិនរាបស្មើ គ្មានគុម្ពោតព្រៃ គ្មានដើមឈើនៅសងខាងផ្លូវ | ៩០ |
| ២ | **មធ្យម ៖** ផ្ទៃលើនៃផ្លូវដែលមានស្រាប់មានសភាពមិនរាបស្មើនិងតូចចង្អៀត មានគុម្ពោតព្រៃ ព្រៃឫស្សី និងមានដើមឈើនៅសងខាងផ្លូវ។ | ១៨០ |
| ៣ | **លំបាក ៖** មិនមែនជាផ្លូវដែលមានស្រាប់ មានគុម្ពោតព្រៃ ព្រៃឫស្សី និងមានដើមឈើច្រើន។ | ៦៣០ |

**តម្លៃឯកតានៃការជីកដីក្នុង១ម³ ៖**

| ល.រ | ស្ថានភាពដី | ការជីកដីក្នុង១ម³ (រៀល) |
|---|---|---|
| ១ | **ងាយស្រួល ៖** ដីធម្មជាតិគ្មានថ្ម និងក្រួសល្អិតៗ។ | ២.៥៥០ |
| ២ | **មធ្យម ៖** ដីធម្មជាតិមានក្រួសល្អិតៗខ្លះៗ។ | ៣.១៥០ |
| ៣ | **លំបាក ៖** ដីធម្មជាតិមានបំណែកថ្មខ្លះៗ។ | ៣.៩៥០ |

**តម្លៃឯកតានៃការបង្ហាប់ក្នុង១ម³ (ការពង្រាយ ការស្រោចទឹក និងការបង្ហាប់) ៖**

| ល.រ | ស្ថានភាពដី | តម្លៃបង្ហាប់ដីក្នុង១ម³ (រៀល) |
|---|---|---|
| ១ | **ងាយស្រួល ៖** ដីធម្មជាតិគ្មានថ្ម និងក្រួសល្អិតៗ។ | ២.៨០០ |
| ២ | **មធ្យម ៖** ដីធម្មជាតិមានក្រួសល្អិតៗខ្លះៗ។ | ៤.០០០ |
| ៣ | **លំបាក ៖** ដីធម្មជាតិមានបំណែកថ្មខ្លះៗ។ | ៨.១០០ |

**២). ការងារធ្វើដោយកម្លាំងពលកម្ម**

ប្រភេទការងារដីខ្លះត្រូវធ្វើដោយកម្លាំងពលកម្ម ហើយប្រភេទការងារដីខ្លះអាចធ្វើដោយកម្លាំងពលកម្ម ឬដោយគ្រឿងចក្រ។

**បទដ្ឋានពលកម្ម** ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានការងារដែលធ្វើដោយកម្លាំងពលកម្ម។ **បទដ្ឋានពលកម្ម** គឺជាចំនួនឬទំហំការងារដែលមនុស្សម្នាក់ត្រូវធ្វើក្នុងរយៈពេលមួយថ្ងៃ។

ការគណនា**តម្លៃឯកតា**សម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃ ក្នុងមួយឯកតាការងារ ត្រូវអនុវត្តដូចខាងក្រោម ៖

- គណនាតម្លៃពលកម្មប្រចាំថ្ងៃ (ពលកម្មគ្មានជំនាញ ពលកម្មមានជំនាញខ្លះៗ និងពលកម្មមានជំនាញ)។ តម្លៃពលកម្មប្រចាំថ្ងៃ គឺជាតម្លៃពលកម្មរបស់មនុស្សម្នាក់ក្នុងការបំពេញការងាររយៈពេលមួយថ្ងៃ។ (តម្លៃនេះ ស្រង់ចេញពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ)
- គណនាតម្លៃពលកម្មក្នុងមួយឯកតា។ តម្លៃពលកម្មក្នុងមួយឯកតា គឺជាតម្លៃពលកម្មរបស់មនុស្សម្នាក់ ក្នុងមួយថ្ងៃ ក្នុងមួយឯកតាការងារ

| **តម្លៃពលកម្មក្នុងមួយឯកតា = តម្លៃពលកម្មប្រចាំថ្ងៃ** *ចែកនឹង* **បទដ្ឋានពលកម្ម** |
|---|

- គណនាតម្លៃឧបករណ៍តូចតាច។ តម្លៃឧបករណ៍តូចតាច ស្មើនឹងតម្លៃឯកតានៃពលកម្ម *គុណនឹង* ៣%

| **តម្លៃឧបករណ៍តូចតាច = តម្លៃពលកម្មក្នុងមួយឯកតា x ៣%** |
|---|

- គណនាតម្លៃឯកតា។ តម្លៃឯកតា គឺជាលទ្ធផលនៃផលបូករវាងតម្លៃឯកតានៃពលកម្ម និងតម្លៃឧបករណ៍តូចតាច

| **តម្លៃឯកតា = តម្លៃពលកម្មក្នុងមួយឯកតា + តម្លៃឧបករណ៍តូចតាច** |
|---|

ប្រសិនបើមានតម្លៃសម្ភារៈផ្សេងៗទៀត ដូចជាតម្លៃទិញស្មៅសម្រាប់ដាំ តម្លៃសម្ភារៈទាំងនេះ ត្រូវបូកបន្ថែមទៅនឹងតម្លៃឯកតា ៖

| **តម្លៃឯកតា = តម្លៃពលកម្មក្នុងមួយឯកតា + តម្លៃឧបករណ៍តូចតាច + តម្លៃសម្ភារៈ** |
|---|

ឧទាហរណ៍ ៖ តម្លៃឯកតាសម្រាប់ការដាំស្មៅ

- បទដ្ឋានពលកម្មសម្រាប់ការដាំស្មៅ = ៣០ម² សម្រាប់មនុស្ស១នាក់ ក្នុងមួយថ្ងៃ
- តម្លៃពលកម្មប្រចាំថ្ងៃគ្មានជំនាញ = ១៥.០០០រៀលក្នុង១នាក់ក្នុង១ថ្ងៃ
- តម្លៃពលកម្មក្នុង១ឯកតាសម្រាប់ដាំស្មៅ១ម² = ១៥.០០០៛ *ចែកនឹង* ៣០ម² = ៥០០៛/ម²
- តម្លៃឧបករណ៍តូចតាចសម្រាប់ដាំស្មៅ១ម² = ៥០០៛ x 0.0៣ = ១៥៛/ម²
- តម្លៃស្មៅក្នុង១ម² = ២.០០០៛
- ដូច្នេះ **តម្លៃឯកតាសម្រាប់ដាំស្មៅ១ម²** = ៥០០៛ + ១៥៛ + ២.០០០៛ = ២.៥១៥៛/ម²

**ជំហានទី២ ៖ គណនាបរិមាណនៃការងារដីនីមួយៗ**

បរិមាណការងារដី គឺជាបរិមាណដី និងទំហំការងារ ដែលត្រូវការជាចាំបាច់សម្រាប់ស្ថាបនាឱ្យបាននូវលទ្ធផលមួយ។

ការគណនាបរិមាណដី គឺគិតអំពីបរិមាណដីដែលមិនទាន់បង្ហាប់។ ជាទូទៅបរិមាណដី ឬមាឌដីដែលដឹកមកចាក់សម្រាប់សាងសង់ផ្លូវ ត្រូវថយចុះប្រមាណ ៣០% បន្ទាប់ពីបង្ហាប់រួច។ ដូច្នេះ ដើម្បីបានបរិមាណដី ឬមាឌដី (V) ដែលបានមកពីការគណនាតាមគំនូសប្លង់បច្ចេកទេស នោះត្រូវគណនាបរិមាណដីសរុបដែលមិន

ទាន់បង្ហាប់ គឺ Q = V x CF ដែល ៖

- Q ៖ ជាបរិមាណដីសរុបដែលមិនទាន់បង្ហាប់ គិតជា ម$^{៣}$
- V ៖ ជាបរិមាណ ឬមាឌដីគណនាតាមគំនូសប្លង់បច្ចេកទេស គិតជា ម$^{៣}$
- CF = ១,៣ ជាមេគុណបង្ហាប់ដី

**ឧទាហរណ៍ ៖ សាងសង់ផ្លូវដីដែលមានប្រវែង២.០០០ម និងទទឹង៦ម**

- បរិមាណ ឬមាឌដី គឺ V = ២.០០០ម x ៦ម x 0,៥ម = ៦.០០០ម$^{៣}$
- បរិមាណដីមិនទាន់បង្ហាប់សរុប គឺ Q = V x CF = ៦.០០០ម$^{៣}$ x ១,៣ = ៧.៨០០ម$^{៣}$
- ចម្ងាយដឹកជញ្ជូនដី១០គ.ម(ពីការដ្ឋានដីទៅទីតាំងគម្រោង) ដូចនេះ តម្លៃដឹកជញ្ជូនដីក្នុង១ម$^{៣}$ ក្នុងចម្ងាយផ្លូវ១០គ.ម សម្រាប់ស្ថានភាពផ្លូវមធ្យម គឺ ៖
  តម្លៃ T = ៥៥0៛ x ១០គ.ម = ៥.៥០០៛/ម$^{៣}$

**តាមរយៈឧទាហរណ៍ខាងលើនេះ បរិមាណនៃការងារដីនីមួយៗ មានដូចខាងក្រោម ៖**

- ទំហំផ្ទៃដីឈូសសម្អាតទីតាំង គឺ ២.០០០ម x ៦ម = ១២.០០០ម$^{២}$
- បរិមាណដីត្រូវជីក គឺ ៧.៨០០ម$^{៣}$
- បរិមាណដីត្រូវទិញ គឺ ៧.៨០០ម$^{៣}$
- បរិមាណដីត្រូវដឹកជញ្ជូន (ពី០ទៅ២០គ.ម) គឺ ៧.៨០០ម$^{៣}$ គ.ម
- បរិមាណដីត្រូវកៀរពង្រាយ ស្រោចទឹក និងកិនបង្ហាប់ គឺ ៧.៨០០ម$^{៣}$
- ទំហំផ្ទៃដីដាំស្មៅ គឺ ២.០០០ម x 0,៥ម x ២ម = ២.០០០ម$^{២}$

**ជំហានទី៣ ៖ គណនាតម្លៃនៃការងារដី**

បន្ទាប់ពីគណនាតម្លៃឯកតា និងបរិមាណការងារដីរួច ជំហានបន្ទាប់ គឺគណនាតម្លៃនៃការងារដី។ ការគណនាតម្លៃនៃការងារដី ត្រូវអនុវត្តដូចខាងក្រោម ៖

- គណនាតម្លៃនៃប្រភេទការងារដីនីមួយៗ។ តម្លៃនៃប្រភេទការងារដីនីមួយៗ គឺជាលទ្ធផលនៃផលគុណរវាងបរិមាណនៃប្រភេទការងារដីនីមួយៗ និងតម្លៃឯកតា

**តម្លៃនៃប្រភេទការងារដីនីមួយៗ = បរិមាណនៃប្រភេទការងារដីនីមួយៗ x តម្លៃឯកតា**

- គណនាតម្លៃសរុបនៃការងារដី។ តម្លៃសរុបនៃការងារដី គឺជាលទ្ធផលនៃផលបូកនៃតម្លៃរបស់ប្រភេទការងារដីនីមួយៗ

**តម្លៃសរុបនៃការងារដី = ផលបូកនៃតម្លៃរបស់ប្រភេទការងារដីនីមួយៗ**

**ឧទាហរណ៍ ៖**

| ការពិពណ៌នា | ឯកតា | បរិមាណ | តម្លៃឯកតា (៛) | តម្លៃ (៛) |
|---|---|---|---|---|
| ការឈូសសម្អាតទីតាំង (ងាយស្រួល) | ម$^{២}$ | ១២.០០០ | ៩០ | ១.០៨០.០០០ |
| ការជីកដី (ងាយស្រួល) | ម$^{៣}$ | ៧.៨០០ | ២.៥៥០ | ១៩.៨៩០.០០០ |
| ការទិញដី | ម$^{៣}$ | ៧.៨០០ | ១.៥០០ | ១១.៧០០.០០០ |
| ការដឹកជញ្ជូនដី (១០គ.ម, ផ្លូវមធ្យម) | ម$^{៣}$គ.ម | ៧.៨០០ | ៥.៥០០ | ៤២.៩០០.០០០ |

| ការពិពណ៌នា | ឯកតា | បរិមាណ | តម្លៃឯកតា (៛) | តម្លៃ (៛) |
|---|---|---|---|---|
| ការក្បៀរពង្រាយ ស្រោចទឹក និងកិនបង្ហាប់ (ងាយស្រួល) | ម៣ | ៧.៨០០ | ២.៨០០ | ២១.៨៤០.០០០ |
| ការដាំស្មៅ | ម២ | ២.០០០ | ២.៥១៥ | ៥.០៣០.០០០ |
| តម្លៃសរុបនៃការងារដី | | | | ១០២.៤៤០.០០០ |

**ជំហានទី៤ ៖ គណនាតម្លៃដឹកជញ្ជូនគ្រឿងចក្រ (ទៅ និងមកពីការដ្ឋាន)**

របៀបគណនាតម្លៃដឹកជញ្ជូនគ្រឿងចក្រ អនុវត្តដូចគ្នាទៅនឹងរបៀបគណនាតម្លៃដឹកញ្ជូនសម្ភារៈសម្រាប់ការងារសំណង់ដែរ។

តម្លៃដឹកជញ្ជូនគ្រឿងចក្រ ត្រូវគណនាសម្រាប់ទាំងការដឹកជញ្ជូនគ្រឿងចក្រទៅកាន់ការដ្ឋាន និងការដឹកជញ្ជូនគ្រឿងចក្រត្រឡប់ពីការដ្ឋានវិញ។

ចំពោះគម្រោងការងារដីរបស់រដ្ឋបាលរាជធានី ខេត្ត ទម្ងន់គ្រឿងចក្រសរុបដែលដឹកជញ្ជូនសន្មតយកមានទម្ងន់៣០តោន។ តម្លៃដឹកជញ្ជូនគ្រឿងចក្រទៅការដ្ឋាន គឺ ៖

**តម្លៃដឹកជញ្ជូនគ្រឿងចក្រ = ៣០ x តម្លៃ T**

ដូច្នេះ

**តម្លៃផ្ទាល់ = តម្លៃសរុបនៃការងារដី + តម្លៃដឹកជញ្ជូនគ្រឿងចក្រ**

**ជំហានទី៥ ៖ គណនាតម្លៃប្រយោល និងប្រាក់ចំណេញ**

តម្លៃប្រយោល និងប្រាក់ចំណេញ ស្មើនឹងតម្លៃផ្ទាល់ *គុណនឹង* ១០%។

**តម្លៃប្រយោល និងប្រាក់ចំណេញ = តម្លៃផ្ទាល់ X ១០%**

ដូច្នេះ

**តម្លៃសរុប = តម្លៃផ្ទាល់ + តម្លៃប្រយោលនិងប្រាក់ចំណេញ**

## ឧទាហរណ៍ ៖ ការប៉ាន់ស្មានតម្លៃសម្រាប់លទ្ធផលគម្រោងការងារដី (ឧម្រង់នី៩)

| ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលការងារដី | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវដីពីទីរួមស្រុក.ក. មកទីរួមខេត្ត | |
| ការពិពណ៌នាលទ្ធផលគម្រោង ៖ ផ្លូវដីប្រវែង២.០០០ម ទទឹង៦ម។ | |
| ទីតាំងលទ្ធផលគម្រោង ៖ ភូមិ១ និងភូមិ២ នៃឃុំក១ ស្រុក.ក. | |

| ការប៉ាន់ស្មានតម្លៃសម្រាប់លទ្ធផលនាំចមូល | | | | | |
|---|---|---|---|---|---|
| ល.រ | ការពិពណ៌នា | ឯកតា | បរិមាណ | តម្លៃឯកតា (៛) | សរុប (៛) |
| ១ | ការឈូសសម្អាតទីតាំង(ងាយស្រួល) | ម² | ១២.០០០ | ៩០ | ១.០៨០.០០០ |
| ២ | ការជីកដី (ងាយស្រួល) | ម³ | ៧.៨០០ | ២.៥៥០ | ១៩.៨៩០.០០០ |
| ៣ | ការទិញដី | ម³ | ៧.៨០០ | ១.៥០០ | ១១.៧០០.០០០ |
| ៤ | ការដឹកជញ្ជូនដី(១០គ.ម, ផ្លូវមធ្យម) | ម³ | ៧.៨០០ | ៥.៥០០ | ៤២.៩០០.០០០ |
| ៥ | ការក្បៀរពង្រាយ ស្រោចទឹក និងកិនបង្ហាប់ (ងាយស្រួល) | ម³ | ៧.៨០០ | ២.៨០០ | ២១.៨៤០.០០០ |
| ៦ | ការដាំស្មៅ | ម² | ២.០០០ | ២.៥១៥ | ៥.០៣០.០០០ |
| ៧ | ដឹកជញ្ជូនគ្រឿងចក្រទៅការដ្ឋាន | តោន | ៣០ | ១១.៥០០ | ៣៤៥.០០០ |
| ៨ | ដឹកជញ្ជូនគ្រឿងចក្រពីការដ្ឋាន | តោន | ៣០ | ១១.៥០០ | ៣៤៥.០០០ |
| ៩ | ស្លាកសញ្ញាគម្រោង | កន្លែង | ១ | ២០០.០០០ | ២០០.០០០ |
| តម្លៃផ្ទាល់ | | | | | ១០៣.៣៣០.០០០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ១០.៣៣៣.០០០ |
| តម្លៃសរុប | | | | | ១១៣.៦៦៣.០០០ |

| តម្លៃមួយឯកតានៃលទ្ធផល | | | | |
|---|---|---|---|---|
| ការពិពណ៌នា | ឯកតា | ចំនួន | តម្លៃសរុប (៛) | តម្លៃមួយឯកតា (៛) |
| ផ្លូវដីប្រវែង២គម ទទឹង៦ម | គ.ម | ២,០០ | ១១៣.៦៦៣.០០០ | ៥៦.៨៣១.៥០០ |

| | |
|---|---|
| ឈ្មោះផ្សារ ៖ ផ្សារ .ក. | ចម្ងាយផ្លូវដឹកជញ្ជូន ៖ ១០គម (ស្ថានភាពផ្លូវមធ្យម) |

| ថ្ងៃទី...... ខែ......... ឆ្នាំ....... | ថ្ងៃទី...... ខែ......... ឆ្នាំ....... | ថ្ងៃទី...... ខែ......... ឆ្នាំ....... |
|---|---|---|
| **អភិបាលរាជធានី ខេត្ត** | **នាយកទីចាត់ការផែនការ និងវិនិយោគ** | **អ្នកជំនួយបច្ចេកទេស** |

## ៧.៤. ការគណនាតម្លៃប៉ាន់ស្មានគម្រោងសេវាកម្ម

**ជំហានទី១ ៖ គណនាបរិមាណការងារ ឬសកម្មភាព**

បរិមាណការងារឬសកម្មភាព គឺជាទំហំការងារឬសកម្មភាព ដែលត្រូវការចាំបាច់ដើម្បីសម្រេចបាននូវលទ្ធផលគម្រោងមួយ។

ការងារ ឬសកម្មភាពនានានៃគម្រោងសេវាកម្ម រួមមានដូចជា ៖

- ការចងក្រងក្រុម និងការរៀបចំលក្ខន្តិកៈក្រុម
- ការបណ្តុះបណ្តាល (ចំនួនដងក្នុងមួយវគ្គ ចំនួនវគ្គ ចំនួនសិក្ខាកាម សម្ភារៈបណ្តុះបណ្តាល)
- ការអនុវត្តការធ្វើបង្ហាញដល់កសិករគោលដៅ (ចំនួនកន្លែង និងសម្ភារៈដែលត្រូវការ)
- ការរៀបចំទិវាស្រែកសិករ
- ការចុះតាមដាន និងជួយដល់កសិករគោលដៅក្នុងការរៀបចំកន្លែងសម្រាប់ការអនុវត្តជាក់ស្តែង ដូចជាការរៀបចំថ្នាលបណ្តុះ ការរៀបចំស្រះ ការរៀបចំដី ការរៀបចំរោងជីកំប៉ុស្ត ការរៀបចំទ្រុង... ។ល។
- ការផ្តល់គ្រាប់ពូជ ឬពូជសត្វ ឬកូនឈើ... សម្រាប់អនុវត្តជាក់ស្តែង។
- ការចុះតាមដាន និងគាំទ្រដល់កសិករគោលដៅនៅក្នុងអំឡុងពេលអនុវត្តជាក់ស្តែង រហូតដល់បញ្ចប់គម្រោង។ ជួនកាលសកម្មភាពនេះ ត្រូវបន្តរហូតដល់កសិករគោលដៅមានសមត្ថភាពគ្រប់គ្រាន់។

**ជំហានទី២ ៖ គណនាបរិមាណសម្ភារៈ និងកម្លាំងពលកម្ម**

បរិមាណសម្ភារៈ និងកម្លាំងពលកម្ម គឺជាចំនួនទំហំសម្ភារៈឬទំនិញ និងកម្លាំងពលកម្ម ដែលត្រូវការចាំបាច់សម្រាប់អនុវត្តលទ្ធផលគម្រោង។

សម្ភារៈឬទំនិញដែលត្រូវការសម្រាប់គម្រោងសេវាកម្ម រួមមានដូចជា ៖

- សម្ភារៈសម្រាប់រៀបចំ ឬសាងសង់កន្លែងអនុវត្តជាក់ស្តែង
- ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែង
- គ្រាប់ពូជ
- ពូជសត្វ
- កូនឈើ

កម្លាំងពលកម្មសម្រាប់គម្រោងសេវាកម្ម រួមមានដូចជា ៖

- អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ទិវាបង្ហាញ
- អ្នកចុះតាមដាន និងគាំទ្របច្ចេកទេស

**ជំហានទី៣ ៖ គណនាតម្លៃផ្ទាល់ (តម្លៃសម្ភារៈ និងកម្លាំងពលកម្ម)**

ការគណនាតម្លៃសម្ភារៈ ត្រូវអនុវត្តដូចខាងក្រោម ៖

- កំណត់រកតម្លៃឯកតានៃប្រភេទសម្ភារៈនីមួយៗ
- គណនាតម្លៃនៃប្រភេទសម្ភារៈនីមួយៗ។ តម្លៃនៃប្រភេទសម្ភារៈនីមួយៗ គឺជាលទ្ធផលនៃផលគុណរវាងបរិមាណនៃប្រភេទសម្ភារៈនីមួយៗ និងតម្លៃឯកតា

| តម្លៃនៃប្រភេទសម្ភារៈនីមួយៗ = បរិមាណនៃប្រភេទសម្ភារៈនីមួយៗ x តម្លៃឯកតា |
|---|

- គណនាតម្លៃសម្ភារៈសរុប។ តម្លៃសម្ភារៈសរុប គឺជាលទ្ធផលនៃផលបូកនៃតម្លៃរបស់ប្រភេទសម្ភារៈនីមួយៗ

| **តម្លៃសម្ភារៈសរុប = ផលបូកនៃតម្លៃរបស់ប្រភេទសម្ភារៈនីមួយៗ** |
|---|

ការគណនាតម្លៃកម្លាំងពលកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

- កំណត់រកតម្លៃឯកតានៃប្រភេទកម្លាំងពលកម្មនីមួយៗ
- គណនាតម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ។ តម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ គឺជាលទ្ធផលនៃផលគុណរវាងបរិមាណនៃប្រភេទកម្លាំងពលកម្មនីមួយៗ និងតម្លៃឯកតា

| **តម្លៃនៃប្រភេទកម្លាំងពលកម្មនីមួយៗ = បរិមាណនៃប្រភេទកម្លាំងពលកម្មនីមួយៗ x តម្លៃឯកតា** |
|---|

- គណនាតម្លៃកម្លាំងពលកម្មសរុប។ តម្លៃកម្លាំងពលកម្មសរុប គឺជាលទ្ធផលនៃផលបូកនៃតម្លៃរបស់ប្រភេទកម្លាំងពលកម្មនីមួយៗ

| **តម្លៃកម្លាំងពលកម្មសរុប = ផលបូកនៃតម្លៃរបស់ប្រភេទកម្លាំងពលកម្មនីមួយៗ** |
|---|

ដូច្នេះ

| **តម្លៃផ្ទាល់ = តម្លៃសម្ភារៈ + តម្លៃកម្លាំងពលកម្ម** |
|---|

ឧទាហរណ៍គម្រោងកសិកម្មចម្រុះមានសួនបន្លែ និងការចិញ្ចឹមត្រី សម្រាប់កសិករ២០គ្រួសារ។ សកម្មភាព និងសម្ភារៈរួមមាន ៖

**១). ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ (សួនបន្លែ និងការចិញ្ចឹមត្រី)**

- សម្ភារៈបណ្តុះបណ្តាល ៖ ២០នាក់ x ៤លើក x ៤.០០០៛ = ៣២០.០០០៛
- ឯកសារបណ្តុះបណ្តាល ៖ ២០នាក់ x ៤លើក x ៨.០០០៛ = ៦៤០.០០០៛
- អាហារសម្រន់ ៖ ២០នាក់ x ៤លើក x ៤.០០០៛ = ៣២០.០០០៛
- ថ្លៃសេវាបណ្តុះបណ្តាល ៖ ២នាក់ x ៤លើក x ១២០.០០០៛ = ៩៦០.០០០៛

**២). ការធ្វើបង្ហាញអំពីសួនបន្លែ (២០បង្ហាញ)**

- គ្រាប់ពូជត្រកួន ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជត្រសក់ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជស្ពៃ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជសណ្តែកកួរ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជឆៃថាវ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- ចបកាប់ ៖ ២០ចបកាប់ x ២០.០០០៛ = ៤០០.០០០៛
- ធុងស្រោចដំណាំ (១៥លីត្រ) ៖ ២០គូ x ៣០.០០០៛ = ៦០០.០០០៛
- អាហារសម្រន់ ៖ ២០នាក់ x ៦លើក x ៤.០០០៛ = ៤៨០.០០០៛
- ថ្លៃសេវាចុះគាំទ្របច្ចេកទេស ៖ ២នាក់ x ៦លើក x ១២០.០០០៛ = ១.៤៤០.០០០៛

**៣). ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី (២០បង្ហាញ)**

- ជីកឬស្តារស្រះចិញ្ចឹមត្រី ៖ ២០ស្រះ x ១០០.០០០៛ = ២.០០០.០០០៛
- កំបោរ ៖ ២០គ្រួសារ x ១០គ.ក្រ x ១.០០០៛ = ២០០.០០០៛
- សំណាញ់ ឬមុង ៖ ២០គ្រួសារ x ២០ម x ២.០០០៛ = ៨០០.០០០៛

- កូនត្រី ៖ ២០គ្រួសារ x ៥០០ក្បាល x ២០០៛ = ២.០០០.០០០៛
- អាហារសម្រន់ ៖ ២០នាក់ x ៦លើក x ៤.០០០៛ = ៤៨០.០០០៛
- ថ្លៃសេវាចុះគាំទ្របច្ចេកទេស ៖ ២នាក់ x ៦លើក x ១២០.០០០៛ = ១.៤៤០.០០០៛

**ជំហានទី៤ ៖ គណនាតម្លៃប្រយោល និងប្រាក់ចំណេញ ឬតម្លៃរដ្ឋបាល និងការគ្រប់គ្រង**

តម្លៃប្រយោល និងប្រាក់ចំណេញ ត្រូវបានប្រើប្រាស់សម្រាប់ក្រុមហ៊ុន ឬអង្គភាពរកប្រាក់ចំណេញ។

**តម្លៃប្រយោលនិងប្រាក់ចំណេញ = តម្លៃផ្ទាល់ x ១០%**

ដូច្នេះ

**តម្លៃសរុប = តម្លៃផ្ទាល់ + តម្លៃប្រយោលនិងប្រាក់ចំណេញ**

តម្លៃរដ្ឋបាល និងការគ្រប់គ្រង ត្រូវបានប្រើប្រាស់សម្រាប់អង្គភាពមិនរកប្រាក់ចំណេញ ដូចជា អង្គការមិនមែនរដ្ឋាភិបាល សមាគម និងអង្គការសហគមន៍មូលដ្ឋានជាដើម។

**តម្លៃរដ្ឋបាលនិងការគ្រប់គ្រង = តម្លៃផ្ទាល់ x ១០%**

ដូច្នេះ

**តម្លៃសរុប = តម្លៃផ្ទាល់ + តម្លៃរដ្ឋបាលនិងការគ្រប់គ្រង**

ឧទាហរណ៍ ៖ ការប៉ាន់ស្មានតម្លៃសម្រាប់គម្រោងសេវាកម្ម (ឧម្រង់ទី១០)

| ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់គម្រោងសេវាកម្ម | | | | | |
|---|---|---|---|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | | លេខកូដរាជធានី ខេត្ត ៖ | | | |
| ឈ្មោះគម្រោង ៖ គម្រោងកសិកម្មចម្រុះខេត្តកំពង់ចាម | | | | | |
| ការពិពណ៌នាលទ្ធផលគម្រោង ៖ កសិកម្មចម្រុះចំនួន២០គ្រួសារដែលក្នុងនោះមានសួនបន្លែ និងចិញ្ចឹមត្រី។ | | | | | |
| ទីតាំងលទ្ធផលគម្រោង ៖ ភូមិ១ ឃុំក១ ស្រុក.ក. | | | | | |
| ការប៉ាន់ស្មានតម្លៃសម្រាប់មួយឯកតានៃលទ្ធផល | | | | | |
| ល.រ | ការពិពណ៌នា | ឯកតា | ចំនួន | តម្លៃឯកតា (៛) | សរុប (៛) |
| ១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ សួនបន្លែ និងការចិញ្ចឹមត្រី (៤វគ្គ) | | | | |
| | សម្ភារៈបណ្តុះបណ្តាល | នាក់ | ៨០ | ៤.០០០ | ៣២០.០០០ |
| | ឯកសារបណ្តុះបណ្តាល | នាក់ | ៨០ | ៨.០០០ | ៦៤០.០០០ |
| | អាហារសម្រន់ | នាក់ថ្ងៃ | ៨០ | ៤.០០០ | ៣២០.០០០ |
| | ថ្លៃសេវាបណ្តុះបណ្តាល | នាក់ថ្ងៃ | ៨ | ១២០.០០០ | ៩៦០.០០០ |
| សរុបតម្លៃផ្ទាល់លទ្ធផលទី១ | | | | | ២.២៤០.០០០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ២២៤.០០០ |
| សរុបលទ្ធផលទី១ | | | | | ២.៤៦៤.០០០ |
| ២ | ការធ្វើបង្ហាញអំពីសួនបន្លែ (២០បង្ហាញ) | | | | |
| | គ្រាប់ពូជត្រកួន | កំប៉ុង | ៤០ | ៥.០០០ | ២០០.០០០ |
| | គ្រាប់ពូជត្រសក់ | កំប៉ុង | ៤០ | ៥.០០០ | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | គ្រាប់ពូជស្ពៃ | កំប៉ុង | ៤០ | ៥.០០០ | ២០០.០០០ |
| | គ្រាប់ពូជសណ្តែកកួរ | កំប៉ុង | ៤០ | ៥.០០០ | ២០០.០០០ |
| | គ្រាប់ពូជឆៃថាវ | កំប៉ុង | ៤០ | ៥.០០០ | ២០០.០០០ |
| | ចបកាប់ | ចបកាប់ | ២០ | ២០.០០០ | ៤០០.០០០ |
| | ធុងស្រោចដំណាំ (១៥លីត្រ) | គូ | ២០ | ៣០.០០០ | ៦០០.០០០ |
| | អាហារសម្រន់ | នាក់ថ្ងៃ | ១២០ | ៤.០០០ | ៤៨០.០០០ |
| | ថ្លៃសេវាចុះគាំទ្របច្ចេកទេស | នាក់ថ្ងៃ | ១២ | ១២០.០០០ | ១.៤៤០.០០០ |
| សរុបតម្លៃផ្ទាល់លទ្ធផលទី២ | | | | | ៣.៩២០.០០០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ៣៩២.០០០ |
| សរុបលទ្ធផលទី២ | | | | | ៤.៣១២.០០០ |
| ៣ | ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី (២០បង្ហាញ) | | | | |
| | ជីក ឬស្តារស្រះសម្រាប់ចិញ្ចឹមត្រី | ស្រះ | ២០ | ១០០.០០០ | ២.០០០.០០០ |
| | កំបោរ | គ.ក្រ | ២០០ | ១.០០០ | ២០០.០០០ |
| | សំណាញ់ ឬមង | ម | ៤០០ | ២.០០០ | ៨០០.០០០ |
| | កូនត្រី | ក្បាល | ១០.០០០ | ២០០ | ២.០០០.០០០ |
| | អាហារសម្រន់ | នាក់ថ្ងៃ | ១២០ | ៤.០០០ | ៤៨០.០០០ |
| | ថ្លៃសេវាចុះគាំទ្របច្ចេកទេស | នាក់ថ្ងៃ | ១២ | ១២០.០០០ | ១.៤៤០.០០០ |
| សរុបតម្លៃផ្ទាល់លទ្ធផលទី៣ | | | | | ៦.៩២០.០០០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ៦៩២.០០០ |
| សរុបលទ្ធផលទី៣ | | | | | ៧.៦១២.០០០ |
| សរុបរួម | | | | | ១៤.៣៨៨.០០០ |

ថ្ងៃទី...... ខែ......... ឆ្នាំ....... ថ្ងៃទី...... ខែ......... ឆ្នាំ....... ថ្ងៃទី...... ខែ......... ឆ្នាំ.......

**អភិបាលរាជធានី ខេត្ត** **នាយកទីចាត់ការផែនការ និងវិនិយោគ** **អ្នកជំនួយបច្ចេកទេស**

### ៧.៥. ការបំពេញទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោង

ទម្រង់លទ្ធផលគម្រោង និងប៉ាន់ស្មានតម្លៃ (**ទម្រង់ទី១១ និង១២**) បង្ហាញ ៖

- លទ្ធផលគម្រោងនីមួយៗ ព្រមទាំងទីតាំង និងទំហំរបស់វា
- តម្លៃប៉ាន់ស្មាននៃលទ្ធផលគម្រោងនីមួយៗ
- តម្លៃប៉ាន់ស្មានគម្រោង។

#### ក). ទីតាំងលទ្ធផលគម្រោង

លទ្ធផលគម្រោងមួយអាចមាននៅក្នុងមួយភូមិ ឬច្រើនជាងមួយភូមិ។ ឧទាហរណ៍គម្រោងផ្លូវមួយមានប្រវែង២គ.ម ហើយផ្លូវនេះ ១,២០គ.ម ស្ថិតនៅក្នុងភូមិ១ ឃុំ"ក១" ស្រុក"ក" និង០,៨០គ.ម ស្ថិតនៅក្នុងភូមិ២ ឃុំ"ក១" ស្រុក"ក"។ នៅលើផ្លូវនេះត្រូវដាក់លូចំនួន៣កន្លែង ដែលក្នុងនោះ២កន្លែងស្ថិតនៅក្នុងភូមិ១ ឃុំ"ក១" ស្រុក"ក" និង១កន្លែងស្ថិតនៅក្នុងភូមិ២ ឃុំ"ក១" ស្រុក"ក"។ ដូច្នេះ យើងត្រូវចែកលទ្ធផលគម្រោងជា៤ ៖

- ភូមិ១ ឃុំ"ក១" ស្រុក"ក" ៖ មានប្រវែងផ្លូវ១,២០គ.ម
- ភូមិ១ ឃុំ"ក១" ស្រុក"ក" ៖ មានលូ២កន្លែង
- ភូមិ២ ឃុំ"ក១" ស្រុក"ក" ៖ មានប្រវែងផ្លូវ០,៨០គ.ម
- ភូមិ២ ឃុំ"ក១" ស្រុក"ក" ៖ មានលូ១កន្លែង

#### ខ). លេខកូដ និងឈ្មោះលទ្ធផលគម្រោង

លទ្ធផលគម្រោងនីមួយៗត្រូវបានសម្គាល់ដោយលេខកូដ និងឈ្មោះ។ លេខកូដ និងឈ្មោះលទ្ធផលគម្រោងមានបរិយាយនៅក្នុងបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ នៅឧបសម្ព័ន្ធទី២នៃសៀវភៅណែនាំនេះ។ ឧទាហរណ៍ លេខកូដផ្លូវដី គឺ១០១០១០១ និងលេខកូដលូទោលអង្កត់ផ្ចិត០,៨ម គឺ ១០១០៣០២។

#### គ). ការធ្វើថ្មី ការជួសជុល ឬការកែលម្អ (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)

លទ្ធផលគម្រោងមួយអាចជាការធ្វើថ្មី ឬការជួសជុល ឬការកែលម្អ។

- **ការធ្វើថ្មី** គឺជាការបង្កើតឡើងនូវលទ្ធផលគម្រោងថ្មី ដែលមិនមានពីមុនមក។ មានន័យថា អ្វីមួយដែលពីមុនមកមិនមាន។ ឧទាហរណ៍ ផ្លូវមួយខ្សែដែលសាងសង់កាត់តាមវាលស្រែ។
- **ការកែលម្អ** គឺជាការធ្វើឱ្យលទ្ធផលគម្រោងដែលមានពីមុនមក មានភាពប្រសើរឡើងជាងមុន។ ឧទាហរណ៍ ក្រាលក្រួសក្រហមនៅលើផ្លូវដី ជាលើកដំបូង។
- **ការជួសជុល** គឺជាការធ្វើឱ្យលទ្ធផលគម្រោងដែលមានពីមុនមក មានស្ថានភាពល្អឡើងវិញ ដូចស្ថានភាពនៅពេលមិនទាន់ខូចខាត។ ឧទាហរណ៍ ក្រាលក្រួសក្រហមឡើងវិញនៅលើផ្លូវក្រួសក្រហមចាស់។

**កំណត់សម្គាល់** ÷ ជានិច្ចកាល លទ្ធផលគម្រោងមួយ គឺជាអ្វីមួយដែលត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ផលប្រយោជន៍ផ្ទាល់ដល់អ្នកទទួលផលគម្រោង។ គម្រោងមួយចំនួនរួមបញ្ចូលការសាងសង់ដែលនឹងកែលម្អ ឬការពារលទ្ធផលដែលមានស្រាប់ ប៉ុន្តែនឹងមិនផ្តល់ផលប្រយោជន៍ណាមួយដោយឡែកពីលទ្ធផលដែលមានស្រាប់នោះទេ។ ការសាងសង់របងជុំវិញស្រះទឹក។ លទ្ធផលមិនមែនជារបងថ្មីទេ (របងនឹងមិនផ្តល់ផលប្រយោជន៍ផ្ទាល់ណាមួយទេ)។ លទ្ធផលនេះ គឺជាការកែលម្អស្រះទឹក។

**ឃ). គំនូសប្លង់បច្ចេកទេសរបស់ គ.ជ.អ.ប (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)**

ប្រសិនបើគំនូសប្លង់បច្ចេកទេស ដែលមាននៅក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប ត្រូវបានប្រើប្រាស់ ត្រូវសរសេរ "បាទ"។

ប្រសិនបើគំនូសប្លង់បច្ចេកទេស ដែលមាននៅក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប មិនត្រូវបានប្រើប្រាស់ ត្រូវសរសេរ "ទេ"។

**ង). ស្តង់ដារទំហំ១ និងស្តង់ដារទំហំ២ (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)**

ស្តង់ដារទំហំ១ និងស្តង់ដារទំហំ២នៃលទ្ធផលគម្រោងនីមួយៗ ត្រូវស្រង់ចេញពីបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ។ ប្រសិនបើលទ្ធផលគម្រោងណាមួយ ពុំមាននៅក្នុងបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ រាជធានី ខេត្តអាចស្នើសុំថ្នាក់ជាតិដើម្បីបញ្ចូលលទ្ធផលគម្រោងនោះទៅក្នុងបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ។ ឧទាហរណ៍ អណ្តូងលូ ៖ ស្តង់ដារទំហំ១ គឺជម្រៅ គិតជាម៉ែត្រ ហើយស្តង់ដារទំហំ២ គឺអង្កត់ផ្ចិត គិតជាមីលីម៉ែត្រ។

**ច). ឯកតា និងបរិមាណ (ឬចំនួន)**

លទ្ធផលគម្រោងនីមួយៗត្រូវមានរង្វាស់ឯកតាស្តង់ដារ។ រង្វាស់ឯកតាស្តង់ដារមានបរិយាយនៅក្នុងបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ នៅឧបសម្ព័ន្ធទី២នៃសៀវភៅណែនាំនេះ។ ឧទាហរណ៍ រង្វាស់ឯកតាស្តង់ដារសម្រាប់ផ្លូវក្រួសក្រហម គឺជាគីឡូម៉ែត្រ មិនមែនជាម៉ែត្រ ឬជាម៉ែត្រត្រីគុណនៃក្រួសក្រហមនោះទេ។ រង្វាស់ឯកតាស្តង់ដារសាលារៀន គឺជាបន្ទប់រៀន មិនមែនជាអគារសាលារៀន១ខ្នងនោះទេ។

**ឆ). តម្លៃប៉ាន់ស្មាននៃលទ្ធផលគម្រោង**

តម្លៃប៉ាន់ស្មាននៃលទ្ធផលគម្រោង ចែកចេញជាពីរ គឺតម្លៃប៉ាន់ស្មានក្នុងមួយឯកតានៃលទ្ធផលគម្រោងនីមួយៗ និងតម្លៃប៉ាន់ស្មាននៃលទ្ធផលគម្រោងនីមួយៗ។ ឧទាហរណ៍ ៖

- តម្លៃប៉ាន់ស្មានក្នុងមួយឯកតាសម្រាប់ផ្លូវក្រួសក្រហម គឺជាតម្លៃសម្រាប់ផ្លូវប្រវែង១គីឡូម៉ែត្រ។
- តម្លៃប៉ាន់ស្មានក្នុងមួយឯកតាសម្រាប់សាលារៀន គឺជាតម្លៃសម្រាប់សាលារៀនមួយបន្ទប់។

តម្លៃប៉ាន់ស្មានក្នុងមួយឯកតា និងតម្លៃប៉ាន់ស្មាននៃលទ្ធផលនីមួយៗ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងទម្រង់ប៉ាន់ស្មានតម្លៃលម្អិត។ ដូចនេះ ត្រូវស្រង់តួលេខនេះចូលក្នុងទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងឱ្យបានត្រឹមត្រូវ។

**ជ). តម្លៃប៉ាន់ស្មានគម្រោង**

តម្លៃប៉ាន់ស្មានគម្រោង គឺជាលទ្ធផលនៃផលបូកតម្លៃប៉ាន់ស្មានរបស់លទ្ធផលគម្រោងទាំងអស់។

**ទម្រង់ទី១១**

## លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ

| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ សាងសង់ផ្លូវដីពីស្រុក‹ក› មកទីរួមខេត្ត |
|---|---|---|

| ល.រ | ទីតាំងលទ្ធផល | | | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬកែលម្អ ឬជួសជុល | តាមប្លង់ គ.ជ.អ.ប (បាទឬទេ) | ស្តង់ដារទំហំ១ | | ស្តង់ដារទំហំ២ | | តម្លៃប៉ាន់ស្មាន (៛) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ភូមិ១ | ឃុំ ក១ | ស្រុក ‹ក› | ១០១០១០១ | ផ្លូវដី | កែលម្អ | បាទ | ទទឹង | ៦ម | មាឌដី | ៤.៦៨០ម$^{៣}$ | គ.ម | ១,២០ | ៥៦.៨៣១.៥០០ | ៦៨.១៩៧.៨០០ |
| ២ | ភូមិ២ | ឃុំ ក១ | ស្រុក ‹ក› | ១០១០១០១ | ផ្លូវដី | កែលម្អ | បាទ | ទទឹង | ៦ម | មាឌដី | ៣.១២០ម$^{៣}$ | គ.ម | ០,៨០ | ៥៦.៨៣១.៥០០ | ៤៥.៤៦៥.២០០ |
| ៣ | ភូមិ១ | ឃុំ ក១ | ស្រុក ‹ក› | ១០១០៣០២ | លូមូលទោល | ថ្មី | បាទ | អង្កត់ផ្ចិត | ៨០០មម | ប្រវែង | ៧ម | កន្លែង | ២ | ៣.៨៧៨.៥០១ | ៧.៧៥៧.០០២ |
| ៤ | ភូមិ២ | ឃុំ ក១ | ស្រុក ‹ក› | ១០១០៣០២ | លូមូលទោល | ថ្មី | បាទ | អង្កត់ផ្ចិត | ៨០០មម | ប្រវែង | ៧ម | កន្លែង | ១ | ៣.៨៧៨.៥០១ | ៣.៨៧៨.៥០១ |
| តម្លៃប៉ាន់ស្មានគម្រោងសរុប | | | | | | | | | | | | | | | ១២៥.២៩៨.៥០៣ |

**កំណត់សម្គាល់ ÷** មានតែលទ្ធផលគម្រោងដែលថវិកាគ្រប់គ្រាន់ប៉ុណ្ណោះ ត្រូវបានកត់ត្រានៅក្នុងទម្រង់នេះ។

ថ្ងៃទី......... ខែ............. ឆ្នាំ.......... ថ្ងៃទី......... ខែ............. ឆ្នាំ.......... ថ្ងៃទី......... ខែ............. ឆ្នាំ..........

**អភិបាលរាជធានី ខេត្ត** **នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **អ្នកជំនួយបច្ចេកទេស**

**ទម្រង់ទី១២**

## លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងសេវាកម្ម

| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ កសិកម្មចម្រុះសួនបន្លែ និងចិញ្ចឹមត្រីខេត្តកំពង់ចាម |
|---|---|---|

| ល.រ | ទីតាំងលទ្ធផល | | | លេខលទ្ធផល | ឈ្មោះលទ្ធផលគម្រោង | ថ្មី ឬ ពង្រឹង | តម្លៃប៉ាន់ស្មាន (រ) | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | | | | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ភូមិ១ | ឃុំ ក១ | ស្រុក ‹ក› | ២០១០១១១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ (សួនបន្លែ-ចិញ្ចឹមត្រី) | ថ្មី | វគ្គ | ៤ | ៦១៦.០០០ | ២.៤៦៤.០០០ |
| ២ | ភូមិ២ | ឃុំ ក១ | ស្រុក ‹ក› | ២០១០១១១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ (សួនបន្លែ-ចិញ្ចឹមត្រី) | ថ្មី | វគ្គ | ៤ | ៦១៦.០០០ | ២.៤៦៤.០០០ |
| ៣ | ភូមិ១ | ឃុំ ក១ | ស្រុក ‹ក› | ២០១០១២២ | ការធ្វើបង្ហាញអំពីសួនបន្លែ | ថ្មី | បង្ហាញ | ២០ | ២១៥.៦០០ | ៤.៣១២.០០០ |
| ៤ | ភូមិ២ | ឃុំ ក១ | ស្រុក ‹ក› | ២០១០១២២ | ការធ្វើបង្ហាញអំពីសួនបន្លែ | ថ្មី | បង្ហាញ | ២០ | ២១៥.៦០០ | ៤.៣១២.០០០ |
| ៥ | ភូមិ១ | ឃុំ ក១ | ស្រុក ‹ក› | ២០១០៤៣០ | ការធ្វើបង្ហាញអំពីចិញ្ចឹមត្រី | ថ្មី | បង្ហាញ | ២០ | ៣៨០.៦០០ | ៧.៦១២.០០០ |
| ៦ | ភូមិ២ | ឃុំ ក១ | ស្រុក ‹ក› | ២០១០៤៣០ | ការធ្វើបង្ហាញអំពីចិញ្ចឹមត្រី | ថ្មី | បង្ហាញ | ២០ | ៣៨០.៦០០ | ៧.៦១២.០០០ |
| តម្លៃប៉ាន់ស្មានគម្រោងសរុប | | | | | | | | | | **២៨.៧៧៦.០០០** |

**កំណត់សម្គាល់ ÷** មានតែលទ្ធផលគម្រោងដែលថវិកាគ្រប់គ្រាន់ប៉ុណ្ណោះ ត្រូវបានកត់ត្រានៅក្នុងទម្រង់នេះ។

| ថ្ងៃទី......... ខែ............. ឆ្នាំ.......... | ថ្ងៃទី......... ខែ............. ឆ្នាំ.......... | ថ្ងៃទី......... ខែ............. ឆ្នាំ.......... |
|---|---|---|
| **អភិបាលរាជធានី ខេត្ត** | **នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** | **អ្នកជំនួយបច្ចេកទេស** |

## ៧.៦. ការបំពេញទម្រង់ទីតាំងលទ្ធផលគម្រោង

ទម្រង់ទីតាំងលទ្ធផលគម្រោង (**ទម្រង់ទី១៣**) បង្ហាញនូវ ៖

- លេខកូដលទ្ធផល
- លេខអាប់ស៊ីស X (តួលេខដែលបង្ហាញដោយ GPS)
- លេខអ័រដោនេ Y (តួលេខដែលបង្ហាញដោយ GPS)
- យោបល់ផ្សេងៗ។

ទម្រង់ទី១៣

| ទីតាំងលទ្ធផលគម្រោង | | | |
|---|---|---|---|
| រាជធានី ខេត្ត ៖ | | | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ | | | |
| **លេខកូដលទ្ធផល** | GPS X | GPS Y | **យោបល់ផ្សេងៗ** |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

ថ្ងៃទី......... ខែ............. ឆ្នាំ.......... ថ្ងៃទី......... ខែ............. ឆ្នាំ..........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **អ្នកជំនួយបច្ចេកទេស**

## ៧.៧. បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ

បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ គឺជាបញ្ជីមួយដែលបរិយាយអំពីលេខកូដ ឈ្មោះ និងរង្វាស់ឯកតានៃលទ្ធផលគម្រោង។ ការបង្កើតបញ្ជីនេះក្នុងគោលបំណង គឺដើម្បីឱ្យមានការឯកភាពគ្នាក្នុងការប្រើប្រាស់លេខកូដ ឈ្មោះ និងរង្វាស់ឯកតានៃលទ្ធផលគម្រោង ដែលជាមធ្យោបាយមួយងាយស្រួលក្នុងការវាស់វែង ការតាមដាន និងការគ្រប់គ្រងលទ្ធផលគម្រោង។ បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារមាននៅ**ឧបសម្ព័ន្ធទី២**។

ក្នុងករណីរដ្ឋបាលរាជធានី ខេត្តអនុវត្តគម្រោងណាមួយ ដែលលទ្ធផលនៃគម្រោងនោះមិនមាននៅក្នុងបញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារ រដ្ឋបាលរាជធានី ខេត្តត្រូវស្នើសុំមក**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ** ដើម្បីផ្តល់លេខកូដសម្រាប់លទ្ធផលថ្មីនោះ។

# ជំពូកទី៨
# កិច្ចប្រតិបត្តិការ និងការថែទាំគម្រោង

# ជំពូកទី៨
# កិច្ចប្រតិបត្តិការ និងការថែទាំគម្រោង

## ៨.១. កិច្ចប្រតិបត្តិការគម្រោង

កិច្ចប្រតិបត្តិការគម្រោង គឺជាសកម្មភាព ឬកិច្ចការនានាដែលទាក់ទងទៅនឹងការប្រើប្រាស់លទ្ធផលគម្រោង ដែលត្រូវបានអនុវត្ត ឬចាត់ចែងគ្រប់គ្រងដោយមានការចូលរួមជាលក្ខណៈសមូហភាព (មិនមែនអ្នកប្រើប្រាស់ម្នាក់ៗនោះទេ)។ ចំពោះប្រភេទគម្រោងមួយចំនួន កិច្ចការប្រតិបត្តិការមានសារៈសំខាន់ណាស់ ប៉ុន្តែចំពោះប្រភេទគម្រោងមួយចំនួនទៀតមិនមានសារៈសំខាន់ទេ។

| **ឧទាហរណ៍អំពីកិច្ចប្រតិបត្តិការ** | |
|---|---|
| **ប្រភេទគម្រោង** | **កិច្ចប្រតិបត្តិការ** |
| សាងសង់សាលារៀន | ការបង្រៀន |
| ប្រព័ន្ធផ្គត់ផ្គង់ទឹកដោយទុយោទឹក | ការបូមទឹក<br>ការប្រមូលថ្លៃប្រើប្រាស់ពីអ្នកប្រើប្រាស់ |
| អណ្តូងខួងដោយប្រើស្នប់ដៃ | មិនមានកិច្ចប្រតិបត្តិការទេ |
| ប្រឡាយ និងទ្វារទឹក | ការបើក និងការបិទទ្វារទឹកទៅតាមពេលវេលាត្រឹមត្រូវ |
| ផ្លូវ | អាចមិនមានកិច្ចប្រតិបត្តិការទេ<br>ការបញ្ឈប់ចរាចរយានជំនិះធ្ងន់ នៅក្នុងអំឡុងពេលភ្លៀងធ្លាក់ |

## ៨.២. ការថែទាំគម្រោង

ការថែទាំគម្រោង គឺជាការថែទាំការពារ ឬការជួសជុលលទ្ធផលគម្រោង។ **ការថែទាំការពារ**ត្រូវបានធ្វើឡើងដើម្បីការពារលទ្ធផលគម្រោងកុំឱ្យឈានទៅដល់ការខូចខាតនានា។ **ការជួសជុល**ត្រូវបានធ្វើឡើងក្រោយពីលទ្ធផលគម្រោងបានខូចខាតរួចមកហើយ។

| | ម៉ូតូ<br> | ផ្លូវ<br> |
|---|---|---|
| ការថែទាំការពារ | ការប្តូរប្រេងម៉ាស៊ីន | ការសម្អាតប្រព័ន្ធដោះទឹក |
| ការជួសជុល | ការផ្លាស់កង់ម៉ូតូ | ការចាក់បំពេញជង្ហុក |

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជាធម្មតា ការថែទាំត្រូវបានចាត់ថ្នាក់ទៅតាមពេលវេលានៃការថែទាំ។ ការថែទាំមានបីប្រភេទ គឺការថែទាំជាប្រចាំ ការថែទាំជាខួប និងការថែទាំជាបន្ទាន់។

### ក). ការថែទាំជាប្រចាំ

ការថែទាំជាប្រចាំ គឺជាការថែទាំការពារ ឬការជួសជុលបន្តិចបន្តួចជាប្រចាំ ដើម្បីថែរក្សាលទ្ធផលគម្រោងឱ្យស្ថិតនៅស្ថានភាពល្អ ក្នុងអំឡុងពេលនៃអាយុកាលប្រើប្រាស់លទ្ធផលគម្រោង។ ជាធម្មតា ការថែទាំជាប្រចាំត្រូវបានធ្វើឡើងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ។ **ឧទាហរណ៍ ៖**

- ការចាក់ក្រួសក្រហមបំពេញជង្ហុកផ្លូវក្រួសក្រហមនៅរៀងរាល់៦ខែម្តង។
- ការជួសជុលបន្តិចបន្តួចនូវគ្រឿងសង្ហារឹមសាលារៀននៅចុងឆ្នាំនីមួយៗ។

**ខ). ការថែទាំជាខួប**

ការថែទាំជាខួប គឺជាការជួសជុលតាមពេលកំណត់ជាក់លាក់មួយ (នៅពេលផុតអាយុកាលប្រើប្រាស់លទ្ធផលគម្រោង) ដើម្បីធ្វើឱ្យលទ្ធផលគម្រោងមានស្ថានភាពល្អឡើងវិញ ដូចស្ថានភាពនៅពេលមិនទាន់ខូចខាត។ **ឧទាហរណ៍ ៖**

- ការក្រាលក្រួសក្រហមឡើងវិញនៅរៀងរាល់៥ឆ្នាំម្តង បន្ទាប់ពីបញ្ចប់ការសាងសង់។
- ការលាបថ្នាំអគារសិក្សាឡើងវិញនៅរៀងរាល់៥ឆ្នាំម្តង បន្ទាប់ពីបញ្ចប់ការសាងសង់។

**គ). ការថែទាំជាបន្ទាន់**

ការថែទាំជាបន្ទាន់ គឺការជួសជុលដែលត្រូវធ្វើឡើង បន្ទាប់ពីលទ្ធផលគម្រោងត្រូវបានខូចខាតដែលបណ្តាលមកពីព្រឹត្តិការណ៍មិនធម្មតា។ ឧទាហរណ៍ ការជួសជុលដំបូលអគារសិក្សា ដែលត្រូវបានខូចខាតដោយសារខ្យល់ព្យុះ។

តារាងខាងក្រោមនេះ ជាឧទាហរណ៍បង្ហាញពីការថែទាំជាប្រចាំ ការថែទាំជាខួប និងការថែទាំជាបន្ទាន់ ៖

| ប្រភេទនៃការថែទាំ | របៀបនៃការថែទាំ | ឧទាហរណ៍ |
|---|---|---|
| ការថែទាំជាប្រចាំ | • ម្តងក្នុងមួយឆ្នាំ (ឬញឹកញាប់) | • បំពេញជង្ហុក<br>• សម្អាតប្រឡាយដោះទឹក<br>• ជួសជុលជម្រាលជើងទេរផ្លូវ<br>• ជួសជុលស្ពានបន្តិចបន្តួច |
| ការថែទាំជាខួប | • រៀងរាល់៥ឆ្នាំម្តង<br>• រៀងរាល់១០ឆ្នាំម្តង | • ក្រាលក្រួសក្រហមឡើងវិញ<br>• ក្រាលក្តារកម្រាលស្ពានឡើងវិញ |
| ការថែទាំជាបន្ទាន់ | • នៅពេលដែលមានការខូចខាតកើតមានឡើង | • ជួសជុលផ្លូវបន្ទាប់ពីមានទឹកជំនន់ |

## ៨.៣. ការរៀបចំផែនការប្រតិបត្តិការ និងការថែទាំ

ផែនការប្រតិបត្តិការនិងការថែទាំ(**ទម្រង់ទី១៤**) ត្រូវភ្ជាប់មកជាមួយនឹងទម្រង់ព័ត៌មានគម្រោង។ ប្រសិនបើពុំមានផែនការប្រតិបត្តិការនិងការថែទាំទេ គម្រោងនឹងពុំទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេសឡើយ។

ផែនការប្រតិបត្តិការ និងការថែទាំមានព័ត៌មានសំខាន់ៗ ដូចខាងក្រោម ៖

១). **ការពិពណ៌នាអំពីគម្រោង** ៖ បរិយាយលម្អិតអំពីឈ្មោះ លទ្ធផល និងទីតាំងគម្រោង

២). **អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំលទ្ធផលគម្រោង**

អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំលទ្ធផលគម្រោងរាជធានី ខេត្ត អាចជា ៖

- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត (ឧទាហរណ៍ គម្រោងសាលារៀន)
- រដ្ឋបាលរាជធានី ខេត្ត (ឧទាហរណ៍ គម្រោងផ្លូវ)
- ក្រុមប្រើប្រាស់ (**ឧទាហរណ៍** គម្រោងអណ្តូងទឹក គឺក្រុមប្រើប្រាស់ទឹកនិងអនាម័យ គម្រោងប្រព័ន្ធធារាសាស្ត្រ គឺសហគមន៍កសិករប្រើប្រាស់ទឹក)
- ផ្នែកឯកជន (ឧទាហរណ៍ គម្រោងប្រព័ន្ធទឹកស្អាត)

**៣). ផែនការអនុវត្តន៍**

សកម្មភាពត្រូវបានបែងចែកដូចខាងក្រោម ៖

- សកម្មភាពប្រតិបត្តិការ
- សកម្មភាពថែទាំជាប្រចាំ និង
- សកម្មភាពថែទាំជាខួប។

សកម្មភាពនីមួយៗ ត្រូវកំណត់ឱ្យបានច្បាស់អំពីចំនួនដងនៃការអនុវត្តសកម្មភាពនោះក្នុងមួយឆ្នាំ និងអ្នកដែលត្រូវអនុវត្តសកម្មភាពនោះ។

**៤). តម្លៃប៉ាន់ស្មាន**

សកម្មភាពនីមួយៗ ត្រូវធ្វើការប៉ាន់ស្មានតម្លៃសម្រាប់ការអនុវត្តក្នុងមួយលើកៗ ហើយបន្ទាប់មកត្រូវធ្វើការប៉ាន់ស្មានតម្លៃសម្រាប់មួយឆ្នាំ។

ឧទាហរណ៍ ការថែទាំផ្លូវជាប្រចាំត្រូវធ្វើឡើងចំនួន២លើកក្នុង១ឆ្នាំ។ តម្លៃប៉ាន់ស្មានសម្រាប់ការថែទាំផ្លូវជាប្រចាំក្នុង១លើក គឺ ១.៦០០.០០០រៀល។ ដូច្នេះ តម្លៃប៉ាន់ស្មានសម្រាប់ការថែទាំជាប្រចាំក្នុង១ឆ្នាំ គឺ ៖

១.៦០០.០០០រៀល x ២ = ៣.២០០.០០០រៀល

ឧទាហរណ៍ ការថែទាំផ្លូវជាខួបត្រូវធ្វើឡើងចំនួន១លើកក្នុងរយៈពេល៥ឆ្នាំ។ តម្លៃប៉ាន់ស្មានសម្រាប់ការថែទាំផ្លូវជាខួប គឺ ៦៤.០០០.០០០រៀល។ ដូច្នេះ តម្លៃប៉ាន់ស្មានសម្រាប់ការថែទាំជាខួបក្នុង១ឆ្នាំ គឺ ៖

៦៤.០០០.០០០រៀល ចែកនឹង ៥ = ១២.៨០០.០០០រៀល

ដូច្នេះ តម្លៃប៉ាន់ស្មានសម្រាប់ការថែទាំក្នុងមួយឆ្នាំ គឺ ៖

៣.២០០.០០០រៀល + ១២.៨០០.០០០រៀល = ១៦.០០០.០០០រៀល

**៥). ប្រភពថវិកា**

ថវិកាសម្រាប់កិច្ចប្រតិបត្តិការ និងការថែទាំគម្រោង អាចបានមកពីប្រភព៣ គឺ ៖

- ថវិការាជធានី ខេត្ត
- ទុនចូលរួមរបស់សហគមន៍ ឬប្រជាពលរដ្ឋមូលដ្ឋាន
- កម្រៃប្រើប្រាស់របស់អ្នកប្រើប្រាស់លទ្ធផលគម្រោង។

ឧបសម្ព័ន្ធ១៤

## ផែនការប្រតិបត្តិការ និងការថែទាំគម្រោង

| | | |
|---|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ សាងសង់ផ្លូវក្រួសក្រហមប្រវែង៤គម និងស្ពានឈើ២កន្លែង នៅក្នុងភូមិ ១ និងភូមិ២ ឃុំក ១ ស្រុកៈកៈ។ |
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំលទ្ធផលគម្រោង ៖ រដ្ឋបាលខេត្ត | | |

| ផែនការអនុវត្តន៍ | | | | ផែនការហិរញ្ញវត្ថុ | | | |
|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ប៉ុន្មានដង | អ្នកធ្វើ | តម្លៃប៉ាន់ស្មាន (គិតជារៀល) | | ប្រភពថវិកា | តម្រូវការផ្សេងៗទៀត |
| | | | | ក្នុង១ដង | ក្នុង១ឆ្នាំ | | |
| **១. កិច្ចប្រតិបត្តិការ** | | | | | | | |
| | មិនមានសកម្មភាពទេ | | | | | | |
| **២. ការថែទាំជាប្រចាំ** | | | | | | | |
| ១ | ចាក់បំពេញជង្ហុក | ១ដងក្នុង១ឆ្នាំ | សហគមន៍ | ១.៦០០.០០០ | ១.៦០០.០០០ | អ្នកដឹកជញ្ជូនមូលដ្ឋាន | កម្លាំងពលកម្មសហគមន៍ចាក់បំពេញ និងបង្ហាប់ |
| ២ | ជួសជុលស្ពានតូចតាច | ២ដងក្នុង១ឆ្នាំ | ជាងក្នុងមូលដ្ឋាន | ៤០.០០០ | ៨០.០០០ | ទុនចូលរួមសហគមន៍ | |
| **៣. ការថែទាំជាខួប** | | | | | | | |
| ១ | ដាក់ក្រួសក្រហម | ៥ ឆ្នាំម្តង | អ្នកទទួលការ | ៦៤.០០០.០០០ | ១២.៨០០.០០០ | ថវិកាខេត្ត | |
| ២ | ជួសជុលក្តារកម្រាល ស្ពាន | ៤ ឆ្នាំម្តង | ជាងក្នុងមូលដ្ឋាន | ៣.០០០.០០០ | ៧៥០.០០០ | | |
| | តម្លៃប៉ាន់ស្មានសរុបក្នុង១ឆ្នាំ | | | | ១៥.២៣០.០០០ | | |

| | | |
|---|---|---|
| ថ្ងៃទី....... ខែ........... ឆ្នាំ.......... | ថ្ងៃទី....... ខែ........... ឆ្នាំ.......... | ថ្ងៃទី....... ខែ........... ឆ្នាំ.......... |
| **នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** | **តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំ** | **អ្នកជំនួយបច្ចេកទេស** |

## ផែនការប្រតិបត្តិការ និងថែទាំគម្រោង

| រាជធានី ខេត្ត ៖ ព្រៃវែង | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ ស្ថានីយបូមទឹក ប្រឡាយប្រវែង៣គ.ម និងទ្វារទឹក២កន្លែង។ |
|---|---|---|
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំលទ្ធផលគម្រោង ៖ សហគមន៍កសិករប្រើប្រាស់ទឹក | | |

| ផែនការអនុវត្តន៍ | | | | ផែនការហិរញ្ញវត្ថុ | | | |
|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ប៉ុន្មានដង | អ្នកធ្វើ | តម្លៃប៉ាន់ស្មាន (គិតជារៀល) | | ប្រភពថវិកា | តម្រូវការផ្សេងៗទៀត |
| | | | | ក្នុង១ដង | ក្នុង១ឆ្នាំ | | |
| **១. កិច្ចប្រតិបត្តិការ** | | | | | | | |
| ១ | ការបូមទឹក | ធ្វើស្រែ២ដង/១ឆ្នាំ | ក្រុមហ៊ុន | ២០.០០០.០០០ | ៤០.០០០.០០០ | ថ្លៃប្រើប្រាស់សេវាប្រព័ន្ធធារាសាស្ត្រ | |
| ២ | បើកបិទ ទ្វារទឹក | ពេលត្រូវការ | សហគមន៍កសិករប្រើទឹក | | | | |
| **២. ការថែទាំជាប្រចាំ** | | | | | | | |
| ១ | ថែទាំម៉ាស៊ីន | ពេលដែលខូច | ក្រុមហ៊ុន | | ៥០០.០០០ | ថ្លៃប្រើប្រាស់សេវាប្រព័ន្ធធារាសាស្ត្រ | កម្លាំងពលកម្មសហគមន៍ |
| ២ | ជួសជុលប្រឡាយរង | ១ឆ្នាំម្តង | កសិករ | | | កម្លាំងពលកម្មរបស់កសិករ | |
| **៣. ការថែទាំជាខួប** | | | | | | | |
| ១ | ជួសជុលប្រឡាយមេ ៣ឆ្នាំម្តង | ៣ឆ្នាំម្តង | អ្នកទទួលការ | ៩.០០០.០០០ | ៣.០០០.០០០ | ថ្លៃប្រើប្រាស់សេវាប្រព័ន្ធធារាសាស្ត្រ | |
| | | | | **តម្លៃប៉ាន់ស្មានសរុបក្នុង១ឆ្នាំ** | ៤៣.៥០០.០០០ | ក្រុមហ៊ុនយកថ្លៃ២០០.០០០រៀល/១ហិកតា ក្នុង១រដូវច្រូតកាត់ x ២រដូវ x ១១០ហិកតា = ៤៤.០០០.០០០រៀល/ឆ្នាំ | |

| ថ្ងៃទី....... ខែ........... ឆ្នាំ.......... | ថ្ងៃទី....... ខែ........... ឆ្នាំ.......... | ថ្ងៃទី....... ខែ........... ឆ្នាំ.......... |
|---|---|---|
| **នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** | **តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំ** | **អ្នកជំនួយបច្ចេកទេស** |

## ៨.៤. ការរៀបចំគម្រោងសម្រាប់សកម្មភាពថែទាំ

ថវិការាជធានី ខេត្តអាចត្រូវបានប្រើប្រាស់សម្រាប់ការថែទាំគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈណាមួយដែលរដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះអាចត្រូវបានស្ថាបនាដោយថវិការបស់រាជធានី ខេត្ត ឬទីភ្នាក់ងារដទៃ។

### ក). ការថែទាំជាប្រចាំនៃលទ្ធផលគម្រោងរាជធានី ខេត្ត

ការថែទាំជាប្រចាំនៃលទ្ធផលគម្រោងរាជធានី ខេត្តត្រូវបានកំណត់ថា ជាលទ្ធផលថ្មីនៃគម្រោងដើម។

| |
|---|
| **ឧទាហរណ៍ ៖**<br>នៅឆ្នាំ២០១៣ រដ្ឋបាលខេត្ត"ក" ក្រាលក្រួសក្រហមប្រវែង៥គ.ម នៅលើផ្លូវដីសដែលមានស្រាប់។<br>• **លទ្ធផល ៖** ផ្លូវក្រួសក្រហមប្រវែង ៥គ.ម (ការកែលម្អ)<br>នៅឆ្នាំ២០១៤ រដ្ឋបាលខេត្ត"ក"ធ្វើការថែទាំផ្លូវជាប្រចាំដើម្បីរក្សាស្ថានភាពផ្លូវឱ្យនៅល្អ។<br>• **លទ្ធផល ៖** ផ្លូវក្រួសក្រហមប្រវែង ៥គ.ម (ការថែទាំជាប្រចាំ)<br>ដូច្នេះ ការថែទាំជាប្រចាំនៃលទ្ធផលគម្រោងនេះ មិនត្រូវការ ៖<br>– ទម្រង់ព័ត៌មានគម្រោង<br>– ការពិនិត្យបញ្ជាក់បច្ចេកទេស។<br>ការថែទាំជាប្រចាំនៃលទ្ធផលគម្រោងរាជធានី ខេត្ត ត្រូវការ ៖<br>– ការត្រួតពិនិត្យបច្ចេកទេស (ការអង្កេតបច្ចេកទេស) ដើម្បីបញ្ជាក់អំពីស្ថានភាពបច្ចុប្បន្នរបស់លទ្ធផលគម្រោង<br>– ការប៉ាន់ស្មានតម្លៃ។ |

### ខ). ការថែទាំជាប្រចាំនៃហេដ្ឋារចនាសម្ព័ន្ធដែលមិនមែនជាលទ្ធផលនៃថវិការាជធានី ខេត្ត

ចំពោះហេដ្ឋារចនាសម្ព័ន្ធដែលបានស្ថាបនាដោយមិនបានប្រើប្រាស់ថវិការាជធានី ខេត្ត ការប្រើប្រាស់ថវិការាជធានី ខេត្តលើកដំបូងក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធនេះ នឹងត្រូវបានចាត់ទុកថា ជាគម្រោងថ្មី។

នៅឆ្នាំបន្តបន្ទាប់មក ការបន្តការថែទាំជាប្រចាំនឹងត្រូវបានចាត់ទុកថា ជាគម្រោងបន្ត។

ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលមួយបានផ្តល់មូលនិធិសម្រាប់សាងសង់ផ្លូវក្រួសក្រហមប្រវែង ៤គ.មនៅក្នុងខេត្ត"ខ"។ ការសាងសង់ត្រូវបានបញ្ចប់នៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៤ ស្រទាប់លើរបស់ផ្លូវបានខូចខាត។ រដ្ឋបាលខេត្ត"ខ" សម្រេចប្រើប្រាស់ថវិការបស់ខេត្តសម្រាប់ការថែទាំផ្លូវនេះ។

នៅឆ្នាំ២០១៤ ខេត្ត"ខ" ត្រូវរៀបចំទម្រង់ព័ត៌មានគម្រោង និងផ្ញើជូនមន្ទីរ អង្គភាពជំនាញដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។

- **លទ្ធផលគម្រោង ៖** ផ្លូវក្រួសក្រហមប្រវែង ៤គ.ម (ការថែទាំជាប្រចាំ)
  នៅឆ្នាំ២០១៥ រដ្ឋបាលខេត្ត"ខ"សម្រេចបន្តថែទាំផ្លូវនេះ។ ក្នុងករណីនេះ ខេត្ត"ខ"មិនចាំបាច់ធ្វើទម្រង់ព័ត៌មានគម្រោងដទៃផ្សេងទៀតនោះទេ ពីព្រោះការងារនេះគឺជាលទ្ធផលថ្មីនៃគម្រោងដដែល។
- **លទ្ធផលគម្រោង ៖** ផ្លូវក្រួសក្រហមប្រវែង ៤គ.ម (ការថែទាំជាប្រចាំ)

**ឥ). ការរៀបចំគម្រោងសម្រាប់ការថែទាំជាខួប**

ការថែទាំជាខួបនៃហេដ្ឋារចនាសម្ព័ន្ធដែលប្រើប្រាស់ថវិការាជធានី ខេត្ត ត្រូវបានចាត់ទុកថា ជាគម្រោងថ្មី។ លទ្ធផល គឺជាការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។ ឧទាហរណ៍ ការជួសជុលផ្លូវក្រួសក្រហម ប្រវែង៥គ.ម។ នៅក្នុងករណីនេះ ត្រូវការ"ទម្រង់ព័ត៌មានគម្រោង" និង"ការពិនិត្យបញ្ជាក់បច្ចេកទេស"។

## ៨.៥. ការអង្កេតបច្ចេកទេសសម្រាប់ការថែទាំជាប្រចាំ

អ្នកជំនួយបច្ចេកទេសត្រូវជួយរដ្ឋបាលរាជធានី ខេត្តក្នុងការអង្កេតបច្ចេកទេសទៅលើលទ្ធផលគម្រោង។ គោលបំណងនៃការអង្កេតបច្ចេកទេសសម្រាប់ការថែទាំជាប្រចាំ គឺដើម្បីកំណត់រកប្រភេទសកម្មភាពថែទាំនានា ដែលត្រូវការ និងទំហំការងារ។

ជំហាននានានៃការអង្កេតបច្ចេកទេស មានដូចខាងក្រោម ៖

- កំណត់អំពីសូចនាករនានាដែលបង្ហាញអំពីស្ថានភាពនៃលទ្ធផលគម្រោង។ សូចនាករទាំងនេះត្រូវតែអាចវាស់វែងបាន
- កំណត់អំពីស្ថានភាព(ល្អ ល្អបង្គួរ មធ្យម និងអន់)នៃសូចនាករទាំងនេះ ផ្អែកតាមបទដ្ឋានបច្ចេកទេស
- ចុះអង្កេតផ្ទាល់នៅទីតាំងលទ្ធផលគម្រោងដើម្បីកំណត់អំពីស្ថានភាពជាក់ស្តែងនៃសូចនាករនីមួយៗ
- វាស់វែងទំហំខូចខាតនៃសូចនាករនីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការគណនាបរិមាណការងារ និងសម្ភារៈដែលត្រូវការសម្រាប់ការជួសជុល
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអង្កេតបច្ចេកទេស។

**ឧទាហរណ៍ ÷ សូចនាករ និងស្ថានភាពផ្លូវ**

| សូចនាករ | ស្ថានភាព | | | |
|---|---|---|---|---|
| | ល្អ | ល្អបង្គួរ | មធ្យម | អន់ |
| ខ្នងអណ្តើកផ្លូវ | ៦-៧% | <៦-៤% | <៤-២% | <២% |
| ជង្ហុក | ពុំមានជង្ហុក | <១៥% នៃផ្ទៃតួផ្លូវ | ១៥-៤០% នៃផ្ទៃតួផ្លូវ | >៤០% នៃផ្ទៃតួផ្លូវ |
| ជើងទេរផ្លូវ | – ពុំមានការហូរច្រោះ<br>– គម្របស្មៅដុះល្អ | – ការហូរច្រោះ<១៥% នៃជើងទេរ<br>– គម្របស្មៅខូចខាត <១៥% នៃជើងទេរ | – ការហូរច្រោះ ១៥-៤០% នៃជើងទេរ<br>– គម្របស្មៅខូចខាត ១៥-៤០% នៃជើងទេរ | – ការហូរច្រោះ>៤០% នៃជើងទេរ<br>– គម្របស្មៅខូចខាត >៤០% នៃជើងទេរ |
| កម្រាស់ក្រួសក្រហម | ១៤០-១៥០មម | <១៤០-១១០មម | <១១០-៨០មម | <៨០មម |

**កំណត់សម្គាល់ ÷** ប្រសិនបើលទ្ធផលនៃការអង្កេតបច្ចេកទេស ត្រូវបានវាយតម្លៃថា ផ្លូវស្ថិតនៅក្នុងស្ថានភាពអន់ ផ្លូវនេះពុំសមស្របសម្រាប់ការថែទាំជាប្រចាំទេ គឺសមស្របសម្រាប់ការថែទាំជាខួប។

**ឧទាហរណ៍ ÷ លទ្ធផលនៃការអង្កេតបច្ចេកទេសនៅលើផ្លូវ**

| ពី | ដល់ | ស្ថានភាពផ្លូវ | ឃោបល់ |
|---|---|---|---|
| ០ម | ១៨០ម | ល្អបង្គួរ | ការកកស្ទះតិចតួច នៅក្នុងប្រឡាយបង្ហូរទឹកត្រូវសម្អាត |
| ១៨០ម | ៥០០ម | មធ្យម | ខ្នងអណ្តើកផ្លូវ ២-៥%។ ជង្ហុកផ្លូវ ជម្រៅរហូតដល់៦០មម គ្របដណ្តប់ប្រហែលជា៣០% នៃផ្លូវ។ |
| ៥០០ម | ១២០០ម | ល្អបង្គួរ | នៅម៉ែត្រទី៨៣០ ៖ លូស្ទះត្រូវការសម្អាត<br>នៅម៉ែត្រទី៩៥០ ៖ ជើងទេរផ្លូវត្រូវបានបំផ្លាញដោយសត្វពាហនៈ |
| ១២០០ម | ១២៦០ម | អន់ | ផ្លូវត្រូវបានបំផ្លាញដោយទឹកជំនន់។ ត្រង់ចំណុចនេះត្រូវក្រាលក្រួសក្រហមជាថ្មី។ |
| ១២៦០ម | ១៥៥០ម | ល្អបង្គួរ | ចង្ហូរគ្របដណ្តប់ប្រហែល១០%នៃផ្លូវ |

## ៨.៦. ការប៉ាន់ស្មានតម្លៃសម្រាប់ការថែទាំជាប្រចាំ

ការប៉ាន់ស្មានតម្លៃសម្រាប់ការថែទាំជាប្រចាំ ត្រូវអនុវត្តដូចគ្នានឹងគោលការណ៍ណែនាំ សម្រាប់ប្រភេទសកម្មភាពដទៃទៀតដែរ។

ការងារថែទាំ អាចចែកជាពីរប្រភេទសកម្មភាព ៖

១). សកម្មភាពដែលត្រូវធ្វើមួយលើក (១ដង) ដើម្បីធ្វើឱ្យស្ថានភាពពី "មធ្យម" ទៅ "ល្អ"

២). សកម្មភាពដែលត្រូវធ្វើច្រើនដង ដើម្បីរក្សាស្ថានភាពផ្លូវ ឱ្យស្ថិតនៅស្ថានភាព "ល្អបង្គួរ" ឬ"ល្អ"

មិនមែនគ្រប់គម្រោងថែទាំទាំងអស់ នឹងមានទាំងពីរប្រភេទសកម្មភាពនោះទេ។ ឧទាហរណ៍ ៖

- រដ្ឋបាលខេត្ត"ក" សាងសង់ផ្លូវថ្មីមួយខ្សែ និងថែទាំផ្លូវនេះរយៈពេល៦ខែ។ នៅចុងបញ្ចប់នៃរយៈពេលថែទាំផ្លូវ រដ្ឋបាលខេត្ត"ក" សម្រេចធ្វើការថែទាំផ្លូវនេះឱ្យស្ថិតនៅក្នុងស្ថានភាពល្អ។ គម្រោងថ្មីនេះនឹងមានតែសកម្មភាពដែលបន្តពីគម្រោងមុនប៉ុណ្ណោះ។
- នៅក្នុងខេត្ត"ខ"មានផ្លូវដីជាច្រើន។ នៅចុងបញ្ចប់នៃរដូវវស្សា ផ្លូវទាំងនេះមានស្ថានភាពមធ្យម។ រដ្ឋបាលខេត្ត"ខ" សម្រេចជួសជុលតែមួយលើក ដើម្បីឱ្យផ្លូវទាំងនេះមានស្ថានភាពល្អ។ ឆ្នាំបន្ទាប់ រដ្ឋបាលខេត្ត"ខ" នឹងបន្តអនុវត្តដូចគ្នានេះ។ ដូច្នេះ គម្រោងមានតែសកម្មភាពដែលត្រូវអនុវត្តតែមួយលើកប៉ុណ្ណោះ។

**ការប៉ាន់ស្មានតម្លៃសម្រាប់ការថែទាំផ្លូវក្រួសក្រហម និងផ្លូវដី មានដូចខាងក្រោម ៖**

### ក). ការប៉ាន់ស្មានបរិមាណការងារ

- ប៉ាន់ស្មានបរិមាណដី ឬក្រួសក្រហម ដើម្បីបំពេញជើងទេរដែលខូចខាតដោយសារការហូរច្រោះ
- វាស់ទំហំផ្ទៃជើងទេរដែលខូចខាត ដែលត្រូវជួសជុល និងដាំស្មៅ
- វាស់ប្រវែងប្រឡាយបង្ហូរទឹក ឬលូដែលត្រូវសម្អាត
- ប៉ាន់ស្មានបរិមាណដី ឬក្រួសក្រហម ដែលត្រូវបំពេញជង្ហុក ឬចង្ហូរ
- បំពេញខ្នងអណ្តើកឡើងវិញឱ្យបាន៧% ដោយកៀរ និងបង្ហាប់។

**៩). ការគណនាតម្លៃឯកតាសម្រាប់ការងារនីមួយៗ**

- តម្លៃឯកតាគ្រួសក្រហម និងដី អាចយកពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ
- តម្លៃឯកតាដឹក អាចយកពីបញ្ជីតម្លៃសម្ភារៈស្តង់ដារ
- តម្លៃឯកតាសម្រាប់ជួសជុល និងដាំស្មៅជើងទេរ អាចគណនាដូចខាងក្រោម ៖

  ឧទាហរណ៍ ៖ តម្លៃឯកតាសម្រាប់ជួសជុល និងដាំស្មៅជើងទេរ ៖

  – បទដ្ឋានពលកម្មសម្រាប់ជួសជុល និងដាំស្មៅជើងទេរ = ១០ម$^{២}$ ក្នុង១នាក់ ក្នុង១ថ្ងៃ
  – តម្លៃពលកម្មគ្មានជំនាញ = ១៥.០០០រៀលក្នុង១នាក់ក្នុង១ថ្ងៃ
  – តម្លៃពលកម្មសម្រាប់ ១ម$^{២}$ = ១៥.០០០រៀល *ចែកនឹង* ១០ = ១.៥០០រៀល
  – តម្លៃឧបករណ៍តូចតាចសម្រាប់ ១ម$^{២}$ = ១.៥០០រៀល x 0,0៣ = ៤៥រៀល
  – តម្លៃស្មៅក្នុង១ម$^{២}$ = ២.០០០រៀល
  – តម្លៃជួសជុល និងដាំស្មៅជើងទេរសម្រាប់ ១ម$^{២}$ = ១.៥០០រៀល + ៤៥រៀល = ១.៥៤៥រៀល
  – ដូច្នេះ **តម្លៃឯកតាសម្រាប់ជួសជុល និងដាំស្មៅជើងទេរ១ម$^{២}$** គឺ ១.៥០០៛ + ៤៥៛ + ២.០០០៛ = **៣.៥៤៥៛/ម$^{២}$**

- តម្លៃឯកតាសម្រាប់ស្តារ ឬសម្អាតប្រឡាយបង្ហូរទឹក និងលូ អាចគណនាដូចខាងក្រោម ៖

  ឧទាហរណ៍ ៖ តម្លៃឯកតាសម្រាប់ស្តារ ឬសម្អាតប្រឡាយបង្ហូរទឹក និងលូ ៖

  – បទដ្ឋានពលកម្មសម្រាប់ស្តារ ឬប្រឡាយបង្ហូរទឹក និងលូ = ៣០ម ក្នុង១នាក់ ក្នុង១ថ្ងៃ
  – តម្លៃកម្មករគ្មានជំនាញ = ១៥.០០០រៀលក្នុង១នាក់ក្នុង១ថ្ងៃ
  – តម្លៃពលកម្មសម្រាប់១គ.ម = ១៥.០០០ *ចែកនឹង* ៣០ *គុណនឹង* ១.០០០ = ៥០០.០០០៛/គ.ម
  – តម្លៃឧបករណ៍តូចតាចសម្រាប់ ១គ.ម = 0,0៣ *គុណនឹង* ៥០០.០០០ = ១៥.០០០៛/គ.ម
  – ដូច្នេះ **តម្លៃឯកតាសម្រាប់ស្តារឬសម្អាតប្រឡាយបង្ហូរទឹកនិងលូក្នុង១គ.ម** គឺ ៥០០.០០០៛ + ១៥.០០០៛ = **៥១៥.០០០៛/គ.ម**

- តម្លៃឯកតាក្នុងការចាក់បំពេញជង្ហុក និងចង្អូរ គៀរ ស្រោចទឹក និងបង្ហាប់ ៖

  ☞ តម្លៃឯកតាសម្រាប់ចាក់បំពេញជង្ហុក និងចង្អូរ គៀរ ស្រោចទឹក និងកិនបង្ហាប់ដោយប្រើប្រាស់គ្រឿងចក្រ អាចគណនាដូចខាងក្រោម ៖

| ល.រ | ប្រភេទដី | តម្លៃឯកតាក្នុងការចាក់បំពេញ គៀរ ស្រោចទឹក និងកិនបង្ហាប់ (រៀល/ម$^{២}$) |
|---|---|---|
| ១ | ដីគ្មានគ្រួស ឬថ្ម | ៣០០ + 0,0៦ x D |
| ២ | ដីមានលាយគ្រួស (គ្រួសក្រហម) | ៤០០ + 0,0៨ x D |

D គឺជាតម្លៃប្រេងម៉ាស៊ូតក្នុងមួយលីត្រ គិតជារៀល។

**ឧទាហរណ៍ ៖ ការប៉ាន់ស្មានតម្លៃថែទាំសម្រាប់ផ្លូវគ្រួសក្រហមប្រវែង ៣គ.ម ទទឹង ៦ម ៖**

បន្ទាប់ពីធ្វើការសិក្សារួច អ្នកជំនួយបច្ចេកទេសប៉ាន់ស្មានបរិមាណការងារថែទាំដូចខាងក្រោម ៖

– បរិមាណដីសម្រាប់ជួសជុលជើងទេរ ៖ ៤០ម$^{៣}$
– ផ្ទៃជើងទេរដែលត្រូវជួសជុល និងដាំស្មៅ ៖ ៤០០ម$^{២}$
– ស្តារ ឬសម្អាតប្រឡាយបង្ហូរទឹក និងលូ ៖ ៣គ.ម

- បរិមាណក្រួសក្រហមដែលត្រូវចាក់បំពេញជង្ហុក និងចង្អូរ ៖ ១៣០ម$^3$
- ការចាក់បំពេញ កៀរ ស្រោចទឹក និងកិនបង្ហាប់ ៖ ១៨.០០០ម$^2$

**តម្លៃឯកតា ៖**

- តម្លៃដី ៖ ១ម$^3$ = ១.៥០០រៀល
- តម្លៃជីកដី (ងាយស្រួល) ៖ ១ម$^3$ = ២.៥៥០រៀល
- តម្លៃដឹកជញ្ជូនដី និងក្រួសក្រហម (ចម្ងាយផ្លូវ១០គ.ម ស្ថានភាពមធ្យម) ៖ T = ៥៥០៛ x ១០គ.ម = ៥.៥០០៛/តោន/គ.ម
- តម្លៃជួសជុលជើងទេរ និងដាំស្មៅ ៖ ៣.៥៤៥៛/ម$^2$
- តម្លៃស្ការ ឬសម្អាតប្រឡាយបង្ហូរទឹក និងលូ ៖ ៥១៥.០០០៛/គ.ម
- តម្លៃក្រួសក្រហម ១ម$^3$ = ១០.០០០រៀល
- តម្លៃជីកក្រួសក្រហម (មធ្យម) ៖ ១ម$^3$ = ៣.១៥០រៀល
- តម្លៃចាក់បំពេញ កៀរ ស្រោចទឹក និងកិនបង្ហាប់ (ក្រួសក្រហម) ៖ ១ម$^2$ = ៤០០ + 0,0៨ x ៥.០០០៛ = ៨០០៛/ម$^2$
- តម្លៃដឹកជញ្ជូនសម្ភារៈទៅការដ្ឋាន (ចម្ងាយផ្លូវ១០គ.ម ស្ថានភាពមធ្យម) ៖ T = ១.១៥០៛ x ១០គ.ម = ១១.៥០០៛/តោន/គ.ម

☞ តម្លៃឯកតាសម្រាប់ចាក់បំពេញជង្ហុក និងចង្អូរ កៀរ ស្រោចទឹក និងបុកបង្ហាប់ដោយកម្លាំងពលកម្ម អាចគណនាដូចខាងក្រោម ៖

**ឧទាហរណ៍ ៖ ទំហំមធ្យមរបស់ជង្ហុក គឺ 0,៥ x 0,៥ x ជម្រៅ0,២ម ហើយផ្លូវប្រវែង១គ.ម មានជង្ហុកចំនួនប្រមាណ២៥០។**

- បទដ្ឋានពលកម្មសម្រាប់ចាក់បំពេញជង្ហុក និងបង្ហាប់ ៖ ១០ជង្ហុក ក្នុង១នាក់ ក្នុង១ថ្ងៃ
- តម្លៃពលកម្មគ្មានជំនាញ ៖ ១៥.០០០រៀល ក្នុង១នាក់ក្នុង១ថ្ងៃ
- តម្លៃពលកម្មសម្រាប់១ជង្ហុក ៖ ១៥.០០០ *ចែកនឹង* ១០ = ១.៥០០រៀល/ជង្ហុក
- តម្លៃឧបករណ៍តូចតាចសម្រាប់១ជង្ហុក ៖ ១.៥០០៛ x 0,0៣ = ៤៥រៀល/ជង្ហុក
- តម្លៃឯកតាសម្រាប់ចាក់បំពេញ និងបង្ហាប់១ជង្ហុក ៖ ១.៥០០ + ៤៥ = ១.៥៤៥៛/ជង្ហុក

ដូច្នេះ តម្លៃសម្រាប់ចាក់បំពេញជង្ហុកនិងបង្ហាប់សម្រាប់ផ្លូវដី១គ.ម ៖ ២៥០ជង្ហុក x ១.៥៤៥៛/ជង្ហុក = ៣៨៦.២៥០រៀល/គ.ម។

| ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់ការងារដី | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ គម្រោងថែទាំជាប្រចាំនូវផ្លូវក្រួសក្រហមពីទីរួមស្រុក.ខ. មកទីរួមខេត្ត | |
| ការពិពណ៌នាលទ្ធផលគម្រោង ៖ ថែទាំជាប្រចាំលើផ្លូវក្រាលក្រួសក្រហម ប្រវែង៣គ.ម ដែលមានទទឹង៦ម។ | |
| ទីតាំងលទ្ធផលគម្រោង ៖ ភូមិ១ និងភូមិ២ នៃឃុំ ខ១ ស្រុក.ខ. | |

**ការប៉ាន់ស្មានតម្លៃ សម្រាប់លទ្ធផលនាំមុខ**

| ល.រ | ការពិពណ៌នា | ឯកតា | ចំនួន | តម្លៃឯកតា (៛) | សរុប (៛) |
|---|---|---|---|---|---|
| ១ | ទិញដី | ម³ | ៤០ | ១.៥០០ | ៦០.០០០ |
| ២ | ជីកដី (ងាយស្រួល) | ម³ | ៤០ | ២.៥៥០ | ១០២.០០០ |
| ៣ | ដឹកជញ្ជូនដី | ម³ | ៤០ | ៥.៥០០ | ២២០.០០០ |
| ៤ | ជួសជុល និងដាំស្មៅជើងទេរ | ម² | ៤០០ | ៣.៥៤៥ | ១.៤១៨.០០០ |
| ៥ | សម្អាតប្រឡាយបង្ហូរទឹក និងលូ | គ.ម | ៣ | ៥១៥.០០០ | ១.៥៤៥.០០០ |
| ៦ | ទិញក្រួសក្រហម | ម³ | ១៣០ | ១០.០០០ | ១.៣០០.០០០ |
| ៧ | ជីកក្រួសក្រហម (មធ្យម) | ម³ | ១៣០ | ៣.១៥០ | ៤០៩.៥០០ |
| ៨ | ដឹកជញ្ជូនក្រួសក្រហម | ម³ | ១៣០ | ៥.៥០០ | ៧១៥.០០០ |
| ៩ | ចាក់បំពេញ កៀរ ស្រោចទឹក បង្ហាប់ | ម² | ១៨.០០០ | ៨០០ | ១៤.៤០០.០០០ |
| ១០ | ដឹកជញ្ជូនគ្រឿងចក្រ | ត | ៣០ | ១១.៥០០ | ៣៤៥.០០០ |
| តម្លៃផ្ទាល់សរុប | | | | | ២០.៥១៤.៥០០ |
| តម្លៃប្រយោល និងប្រាក់ចំណេញ | | | | ១០% | ២.០១៥.៤៥០ |
| តម្លៃសរុប | | | | | **២២.៥៦៥.៩៥០** |

**តម្លៃក្នុងមួយឯកតានៃលទ្ធផល**

| ការពិពណ៌នា | ឯកតា | ចំនួន | តម្លៃសរុប (៛) | តម្លៃឯកតា (៛) |
|---|---|---|---|---|
| ជួសជុលផ្លូវក្រួសក្រហម | គ.ម | ៣ | ២២.៥៦៥.៩៥០ | ៧.៥២១.៩៨៣ |

| ឈ្មោះផ្សារ ៖ ផ្សារ.ខ. | ចម្ងាយផ្លូវដឹកជញ្ជូន ៖ ១០គ.ម (ស្ថានភាពផ្លូវមធ្យម) |
|---|---|

| ថ្ងៃទី...... ខែ......... ឆ្នាំ....... | ថ្ងៃទី...... ខែ......... ឆ្នាំ....... | ថ្ងៃទី...... ខែ......... ឆ្នាំ....... |
|---|---|---|
| **អភិបាលរាជធានី ខេត្ត** | **នាយកទីចាត់ការផែនការ និងវិនិយោគ** | **អ្នកជំនួយបច្ចេកទេស** |

# ជំពូកទី៩

# គោលការណ៍ណែនាំ

# ស្តីពីការវភាគផលប៉ះពាល់បរិស្ថាន

# ជំពូកទី៩
# គោលការណ៍ណែនាំស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន

## ៩.១. និយមន័យនៃការវិភាគផលប៉ះពាល់បរិស្ថាន

**ការវិភាគផលប៉ះពាល់បរិស្ថាន** គឺជាដំណើរការសិក្សាមួយ ដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានក្នុងការប្រមើលមើលផលប៉ះពាល់បរិស្ថាននានាដែលកើតឡើងដោយសារគម្រោង ដើម្បីកំណត់វិធានការការពារ ឬបន្ធូរបន្ថយ និងរៀបចំផែនការគ្រប់គ្រង និងតាមដានផលប៉ះពាល់បរិស្ថានទាំងនោះ។ **ផលប៉ះពាល់បរិស្ថាន** គឺជាផលប៉ះពាល់ទៅលើបរិស្ថានធម្មជាតិ និងស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ការវិភាគផលប៉ះពាល់បរិស្ថានត្រូវអនុវត្តឱ្យបានរួចរាល់ នៅមុនពេលទម្រង់ព័ត៌មានគម្រោងត្រូវបានបំពេញចប់សព្វគ្រប់។

ចំពោះគម្រោងទាំងឡាយណាដែលមានទីតាំងស្ថិតនៅក្នុងឃុំ សង្កាត់ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិនិត្យទៅលើការពិនិត្យអំពីតម្រូវការការសិក្សាផលប៉ះពាល់បរិស្ថាននៃគម្រោងទាំងនោះ ដើម្បីបញ្ជាក់អំពីសក្តានុពលផលប៉ះពាល់បរិស្ថាននៃគម្រោងទាំងនោះ ដែលត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថាន។

បញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន គឺជាបញ្ជីមួយដែលចង្អុលបង្ហាញអំពីបណ្តាឃុំ សង្កាត់ដែលស្ថិតនៅក្នុងតំបន់ដីសើម និងតំបន់ការពារផ្សេងៗទៀត ដែលតំបន់ទាំងនោះងាយនឹងទទួលរងនូវផលប៉ះពាល់បរិស្ថាន។

## ៩.២. អ្នកទទួលខុសត្រូវក្នុងការវិភាគផលប៉ះពាល់បរិស្ថាន

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទទួលខុសត្រូវក្នុងការវិភាគផលប៉ះពាល់បរិស្ថាន ដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានដែលនឹងទទួលរងនូវផលប៉ះពាល់ពីគម្រោង។ ប្រជាពលរដ្ឋដទៃទៀតក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការវិភាគផលប៉ះពាល់បរិស្ថានផងដែរ។ ជាការប្រសើរ ប្រសិនបើមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ប្រភេទ ដូចជា យុវជន ចាស់ បុរស ស្ត្រី កសិករ និងព្រះសង្ឃជាដើម។

គម្រោងទាំងឡាយដែលមានទីតាំងនៅក្នុងឃុំ សង្កាត់ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ហើយដែលត្រូតពិនិត្យឃើញថា មានសក្តានុពលនៃផលប៉ះពាល់បរិស្ថាន ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវចុះពិនិត្យដល់ទីតាំងគម្រោង និងផ្តល់ការណែនាំអំពីរបៀបធ្វើការវិភាគផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។

## ៩.៣. ទីកន្លែងសម្រាប់ធ្វើការវិភាគផលប៉ះពាល់បរិស្ថាន

ការវិភាគផលប៉ះពាល់បរិស្ថានត្រូវធ្វើនៅទីតាំងគម្រោង ឬជិតទីតាំងគម្រោង ដែលប្រជាពលរដ្ឋងាយស្រួលក្នុងការចូលរួម។ ចំពោះគម្រោងមួយចំនួន ចាំបាច់ត្រូវធ្វើការសិក្សាឬធ្វើការវិភាគផ្ទាល់នៅទីតាំងគម្រោងជាមួយប្រជាពលរដ្ឋមូលដ្ឋាន។

## ៩.៤. ការផ្សព្វផ្សាយអំពីគម្រោងដល់ប្រជាពលរដ្ឋ

ជំហានដំបូងនៃការវិភាគផលប៉ះពាល់បរិស្ថាន គឺការរៀបចំប្រជុំមួយជាមួយប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយ និងជម្រាបដល់ប្រជាពលរដ្ឋឱ្យបានយល់ច្បាស់អំពី ៖

- លទ្ធផលគម្រោង
- របៀបអនុវត្តគម្រោង
- ផលប្រយោជន៍ដែលរំពឹងថា នឹងទទួលបានពីគម្រោង

- មូលហេតុចាំបាច់ដែលតម្រូវឱ្យធ្វើការវិភាគផលប៉ះពាល់បរិស្ថានចំពោះគម្រោង
- លទ្ធផលនៃការវិភាគផលប៉ះពាល់បរិស្ថាន គឺគ្រាន់តែជាការផ្តល់អនុសាសន៍តែប៉ុណ្ណោះ។ ជួនកាលអនុសាសន៍ដែលបានលើកឡើង អាចនឹងមិនត្រូវបានអនុវត្តតាមទាំងស្រុងនោះទេ។

## ៩.៥ ការរៀបចំផែនទីបរិស្ថាន

បន្ទាប់ពីផ្សព្វផ្សាយអំពីគម្រោងដល់ប្រជាពលរដ្ឋ ជំហានបន្ទាប់ គឺការរៀបចំផែនទីបរិស្ថានរបស់គម្រោងជាមួយប្រជាពលរដ្ឋ។ ផែនទីបរិស្ថាននេះត្រូវផ្អែកតាមផែនទីគម្រោងនៅក្នុងទម្រង់ព័ត៌មានគម្រោង។

កិច្ចដំណើរការនៃការរៀបចំផែនទីបរិស្ថានមានដូចខាងក្រោម ៖

- គូសចម្លងផែនទីគម្រោងនៅលើផ្ទាំងក្រដាសធំ ដើម្បីឱ្យប្រជាពលរដ្ឋមូលដ្ឋានអាចមើលឃើញ និងចូលរួមយោបល់
- ពិភាក្សាជាមួយប្រជាពលរដ្ឋ ដើម្បីបញ្ចូលព័ត៌មានសំខាន់ៗនៅលើផែនទី
- ចម្លងផែនទីបរិស្ថានចូលក្រដាសទំហំអា៤សម្រាប់ភ្ជាប់ជាមួយរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។

ព័ត៌មានសំខាន់ៗ ដែលត្រូវបង្ហាញនៅលើផែនទី រួមមាន ៖

1. ឋានលេខា ៖ ទីចំណោត ទីជម្រាល ឬផ្ទៃដីរាបស្មើ
2. ប្រភេទដី ៖ ការហូរច្រោះខ្លាំង ការហូរច្រោះតិចតួច និងមិនមានការហូរច្រោះ
3. គម្របរុក្ខជាតិ និងការប្រើប្រាស់ដី ពិសេសតំបន់ព្រៃឈើ និងតំបន់ដីសើម
4. ទីតាំងវប្បធម៌សំខាន់ៗ
5. ផ្លូវអាចចូលដល់ទីតាំងការដ្ឋាន
6. ប្រភពទឹក
7. ទំហំ (កម្រិត)នៃទឹកជំនន់តាមរដូវ
8. តំបន់លំនៅស្ថាន និងប្រភពទឹកប្រើប្រាស់
9. តំបន់ការពារ
10. តំបន់ជីវៈចម្រុះ
11. តំបន់ជនជាតិដើមភាគតិចរស់នៅ។

**ការប្រើប្រាស់និមិត្តសញ្ញានៅលើផែនទី**

| និមិត្តសញ្ញា | អត្ថន័យ |
|---|---|
|  | ចំណោតខ្ពស់ (ច្រើនជាង៥%) |
|  | ចំណោតទាប (តិចជាង៥%) |
|  | ការហូរច្រោះ |
|  | វាលស្រែ |
|  | វាលសម្រាប់ដំណាំប្រចាំឆ្នាំ |
|  | ដំណាំឈើហូបផ្លែ |

| និមិត្តសញ្ញា | អត្ថន័យ |
|---|---|
|  | វាលស្មៅ |
|  | ព្រៃរបោះ |
|  | ព្រៃស្រោង |
|  | ផ្ទះ |
|  | មានទឹកពេញ១ឆ្នាំ |
|  | មិនមានទឹកពេញ១ឆ្នាំទេ |
|  | ទីតាំងវប្បធម៌ |
|  | ផ្លូវអាចចូលដល់ទីតាំងការដ្ឋាន |
|  | តំបន់ការពារដែលកំណត់ដោយថ្នាក់ជាតិ និងថ្នាក់ខេត្ត |
|  | តំបន់ជីវៈចម្រុះដែលកំណត់ដោយក្រសួងបរិស្ថាន |
|  | តំបន់ជនជាតិដើមភាគតិចរស់នៅ |

**ផែនទីបរិស្ថាន**



## ៩.៦. ការវិភាគផលប៉ះពាល់បរិស្ថាន

បន្ទាប់ពីគូរផែនទីបរិស្ថាន ត្រូវធ្វើការវិភាគបរិស្ថានជាមួយប្រជាពលរដ្ឋ ដោយប្រើបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន(**ទម្រង់ទី១៥.២**)។ បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន គឺជាបញ្ជីមួយសម្រាប់ធ្វើការវិភាគអំពីផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការអនុវត្តគម្រោង។ បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន ចែកជាពីរផ្នែក គឺផលប៉ះពាល់បរិស្ថានរយៈពេលវែង និងផលប៉ះពាល់បរិស្ថានរយៈពេលខ្លី។

ចំពោះបញ្ហានីមួយៗនៅក្នុងបញ្ជីនេះ មន្ត្រីទទួលបន្ទុកត្រូវពន្យល់អត្ថន័យ និងឯកភាពជាមួយប្រជាពលរដ្ឋមូលដ្ឋាន ប្រសិនបើបញ្ហានេះនឹងកើតមានឡើង។ ចំពោះបញ្ហានីមួយៗនៅក្នុងបញ្ជី មន្ត្រីទទួលបន្ទុកត្រូវគូសសម្គាល់ ដូចជា"**ផលប៉ះពាល់ធំ**" "**ផលប៉ះពាល់មធ្យម**" **ឬ**"**ផលប៉ះពាល់តិចតួចឬគ្មាន**"។ ផលប៉ះពាល់ធំ និងផលប៉ះពាល់មធ្យម មានន័យថា បញ្ហាគឺធំគ្រប់គ្រាន់ល្មមដែលគម្រោងមួយចំនួនត្រូវតែធ្វើការផ្លាស់ប្តូរ ដើម្បីដោះស្រាយបញ្ហា។

ចំពោះបញ្ហានានាដែលត្រូវបានគូសសម្គាល់ថា មានផលប៉ះពាល់ធំ ឬមានផលប៉ះពាល់មធ្យមនោះ កន្លែងទាំងនោះត្រូវគូសសម្គាល់នៅលើផែនទី។ កន្លែងនីមួយៗត្រូវគូសសម្គាល់ជាអក្សរ ឬជាលេខ។ ឧទាហរណ៍ ការខូចខាតបណ្តាលមកពីការជីកកាយដីនៅកន្លែង"ក" និងកន្លែង"ខ"។ សរសេរ"ក" "ខ" នៅក្នុងកូឡោនចុងក្រោយនៃបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន ហើយក៏ត្រូវគូសសម្គាល់កន្លែង"ក" និង"ខ" នៅលើផែនទីបរិស្ថានផងដែរ។

នៅក្នុងពេលធ្វើការវិភាគផលប៉ះពាល់បរិស្ថាន មន្ត្រីទទួលបន្ទុក និងប្រជាពលរដ្ឋត្រូវពិចារណា និងវិនិច្ឆ័យអំពីទំហំនៃផលប៉ះពាល់ទៅលើបរិស្ថាន។

ប្រសិនបើការអនុវត្តគម្រោងផ្តល់នូវផលប៉ះពាល់បរិស្ថានធំ គម្រោងនោះទាមទារឱ្យធ្វើការពិចារណាឡើងវិញ ថាតើត្រូវលុបគម្រោងនោះចោល ឬយ៉ាងហោចណាស់ត្រូវរៀបចំគ្រោងការគម្រោងនោះឡើងវិញ។

ប្រសិនបើការអនុវត្តគម្រោងផ្តល់នូវផលប៉ះពាល់បរិស្ថានមធ្យម គម្រោងនេះអាចអនុវត្តបាន ដោយធ្វើការកែសម្រួលគំនូសប្លង់បច្ចេកទេស និងឬចាត់វិធានការការពារផ្សេងៗនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

ប្រសិនបើការអនុវត្តគម្រោងផ្តល់នូវផលប៉ះពាល់បរិស្ថានតិចតួច គម្រោងនេះអាចអនុវត្តបានដោយគ្រាន់តែកំណត់បណ្តាសកម្មភាពគ្រប់គ្រងបរិស្ថាននៅក្នុងផែនការការងារសម្រាប់ការអនុវត្តគម្រោង និងផែនការគ្រប់គ្រងបរិស្ថាន។

របៀបពិចារណា និងវិនិច្ឆ័យផលប៉ះពាល់បរិស្ថានធំ ឬមធ្យម មានដូចខាងក្រោម ៖

### ក). ផលប៉ះពាល់បរិស្ថានរយៈពេលវែង

- ការគំរាមកំហែងដែលបណ្តាលឱ្យអន្តរាយដល់ការរស់នៅរបស់សត្វព្រៃដែលរស់នៅក្នុងតំបន់នោះ។ បើគម្រោងគំរាមកំហែងដោយផ្ទាល់ដល់ការរស់នៅរបស់សត្វ ដែលស្ថិតនៅក្នុងបញ្ជីប្រភេទសត្វងាយបាត់បង់ ឬងាយផុតពូជ ផលប៉ះពាល់នេះគឺជាផលប៉ះពាល់ធំ ដែលចាំបាច់ត្រូវលុបគម្រោងនោះចោល ឬរៀបចំគ្រោងការគម្រោងឡើងវិញ។
- ការធ្វើឱ្យខូចខាតដល់មច្ឆជាតិ ឬជម្រកមច្ឆជាតិ។ បើគម្រោងគំរាមកំហែងដល់ការរស់នៅនៃប្រភេទពូជត្រីធុនធំ ឬធ្វើឱ្យអន្តរាយធ្ងន់ធ្ងរដល់តំបន់ត្រីពង-កូន ផលប៉ះពាល់នេះគឺជាផលប៉ះពាល់ធំ ដែលត្រូវតែជៀសវាងជាដាច់ខាត។ ប្រសិនបើការគំរាមកំហែង ឬការអន្តរាយនេះមិនសូវធ្ងន់ធ្ងរ ផលប៉ះពាល់នេះគឺជាផលប៉ះពាល់មធ្យម។ ក្នុងករណីនេះ អាចដោះស្រាយបានដោយចាត់វិធានការនានាតាមរយៈការរៀបចំផែនការគ្រប់គ្រងបរិស្ថាន។ ឧទាហរណ៍ គម្រោងវារីវប្បកម្មដោយប្រើពូជត្រីនាំ

ចូលផ្សេងៗនៅក្បែរ ឬនៅក្នុងបឹងធម្មជាតិ ពីព្រោះពូជត្រីនាំចូលនេះ អាចចូលទៅក្នុងបឹងធម្មជាតិ ហើយបំផ្លាញដល់ពូជត្រីធម្មជាតិ។

- ការធ្វើឱ្យខូចខាតដល់ព្រៃឈើ(ជាពិសេសនៅតំបន់ជីវៈចម្រុះ)។ ប្រសិនបើគម្រោងបណ្តាលឱ្យកើនឡើងនូវការកាប់បំផ្លាញព្រៃឈើ ឬកើនឡើងនូវការប្រើប្រាស់ផលិតផលព្រៃឈើ ដូចជាបង្កើននូវការផលិតធ្យូង ឬកាប់អុស។ ផលប៉ះពាល់នេះគឺជាផលប៉ះពាល់ធំ ដែលត្រូវតែជៀសវាងជាដាច់ខាត។ ឧទាហរណ៍ គម្រោងកែលម្អផ្លូវកាត់តំបន់ព្រៃឈើ (ពិសេសតំបន់ជីវៈចម្រុះ តំបន់ការពារ តំបន់ព្រៃស្រោង) ទៅដល់ភូមិមួយ។ គម្រោងនេះមិនគួរអនុវត្តទេ ពីព្រោះវាផ្តល់នូវផលប៉ះពាល់ធំទាំងផលប៉ះពាល់ផ្ទាល់ និងប្រយោលដល់តំបន់ព្រៃឈើ។ គម្រោងផ្លូវនេះ អាចអនុវត្តបានដោយបង្វៀងខ្សែផ្លូវនេះឱ្យកាត់តំបន់ព្រៃតិចតួចបំផុត ឬមិនកាត់តំបន់ព្រៃ និងចាត់វិធានការដទៃទៀត ដើម្បីធានាថាការកើនឡើងនូវការទៅដល់តំបន់ព្រៃឈើ មិននាំឱ្យកើនឡើងនូវការកាប់បំផ្លាញព្រៃឈើនោះទេ។ ក្នុងករណីនេះ ផលប៉ះពាល់មធ្យម ហើយគម្រោងអាចអនុវត្តបានដោយរៀបចំវិធានការការពារនានានៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដូចជាដាក់បង្គោលការពារកុំឱ្យរថយន្តធំឆ្លងកាត់ និងឬវិធានការការពារប្រកបដោយប្រសិទ្ធភាពដទៃទៀត។
- ការប៉ះពាល់ខូចខាតដល់និរន្តរភាពនៃតំបន់ដីសើម ឬប្រភពទឹកនានា (ជាពិសេសនៅក្នុងតំបន់ជីវៈចម្រុះ ឬតំបន់ការពារ)។ ការសាងសង់ផ្លូវ ឬប្រឡាយក្នុងតំបន់ដីសើម មិនគួរត្រូវអនុវត្តឡើយ។ ការសាងសង់ប្រព័ន្ធធារាសាស្ត្រ និងព្រែកជីកនៅជាប់ទៅនឹងតំបន់ដីសើម ត្រូវធ្វើការវាយតម្លៃឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ដើម្បីប្រាកដថា មិនមានផលប៉ះពាល់ទៅលើតំបន់ដីសើម ឬកម្រិតនៃផលប៉ះពាល់ទៅលើតំបន់ដីសើមនោះអាចទទួលយកបាន។
- ការខូចខាតរយៈពេលយូរអង្វែងទៅលើដីកសិកម្ម។ ប្រសិនបើគម្រោងបណ្តាលឱ្យចុះថយនូវជីជាតិដីធ្លាក់ចុះនូវគុណភាពដី ផលប៉ះពាល់នេះគឺជាផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យម អាស្រ័យទៅនឹងកម្រិត និងទំហំនៃផលប៉ះពាល់ទៅលើតំបន់ដែលទទួលរងនូវផលប៉ះពាល់នោះ។ ឧទាហរណ៍ គម្រោងបណ្តាលឱ្យមានការហូរច្រោះស្រទាប់ដីខាងលើ ដោយសារតែការសាងសង់សំណង់ទ្វារទឹកនៅផ្នែកខាងលើនៃស្ទឹង ឬអូរមិនបានត្រឹមត្រូវ ឬបណ្តាលឱ្យដីស្ងួតហួតហែងដោយសារគ្មានទឹកគ្រប់គ្រាន់ ដែលបណ្តាលមកពីការសាងសង់ទំនប់នៅផ្នែកខាងលើស្ទឹង ឬអូរ។
- ការហូរច្រោះដែលបណ្តាលមកពីការផ្លាស់ប្តូរចរន្តទឹក និងការពង្រីកទំហំព្រែក ឬអូរ។ ការបើកផ្លូវទឹកមិនបានត្រឹមត្រូវ អាចបង្កើតឱ្យមានល្បឿនទឹកខ្លាំង ដែលបណ្តាលឱ្យខូចខាតដល់ច្រាំងទន្លេ ឬប្រឡាយដោយសារការហូរច្រោះ។ ជាទូទៅ ផលប៉ះពាល់នេះ គឺជាផលប៉ះពាល់មធ្យម ដែលអាចដោះស្រាយបានតាមរយៈការរៀបចំគ្រោងការគម្រោង និងការចាត់វិធានការនានានៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។
- ការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិ។ ជាទូទៅ ការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិ ត្រូវបានចាត់ទុកថាជាផលប៉ះពាល់កម្រិតតិចតួចទៅមធ្យម ដែលអាចដោះស្រាយបានតាមរយៈរៀបចំគំនូសប្លង់បច្ចេកទេស ឡើងវិញ ឬវិធានការសាមញ្ញៗ នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដូចជា ការដាំស្មៅ ការដាំដើមឈើឡើងវិញ ...។ល។

- ទឹកជំនន់ជន់លិច។ ការសាងសង់ទំនប់បណ្តាលឱ្យផ្ទៃជម្រាលផ្នែកខាងលើនៃទំនប់ត្រូវបានលិចទឹក។ ក្នុងករណីនេះ ត្រូវថ្លឹងថ្លែងអំពីទំហំផ្ទៃដី និងតម្លៃនៃផលិតផលកសិកម្មនៃតំបន់ដែលលិចទឹកនោះ ជាមួយនឹងទំហំផ្ទៃដី និងតម្លៃផលិតផលកសិកម្មនៃតំបន់ដែលត្រូវស្រោចស្រព។ ការរៀបចំគ្រោងការគម្រោង ត្រូវតែប្រាកដថា តម្លៃផលិតផលកសិកម្មនៃផ្ទៃជម្រាលផ្នែកខាងលើទំនប់ មានតម្លៃទាបជាងតម្លៃផលិតផលកសិកម្មនៃផ្នែកខាងក្រោមទំនប់។ លើសពីនេះទៀត វិធានការការពារដើម្បីការពារដល់ការជន់លិចដែលមិនបានគ្រោងទុក ក៏ត្រូវត្រៀមរៀបចំផងដែរ។
- ការខូចខាតដល់គុណភាពទឹកដោយសារសារធាតុគីមី។ រាល់គម្រោងដែលលើកទឹកចិត្តឱ្យកសិករប្រើប្រាស់ជីគីមី និងបង្ហូរកាកសំណល់រាវពីស្រែរបស់ខ្លួនទៅក្នុងស្ទឹង ឬបឹងធម្មជាតិនានាដែលជាប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ គម្រោងទាំងនោះត្រូវបានចាត់ទុកថា ផ្តល់ផលប៉ះពាល់ធំដែលត្រូវតែជៀសវាង។
- ផលប៉ះពាល់រយៈពេលវែងដែលបណ្តាលមកពីធូលីហុយ សំឡេង និងបញ្ហាសុវត្ថិភាព។ រាល់គម្រោងផ្លូវក្រួសក្រហមដែលស្ថិតនៅតំបន់ដង់ស៊ីតេប្រជាជនខ្ពស់ ដែលមានចរាចរមមាញឹកខ្លាំងពេញមួយថ្ងៃ នឹងបង្កើតឱ្យមានធូលី សំឡេង និងគ្រោះថ្នាក់ផ្សេងៗ។ គម្រោងទាំងនេះ អាចពិចារណាថា គម្រោងផ្តល់នូវផលប៉ះពាល់មធ្យម ឬផលប៉ះពាល់តិចតួច ដែលអាចធ្វើឱ្យប្រសើរឡើងតាមរយៈការរៀបចំវិធានការនានានៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។
- ការខូតខាតដល់ទីតាំងវប្បធម៌ ឬទីសក្ការៈ។ គម្រោងដែលបណ្តាលឱ្យមានការខូចខាតដល់ទីតាំងវប្បធម៌ ឬទីសក្ការៈនានា ឬបណ្តាលឱ្យខូចខាតដល់បរិស្ថានជុំវិញ ឬបណ្តាលឱ្យប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋមូលដ្ឋាន គម្រោងទាំងនោះត្រូវចាត់ទុកថា មានផលប៉ះពាល់ធំ ហើយត្រូវជៀសវាង។
- ការប៉ះពាល់ដល់ជីវភាពរស់នៅ បរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច។ គម្រោងដែលបណ្តាលឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ បរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ឬគម្រោងដែលបណ្តាលឱ្យជនជាតិដើមភាគតិចផ្លាស់ប្តូរទីតាំងរស់នៅ គម្រោងទាំងនោះត្រូវចាត់ទុកថា មានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យម។

**ខ). ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី**

- ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី គឺជាផលប៉ះពាល់ដែលកើតមានឡើងនៅក្នុងអំឡុងពេលអនុវត្ត ឬសាងសង់គម្រោង។ ជាទូទៅ គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចកម្រនឹងបណ្តាលឱ្យមានផលប៉ះពាល់ធំ រយៈពេលខ្លី ប៉ុន្តែអាចបណ្តាលឱ្យមានផលប៉ះពាល់មធ្យម ឬតិចតួចក្នុងរយៈពេលខ្លី។ ផលប៉ះពាល់បរិស្ថានរយៈពេលខ្លីភាគច្រើន អាចត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការអនុវត្តសកម្មភាពគ្រប់គ្រងបរិស្ថាន ដែលបានកំណត់នៅក្នុងផែនការការងាររបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម និងផែនការគ្រប់គ្រងបរិស្ថាន។

នៅក្នុងបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន មានបម្រុងទុកកន្លែងសម្រាប់បរិយាយបន្ថែមនូវបញ្ហានៃផលប៉ះពាល់បរិស្ថាននានា ដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោង។

នៅផ្នែកចុងក្រោយនៃបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន មានបម្រុងទុកកន្លែងសម្រាប់បរិយាយបន្ថែមនូវផលប៉ះពាល់ល្អទៅលើបរិស្ថាន ដែលរំពឹងទុកពីការអនុវត្តគម្រោង។

## ៩.៧. ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន(**ទម្រង់ទី១៥.៣**) ត្រូវរៀបចំឡើងដោយមានការពិភាក្សាជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ផ្ទាល់ពីគម្រោង។ រាល់បញ្ហានៃផលប៉ះពាល់បរិស្ថានទាំងឡាយណាដែលមានផលប៉ះពាល់មធ្យម និងខ្លាំង ត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ហើយបញ្ហាទាំងនេះត្រូវបានផ្តល់អនុសាសន៍ផ្លាស់ប្តូរនៅក្នុងកម្រិតបី គឺ ៖

- ការផ្លាស់ប្តូរនៅក្នុងគ្រោងការគម្រោង (ឧទាហរណ៍ ការផ្លាស់ប្តូរទីតាំងស្ពាន)។
- ការផ្លាស់ប្តូរមធ្យោបាយក្នុងការអនុវត្តគម្រោង (ឧទាហរណ៍ ការបង្ហាញអំពីផ្លូវសម្រាប់ដឹកជញ្ជូនសម្ភារៈ និងឧបករណ៍នានាទៅកាន់ការដ្ឋាន)។ ចំពោះការផ្លាស់ប្តូរនេះ ត្រូវបញ្ចូលទៅក្នុងផែនការការងារសម្រាប់ការអនុវត្តគម្រោង នៅមុនពេលចាប់ផ្តើមអនុវត្តគម្រោង។
- ការផ្លាស់ប្តូរមធ្យោបាយក្នុងការប្រតិបត្តិ និងថែទាំគម្រោង (ឧទាហរណ៍ ការបើកទ្វារទឹកដោយសន្សឹមៗ ដើម្បីកាត់បន្ថយការហូរច្រោះដី)។

ផែនការគ្រប់គ្រងបរិស្ថានបរិយាយលម្អិតអំពី ៖

- **បញ្ហា** ៖ បញ្ហានៃផលប៉ះពាល់បរិស្ថានទាំងឡាយណាដែលមានផលប៉ះពាល់មធ្យម និងខ្លាំង
- **វិធានការបន្ធូរបន្ថយ** ៖ វិធានការកាត់បន្ថយ ឬបន្ធូរបន្ថយនូវផលប៉ះពាល់មិនល្អទៅលើបរិស្ថាន
- **ការចំណាយ** ៖ តម្លៃប៉ាន់ស្មានសម្រាប់ការចំណាយក្នុងការស្ថាបនា និងកិច្ចប្រតិបត្តិការសម្រាប់ការអនុវត្តវិធានការបន្ធូរបន្ថយនានា
- **អ្នកទទួលខុសត្រូវ** ៖ អ្នកទទួលខុសត្រូវក្នុងការស្ថាបនា និងកិច្ចប្រតិបត្តិការសម្រាប់ការអនុវត្តវិធានការបន្ធូរបន្ថយនានា
- **ផលប៉ះពាល់នៅសល់បន្ទាប់ពីបន្ធូរបន្ថយ** ៖ កម្រិតផលប៉ះពាល់ដែលនៅសេសសល់បន្ទាប់ពីចាត់វិធានការបន្ធូរបន្ថយ (ធំ មធ្យម និងគ្មាន)
- **អាទិភាព** ៖ កម្រិតអាទិភាពនៃបញ្ហាផលប៉ះពាល់បរិស្ថាន (ខ្ពស់ មធ្យម ទាប)
- **យោបល់ផ្សេងៗ** ៖ យោបល់បញ្ជាក់បន្ថែមនានា។

## ៩.៨. ការរៀបចំផែនការតាមដានផលប៉ះពាល់បរិស្ថាន

ផែនការតាមដានផលប៉ះពាល់បរិស្ថាន(**ទម្រង់ទី១៥.៤**) ត្រូវរៀបចំដោយមានការចូលរួមពីប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ផ្ទាល់ពីគម្រោង។ ផែនការតាមដានផលប៉ះពាល់បរិស្ថានបង្ហាញអំពីរបៀបដែលត្រូវធ្វើការតាមដានដូចជា ៖

- **អ្វីខ្លះ?** ៖ តើត្រូវតាមដានទៅលើអ្វីខ្លះ? (ឧទាហរណ៍ ៖ "ធូលីហុយដែលបណ្តាលមកពីការធ្វើចរាចរ" "គុណភាពទឹក"...។ល។)។
- **កន្លែងណា?** ៖ តើត្រូវតាមដាននៅកន្លែងណា?
- **របៀបណា?** ៖ តើត្រូវតាមដានរបៀបណា? ចំពោះប្រភេទបញ្ហាមួយចំនួនអាចធ្វើការវាស់វែងជាក់ស្តែងបាន (ឧទាហរណ៍ ៖ ជម្រៅអតិបរមានៃទឹកជំនន់នៅកន្លែងជាក់លាក់ណាមួយ)។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានប្រភេទផ្សេងទៀត (ឧទាហរណ៍ ៖ ធូលីនៅក្នុងខ្យល់ យើងអាចវាស់វែងបាន ដោយសួរប្រជាពលរដ្ឋ ដូចជាសួរថា ធ្ងន់ធ្ងរជាងមុន ឬដូចកាលពីមុន ឬល្អប្រសើរជាងពីមុន)។

- **នៅពេលណា?** ៖ តើត្រូវតាមដាននៅពេលណា? (ឧទាហរណ៍ ៖ "តាមដានម្តងក្នុង១ខែ" "តាមដានរៀងរាល់ថ្ងៃក្នុងអំឡុងពេលសាងសង់"...។ល។)។
- **នរណា?** ៖ តើនរណាជាអ្នកទទួលខុសត្រូវក្នុងការតាមដាន?

## ៩.៩. ការរៀបចំរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន

របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន(**ទម្រង់ទី១៥.១**) មាន២ផ្នែក គឺផ្នែកទី១ "មូលហេតុនៃការវិភាគផលប៉ះពាល់បរិស្ថាន" និងផ្នែកទី២ "អនុសាសន៍"។

**មូលហេតុនៃការវិភាគផលប៉ះពាល់បរិស្ថាន** រួមមាន ៖

- ទីតាំងគម្រោងស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន
- គម្រោងអាចបណ្តាលឱ្យខូចខាតដល់តំបន់ ដែលមានសារៈសំខាន់ចំពោះបរិស្ថាន ឬវប្បធម៌
- គម្រោងអាចបណ្តាលឱ្យខូចខាត ដល់ប្រភពផ្គត់ផ្គង់ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ
- គម្រោងផ្លូវថ្មី (ផ្លូវថ្មី គឺជាផ្លូវ ឬផ្នែកមួយនៃផ្លូវដែលមិនមែនជាផ្លូវពីមុន ឬផ្នែកមួយនៃផ្លូវចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្ស ឬផ្លូវចាស់ដែលត្រូវបានពង្រីកទទឹងផ្លូវធំជាងមុនចាប់ពី២៥%ឡើងទៅ)
- គម្រោងប្រព័ន្ធធារាសាស្ត្រថ្មី (ប្រព័ន្ធធារាសាស្ត្រថ្មី គឺជាប្រព័ន្ធធារាសាស្ត្រ ឬផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រដែលមិនមែនជាប្រព័ន្ធធារាសាស្ត្រពីមុន ឬផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្ស)
- គម្រោងព្រែកជីកថ្មីសម្រាប់ការធ្វើដំណើរតាមផ្លូវទឹក ឬផ្គត់ផ្គង់ទឹកប្រើប្រាស់ (ព្រែកជីកថ្មី គឺជាព្រែកជីក ឬផ្នែកមួយនៃព្រែកជីក ដែលមិនមែនជាព្រែកជីកពីមុន ឬផ្នែកមួយនៃព្រែកជីកចាស់ដែលត្រូវបានផ្លាស់ប្តូរអ័ក្ស)។

ក្នុងចំណោមមូលហេតុខាងលើនេះ សម្រាប់គម្រោងមួយអាចមានមូលហេតុលើសពីមួយ។

**អនុសាសន៍នៃការវិភាគផលប៉ះពាល់បរិស្ថាន**មានដូចខាងក្រោម ៖

- គម្រោងនឹងមិនមានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមណាមួយទៅលើបរិស្ថាន ដែលមិនអាចទទួលយកបាននោះទេ។
- គម្រោងនឹងមានផលប៉ះពាល់មធ្យម ប៉ុន្តែផលប៉ះពាល់មធ្យមនេះអាចត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។
- គ្រោងការគម្រោងត្រូវបានផ្លាស់ប្តូរដើម្បីជៀសវាងផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមទៅលើបរិស្ថាន ដែលមិនអាចទទួលយកបាន។
- គម្រោងមិនអាចអនុវត្តបានទេ ពីព្រោះផលប៉ះពាល់ទៅលើបរិស្ថាន មានទំហំធំជាងផលប្រយោជន៍ដែលទទួលបានពីគម្រោង។

## ៩.១០. ការពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានមួយច្បាប់ទៅមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ មន្ទីរបរិស្ថានរាជធានី ខេត្តមានសិទ្ធិជំទាស់នៅក្នុងអំឡុងពេល**១៥ថ្ងៃ** បន្ទាប់ពីទទួលបានរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។

ប្រសិនបើមន្ទីរបរិស្ថានរាជធានី ខេត្តចង់ធ្វើការជំទាស់អ្វីមួយទៅលើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅទីចាត់ការផែនការ និងវិនិយោគរាជធានីខេត្តវិញ។

ប្រសិនបើនៅក្នុងអំឡុងពេល១៥ថ្ងៃ ពុំមានការជំទាស់ទេនោះ មានន័យថា របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ត្រូវបានពិនិត្យបញ្ជាក់បច្ចេកទេសដោយមន្ទីរបរិស្ថានរាជធានី ខេត្តរួចជាស្ថាពរ។

ចំពោះគម្រោងនានាដែលទីតាំងនៃគម្រោងទាំងនោះស្ថិតនៅឃុំ សង្កាត់ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសារឧបសម្ព័ន្ធនានានៃរបាយការណ៍នេះ ជាទម្រង់ឯកសារក្នុងកុំព្យូទ័រ (Electronic File) ជូនក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យជាមុន មុននឹងផ្ញើរបាយការណ៍វិភាគបរិស្ថាននេះទៅមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានរយៈពេល**១០ថ្ងៃធ្វើការ**ក្នុងការពិនិត្យ បន្ទាប់ពីទទួលបានរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។ ប្រសិនបើពិនិត្យទៅឃើញថាមានចំណុចខុសឆ្គងឬខ្វះខាត ដែលត្រូវធ្វើការកែតម្រូវឬបំពេញបន្ថែម ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជម្រាបទៅទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តវិញ តាមរយៈអ៊ីម៉ែលក្នុងអំឡុងពេល១០ថ្ងៃធ្វើការ។ ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធដទៃទៀត មិនអាចផ្ញើទៅមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធដើម្បីពិនិត្យបញ្ជាក់បច្ចេកទេសបានទេ នៅមុនរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ត្រូវបានយល់ព្រមដោយក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប។

## ៩.១១. ការបំពេញទម្រង់របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន (ទម្រង់ទី១៥.១)

| របាយការណ៍ស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក.ក.មកទីរួមខេត្ត | |
| កាលបរិច្ឆេទនៃការវិភាគបរិស្ថានដោយមានការចូលរួម<br>២៤/០៧/២០១៤ | ឈ្មោះមន្ត្រីទទួលបន្ទុកក្នុងការវិភាគបរិស្ថាន<br>អ្នក គុណវ័ត្ត |
| ទីកន្លែងធ្វើការវិភាគបរិស្ថាន<br>វត្ត........................ នៃភូមិ១ ឃុំ ក១ ស្រុក.ក. | ចំនួនប្រជាពលរដ្ឋដែលបានចូលរួមវិភាគបរិស្ថាន<br>៧០នាក់ (ស្រី៤០នាក់) |

### ១. មូលហេតុនៃការវិភាគផលប៉ះពាល់បរិស្ថាន (អាចច្រើនជាងមួយ)

| | |
|---|---|
| ទីតាំងគម្រោងស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន | ✓ |
| គម្រោងអាចបណ្តាលឱ្យខូចខាតដល់តំបន់ ដែលមានសារៈសំខាន់ចំពោះបរិស្ថាន ឬវប្បធម៌ | |
| គម្រោងអាចបណ្តាលឱ្យខូចខាត ដល់ប្រភពផ្គត់ផ្គង់ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ | |
| គម្រោងផ្លូវថ្មី | ✓ |
| គម្រោងប្រព័ន្ធធារាសាស្ត្រថ្មី | |
| គម្រោងព្រែកជីកថ្មីសម្រាប់ការធ្វើដំណើរតាមផ្លូវទឹក ឬផ្គត់ផ្គង់ទឹកប្រើប្រាស់ | |

### ២. អនុសាសន៍

| ល.រ | ការពិពណ៌នា | ជ្រើសយកចម្លើយ១ |
|---|---|---|
| ១ | គម្រោងនឹងមិនមានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមណាមួយទៅលើបរិស្ថាន ដែលមិនអាចទទួលយកបាននោះទេ។ | |
| ២ | គម្រោងនឹងមានផលប៉ះពាល់មធ្យម ប៉ុន្តែផលប៉ះពាល់មធ្យមនេះអាចត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ | ✓ |
| ៣ | គ្រោងការគម្រោងត្រូវបានផ្លាស់ប្តូរដើម្បីជៀសវាងផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមទៅលើបរិស្ថានដែលមិនអាចទទួលយកបាន។ | |
| ៤ | គម្រោងមិនអាចអនុវត្តបានទេ ពីព្រោះផលប៉ះពាល់ទៅលើបរិស្ថានមានទំហំធំជាងផលប្រយោជន៍ដែលទទួលបានពីគម្រោង។ | |

**ឯកសារឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ៖**

- ផែនទីបរិស្ថាន
- បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន
- ផែនការគ្រប់គ្រងបរិស្ថាន
- ផែនការតាមដានបរិស្ថាន
- បញ្ជីឈ្មោះអ្នកចូលរួមវិភាគផលប៉ះពាល់បរិស្ថាន
- កំណត់ហេតុប្រជុំវិភាគផលប៉ះពាល់បរិស្ថាន

ថ្ងៃទី........ ខែ........... ឆ្នាំ.........    ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**    **មន្ត្រីទទួលបន្ទុក**

ទម្រង់ទី១៥.២

## បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន

| | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក.ក.មកទីរួមខេត្ត | |

### ១. ផលប៉ះពាល់បរិស្ថានរយៈពេលវែង

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការគំរាមកំហែងដល់ការអន្តរាយដល់ការរស់នៅរបស់សត្វព្រៃដែលងាយនឹងបាត់បង់ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការធ្វើឱ្យខូចខាតដល់មច្ឆជាតិ ឬជម្រកមច្ឆជាតិ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការធ្វើឱ្យខូចខាតដល់ព្រៃឈើ | ផលប៉ះពាល់ធំ | ✓ | ខ |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការប៉ះពាល់ខូចខាតដល់និរន្តរភាពនៃតំបន់ដីសើម ឬប្រភពទឹក | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការខូចខាតរយៈពេលវែងទៅលើដីកសិកម្ម | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការហូរច្រោះដែលបណ្តាលមកពីផ្លាស់ប្តូរចរន្តទឹក និងការពង្រីកទំហំព្រែក ឬអូរ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ទឹកជំនន់ជន់លិចដែលបណ្តាលមកពីការអនុវត្តគម្រោង | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការខូចខាតដល់គុណភាពទឹកដោយសារសារធាតុគីមី | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ផលប៉ះពាល់រយៈវែងដែលបណ្តាលមកពីធូលីហុយ សំឡេង និងបញ្ហាសុវត្ថិភាព | ផលប៉ះពាល់ធំ | | គ និងឃ |
| | ផលប៉ះពាល់មធ្យម | ✓ | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការខូចខាតដល់ទីតាំងវប្បធម៌ ឬទីសក្ការៈ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការប៉ះពាល់ដល់ជីវភាពរស់នៅ បរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## ២. ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការខូចខាតដែលបណ្តាលមកពីការដឹកសម្ភារៈតាមរថយន្តទៅកាន់ការដ្ឋាន | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការហុយធូលី នៅក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់មធ្យម | ✓ | គ (សាលារៀនភូមិ១) និង ច |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំឡេងរំខាន នៅក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់មធ្យម | ✓ | គ (សាលារៀនភូមិ១) និង ច |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បញ្ហាដែលបណ្តាលឱ្យកខ្វក់ដល់ប្រភពទឹក នៅក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការខូចខាតដល់ច្បារដំណាំ ឬឈើហូបផ្លែរបស់ប្រជាពលរដ្ឋ | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ការខូចខាតដល់ដីកសិកម្មរយៈពេលខ្លី | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការខូចខាតដល់ទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | ✓ | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

| |
|---|
| ចូររៀបរាប់ថាតើគម្រោងមានផលប៉ះពាល់ល្អទៅលើបរិស្ថានអ្វីខ្លះ ? |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

**ឧបសម្ព័ន្ធ១៥.៣** 

## ផែនការគ្រប់គ្រងបរិស្ថាន

| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក:ក:មកទីរួមខេត្ត |
|---|---|---|

| បញ្ហា | វិធានការបន្ធូរបន្ថយ | ការចំណាយ | | អ្នកណាទទួលខុសត្រូវ | | ផលប៉ះពាល់នៅសល់បន្ទាប់ពីបន្ធូរបន្ថយ (ធំ មធ្យម គ្មាន) | អាទិភាព (ខ្ពស់ មធ្យម ទាប) | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ស្ថាបនា | ប្រតិបត្តិការ | ស្ថាបនា | ប្រតិបត្តិការ | | | |
| ១. អនុសាសន៍នៃការផ្លាស់ប្តូរគ្រោងការគម្រោង | | | | | | | | |
| ការធ្វើឱ្យខូចខាតដល់ព្រៃឈើ | • ប្តូរទីតាំងគម្រោង<br>• ប្តូរគ្រោងការគម្រោងដោយកាត់លទ្ធផលគម្រោង ឬបន្ថយទទឹងផ្លូវ<br>• គម្រោងមិនអាចអនុវត្ត | | | • អ្នកជំនួយបច្ចេកទេស<br>• គណៈកម្មការរៀបចំគម្រោង | | គ្មាន | ខ្ពស់ | |
| ២. អនុសាសន៍នៃការផ្លាស់ប្តូរមធ្យោបាយក្នុងការសាងសង់គម្រោង | | | | | | | | |
| សំឡេង និងធូលីដែលបណ្តាលមកពីរថយន្តដឹកដីនឹងរំខានដល់ថ្នាក់រៀននៅក្នុងភូមិ។ | រថយន្តដឹកដីតាមផ្លូវផ្សេង។ | តិចតួច | | អ្នកទទួលការ និងរដ្ឋបាលខេត្ត | | គ្មាន | មធ្យម | |
| ៣. អនុសាសន៍នៃការផ្លាស់ប្តូរមធ្យោបាយនៅក្នុងការប្រើប្រាស់ ឬការថែទាំគម្រោង | | | | | | | | |
| ផលប៉ះពាល់រយៈវែងដែលបណ្តាលមកពីធូលីហុយ សំឡេង និងបញ្ហាសុវត្ថិភាព | • បោះបង្គោលសុវត្ថិភាព<br>• ធ្វើទួលបន្ថយល្បឿន<br>• ដាក់ស្លាកសញ្ញា | ១០០$<br>តិចតួច | | អ្នកទទួលការ | | មធ្យម | ខ្ពស់ | អាចមានសុវត្ថិភាព |
| | • ជំរុញឱ្យប្រជាពលរដ្ឋស្រោចទឹកនៅរដូវប្រាំង | តិចតួច | | រដ្ឋបាលខេត្ត | | គ្មាន | មធ្យម | |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៥.៤**

**ផែនការតាមដានផលប៉ះពាល់បរិស្ថាន**

| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវក្រួសក្រហមពីទីរួមស្រុក.ក.មកទីរួមខេត្ត |
|---|---|---|

| តើអ្វីខ្លះ? | តើនៅកន្លែងណា? | ដោយរបៀបណា? | នៅពេលណា? | ដោយអ្នកណា? |
|---|---|---|---|---|
| តើអ្វីខ្លះដែលត្រូវធ្វើការតាមដាន? | តើទីកន្លែងណាត្រូវតាមដាន? | តើត្រូវតាមដានដោយរបៀបណា? | តើពេលណាត្រូវធ្វើការតាមដាន? | តើនរណាទទួលខុសត្រូវក្នុងការតាមដាន? |
| ការធ្វើឱ្យខូចខាតដល់ព្រៃឈើ | នៅតំបន់ព្រៃការពារ ឬ ព្រៃសហគមន៍ | រដ្ឋបាលខេត្ត គណៈកម្មការរៀបចំគម្រោង និងសហគមន៍ ចុះពិនិត្យទីតាំងគម្រោង ដើម្បីធានាថា គម្រោងមានការផ្លាស់ប្តូរ ទីតាំងដែរឬទេ | ក្នុងអំឡុងពេលសិក្សាគម្រោង | រដ្ឋបាលខេត្ត គណៈកម្មការរៀបចំគម្រោង សហគមន៍ |
| ធូលីហុយដែលបណ្តាលមកពីចរាចរណ៍ | សាលារៀននៅក្នុងភូមិ | គ្រូបង្រៀនរាយការណ៍អំពីបញ្ហាធូលីហុយ វាកាន់តែហុយខ្លាំង ឬមិនសូវហុយទេ បើធៀបទៅនឹងមុនការសាងសង់។ | ក្នុងពេលកំពុងសាងសង់ និងបន្ទាប់ពីការសាងសង់។ | រដ្ឋបាលខេត្ត គណៈកម្មការថែទាំផ្លូវ និងគ្រូបង្រៀន។ |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៥.៥**

## បញ្ជីឈ្មោះអ្នកចូលរួមក្នុងការវិភាគផលប៉ះពាល់បរិស្ថាន

ថ្ងៃទី......... ខែ............. ឆ្នាំ.........

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | តួនាទី | ហត្ថលេខា ឬស្នាមមេដៃ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ជំពូកទី១០

# គោលការណ៍ណែនាំស្តីពីការសិក្សាដីធ្លី

# ជំពូកទី១០
# គោលការណ៍ណែនាំស្តីពីការសិក្សាដីធ្លី

## ១០.១. និយមន័យនៃការសិក្សាដីធ្លី

ការសិក្សាដីធ្លី គឺជាដំណើរការអង្កេតដីធ្លីមួយ ដោយមានការចូលរួមពីប្រជាពលរដ្ឋដែលនឹងទទួលរងនូវផលប៉ះពាល់ផ្ទាល់ពីគម្រោង ដើម្បីកំណត់អំពីទំហំនៃផលប៉ះពាល់ទៅលើដីធ្លី និងទ្រព្យសម្បត្តិនានារបស់ប្រជាពលរដ្ឋ ដែលបណ្តាលមកពីការអនុវត្តគម្រោង ព្រមទាំងចាត់ចែងដោះស្រាយផលប៉ះពាល់ទាំងនោះប្រកបដោយតម្លាភាព និងយុត្តិធម៌។ ការសិក្សាដីធ្លីត្រូវអនុវត្តឱ្យបានរួចរាល់ នៅមុនពេលទម្រង់ព័ត៌មានគម្រោងត្រូវបានបំពេញចប់សព្វគ្រប់។

## ១០.២. អ្នកទទួលខុសត្រូវក្នុងការសិក្សាដីធ្លី

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទទួលខុសត្រូវក្នុងការសិក្សាដីធ្លី ដោយមានការចូលរួមពីប្រជាពលរដ្ឋដែលនឹងទទួលរងនូវផលប៉ះពាល់ផ្ទាល់ពីគម្រោង។ ប្រជាពលរដ្ឋដទៃទៀតក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការសិក្សាដីធ្លីផងដែរ។ ជាការប្រសើរ ប្រសិនបើមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់ ដូចជាយុវជន ចាស់ ប្រុស ស្រី កសិករ ព្រះសង្ឃជាដើម។ល។

## ១០.៣. ការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី

ជំហានដំបូងនៃការរៀបចំរបាយការណ៍សិក្សាដីធ្លី ត្រូវធានាថា គ្រប់ប្រជាពលរដ្ឋទាំងអស់ដែលទទួលរងនូវផលប៉ះពាល់ពីគម្រោង បានដឹងអំពីសំណើគម្រោង និងបានដឹងនូវអ្វីៗដែលជាសិទ្ធិរបស់ខ្លួន ក្នុងនាមជាកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី។

ការប្រជុំជាសាធារណៈមួយត្រូវធ្វើនៅជិតទីតាំងគម្រោង ឬនៅតាមភូមិនីមួយៗ ដែលមានប្រជាពលរដ្ឋទទួលរងនូវផលប៉ះពាល់ដោយគម្រោង។ នៅក្នុងការប្រជុំ មន្ត្រីទទួលបន្ទុកត្រូវពន្យល់អំពីគម្រោង សិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី និងនីតិវិធីដែលត្រូវអនុវត្ត ដើម្បីរៀបចំរបាយការណ៍សិក្សាដីធ្លី។ ផែនទីគម្រោង និងសេចក្តីប្រកាសអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី ត្រូវបានបិទនៅលើក្តារព័ត៌មាន ឬកន្លែងសមរម្យផ្សេងទៀតនៅក្នុងភូមិនីមួយៗ។

ការប្រជុំផ្សព្វផ្សាយនេះត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន**២សប្តាហ៍** មុនការប្រជុំជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ដោយសារគម្រោង ដើម្បីពិភាក្សា និងព្រមព្រៀងជាមួយនឹងកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីអំពីការបរិច្ចាគ ឬសំណងទូទាត់នៃដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេ។ ការធ្វើបែបនេះ ដើម្បីឱ្យប្រជាពលរដ្ឋដែលមិនបានចូលរួមប្រជុំខាងលើ មានពេលវេលាគ្រប់គ្រាន់ដើម្បីស្វែងយល់ ពិចារណា និងពិភាក្សា ថាតើគម្រោងមានផលប៉ះពាល់អ្វីខ្លះដល់ពួកគាត់។

ឧបសម្ព័ន្ធ១៦

## សេចក្តីប្រកាសស្តីពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី

**ក). ការបរិយាយអំពីគម្រោង**

(ឈ្មោះគម្រោង ចំនួនលទ្ធផលគម្រោង ទីតាំងគម្រោង.........................)

**ខ). តើអ្នកណាជាកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលទទួលរងនូវការប៉ះពាល់?**

បុគ្គលដែលជាកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីសម្រាប់លំនៅដ្ឋាន សម្រាប់ពាណិជ្ជកម្ម ឬសម្រាប់កសិកម្មនាពេលបច្ចុប្បន្ននេះ (ទោះបីជាពួកគាត់ពុំមានប្លង់កម្មសិទ្ធិដីធ្លីក៏ដោយ) បានទទួលរងនូវការប៉ះពាល់ មានន័យថា ដីធ្លីរបស់ពួកគាត់ត្រូវបានប្រើប្រាស់សម្រាប់គម្រោង។

**គ). សិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីក្នុងការទទួលព័ត៌មាន**

កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលបានទទួលរងនូវការប៉ះពាល់ទាំងអស់មានសិទ្ធិក្នុងការទទួលបាននូវព័ត៌មានយ៉ាងពេញលេញអំពីសំណើគម្រោង និងអំពីសំណងទូទាត់សម្រាប់ការបាត់បង់ ឬការខូចខាតនានា។ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីទាំងអស់មានសិទ្ធិដឹងអំពីនីតិវិធីតវ៉ា និងអនុវត្តនីតិវិធីតវ៉ានេះដោយគ្មានបង់ប្រាក់។

**ឃ). ការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តទៅឱ្យគម្រោង**

រាជធានី ខេត្តអាចស្នើសុំទៅកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីក្នុងការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិបន្តិចបន្តួចដោយស្ម័គ្រចិត្តទៅឱ្យគម្រោង។ រាជធានី ខេត្តមិនត្រូវស្នើសុំកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីឱ្យបរិច្ចាគដីធ្លីលើសពីចំនួន៥%នៃផ្ទៃដីដាំដុះ(ឬផលិតកម្ម)សរុបរបស់ខ្លួនឡើយ។ រាជធានី ខេត្តមិនត្រូវស្នើសុំកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី ឱ្យបរិច្ចាគទ្រព្យសម្បត្តិផ្សេងៗដែលមានតម្លៃលើសពីចំនួន១.000.000រៀលឡើយ។

កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី មានសិទ្ធិបដិសេធក្នុងការបរិច្ចាគដោយស្ម័គ្រចិត្ត។ រាជធានី ខេត្តអាចទទួលយកការបរិច្ចាគដីធ្លី ឬទ្រព្យសម្បត្តិណាមួយបាន លុះត្រាតែកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី បានចុះហត្ថលេខា ឬផ្តិតមេដៃដើម្បីបញ្ជាក់ថា ខ្លួនបានយល់ព្រមបរិច្ចាគ។ ប្រសិនបើកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ពួកគាត់មិនត្រូវបានស្នើសុំឱ្យបង់ប្រាក់ដែលជាទុនចូលរួមរបស់មូលដ្ឋានសម្រាប់គម្រោងទៀតនោះទេ។

**ង). សិទ្ធិក្នុងការទទួលសំណងទូទាត់**

ប្រសិនបើរាជធានី ខេត្តយកដីធ្លីឯកជនណាមួយសម្រាប់គម្រោង (លើកលែងតែការបរិច្ចាគដីធ្លី ឬទ្រព្យសម្បត្តិបន្តិចបន្តួចដោយស្ម័គ្រចិត្ត) រាជធានី ខេត្តត្រូវផ្តល់សំណងចំពោះការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិ ឬការខូចខាតទ្រព្យសម្បត្តិនានា ដែលមាននៅលើដីទាំងនោះ ទៅឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីនោះវិញ។

ចំពោះដីកសិកម្មត្រូវតែសងមកវិញ ដោយដីដែលមានតម្លៃជាប្រាក់ស្មើគ្នា ឬក៏ស្មើនឹងតម្លៃដី និងទ្រព្យសម្បត្តិដែលមាននៅលើដីធ្លីនោះ។

ប្រសិនបើសំណងជាសាច់ប្រាក់ តម្លៃសំណងនោះ គឺជាតម្លៃនៃការទិញដីដែលមានទំហំផ្ទៃដី និងគុណភាពដីប្រហាក់ប្រហែលទៅនឹងដីធ្លីដែលបានបាត់បង់នោះ (គិតគូរតាំងពីទីតាំងដី ជីជាតិដី និងកត្តាដែលជាប់

ទាក់ទងផ្សេងៗទៀត)។ ចំនួនតម្លៃសំណងយ៉ាងពេញលេញត្រូវបានទូទាត់ទៅឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី។ រាល់ការចំណាយសម្រាប់បង់ពន្ធ និងថ្លៃសេវានានា គឺជាបន្ទុករបស់រដ្ឋបាលរាជធានី ខេត្ត។

ប្រសិនបើមានដំណាំប្រចាំរដូវផ្សេងៗដែលកំពុងដាំដុះនៅលើដីនោះ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីមានសិទ្ធិប្រមូលផលដំណាំទាំងនោះ មុនការចាប់ផ្តើមអនុវត្តគម្រោង។ ប្រសិនបើដំណាំទាំងនោះត្រូវបានខូចខាតឬបំផ្លាញ រាជធានី ខេត្តត្រូវតែទូទាត់ថ្លៃទៅឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីនូវតម្លៃដំណាំដែលបានខូចខាតទាំងនោះ។ ប្រសិនបើដើមឈើនានាត្រូវបានបំផ្លាញ រាជធានី ខេត្តត្រូវតែទូទាត់ថ្លៃទៅឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីនូវតម្លៃដើមឈើទាំងនោះ។

- **ដីធ្លីដែលបាត់បង់បណ្តោះអាសន្ន**

  មិនមានដីធ្លីណាអាចត្រូវបានដកយកជាបណ្តោះអាសន្ន នៅក្នុងអំឡុងពេលអនុវត្តគម្រោងឡើយ លើកលែងតែមានការព្រមព្រៀងដោយស្ម័គ្រចិត្តរវាងកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី និងអ្នកទទួលការ។ អ្នកទទួលការត្រូវទទួលខុសត្រូវក្នុងការជួសជុលការខូចខាតទាំងនោះឡើងវិញ មុនពេលប្រគល់ទៅឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីវិញ។

- **ការបាត់បង់ទ្រព្យសម្បត្តិផ្សេងៗទៀត**

  អចលនទ្រព្យផ្សេងៗទៀតក្រៅពីដីធ្លី (ដូចជារបង) ដែលបានបាត់បង់ឬខូចខាត ការជួសជុល ឬសាងសង់ទ្រព្យសម្បត្តិទាំងនោះឡើងវិញ ត្រូវធ្វើការចរចាជាមួយនឹងកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី ហើយបន្ទាប់មកត្រូវបញ្ចូលទៅជាផ្នែកមួយនៃកិច្ចសន្យារបស់គម្រោងសាងសង់។

- **នីតិវិធីនៃការតវ៉ា**

  កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីណាម្នាក់ដែលមានអារម្មណ៍ថា ខ្លួនមិនត្រូវបានគេប្រព្រឹត្តដោយយុត្តិធម៌ ឬមិនត្រូវបានផ្តល់សំណងឱ្យបានគ្រប់ចំនួនចំពោះដីធ្លី ឬទ្រព្យសម្បត្តិរបស់ខ្លួនដែលបានបាត់បង់ ឬខូចខាត អាចធ្វើការតវ៉ាដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរទៅក្រុមប្រឹក្សារាជធានី ខេត្ត។

  ប្រសិនបើការតវ៉ានេះមិនត្រូវបានដោះស្រាយ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីអាចធ្វើការតវ៉ាដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរទៅលេខាធិការដ្ឋាន គ.ជ.អ.ប ដែលស្ថិតនៅក្នុងក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការសម្របសម្រួលដើម្បីដោះស្រាយបញ្ហានេះ។

  នៅលំដាប់ថ្នាក់នីមួយៗ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីមានសិទ្ធិទទួលនូវការឆ្លើយតបជាលាយល័ក្ខណ៍អក្សរវិញ នៅក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីការដាក់ពាក្យតវ៉ា។

  កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីមិនចាំបាច់បង់ប្រាក់ក្នុងការតវ៉ានៅក្នុងនីតិវិធីនៃការតវ៉ានេះទេ។

## ១០.៤. ការធ្វើអង្កេតដីធ្លីដោយមានការចូលរួម

### ក). ការប្រមូលព័ត៌មានដីធ្លី និងទ្រព្យសម្បត្តិដែលទទួលរងនូវផលប៉ះពាល់

បន្ទាប់ពីការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីភ្លាម មន្ត្រីទទួលបន្ទុកត្រូវធ្វើការវាស់វែងដីធ្លី និងកត់ត្រាទ្រព្យសម្បត្តិនានាដែលទទួលនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង តាមក្បាលដីនីមួយៗ។ នៅក្នុងការធ្វើអង្កេតនេះ មន្ត្រីទទួលបន្ទុក និងអ្នកពាក់ព័ន្ធត្រូវជម្រាបដល់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីអំពីទំហំដីធ្លី និងទ្រព្យសម្បត្តិនានាដែលទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោង ដើម្បីឱ្យកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីទាំងនោះ ធ្វើការពិភាក្សាជាមួយគ្រួសាររបស់ពួកគេ។

មន្ត្រីទទួលបន្ទុកមិនមែនអនុវត្តការអង្កេតដីធ្លីតែម្នាក់ឯងនោះទេ មន្ត្រីទទួលបន្ទុកនឹងអនុវត្តកិច្ចការនេះដោយមានជំនួយគណៈកម្មការរៀបចំគម្រោង អ្នកជំនួយបច្ចេកទេស ប្រជាពលរដ្ឋ ជាពិសេសកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី។

### ខ). ការរៀបចំផែនទីអង្កេតដីធ្លី និងតារាងលទ្ធកម្មដីធ្លី

បន្ទាប់ពីការប្រមូលព័ត៌មានដីធ្លី និងទ្រព្យសម្បត្តិដែលទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងចប់សព្វគ្រប់ មន្ត្រីទទួលបន្ទុកដោយមានជំនួយពីអ្នកពាក់ព័ន្ធ ត្រូវរៀបចំផែនទីអង្កេតដីធ្លី និងតារាងលទ្ធកម្មដីធ្លី។

**ផែនទីអង្កេតដីធ្លី**បង្ហាញអំពីក្បាលដីនីមួយៗដែលនឹងត្រូវទទួលផលប៉ះពាល់ពីគម្រោង ហើយតាមក្បាលដីនីមួយៗនេះត្រូវបានផ្តល់ជាលេខកូដជាអក្សរ ឬជាលេខ។

**ផែនទីអង្កេតដីធ្លី**




**តារាងលទ្ធកម្មដីធ្លី** បង្ហាញអំពីព័ត៌មានដីធ្លី ដូចខាងក្រោម ៖

- ឈ្មោះកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី
- ផ្ទៃដីដែលនឹងត្រូវបាត់បង់
- ផ្ទៃដីសរុប

- ផ្ទៃដីដែលនឹងត្រូវបាត់បង់ គិតជាភាគរយធៀបទៅនឹងផ្ទៃដីសរុប
- ប្រភេទដំណាំដែលមាននៅលើដី
- ពេលវេលាដែលត្រូវប្រមូលផលដំណាំ
- ចំនួនដើមឈើហូបផ្លែ (សម្រាប់ជាចំណូល និងផ្គត់ផ្គង់គ្រួសារ) ដែលនឹងត្រូវបាត់បង់
- ចំនួនដើមឈើដែលនឹងត្រូវបាត់បង់
- ទ្រព្យសម្បត្តិផ្សេងៗទៀតដែលនឹងត្រូវបាត់បង់។

ជាការពិតណាស់ ការប្រមូលព័ត៌មានពិតប្រាកដអំពីផ្ទៃដីដែលប្រើប្រាស់សរុបដោយកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីនីមួយៗ អាចជាការលំបាក។ ថ្វីបើយ៉ាងដូច្នេះក៏ដោយ នៅក្នុងករណីភាគច្រើន ព័ត៌មានទាំងនេះអាចគ្រប់គ្រាន់ល្មម។

**ឧទាហរណ៍ ៖**

- លោក"ក" នឹងបាត់បង់ដីចំនួន២០០ម៉ែត្រការ៉េ (០,០២ហិកតា)។ លោក"ក" មានដីស្រែចំនួន ៣ កន្លែងផ្សេងៗគ្នានៅក្នុងភូមិ ដែលមួយកន្លែងៗប្រហែលជាកន្លះហិកតា។ ដូច្នេះ ដីសរុបរបស់គាត់គឺជាង១ហិកតា ក្នុងករណីនេះ ងាយមើលឃើញថា គាត់នឹងបាត់បង់តិចជាង៥%។
- អ្នកស្រី"ខ" នឹងបាត់បង់ដីចំនួន០,១ហិកតា ពីដីចំការរបស់គាត់ដែលមានចំនួនសរុប០,២៥ហិកតា។ គាត់មិនមានដីឯណាផ្សេងទៀតទេ។ ដូច្នេះ គាត់នឹងបាត់បង់ដីច្រើនជាង៥%។

ប្រសិនបើភាគរយនៃការបាត់បង់ដីដែលបានប៉ាន់ប្រមាណចំពោះកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីណាមួយ មានចំនួនជិតស្មើ៥% ជាការចាំបាច់ណាស់ ត្រូវវាស់វែងផ្ទៃដីរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីនោះយ៉ាងប្រុងប្រយ័ត្ន។

## ត). ការប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង

បន្ទាប់ពីរៀបចំផែនទីអង្កេតដីធ្លី និងតារាងលទ្ធកម្មដីធ្លីចប់សព្វគ្រប់ និងបន្ទាប់ពីរយៈពេល**២សប្តាហ៍**នៃការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី មន្ត្រីទទួលបន្ទុកត្រូវរៀបចំការប្រជុំសាធារណៈមួយនៅជិតទីតាំងគម្រោង ឬនៅតាមភូមិនីមួយៗ។ ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគាត់ទទួលរងនូវផលប៉ះពាល់ដោយសារគម្រោង ត្រូវបានអញ្ជើញចូលរួមប្រជុំនេះ។ នៅក្នុងការប្រជុំនេះ មន្ត្រីទទួលបន្ទុកត្រូវ ៖

- បង្ហាញផែនទីអង្កេតដីធ្លី និងតារាងលទ្ធកម្មដីធ្លី ដោយជម្រាបប្រជាពលរដ្ឋឱ្យបានច្បាស់លាស់អំពីទំហំដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេដែលត្រូវទទួលរងនូវផលប៉ះពាល់ដោយសារគម្រោង។
- ពិភាក្សា និងព្រមព្រៀងជាមួយប្រជាពលរដ្ឋម្តងមួយគ្រួសារៗ រហូតអស់គ្រួសារដែលដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេទទួលរងនូវផលប៉ះពាល់ដោយសារគម្រោង។ នៅក្នុងការពិភាក្សានិងព្រមព្រៀងនេះ មន្ត្រីទទួលបន្ទុកត្រូវធានាថា មិនមានការគាបសង្កត់ណាមួយទៅលើប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់បរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនដល់គម្រោងឡើយ។ រាជធានី ខេត្តមិនមានសិទ្ធិដកហូតដីធ្លី និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋឡើយ។ រាជធានី ខេត្តអាចទទួលយកដីធ្លី និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋបាន លុះត្រាតែពួកគាត់បានយល់ព្រមប្រគល់ដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឬគាបសង្កត់ ហើយចុះហត្ថលេខា ឬផ្តិតមេដៃបញ្ជាក់អំពីការយល់ព្រមរបស់ខ្លួន។

## ១០.៥. ការរៀបចំកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី

តារាងលទ្ធកម្មដីធ្លីបង្ហាញអំពីកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលយល់ព្រមបរិច្ចាគ និងមិនយល់ព្រមបរិច្ចាគដីធ្លី និងឬទ្រព្យសម្បត្តិរបស់ពួកគេទៅឱ្យគម្រោង។

មន្ត្រីទទួលបន្ទុកត្រូវស្រង់ឈ្មោះកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលយល់ព្រមបរិច្ចាគដីធ្លី និងឬទ្រព្យសម្បត្តិរបស់ខ្លួនដោយស្ម័គ្រចិត្តឱ្យទៅគម្រោង ចូលក្នុងទម្រង់បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង(**ទម្រង់ទី១៧.៥**) ដោយបង្ហាញអំពីទំហំដីធ្លី និងឬទ្រព្យសម្បត្តិដែលពួកគាត់បានយល់ព្រមបរិច្ចាគឱ្យទៅគម្រោង ហើយបន្ទាប់មកសុំឱ្យពួកគាត់ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើបញ្ជីនេះ។

ចំពោះកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលត្រូវទទួលសំណងទូទាត់ មន្ត្រីទទួលបន្ទុកត្រូវធ្វើកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី ដោយប្រើប្រាស់ទម្រង់កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី(**ទម្រង់ទី១៧.៣**) ។ កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លីបង្ហាញព័ត៌មានដូចខាងក្រោម ៖

ក). **អំពីកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី** (ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ភេទ អាយុ តួនាទី និងអាសយដ្ឋាន)

ខ). **សេចក្តីលម្អិតអំពីដីធ្លី និងទ្រព្យសម្បត្តិដែលត្រូវបាត់បង់**

- ការពិពណ៌នាអំពីផ្ទៃដី និងលេខកូដក្បាលដីនៅលើផែនទីអង្កេតដីធ្លីនៃដីធ្លីដែលបានប៉ះពាល់ផ្ទាល់ និងដីធ្លីដែលទទួលរងនូវផលប៉ះពាល់ពីគម្រោង។
- ប្រភេទដំណាំដាំដុះប្រចាំឆ្នាំនៅលើដី និងពេលវេលាប្រមូលផល។
- ដើមឈើដែលត្រូវបាត់បង់ ចែកចេញជា ៖ ដើមឈើហូបផ្លែ ដើមត្នោត ប្រភេទដើមឈើដទៃទៀតដែលទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ ឬសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងដើមឈើព្រៃ។
- ទ្រព្យសម្បត្តិផ្សេងៗទៀត (ដូចជារបង អណ្តូងទឹក) ដែលត្រូវបាត់បង់ ឬត្រូវរុះរើចេញ។
- ផលប៉ះពាល់ជាបណ្តោះអាសន្នដែលកើតឡើងបណ្តាលមកពីការអនុវត្តគម្រោង។

គ). **ការទូទាត់សំណងការខូចខាត**

ការពិពណ៌នាលម្អិតអំពីសំណងដែលត្រូវទូទាត់ចំពោះការខូចខាត ចែកចេញជា ៖

- ដីធ្លីដែលត្រូវបានផ្តល់ជាសំណង ៖ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ទំហំផ្ទៃដី និងលេខកូដនៅលើផែនទីអង្កេតដីធ្លី។
- កាលបរិច្ឆេទអំពីសំណងដីធ្លីដែលត្រូវបានផ្ទេរទៅឱ្យម្ចាស់ថ្មី (កាលបរិច្ឆេទនេះត្រូវតែមុនពេលចាប់ផ្តើមធ្វើកិច្ចលទ្ធកម្ម)។
- ប្រភេទសំណងផ្សេងៗទៀត ដែលត្រូវទូទាត់ការខូចខាត។
- ការងារណាមួយដែលអ្នកទទួលការ ត្រូវធ្វើ ដូចជាជួសជុលរបងដែលបានខូចខាត។

ក្នុងករណីមានការទូទាត់សំណងការខូចខាតដល់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី រាជធានី ខេត្តត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- គណៈអភិបាលរាជធានី ខេត្តត្រូវបង្កើតក្រុមវាយតម្លៃសំណងទូទាត់ចំពោះដីធ្លី និងទ្រព្យសម្បត្តិដទៃទៀត ដែលប៉ះពាល់ដោយសារការអនុវត្តគម្រោងរាជធានី ខេត្ត
- សមាសភាពនៃក្រុមវាយតម្លៃនេះ ត្រូវមានតំណាងក្រុមប្រឹក្សារាជធានី ខេត្ត និងតំណាងក្រុមអ្នកទទួលរងនូវផលប៉ះពាល់។ ចំពោះសមាសភាពផ្សេងៗទៀតត្រូវកំណត់ដោយអភិបាលរាជធានី ខេត្ត

- ក្រុមវាយតម្លៃត្រូវកំណត់ថ្លៃដី និងទ្រព្យសម្បត្តិដែលទទួលរងនូវផលប៉ះពាល់
- ក្នុងករណីសំណងទូទាត់ជាដីធ្លី និងឬទ្រព្យសម្បត្តិ ក្រុមវាយតម្លៃត្រូវកំណត់អំពីទំហំដី ឬទ្រព្យសម្បត្តិ ដែលជាសំណងនោះ
- ក្រុមវាយតម្លៃត្រូវកំណត់កាលបរិច្ឆេទនៃការទូទាត់សំណង
- ថ្លៃចំណាយសម្រាប់ការទូទាត់សំណងនេះ នឹងត្រូវបញ្ចូលបន្ថែមទៅក្នុងតម្លៃគម្រោង
- អ្នកដែលទទួលរងនូវផលប៉ះពាល់ត្រូវពិចារណាលើថ្លៃដែលក្រុមវាយតម្លៃបានស្នើឡើង និងធ្វើការសម្រេចចិត្តយល់ព្រម ឬមិនយល់ព្រម។
- ចំនួនសំណងទូទាត់ដែលមានការព្រមព្រៀង និងការទូទាត់ជាក់ស្តែងនៃសំណងនេះត្រូវកត់ត្រានៅក្នុងទម្រង់គណនាតម្លៃសំណង និងការទូទាត់សំណង (**ទម្រង់ទី១៧.៤**)។

**ឃ). ការយល់ព្រមរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី**

ប្រសិនបើកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីយល់ព្រមទទួលយកសំណងពីការបាត់បង់ដីធ្លី និងឬទ្រព្យសម្បត្តិរបស់ខ្លួន នោះគាត់ត្រូវចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី។

ប្រសិនបើកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីមិនយល់ព្រមទទួលយកសំណងពីការបាត់បង់ដីធ្លី និងឬទ្រព្យសម្បត្តិរបស់ខ្លួនទេ នោះគាត់មិនត្រូវចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លីឡើយ។

## ១០.៦. ការរៀបចំរបាយការណ៍សិក្សាដីធ្លី

របាយការណ៍សិក្សាដីធ្លីមាន២ប្រភេទ គឺ"**របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**" និង"**របាយការណ៍លទ្ធកម្មដីធ្លី**"។

**ក). ការរៀបចំរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត**

របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត បង្ហាញព័ត៌មានដូចខាងក្រោម ៖

- **ការពិពណ៌នាអំពីគម្រោង** ៖ ឈ្មោះគម្រោង លទ្ធផលគម្រោង កាលបរិច្ឆេទគ្រោងចាប់ផ្តើមអនុវត្តគម្រោង
- **ការផ្សព្វផ្សាយជាសាធារណៈ** ៖ កាលបរិច្ឆេទ ចំនួនប្រជាពលរដ្ឋចូលរួម និងមធ្យោបាយនៃការផ្សព្វផ្សាយអំពីគម្រោង និងអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដល់ប្រជាពលរដ្ឋដែលទទួលនូវការប៉ះពាល់
- **ការអង្កេតដីធ្លីដោយមានការចូលរួម** ៖ កាលបរិច្ឆេទនៃការប្រមូលព័ត៌មាន និងប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សានិងព្រមព្រៀង ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ ទំហំដីដែលបានបរិច្ចាគដោយស្ម័គ្រចិត្ត និងតម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបានបរិច្ចាគដោយស្ម័គ្រចិត្ត។

របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត រួមមាន ៖

- របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត
- ផែនទីអង្កេតដីធ្លី
- តារាងលទ្ធកម្មដីធ្លី
- បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត
- បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី

- កំណត់ហេតុប្រជុំនានា ៖ កំណត់ហេតុប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី និងកំណត់ហេតុប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង។

**ខ). ការរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី**

របាយការណ៍លទ្ធកម្មដីធ្លី បង្ហាញព័ត៌មានដូចខាងក្រោម ៖

- **ការពិពណ៌នាអំពីគម្រោង** ៖ ឈ្មោះគម្រោង លទ្ធផលគម្រោង កាលបរិច្ឆេទគ្រោងចាប់ផ្តើមអនុវត្តគម្រោង
- **ការផ្សព្វផ្សាយជាសាធារណៈ** ៖ កាលបរិច្ឆេទ ចំនួនប្រជាពលរដ្ឋចូលរួម និងមធ្យោបាយនៃការផ្សព្វផ្សាយអំពីគម្រោង និងអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដល់ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់
- **ការអង្កេតដីធ្លីដោយមានការចូលរួម** ៖ កាលបរិច្ឆេទនៃការប្រមូលព័ត៌មាន និងប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សានិងព្រមព្រៀង ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ ទំហំដីដែលបានបរិច្ចាគដោយស្ម័គ្រចិត្តនិងដែលត្រូវទូទាត់សំណង និងតម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបានបរិច្ចាគដោយស្ម័គ្រចិត្តនិងដែលត្រូវទូទាត់សំណង។

របាយការណ៍លទ្ធកម្មដីធ្លី រួមមាន ៖

- របាយការណ៍ស្តីពីលទ្ធកម្មដីធ្លី
- ផែនទីអង្កេតដីធ្លី
- តារាងលទ្ធកម្មដីធ្លី
- កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី
- ការគណនាតម្លៃសំណង និងការទូទាត់សំណង
- បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត
- សកម្មភាពនានាដែលត្រូវបញ្ចប់មុនពេលចាប់ផ្តើមកិច្ចលទ្ធកម្ម
- សកម្មភាពនានាដែលត្រូវបញ្ចូលក្នុងកិច្ចសន្យា
- តារាងប្រគល់ ទទួលសំណង
- បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី
- កំណត់ហេតុប្រជុំនានា ៖ កំណត់ហេតុប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី និងកំណត់ហេតុប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង។

## ១០.៧. ការរៀបចំឯកសារដើម្បីទូទាត់ថៃសំណង

**ក). ការទូទាត់សំណងជាដីធ្លី ឬប្រាក់ ឬប្រភេទសំណងផ្សេងទៀត**

ការទូទាត់សំណងជាដីធ្លី ឬប្រាក់ ឬប្រភេទសំណងផ្សេងៗទៀតចប់សព្វគ្រប់ (លើកលែងតែសកម្មភាពនានាដែលត្រូវបញ្ចូលទៅក្នុងកិច្ចសន្យា) ត្រូវធ្វើឡើងមុនការចាប់ផ្តើមកិច្ចលទ្ធកម្ម។

នៅពេលទទួលសំណងទូទាត់ កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី ត្រូវផ្តិតមេដៃ ឬចុះហត្ថលេខានៅលើតារាងប្រគល់ ទទួលសំណង(**ទម្រង់ទី១៧.៨**)។ តារាងប្រគល់ ទទួលសំណងត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍លទ្ធកម្មដីធ្លី។

តារាងប្រគល់ ទទួលសំណងបង្ហាញព័ត៌មានដូចខាងក្រោម ៖

- ឈ្មោះ ភេទ អាយុ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងអាសយដ្ឋានរបស់អ្នកទទួលរងនូវការប៉ះពាល់ (អ្នកទទួលសំណង)
- បរិមាណសំណង (ដីធ្លី ប្រាក់ និងប្រភេទសំណងផ្សេងៗទៀត)
- កាលបរិច្ឆេទទទួលសំណង
- ស្នាមមេដៃ ឬហត្ថលេខាអ្នកទទួលរងនូវការប៉ះពាល់ (អ្នកទទួលសំណង)។

**៩). សកម្មភាពសំណងនានាដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចសន្យា**

ចំពោះគម្រោងដែលបានគ្រោងសកម្មភាពសំណងនានាបន្ទាប់ពីការអនុវត្តកិច្ចសន្យា ពិសេសបន្ទាប់ពីបញ្ចប់ការសាងសង់ សកម្មភាពសំណងទូទាត់ទាំងនោះត្រូវដាក់បញ្ចូលទៅក្នុងកិច្ចសន្យា (ឧទាហរណ៍ ការសាងសង់របងឡើងវិញដែលត្រូវបានខូចខាត)។ សកម្មភាពទាំងនោះត្រូវពិពណ៌នាឱ្យបានច្បាស់លាស់ក្នុងឯកសារកិច្ចសន្យា។ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តត្រូវប្រាកដថា សកម្មភាពសំណងទាំងនោះត្រូវបានបញ្ចូលទៅក្នុងកិច្ចសន្យា។

## ១០.៨. ការទូទាត់សំណងជាសាច់ប្រាក់នៅមុនពេលកិច្ចលទ្ធកម្ម

ការទូទាត់សំណងជាសាច់ប្រាក់ដែលត្រូវធ្វើឡើងនៅមុនពេលកិច្ចលទ្ធកម្ម ហើយសំណងជាសាច់ប្រាក់នេះប្រើប្រាស់ថវិការាជធានី ខេត្ត អភិបាលរាជធានី ខេត្តត្រូវរៀបចំឯកសារដូចខាងក្រោម ៖

- អាណត្តិបើកប្រាក់
- ដីកាអមបញ្ចេញអាណត្តិបើកប្រាក់
- ដីកាអមលិខិតយុត្តិការ ៖ របាយការណ៍លទ្ធកម្មដីធ្លី
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកទទួលប្រាក់ (ច្បាប់ថតចម្លង)។

## ១០.៩. ការបំពេញទម្រង់របាយការណ៍លទ្ធកម្មដីធ្លី (ទម្រង់ទី១៧.១)

| **របាយការណ៍ស្តីពីលទ្ធកម្មដីធ្លី** | |
|---|---|
| រាជធានី ខេត្ត ៖ *កំពង់ចាម* | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ *ការសាងសង់សាលាបឋមសិក្សានៅភូមិ ១ ឃុំ ក១ ស្រុក ក*។ | កាលបរិច្ឆេទគ្រោងចាប់ផ្តើមអនុវត្តគម្រោង(ខែឆ្នាំ) ៖ *០៣/២០១៤* |
| ការពិពណ៌នាគម្រោង ៖ *សាងសង់អគារសាលារៀន១ខ្នង មាន៥បន្ទប់ នៅសាលាបឋមសិក្សា*...................... *ដែលស្ថិតនៅភូមិ១ ឃុំ ក១ ស្រុក ក*។ | |
| **១. ការផ្សព្វផ្សាយជាសាធារណៈ** | |
| ពិពណ៌នាអំពីមធ្យោបាយដែលប្រជាពលរដ្ឋទទួលបានព័ត៌មានអំពីសំណើគម្រោង និងអំពីសិទ្ធិរបស់ខ្លួនក្នុងនាមកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី។<br>*ការប្រជុំជាមួយប្រជាពលរដ្ឋមួយត្រូវបានរៀបចំឡើង នៅក្នុងភូមិ............ ដើម្បីពន្យល់អំពីគម្រោង និងសិទ្ធិរបស់កម្មសិទ្ធិករឬភោគីឬអ្នកប្រើប្រាស់ដីធ្លីដល់ប្រជាពលរដ្ឋ។ សំណួររបស់ប្រជាពលរដ្ឋត្រូវបានឆ្លើយបំភ្លឺ។ សេចក្តីប្រកាសអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីត្រូវបានបិទនៅលើក្តារខៀនព័ត៌មានភូមិ* | |

| | |
|---|---|
| ក្រោមដើមឈើនៅទីតាំងគម្រោង។ | |
| កាលបរិច្ឆេទនៃការប្រជុំផ្សព្វផ្សាយជាសាធារណៈ | ០៩/០៧/២០១៤ |
| ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ (ភ្ជាប់បញ្ជីឈ្មោះ) | ៣៥នាក់ (ស្រី២០នាក់) |
| **២. ការអង្កេតដីធ្លីដោយមានការចូលរួម** | |
| កាលបរិច្ឆេទនៃការប្រមូលព័ត៌មានដីធ្លី និងទ្រព្យសម្បត្តិដែលប៉ះពាល់ | ០៩/០៧/២០១៤ |
| កាលបរិច្ឆេទនៃការប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង | ២៤/០៧/២០១៤ |
| ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ (ភ្ជាប់បញ្ជីឈ្មោះ) | ២៥នាក់ (ស្រី១០នាក់) |
| ទំហំផ្ទៃដីដែលបានបរិច្ចាគដោយស្ម័គ្រចិត្ត (ម$^2$ ឬហត) | ០,២៥ហិកតា |
| ទំហំផ្ទៃដីដែលត្រូវទូទាត់សំណង (ម$^2$ ឬហត) | ០,១៥ហិកតា |
| **សរុបផ្ទៃដីដែលបាត់បង់** | ០,៤០ហិកតា |
| តម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបានបរិច្ចាគដោយស្ម័គ្រចិត្ត | ៤០០.០០០រៀល |
| តម្លៃទ្រព្យសម្បត្តិផ្សេងៗដែលត្រូវទូទាត់សំណង | |
| **សរុបតម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបាត់បង់** | ៤០០.០០០រៀល |

**ឯកសារឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ៖**

- ផែនទីអង្កេតដីធ្លី
- តារាងលទ្ធកម្មដីធ្លី
- កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី
- ការគណនាតម្លៃសំណង និងការទូទាត់សំណង
- បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត
- សកម្មភាពនានាដែលត្រូវបញ្ចប់មុនពេលចាប់ផ្តើមកិច្ចលទ្ធកម្ម
- សកម្មភាពនានាដែលត្រូវបញ្ចូលក្នុងកិច្ចសន្យា
- តារាងប្រគល់ ទទួលសំណង
- បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី
- កំណត់ហេតុប្រជុំ

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៧.២**

**តារាងលទ្ធកម្មដីធ្លី**

| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ ការសាងសង់សាលាបឋមសិក្សានៅភូមិ១ ឃុំក១ ស្រុកៈក។ |
|---|---|---|

| លេខកូដលើផែនទី | ឈ្មោះកម្មសិទ្ធិករ ឬភោគី | ផ្ទៃដីដែលបាត់បង់ | ផ្ទៃដីសរុប | %ដីដែលត្រូវបាត់បង់ | ដំណាំប្រចាំឆ្នាំដែលមាន | កាលបរិច្ឆេទប្រមូលផល | ចំនួនដើមឈើដែលត្រូវបំផ្លាញ | | ទ្រព្យធនផ្សេងៗដែលត្រូវបាត់បង់ | តម្លៃទ្រព្យសម្បត្តិ ផ្សេងៗដែលត្រូវបាត់បង់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ឈើហូបផ្លែ | ព្រៃឈើ | | |
| ១ | លោក ក | ០,១ហត | ១,៣ហត | ៧,៧% | ស្រូវ | ១១/១៤ | ០ | ០ | ០ | ០ |
| ២ | លោកស្រី ខ | ០,២ហត | ៤,៥ហត | ៤,៤% | ស្រូវ | ១១/១៤ | ០ | ០ | របងបេតុង | ២០០,០០០រៀល |
| ៣ | លោកស្រី គ | ០,០៥ហត | ៣ហត | ១,៧% | គ្មាន | ០ | ស្វាយ២ដើម | ០ | ០ | ២០០,០០០រៀល |
| ៤ | លោក ឃ | ០,០៥ហត | ០,៥ហត | ១០% | ស្រូវ | ១១/១៤ | ០ | ០ | ០ | ០ |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៧.៣**

## កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មដីធ្លី

<table>
<tr><td colspan="3">រាជធានី ខេត្ត ៖ *កំពង់ចាម*</td><td colspan="2">លេខកូដរាជធានី ខេត្ត ៖</td></tr>
<tr><td colspan="5">ឈ្មោះគម្រោង ៖ *ការសាងសង់សាលាបឋមសិក្សានៅភូមិ ១ ឃុំក១ ស្រុកៈកៈ។*</td></tr>
<tr><td colspan="3">ឈ្មោះអ្នកទទួលរងនូវការប៉ះពាល់ ៖<br>*លោក "ក"*</td><td colspan="2">លេខអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ៖<br>*១២៣៤៥៦៧៨៩*</td></tr>
<tr><td>ភេទ ៖ *ប្រុស*</td><td>អាយុ ៖ *៤៣*</td><td colspan="3">មុខរបរ ៖ *កសិករ*</td></tr>
<tr><td colspan="5">អាសយដ្ឋាន ៖ *ក្រុមទី១០ ភូមិ១ ឃុំក១ ស្រុកៈកៈ ខេត្តកំពង់ចាម។*</td></tr>
<tr><td colspan="3" rowspan="2">ការពិពណ៌នាអំពីដីធ្លីដែលត្រូវបានប្រើប្រាស់ដោយគម្រោង<br>*វាលស្រែដែលស្ថិតនៅខាងត្បូងទីតាំងសាលារៀនចាស់*</td><td colspan="2">ផ្ទៃដីដែលបានបាត់បង់(ម$^2$ ឬហត) ៖<br>*០,១ហិកតា*</td></tr>
<tr><td colspan="2">លេខកូដលើផែនទីអង្កេតដីធ្លី ៖ *១*</td></tr>
<tr><td colspan="3">ដំណាំប្រចាំឆ្នាំដែលកំពុងដាំដុះនៅលើដីបច្ចុប្បន្ន ៖<br>*ស្រូវវស្សា*</td><td colspan="2">កាលបរិច្ឆេទការប្រមូលផលបន្ទាប់ ៖<br>*ខែ១២ ឆ្នាំ២០១៣*</td></tr>
<tr><td colspan="2">**ដើមឈើដែលត្រូវបំផ្លាញ**</td><td colspan="2">**ប្រភេទ**</td><td>**ចំនួន**</td></tr>
<tr><td colspan="2">ដើមឈើហូបផ្លែ</td><td colspan="2"></td><td>*គ្មាន*</td></tr>
<tr><td colspan="2">ដើមឈើសម្រាប់ជាចំណូល ឬផ្គត់ផ្គង់ជីវភាពគ្រួសារ</td><td colspan="2"></td><td>*គ្មាន*</td></tr>
<tr><td colspan="4">ដើមត្នោត</td><td>*គ្មាន*</td></tr>
<tr><td colspan="4">ដើមឈើធម្មជាតិ</td><td>*គ្មាន*</td></tr>
<tr><td colspan="5">ពិពណ៌នាទ្រព្យសម្បត្តិផ្សេងៗទៀតដែលត្រូវបាត់បង់ ឬត្រូវរុះរើចេញក្នុងការអនុវត្តគម្រោង ៖<br>*គ្មាន*</td></tr>
<tr><td colspan="5">ពិពណ៌នាអំពីផលប៉ះពាល់បណ្តោះអាសន្ននៃការអនុវត្តគម្រោង ៖<br>*មិនមានការប៉ះពាល់ទេ ពីព្រោះការអនុវត្តគម្រោងត្រូវបានធ្វើឡើងនៅរដូវប្រាំង ពេលដែលដីស្រែមិនមានការដាំដុះ។*</td></tr>
<tr><td colspan="2" rowspan="2">ដីធ្លីដែលត្រូវធ្វើការទូទាត់សងវិញ<br>*ដីនៅខាងជើងភូមិមានប្រឡាយថ្មីដែលអាចឱ្យដីស្រែនោះអាចបង្កបង្កើនផលបានសមរម្យ។*</td><td colspan="2" rowspan="2">កម្មសិទ្ធិករឬភោគីបច្ចុប្បន្ន<br>*មិនមានម្ចាស់ទេ*</td><td>ផ្ទៃដី ៖ *០,៦ ហិកតា*</td></tr>
<tr><td>លេខកូដលើផែនទីអង្កេតដីធ្លី<br>*១៥*</td></tr>
<tr><td colspan="4">កាលបរិច្ឆេទនៃការផ្ទេរដីធ្លីសំណងទៅឱ្យកម្មសិទ្ធិករឬភោគី</td><td>*៣១/០១/២០១៤*</td></tr>
<tr><td colspan="5">ប្រភេទសំណងទូទាត់ផ្សេងៗទៀតដែលត្រូវផ្តល់មុនពេលការអនុវត្តគម្រោងចាប់ផ្តើម ៖<br>*គ្មាន*</td></tr>
</table>

<table>
<tr><td colspan="6">ការងារដែលត្រូវអនុវត្តដោយអ្នកទទួលការ ដើម្បីទូទាត់សងការខូចខាតទ្រព្យសម្បត្តិដែលមានស្រាប់ ៖<br>គ្មាន</td></tr>
<tr><td colspan="6">សំណងទូទាត់ជាប្រាក់មុនកិច្ចលទ្ធកម្ម</td></tr>
<tr><td>ល.រ</td><td>ការបរិយាយ</td><td>ឯកតា</td><td>ចំនួន</td><td>តម្លៃឯកតា</td><td>តម្លៃសរុប</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="5">សរុបសំណងទូទាត់</td><td></td></tr>
<tr><td colspan="4">កាលបរិច្ឆេទទូទាត់សំណង</td><td colspan="2"></td></tr>
</table>

<table>
<tr><td colspan="4">សំណងទូទាត់ជាទ្រព្យសម្បត្តិក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា (បន្ទាប់ពីបញ្ចប់ការសាងសង់)</td></tr>
<tr><td>ល.រ</td><td>ការបរិយាយ</td><td>ឯកតា</td><td>ចំនួន</td></tr>
<tr><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td></tr>
<tr><td colspan="2">កាលបរិច្ឆេទទូទាត់សំណង</td><td colspan="2"></td></tr>
</table>

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**អ្នកទទួលរងនូវការប៉ះពាល់**

ទម្រង់ទី១៧.៤

**ការគណនាតម្លៃសំណង និងការទូទាត់សំណង**

| | |
|---|---|
| រាជធានី ខេត្ត ៖ | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ | |
| ឈ្មោះអ្នកទទួលរងនូវការប៉ះពាល់ | |
| ផ្ទៃដីដែលបាត់បង់ (ម$^2$ ឬហត) | |
| ប្រភេទដីដែលបាត់បង់ | |
| តម្លៃដី និងទ្រព្យសម្បត្តិនានានៅលើដីនោះ ៖ | |

**ក). សំណងទូទាត់ជាប្រាក់មុនកិច្ចលទ្ធកម្ម**

| ល.រ | ការបរិយាយ | ឯកតា | ចំនួន | តម្លៃឯកតា | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ផ្ទៃដីប៉ះពាល់សរុប | ហត | ០,០៥ | | |
| | | | | | |
| | | | | | |
| | | | | សរុបសំណងទូទាត់ | |

| | |
|---|---|
| កាលបរិច្ឆេទនៃការទូទាត់សំណង | |

**ខ). សំណងទូទាត់ជាទ្រព្យសម្បត្តិក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា (បន្ទាប់ពីបញ្ចប់ការសាងសង់)**

| ល.រ | ការបរិយាយ | ឯកតា | ចំនួន |
|---|---|---|---|
| | | | |
| | | | |
| | | | |

| | |
|---|---|
| កាលបរិច្ឆេទនៃការទូទាត់សំណង | |

មូលដ្ឋាននៃការកំណត់តម្លៃ ៖ ផ្ទៃដីលក់បច្ចុប្បន្ន ក្នុង១ម៉ែត្រការ៉េ.............................. ដែលកំណត់ដោយក្រុមវាយតម្លៃសំណងទូទាត់។ ........................................................................................................................................................................................................................................................។

| | |
|---|---|
| កាលបរិច្ឆេទប្រជុំរបស់ក្រុមវាយតម្លៃសំណងទូទាត់ | |
| ចំនួនអ្នកចូលរួមប្រជុំ (ភ្ជាប់មកជាមួយនូវបញ្ជីវត្តមាន និងកំណត់ហេតុ) | |
| កាលបរិច្ឆេទនៃការយល់ព្រមទៅលើថ្លៃសំណងរបស់អ្នកប៉ះពាល់ | |

ក្រុមវាយតម្លៃសំណងទូទាត់សូមបញ្ជាក់ថា ការទូទាត់សំណងនេះត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ និងពេញលេញទៅតាមថ្លៃដីដែលបានឯកភាពគ្នា ចំពោះអ្នកដែលបានទទួលរងនូវផលប៉ះពាល់ ៖

| ឈ្មោះសមាជិកក្រុមវាយតម្លៃ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|
| | | |
| | | |
| | | |
| | | |

ទម្រង់ទី១៧.៥

## បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឱ្យគម្រោង

| | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ ការសាងសង់សាលាបឋមសិក្សានៅភូមិ១ ឃុំក១ ស្រុក‹ក›។ | |

កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីបានយល់ព្រមបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនឱ្យគម្រោងដោយចុះហត្ថលេខា ឬផ្តិតមេដៃនៅលើទម្រង់នេះ។ ការបរិច្ចាគនេះគឺជាការបរិច្ចាគដោយស្ម័គ្រចិត្ត។ ប្រសិនបើកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីមិនចង់បរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួនឱ្យគម្រោងទេ មិនត្រូវចុះហត្ថលេខា ឬផ្តិតមេដៃនៅលើទម្រង់នេះឡើយ។

| ល.រ | ឈ្មោះ | ភូមិ | មុខរបរ | លេខកូដលើផែនទីអង្កេតដីធ្លី | ផ្ទៃដីដែលបាត់បង់ | តម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបាត់បង់ | ហត្ថលេខា ឬស្នាមមេដៃ |
|---|---|---|---|---|---|---|---|
| ១ | លោកស្រី ខ | ទាលធំ | អ្នកជំនួញ | ២ | ០,២ហត | ២០០.០០០៛ | ខ |
| ២ | លោកស្រី គ | ទាលធំ | កសិករ | ៣ | ០,០៥ហត | ២០០.០០០៛ | គ |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | ០,២៥ហត | ៤០០.០០០៛ | |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

ទម្រង់ទី១៧.៦

## សកម្មភាពនានាដែលត្រូវបញ្ចប់មុនពេលចាប់ផ្តើមកិច្ចលទ្ធកម្ម

| | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ ការសាងសង់សាលាបឋមសិក្សានៅភូមិ១ ឃុំក១ ស្រុក‹ក›។ | |

| សកម្មភាព | កាលបរិច្ឆេទគ្រោង | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|
| ការទូទាត់សំណងជាប្រាក់ចំពោះដីដែលបានបាត់បង់ដល់លោក ‹ឃ› | ២៧/០១/២០១៨ | តារាងប្រគល់ ទទួលសំណង |
| ការទូទាត់សំណងជាដីចំពោះដីដែលបានបាត់បង់ដល់លោក ‹ក› | ៣១/០១/២០១៨ | តារាងប្រគល់ ទទួលសំណង |
| | | |
| | | |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

ឧបសម្ព័ន្ធទី១៧.៧

## សកម្មភាពនានាដែលត្រូវបញ្ចូលក្នុងកិច្ចសន្យា

| | |
|---|---|
| រាជធានី ខេត្ត ៖ កំពង់ចាម | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ ការសាងសង់សាលាបឋមសិក្សានៅភូមិ១ ឃុំក១ ស្រុក.ក.។ | |

អ្នកទទួលការត្រូវអនុវត្តសកម្មភាពនានាខាងក្រោមនេះ ដែលជាផ្នែកមួយនៃកិច្ចសន្យា ដើម្បីធ្វើការទូទាត់សងឱ្យទៅកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លីដែលបានបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិ និងដើម្បីជួសជុលឡើងវិញនូវការខូចខាតបណ្ដោះអាសន្ន នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។

| ទីកន្លែង | ពិពណ៌នាអំពីការបាត់បង់ ឬខូចខាត | ការងារដែលត្រូវធ្វើដោយអ្នកទទួលការ |
|---|---|---|
| តាមបណ្ដោយផ្លូវនៅខាងកើតសាលារៀនចាស់ | របងបេតុងប្រវែង៤០មត្រូវបានបំផ្លាញដោយការអនុវត្តគម្រោង។ | ធ្វើរបងបេតុងថ្មី ចន្លោះសាលារៀន និងដីលោក ខ។ |
| | | |
| | | |
| | | |
| | | |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៧.៨**

**តារាងប្រគល់ ទទួលសំណង**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

| ល.រ | ឈ្មោះអ្នកទទួលសំណង | ភេទ | អាយុ | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អស័យដ្ឋាន | បរិមាណសំណង | | | កាលបរិច្ឆេទទទួលសំណង | ហត្ថលេខា ឬស្នាមមេដៃ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ដីធ្លី | ប្រាក់ | ...... | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកដ្ឋានទទួលបន្ទុកការងារ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

**ឧបសម្ព័ន្ធ១៧.៩**

## បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី

..........................................................................................

ថ្ងៃទី......... ខែ............. ឆ្នាំ.........

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | តួនាទី | ហត្ថលេខា ឬស្នាមមេដៃ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

## ១០.១០. ការបំពេញទម្រង់របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត

ទម្រង់ទី១៧.១០

| **របាយការណ៍ស្តីពីការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត** | |
|---|---|
| រាជធានី ខេត្ត ៖ *កំពង់ចាម* | លេខកូដរាជធានី ខេត្ត ៖ |
| ឈ្មោះគម្រោង ៖ *គម្រោងសាងសង់ផ្លូវដីស និងក្រួសក្រហមពីទីរួមស្រុក.ក. មកទីរួមខេត្ត* | កាលបរិច្ឆេទគ្រោងចាប់ផ្តើមអនុវត្តគម្រោង(ខែឆ្នាំ) ៖ *០៣/២០១៨* |
| ការពិពណ៌នាគម្រោង ៖ *សាងសង់ផ្លូវដីស និងក្រាលក្រួសក្រហមប្រវែង២.០០០ម និងស្ពាន១កន្លែង។* | |
| **១. ការផ្សព្វផ្សាយជាសាធារណៈ** | |
| ពិពណ៌នាអំពីមធ្យោបាយដែលប្រជាពលរដ្ឋ ទទួលបានព័ត៌មានអំពីសំណើគម្រោង និងអំពីសិទ្ធិរបស់ខ្លួនក្នុងនាមកម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី។<br>*ការប្រជុំជាមួយប្រជាពលរដ្ឋមួយត្រូវបានរៀបចំឡើង នៅក្នុងភូមិ........... ដើម្បីពន្យល់អំពីគម្រោង និងសិទ្ធិរបស់កម្មសិទ្ធិករឬភោគីឬអ្នកប្រើប្រាស់ដីធ្លីដល់ប្រជាពលរដ្ឋ។ សំណួររបស់ប្រជាពលរដ្ឋត្រូវបានឆ្លើយបំភ្លឺ។ សេចក្តីប្រកាសអំពីសិទ្ធិរបស់កម្មសិទ្ធិករឬភោគីឬអ្នកប្រើប្រាស់ដីធ្លី ត្រូវបានបិទនៅលើក្តារខៀនព័ត៌មានភូមិ ក្រោមដើមឈើនៅទីតាំងគម្រោង។* | |
| កាលបរិច្ឆេទនៃការប្រជុំផ្សព្វផ្សាយជាសាធារណៈ | *០៩/០១/២០១៨* |
| ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ (ភ្ជាប់បញ្ជីឈ្មោះ) | *១១៥នាក់ (ស្រី៦៥)* |
| **២. ការអង្កេតដីធ្លីដោយមានការចូលរួម** | |
| កាលបរិច្ឆេទនៃការប្រមូលព័ត៌មានដីធ្លី និងទ្រព្យសម្បត្តិដែលប៉ះពាល់ | *០៩/០១/២០១៨* |
| កាលបរិច្ឆេទនៃការប្រជុំជាមួយប្រជាពលរដ្ឋដើម្បីពិភាក្សា និងព្រមព្រៀង | *២៨/០១/២០១៨* |
| ចំនួនប្រជាពលរដ្ឋដែលបានចូលរួមប្រជុំ (ភ្ជាប់បញ្ជីឈ្មោះ) | *៥៥នាក់ (ស្រី៣០)* |
| ទំហំផ្ទៃដីដែលបានបរិច្ចាគដោយស្ម័គ្រចិត្តសរុប (ម$^{២}$ ឬហត) | *១,៥ហាត* |
| តម្លៃទ្រព្យសម្បត្តិផ្សេងៗដែលបានបរិច្ចាគដោយស្ម័គ្រចិត្ត | *២.០០០.០០០រៀល* |
| **ឯកសារឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ៖**<br>– ផែនទីអង្កេតដីធ្លី<br>– តារាងលទ្ធកម្មដីធ្លី<br>– បញ្ជីឈ្មោះអ្នកបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត<br>– បញ្ជីឈ្មោះអ្នកចូលរួមធ្វើអង្កេតដីធ្លី<br>– កំណត់ហេតុប្រជុំ | |

ថ្ងៃទី........ ខែ........... ឆ្នាំ......... ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

# ជំពូកទី១១

# គោលការណ៍ណែនាំ

# ស្តីពីសុវត្ថិភាពជនជាតដើមភាគតច

# ជំពូកទី១១
# គោលការណ៍ណែនាំស្តីពីសុវត្ថិភាពជនជាតិដើមភាគតិច

## ១១.១. ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិច គឺសំដៅអ្នកស្រុកចាស់បុរាណជាងគេ ដែលភាគច្រើនរស់នៅតាមតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា។ ជំនឿសាសនា និងរបៀបរស់នៅរបស់ជនជាតិដើមភាគតិចរាប់សតវត្សមកហើយនោះ មានការជាប់ទាក់ទងទៅនឹងធនធានធម្មជាតិ និងបរិស្ថាន។

ជនជាតិដើមភាគតិចមានរបៀបរបបរស់នៅ និងទំនៀមទំលាប់ប្រពៃណី ដូចខាងក្រោម ៖

- ដី និងព្រៃ ជាប្រពៃណីបានបង្កើតនូវមូលដ្ឋាននៃការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច ក្នុងនោះរាប់ទាំងជីវិតអារក្សរបស់ពួកគេផងដែរ។
- ប្រព័ន្ធជំនឿជាប្រពៃណីត្រូវបានជឿថា អ្វីៗទាំងអស់មានវិញ្ញាណក្នុងធម្មជាតិ នោះគឺការគោរពលើអារក្សដែលរស់នៅក្នុងបឹង ភ្នំ ដើមឈើ និងវត្ថុធម្មជាតិផ្សេងៗទៀត។
- ប្រពៃណីសង្គមរបស់ជនជាតិដើមភាគតិចមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងដីធ្លី និងព្រៃឈើ។ ភូមិនីមួយៗមានដី និងព្រៃឈើជាប្រពៃណីរបស់ខ្លួន ដែល ៖
  - មានតំបន់ខ្លះប្រើប្រាស់សម្រាប់ប្រមូលអនុផលព្រៃឈើ និងបរបាញ់
  - តំបន់ខ្លះប្រើប្រាស់សម្រាប់ដាំដុះ និង
  - តំបន់ខ្លះទៀតសម្រាប់គោរពបូជាទុកដូចជា**លំនៅដ្ឋានរបស់អារក្ស**។
- ការដាំដុះតាមប្រពៃណី គឺការធ្វើកសិកម្មពនេចរ។ នៅក្នុងប្រព័ន្ធកសិកម្មនេះ ចំការនីមួយៗត្រូវបានកសិករដាំដុះរយៈពេល២ ឬ៣ឆ្នាំ មុននឹងបោះបង់ឱ្យនៅទំនេរ ដែលអាចឱ្យព្រៃដុះដាលឡើងវិញ ព្រមពេលជាមួយគ្នានេះ គាត់នឹងផ្លាស់ទីទៅចំការថ្មីដែលស្ថិតនៅក្នុងដីភូមិជាប្រពៃណីរបស់គាត់។
- នៅពេលដែលចំការចាស់ណាមួយមានជីជាតិគ្រប់គ្រាន់ កសិករនេះអាចនឹងត្រឡប់ទៅដាំដុះនៅទីនោះវិញ ហើយខួបនេះនឹងកើតមានឡើងដដែលៗ។ ការប្រើប្រាស់ប្រព័ន្ធនេះ ធ្វើឱ្យព្រៃឈើនៅតំបន់ខ្ពង់រាប អាចនៅសល់យ៉ាងច្រើន និងមានតុល្យភាពជាច្រើនសតវត្ស។ ទោះបីជាមានទស្សនអវិជ្ជមានខ្លះទៅលើប្រព័ន្ធកសិកម្មពនេចរនេះក៏ដោយ ប៉ុន្តែការទទួលស្គាល់ជាសកលថា ប្រព័ន្ធនេះមានការវិវត្តន៍ខ្ពស់ ការដាំដុះមានប្រសិទ្ធភាព និងមាននិរន្តរភាពនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប។
- ដីចំការបន្ទាប់ពីប្រើប្រាស់សម្រាប់ការដាំដុះ (ចំការចាស់នេះនឹងបង្កើតបានជាប្រព័ន្ធបរិស្ថានព្រៃឈើឡើងវិញ) គឺជាប្រភពផ្តល់នូវផលិតផលព្រៃឈើ និងអាហារដែលជាធនធានសំខាន់ទី២ សម្រាប់ទ្រទ្រង់ដល់ការរស់នៅរបស់ជនជាតិដើមភាគតិច។

ជាទូទៅ ប្រជាពលរដ្ឋខ្មែរបានចាត់ទុកក្រុមជនជាតិដើមភាគតិចថាជាខ្មែរលើ ដែលមានប្រពៃណីវប្បធម៌ និងការប្រកបរបរចិញ្ចឹមជីវិត មានលក្ខណៈខុសប្លែកពីគេ។ ជាទូទៅ ក្រុមជនជាតិដើមភាគតិចនេះបង្ហាញឱ្យឃើញនូវលក្ខណៈងាយនឹងទទួលរងគ្រោះបំផុត ៖

- ជីវភាពរស់នៅជាប់ទាក់ទងនឹងទឹកដី និងធនធានពីដូនតា
- ពឹងផ្អែកលើផលិតកម្មសម្រាប់ផ្គត់ផ្គង់តែជីវភាពប្រចាំថ្ងៃ
- ខ្លួនឯងបង្ហាញ ឬអ្នកដទៃងាយស្គាល់អត្តសញ្ញាណថា ជាក្រុមខុសប្លែកពីគេ

- ប្រើភាសាខុសពីភាសាដែលគេប្រើប្រាស់ភាគច្រើន ឬភាសាផ្លូវការនៅក្នុងប្រទេស
- ពឹងផ្អែកលើវប្បធម៌ និងសង្គមសេដ្ឋកិច្ចតាមទំនៀមទំលាប់ប្រពៃណី។

ដូចនេះ ជនជាតិដើមភាគតិចត្រូវបានយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា រាល់ការអនុវត្តគម្រោងរាជធានី ខេត្តនឹងមិនមានផ្តល់ផលប៉ះពាល់អវិជ្ជមានណាមួយដល់ជីវភាពរស់នៅ និងប្រពៃណីវប្បធម៌របស់ជនជាតិដើមភាគតិចឡើយ។

## ១១.២. សិទ្ធិ និងការចូលរួមរបស់ជនជាតិដើមភាគតិច

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** មាត្រា៣១ វាក្យខ័ណ្ឌទី២ មានខ្លឹមសារថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។

ប្រជាពលរដ្ឋខ្មែររួមបញ្ចូលទាំងជនជាតិដើមភាគតិចកម្ពុជា ដូចជាប្រជាជនតំបន់ខ្ពង់រាបដែលគេហៅថាខ្មែរលើ។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** មាត្រា១៩ បានចែងថា ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មាត្រា២០ បានចែងថា ក្រុមប្រឹក្សានីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ១១.៣. គម្រោងដែលត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

គម្រោងទាំងឡាយដែលមានទីតាំងស្ថិតនៅភូមិដែលមានឈ្មោះក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចរស់នៅចាប់ពី៥%នៃចំនួនប្រជាពលរដ្ឋសរុបក្នុងភូមិ) ត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច (**ទម្រង់ទី១៨.១**)។

## ១១.៤. ការប្រជុំផ្សព្វផ្សាយអំពីគម្រោងដល់ជនជាតិដើមភាគតិច

បន្ទាប់ពីគម្រោងត្រូវបានជ្រើសរើសសម្រាប់ប្រើប្រាស់ថវិការាជធានី ខេត្ត ទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្ត ដោយសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ និងមេដឹកនាំរបស់ជនជាតិដើមភាគតិច ត្រូវរៀបចំការប្រជុំមួយ ដើម្បីផ្សព្វផ្សាយអំពីគម្រោងដែលបានជ្រើសរើសនេះនៅតាមបណ្តាភូមិ ដែលស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច។ កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំនេះ ត្រូវបានយល់ព្រមដោយមេដឹកនាំរបស់ជនជាតិដើមភាគតិច។ នៅក្នុងការប្រជុំនេះ ប្រសិនបើជនជាតិដើមភាគតិចមិនអាចយល់បាននូវភាសាខ្មែរ ត្រូវប្រើប្រាស់វិធីសាស្ត្រ ឬឧបករណ៍សាមញ្ញៗ និងបកប្រែជាភាសាដែលជនជាតិដើមភាគតិចអាចយល់បានច្បាស់។

នៅក្នុងការប្រជុំផ្សព្វផ្សាយអំពីគម្រោងនេះ មន្ត្រីទទួលបន្ទុកត្រូវ ៖

- ជម្រាបដល់ជនជាតិដើមភាគតិចអំពីលក្ខណៈវិនិច្ឆ័យ និងដំណើរការនៃការជ្រើសរើសគម្រោង
- ជម្រាបដល់ជនជាតិដើមភាគតិចអំពីទីតាំងគម្រោង
- ពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីផលប្រ/យោជន៍ដែលទទួលបានពីការអនុវត្តគម្រោង

- ពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីផល+ប៉ះពាល់ជាអវិជ្ជមានដល់ពួកគាត់ ដែលបណ្តាលមកពីការអនុវត្តគម្រោងនេះ
- ពិភាក្សាជាមួយជនជាតិដើមភាគតិច ថាតើពួកគាត់យល់ព្រមចំពោះការអនុវត្តគម្រោងនេះដែរឬទេ។

មន្ត្រីទទួលបន្ទុកត្រូវរៀបចំកំណត់ហេតុ និងបញ្ជីវត្តមាននៃការប្រជុំនេះ។ រាល់មតិយោបល់ដែលបានលើកឡើង រួមទាំងការជំទាស់ ការយល់ព្រម មូលហេតុនានា។ល។ ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុប្រជុំ។ កំណត់ហេតុ និងបញ្ជីវត្តមាននៃការប្រជុំនេះ ត្រូវភ្ជាប់មកជាមួយរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។

## ១១.៥. ការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោង

នៅក្នុងដំណាក់កាលរៀបចំគម្រោង និងមុនពេលអនុម័តសំណើគម្រោង មន្ត្រីទទួលបន្ទុករួមជាមួយអ្នកជំនួយបច្ចេកទេសដោយសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំប្រជុំមួយដាច់ដោយឡែកជាមួយតំណាងជនជាតិដើមភាគតិច ដើម្បីពិភាក្សាអំពីគ្រោងការគម្រោង។ កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំនេះត្រូវបានយល់ព្រមដោយមេដឹកនាំរបស់ជនជាតិដើមភាគតិចនៃភូមិពាក់ព័ន្ធទាំងនោះ។ នៅក្នុងការប្រជុំនេះ ប្រសិនបើជនជាតិដើមភាគតិចមិនអាចយល់បាននូវភាសាខ្មែរ ត្រូវប្រើប្រាស់វិធីសាស្ត្រឬឧបករណ៍សាមញ្ញៗ និងបកប្រែជាភាសាដែលជនជាតិដើមភាគ តិចអាចយល់បានច្បាស់។

ការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោងនេះ ត្រូវដំណើរការដូចខាងក្រោម ៖

- មន្ត្រីទទួលបន្ទុកជម្រាបដល់ជនជាតិដើមភាគតិចអំពី ៖
  - សិទ្ធិ និងការចូលរួមរបស់ជនជាតិដើមភាគតិច
  - គោលបំណងរបស់គម្រោង
  - ទីតាំងគម្រោង
  - ព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងជនជាតិដើមភាគតិច
- អ្នកជំនួយបច្ចេកទេសបង្ហាញ និងពន្យល់អំពីគំនូសប្លង់បច្ចេកទេសគម្រោងដល់ជនជាតិដើមភាគតិច
- បន្ទាប់មក មន្ត្រីទទួលបន្ទុកពិភាក្សាជាមួយជនជាតិដើមភាគតិចអំពី ៖
  - ផលប្រយោជន៍ដែលទទួលបានពីការអនុវត្តគម្រោង
  - ផលប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរស់នៅរបស់ពួកគាត់ដែលបណ្តាលមកពីការអនុវត្តគម្រោងនេះ
  - ផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន
  - ផលប៉ះពាល់ដីធ្លី និងសិទ្ធិ (សិទ្ធិរបស់អ្នកប្រើប្រាស់ដីធ្លីក្នុងការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត និងការទាមទារសំណង)
  - ហានិភ័យ និងការព្រមព្រៀងទៅលើវិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច
  - ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
  - ការព្រមព្រៀងទៅលើគ្រោងការគម្រោង វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច និងផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។

អ្នកចូលរួមក្នុងការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោងនេះ រួមមាន ៖

- តំណាងគណៈកម្មការរៀបចំគម្រោងនេះ
- មេឃុំ ចៅសង្កាត់
- សមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់មកពីភូមិពាក់ព័ន្ធដែលមានជនជាតិដើមភាគតិចរស់នៅ
- មេដឹកនាំជនជាតិដើមភាគតិចនៃភូមិដែលពាក់ព័ន្ធ
- តំណាងគ្រួសារជនជាតិដើមភាគតិច
- អ្នកជំនួយបច្ចេកទេស

មន្ត្រីទទួលបន្ទុកត្រូវរៀបចំកំណត់ហេតុ និងបញ្ជីវត្តមាននៃការប្រជុំនេះ។ រាល់មតិយោបល់ដែលបានលើកឡើង រួមទាំងការជំទាស់ ការយល់ព្រម មូលហេតុនានា។ល។ ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុប្រជុំ។ កំណត់ហេតុ និងបញ្ជីវត្តមាននេះ ត្រូវភ្ជាប់ជាមួយរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។

## ១១.៦. របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

មន្ត្រីទទួលបន្ទុក ត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច(**ទម្រង់ទី ១៨.១**) ហើយដាក់ជូនទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តពិនិត្យ និងចុះហត្ថលេខា។

បន្ទាប់មកទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍នេះ និងឯកសារឧបសម្ព័ន្ធនានា ជាទម្រង់ឯកសារក្នុងកុំព្យូទ័រ (Electronic File) ជូនក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យជាមុន មុននឹងដាក់ជូនទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានរយៈពេល**១០ថ្ងៃធ្វើការ**ក្នុងការពិនិត្យ បន្ទាប់ពីទទួលបានរបាយការណ៍។ ប្រសិនបើពិនិត្យឃើញថា របាយការណ៍នេះមានចំណុចខុសឆ្គង ឬខ្វះខាតដែលត្រូវធ្វើការកែតម្រូវ ឬបំពេញបន្ថែម ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជម្រាបមកទីចាត់ការផែនការ និងវិនិយោគខេត្តវិញតាមរយៈអ៊ីម៉ែលក្នុងរយៈពេល១០ថ្ងៃធ្វើការ។ ប្រសិនបើក្នុងអំឡុងពេល១០ថ្ងៃនេះ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប មិនមានការឆ្លើយតបទេ នោះចាត់ទុកថា របាយការណ៍នេះទទួលបាននូវការពិនិត្យយ៉ាងត្រឹមត្រូវពីក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប។

## ១១.៧. វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច

ប្រសិនបើគ្រោងការគម្រោងមានហានិភ័យនានាដល់ជនជាតិដើមភាគតិច ហានិភ័យទាំងនោះត្រូវតែធ្វើការពិភាក្សាជាមួយជនជាតិដើមភាគតិចដែលពាក់ព័ន្ធទាំងអស់ឱ្យបានលម្អិត និងច្បាស់លាស់ ដើម្បីរកមធ្យោបាយក្នុងការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យទាំងនោះ។ វិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យទាំងនេះអាចតម្រូវឱ្យមានការកែសម្រួលគ្រោងការគម្រោង។

ហានិភ័យដល់ជនជាតិដើមភាគតិច សំដៅទៅលើរាល់ផលប៉ះពាល់អវិជ្ជមានដល់ការរស់នៅ និងទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច ដូចជាប៉ះពាល់ដល់តំបន់គោរពបូជា ការកាប់ទន្រ្ទានព្រៃឈើ ប៉ះពាល់

ដល់តំបន់ធ្វើកសិកម្មជាដើម។ល។

វាល់វិធានការការពារឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យទាំងអស់ដែលជនជាតិដើមភាគតិចបានឯកភាព ត្រូវកត់ត្រានៅក្នុង**ទម្រង់ទី១៨.២ "វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច"** ។

វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច រួមមានព័ត៌មានដូចខាងក្រោម ៖

- **ហានិភ័យ** ៖ ផលប៉ះពាល់អវិជ្ជមានដល់ការរស់នៅ និងទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច
- **អាទិភាព** ៖ កម្រិតអាទិភាពនៃហានិភ័យ (ខ្ពស់ មធ្យម ទាប)
- **វិធានការកាត់បន្ថយ** ៖ វិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ
- **អ្នកទទួលខុសត្រូវអនុវត្តវិធានការ** ៖ អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយហានិភ័យ
- **ផលប៉ះពាល់បន្ទាប់ពីការកាត់បន្ថយ** ៖ ទំហំនៃផលប៉ះពាល់ដែលអាចនៅមាន បន្ទាប់ពីការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយហានិភ័យ។

## ១១.៨. ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

មន្ត្រីទទួលបន្ទុក ត្រូវរៀបចំផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច (**ទម្រង់ទី១៨.៣**) បន្ទាប់ពីរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច និងវិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិចចប់សព្វគ្រប់។ ផែនការតាមដាននេះ រួមមានព័ត៌មានដូចខាងក្រោម ៖

- **អ្វីខ្លះ? (តើត្រូវធ្វើការតាមដានទៅលើអ្វីខ្លះ?)** ៖ គឺជាវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ
- **កន្លែងណា? (តើត្រូវធ្វើការតាមដាននៅកន្លែងណា?)** ៖ ទីតាំងដែលត្រូវធ្វើការតាមដាននូវការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ
- **របៀបណា? (តើត្រូវធ្វើការតាមដានរបៀបណា?)** ៖ វិធីសាស្ត្រក្នុងការតាមដានការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ
- **នៅពេលណា? (តើត្រូវធ្វើការតាមដាននៅពេលណា?)** ៖ ពេលវេលាក្នុងការតាមដានការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ
- **អ្នកណា? (តើអ្នកណាទទួលខុសត្រូវក្នុងការតាមដាន?)** ៖ អ្នកដែលទទួលខុសត្រូវក្នុងការតាមដានការអនុវត្តវិធានការការពារ ឬកាត់បន្ថយ ឬបន្ធូរបន្ថយនូវហានិភ័យ។

**ទម្រង់ទី១៨.១**

**របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច**

| រាជធានី ខេត្ត ៖ | លេខកូដរាជធានី ខេត្ត ៖ |
|---|---|

ឈ្មោះគម្រោង ៖

ចំនួនភូមិមានជនជាតិដើមភាគតិចដែលពាក់ព័ន្ធនឹងគម្រោង ៖

ឈ្មោះក្រុមជនជាតិ ៖

**១. ការប្រជុំផ្សព្វផ្សាយអំពីគម្រោងដល់ជនជាតិដើមភាគតិច**

១.១. ការបរិយាយលម្អិតអំពីកាលបរិច្ឆេទ ទីកន្លែង អ្នកចូលរួម ដំណើរការ មតិយោបល់ និងលទ្ធផលនៃការប្រជុំតាមភូមិនីមួយៗ ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១.២. តើកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំផ្សព្វផ្សាយអំពីគម្រោងនេះ បានទទួលការយល់ព្រមពីមេដឹកនាំរបស់ជនជាតិដើមភាគតិចដែរឬទេ? បាទ ☐ ទេ ☐

បើបាន សូមបញ្ជាក់ ៖..................................*(ឈ្មោះមេដឹកនាំរបស់ជនជាតិដើមភាគតិច ឈ្មោះជនជាតិ ឈ្មោះភូមិ កាលបរិច្ឆេទនៃការព្រមព្រៀង)* ..............................................................................

..........................................................................................................................................

..........................................................................................................................................

បើមិនបាន សូមបញ្ជាក់អំពីមូលហេតុ ៖...................................................................................

..........................................................................................................................................

..........................................................................................................................................

១.៣.តើការប្រជុំផ្សព្វផ្សាយអំពីគម្រោងដល់ជនជាតិដើមភាគតិច មានបកប្រែជាភាសាដែលជនជាតិដើមភាគតិចអាចយល់បាន និងប្រើប្រាស់វិធីសាស្រ្តឬឧបករណ៍សាមញ្ញៗដែរឬទេ? បាទ ☐ ទេ ☐

បើបាន សូមបញ្ជាក់ ៖................... *(ជាភាសាអ្វីខ្លះ ប្រើប្រាស់វិធីសាស្រ្ត ឬឧបករណ៍អ្វីខ្លះ)* ....................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

បើមិនបាន សូមបញ្ជាក់អំពីមូលហេតុ ៖...................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**២. ការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោង**

២.១. ការបរិយាយលម្អិតអំពីកាលបរិច្ឆេទ ទីកន្លែង អ្នកចូលរួម ដំណើរការ មតិយោបល់ និងលទ្ធផលនៃការប្រជុំនេះ ៖

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

២.២. តើកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោងបានទទួលការយល់ព្រមពីមេដឹកនាំរបស់ជនជាតិដើមភាគតិចដែរឬទេ? បាទ ☐ ទេ ☐

បើបាន សូមបញ្ជាក់ ៖..................................*(ឈ្មោះមេដឹកនាំរបស់ជនជាតិដើមភាគតិច ឈ្មោះជនជាតិ ឈ្មោះភូមិ កាលបរិច្ឆេទនៃការព្រមព្រៀង)* ......................................................................................

......................................................................................................................................

បើមិនបាន សូមបញ្ជាក់អំពីមូលហេតុ ៖........................................................................................

......................................................................................................................................

......................................................................................................................................

២.៣. តើការប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីគ្រោងការគម្រោង មានបកប្រែជាភាសាដែលជនជាតិដើមភាគតិចអាចយល់បាន និងប្រើប្រាស់វិធីសាស្ត្រឬឧបករណ៍សាមញ្ញៗដែរឬទេ? បាទ ☐ ទេ ☐

បើបាន សូមបញ្ជាក់ ៖................... *(ជាភាសាអ្វីខ្លះ ប្រើប្រាស់វិធីសា ស្ត្រ ឬឧបករណ៍អ្វីខ្លះ)* ....................

......................................................................................................................................

......................................................................................................................................

បើមិនបាន សូមបញ្ជាក់អំពីមូលហេតុ ៖........................................................................................

......................................................................................................................................

......................................................................................................................................

**ឯកសារឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ៖**

- វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច
- ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- បញ្ជីវត្តមានប្រជុំជាមួយជនជាតិដើមភាគតិចនានា
- កំណត់ហេតុប្រជុំជាមួយជនជាតិដើមភាគតិចនានា។

ថ្ងៃទី...... ខែ......... ឆ្នាំ....... ថ្ងៃទី...... ខែ......... ឆ្នាំ.......

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត** **មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៨.២**

**វិធានការកាត់បន្ថយហានិភ័យដល់ជនជាតិដើមភាគតិច**

| រាជធានី ខេត្ត ៖ | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ |
|---|---|---|

| ហានិភ័យ | អាទិភាព (ខ្ពស់ មធ្យម ទាប) | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវអនុវត្តវិធានការ | ផលប៉ះពាល់បន្ទាប់ពីកាត់បន្ថយ |
|---|---|---|---|---|
| *ការសាងសង់ផ្លូវនេះបណ្តាលឱ្យប៉ះពាល់ដល់ទីសក្ការៈបូជារបស់ជនជាតិដើមភាគតិច* | *ខ្ពស់* | • *ប្តូរទីតាំងផ្លូវនៅត្រង់ចំណុចដែលមានការប៉ះពាល់*<br>• *រៀបចំគំនូសប្លង់បច្ចេកទេសដោយជៀសវាងនូវការប៉ះពាល់* | • *មេដឹកនាំជនជាតិដើមភាគតិច និងជនជាតិដើមភាគតិចចូលរួមកំណត់ទីតាំងផ្លូវ*<br>• *រដ្ឋបាលខេត្ត និងគណៈកម្មការរៀបចំគម្រោង* | • *អាចនៅមានផលប៉ះពាល់បន្តិចបន្តួច* |
| | | | | |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

ឧបសម្ព័ន្ធទី១៤.៣

## ផែនការតាមដានការអនុវត្តវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

| រាជធានី ខេត្ត ៖ | លេខកូដរាជធានី ខេត្ត ៖ | ឈ្មោះគម្រោង ៖ |
|---|---|---|

| តើអ្វីខ្លះ?<br>(តើអ្វីខ្លះដែលត្រូវធ្វើការតាមដាន?) | នៅកន្លែងណា?<br>(តើត្រូវតាមដាននៅកន្លែងណា?) | ដោយរបៀបណា?<br>(តើត្រូវតាមដានដោយរបៀបណា?) | នៅពេលណា?<br>(តើត្រូវតាមដាននៅពេលណា?) | ដោយអ្នកណា?<br>(តើអ្នកណាទទួលខុសត្រូវក្នុងការតាមដាន?) |
|---|---|---|---|---|
| • *ប្តូរទីតាំងផ្លូវនៅត្រង់ចំណុចដែលមានការប៉ះពាល់*<br>• *រៀបចំគំនូសប្លង់បច្ចេកទេសដោយជៀសវាងនូវការប៉ះពាល់* | • *នៅទីតាំងគម្រោង* | • *ចុះពិនិត្យដល់ទីតាំងគម្រោងនៅត្រង់ចំណុចដែលប៉ះពាល់*<br>• *ពិនិត្យគំនូសប្លង់បច្ចេកទេសគម្រោង* | • *នៅពេលសិក្សាលទ្ធភាពគម្រោង និងចាប់ផ្តើមអនុវត្តគម្រោង*<br>• *នៅពេលអនុម័តគម្រោង* | • *មេដឹកនាំជនជាតិដើមភាគតិច និងជនជាតិដើមភាគតិច*<br>• *រដ្ឋបាលខេត្ត និងគណៈកម្មការរៀបចំគម្រោង* |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី១៨.៤**

**បញ្ជីឈ្មោះអ្នកចូលរួមប្រជុំ**

**ការប្រជុំ.......................................................................**

ថ្ងៃទី......... ខែ............. ឆ្នាំ.........

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | តួនាទី | ហត្ថលេខា<br>ឬស្នាមមេដៃ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ឧបសម្ព័ន្ធទី១

# ឧប្បត្តិនានា

ឧម្រង់នី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

# ស្តីពី

# ការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល

កិច្ចព្រមព្រៀងនេះ ធ្វើឡើងនៅថ្ងៃទី....... ខែ........... ឆ្នាំ......... រវាង ៖

- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី..............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី..............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី..............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី..............................................

ភាគីទាំងអស់បានឯកភាពគ្នាតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោម ៖

**ប្រការ ១.-**

គម្រោង.......................................................................................................... នឹងអនុវត្តទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

**ប្រការ ២.-**

ចំនួនថវិកាប៉ាន់ស្មានដែលត្រូវចូលរួមចំណែកដល់គម្រោងអន្តររដ្ឋបាលនៃរដ្ឋបាលនីមួយៗដែលពាក់ព័ន្ធមានដូចខាងក្រោម ៖

- រដ្ឋបាល............... ចំនួន................ (ជាអក្សរ...................................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ...................................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ...................................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ...................................................................)

**សរុប**......................... (ជាអក្សរ...................................................................)

រដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលបានឯកភាពគ្នា ក្នុងការផ្ទេរថវិកានៃចំណែករបស់ខ្លួនទាំងអស់ ឬជាដំណាក់កាលទៅក្នុងគណនីរបស់រដ្ឋបាលនៃប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល បន្ទាប់ពីកិច្ចសន្យានៃគម្រោងនេះត្រូវបានចុះហត្ថលេខា។

**ប្រការ ៣.-**

គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានសមាសភាពដូចខាងក្រោម ៖

| ល.រ | ឈ្មោះ | ភេទ | មកពី | តួនាទី |
|---|---|---|---|---|
| | | | | ប្រធាន |
| | | | | សមាជិក |

| ល.រ | ឈ្មោះ | ភេទ | មកពី | តួនាទី |
|---|---|---|---|---|
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | លេខាធិការ |

**ប្រការ ៤.-**

គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោងអន្តររដ្ឋបាល
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការរៀបចំ និងការអនុវត្តគម្រោងអន្តររដ្ឋបាល
- រៀបចំសំណើគម្រោងអន្តររដ្ឋបាល ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោងអន្តររដ្ឋបាល។

**ប្រការ ៥.-**

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាតំណាងផ្លូវការរបស់គណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ក្នុងការចុះហត្ថលេខាលើឯកសារផ្លូវការនានាដែលទាក់ទងនឹងការរៀបចំគម្រោង ដោយប្រើប្រាស់ត្រា និងចុះលេខរបស់រដ្ឋបាលសាមី។

ក្នុងករណីប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាលអវត្តមាន អភិបាលស្តីទី ឬមេឃុំ ចៅសង្កាត់ស្តីទីនៃរដ្ឋបាលដែលទទួលភារកិច្ចជាប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល គឺជាប្រធានស្តីទីនៃគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល។

ប្រធានគណៈកម្មការរៀបចំគម្រោងអន្តររដ្ឋបាល ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការរៀបចំគម្រោង។ ក្នុងករណីប្រធានអវត្តមាន ប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

